ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
ចូល
មកដល់ថ្ងៃទី៖ 3.4.26 | ម៉ោង៖ 3:00
លេខ៖ 1363
អ្នកទទួល៖ | ហត្ថលេខា
អ្នកប្រគល់៖ | ហត្ថលេខា
បញ្ជូនទៅ៖

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្ដីពី
# សកម្មភាពការងារ
## របស់
## រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
## ប្រចាំខែមករា ឆ្នាំ២០២៦

ទីស្ដីការគណៈរដ្ឋមន្ត្រី

# មាតិកា


សកម្មភាពរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ១

**ស្ទួលនៃយុទ្ធសាស្ត្របញ្ចកោណ**
**«ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច»**

**១- ការពង្រឹងនិងការកែទម្រង់ស្ថាប័ន** ៣
- ក- ការងារពង្រឹងសមត្ថភាពនៃភាពជាអ្នកដឹកនាំ ៣
- ខ- ការងារវិមជ្ឈការនិងវិសហមជ្ឈការ ៣
- គ- ការកែទម្រង់កងកងកម្លាំងប្រដាប់អាវុធ ៤

**២- ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ** ៥
- ក- ការកែតម្រូវស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលនៅក្នុងប្រព័ន្ធគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា ៥
- ខ- ការងារគ្រប់គ្រងក្របខ័ណ្ឌនិងអភិវឌ្ឍអាជីពមន្ត្រីរាជការស៊ីវិល ៥

**៣- ការលើកកម្ពស់និងការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ** ៥
- ក- ការងារយន្តការទទួលនិងដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ ៥
- ខ- ការងារអធិការកិច្ចនិងសវនកម្ម ៧
- គ- ការងារពង្រឹងយន្តការគ្រប់គ្រងនិងផ្តល់សេវាសាធារណៈ ៧
- ឃ- ការងារលើកកម្ពស់ការគោរពច្បាប់និងការផ្តល់សេវាជំនួយផ្នែកច្បាប់ ៧
- ង- ការងារជំរុញការរៀបចំក្របខ័ណ្ឌគតិយុត្ត និងយន្តការសម្រុះសម្រួលនិងផ្សះផ្សាវិវាទទាំងក្នុងប្រព័ន្ធតុលាការនិងក្រៅប្រព័ន្ធតុលាការ ៧

**៤- ការលើកកម្ពស់និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌** ៨
- ក- ការពង្រឹងនីតិរដ្ឋ ៨
- ខ- ការងារពង្រឹងវិស័យយុត្តិធម៌ ៩

**៥- ការពង្រឹងអភិបាលកិច្ចវិស័យឯកជននិងធុរកិច្ច** ១០

**បរិស្ថានគ្រប់ជណ្តប់សម្រាប់ធានាបរិយាកាស**
**អំណោយផលដល់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល**

**១- ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ១១
- ក- ការងារគ្រប់គ្រងច្រកទ្វារព្រំដែន សភាពការណ៍សន្តិសុខនៅតាមតំបន់ព្រំដែន និងការងារគ្រប់គ្រងព្រំដែន ១១
- ខ- ការងារប្រជាធិបតេយ្យនីយកម្ម ១២
- គ- ការងារការបង្ក្រាបបទល្មើស ១៣
- ឃ- ការងារទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់សង្គម និងគ្រោះមហន្តរាយផ្សេងៗ ១៤
- ង- ការងារគ្រប់គ្រងគ្រោះមហន្តរាយ ១៤
- ច- ការងារបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ១៥
- ឆ- ការពង្រឹងការងារអន្តោប្រវេសន៍ និងការងារអត្តសញ្ញាណកម្ម ១៥

**២- ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់និងឈ្នះឈ្នះ** ១៩
ក- ការងារទំនាក់ទំនងទ្វេភាគីនិងពហុភាគី ១៩
ខ- ការងារការទូតសេដ្ឋកិច្ច វប្បធម៌ ទេសចរណ៍ និងការការពារផលប្រយោជន៍ខ្មែរនៅបរទេស ២០
គ- ការបន្តអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់អន្តរជាតិ ការបន្តប្រកាន់គោលការណ៍អព្យាក្រឹត្យអចិន្ត្រៃយ៍មិនចូលបក្សសម្ព័ន្ធ និងការបន្តតម្កល់ផលប្រយោជន៍ស្នូលរបស់ជាតិជាចម្បង ២១
ឃ- ការចូលរួមរបស់កងយោធពលខេមរភូមិន្ទ ក្នុងការបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ២១
**៣- ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ២១
ក- ការងារម៉ាក្រូសេដ្ឋកិច្ច ២១
ខ- ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២២
គ- ការរក្សាចីរភាពហិរញ្ញវត្ថុសាធារណៈ និងការពង្រឹងការគ្រប់គ្រងការប្រមូលចំណូល ២២
ឃ- ទំហំពាណិជ្ជកម្មអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ២៥
**៤- ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាបន្ននិងសក្តិសិទ្ធិភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍** ២៦
ក- ការចូលរួមពីសហគមន៍ជាតិនិងអន្តរជាតិ ២៦
ខ- ការងារសង្គមស៊ីវិល ២៦
**៥- ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងតំបន់និងសកលលោក** ២៧

**បញ្ចកោណយុទ្ធសាស្ត្រទី១**
**«ការអភិវឌ្ឍមូលធនមនុស្ស»**

**១- ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** ២៨
ក- ការងារអប់រំ ២៨
ខ-ការងារយុវជន ២៩
គ- ការងារកីឡា ២៩
**២- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស** ៣០
ក- ការងារបណ្តុះបណ្តាលធនធានមនុស្សរបស់ក្រសួង ស្ថាប័ន ៣០
ខ- ការងារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ៣១
**៣- ការលើកកម្ពស់សុខភាពនិងសុខុមាលភាពប្រជាជន** ៣៤
ក- ការងារពិនិត្យនិងពិគ្រោះព្យាបាលជំងឺទូទាំងប្រទេស ៣៤
ខ- ការងារមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន ៣៥
**៤- ការពង្រឹងប្រព័ន្ធគាំពារសង្គមនិងប្រព័ន្ធស្បៀង** ៣៧
ក- ការងារជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ការអនុវត្តរបបសន្តិសុខសង្គម ៣៧
ខ- ការងារអនុវត្តបេឡាជាតិសន្តិសុខសង្គម ៣៨
គ- ការជំរុញនិងការបង្កើនសុខុមាលភាពនៃគ្រួសារក្រីក្រ គ្រួសារយុទ្ធជនមានពិការភាព ពលី មរណៈ និងគ្រួសារអតីតយុទ្ធជន ៣៩
ឃ- ការងារលើកកម្ពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ៣៩

**៥- ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន** ៤០
ក- ការលើកកម្ពស់ការយល់ដឹងពីអត្តសញ្ញាណជាតិ ការអភិរក្ស ការអភិវឌ្ឍវប្បធម៌ជាតិ ៤០
ខ- ការបណ្ដុះទស្សនៈមនសិការជាតិ ឧត្ដមគតិវិជ្ជមាន ការពង្រឹងប្រសិទ្ធភាពនៃការស្រាវជ្រាវ ការចងក្រង និងការផ្សព្វផ្សាយគុណតម្លៃប្រវត្តិសាស្ត្រ ៤០
គ- ការលើកកម្ពស់ការយល់ដឹងនិងការជំរុញតួនាទីព្រះពុទ្ធសាសនា ៤១

**បញ្ចកោណយុទ្ធសាស្ត្រទី២**
**«ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង»**

**១- ការអភិវឌ្ឍវិស័យគន្លឹះនិងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច** ៤២
ក- ការងារពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស ៤២
ខ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៤៣
គ ការងារលើកកម្ពស់វិស័យទេសចរណ៍ ៤៤
ឃ- ការងារលើកកម្ពស់វិស័យសេវាកម្ម ៤៤
ង- ការងារកសាងមូលដ្ឋានឧស្សាហកម្ម ៤៥
**២- ការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡូជីស្ទិក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល** ៤៥
២.១- វិស័យដឹកជញ្ជូននិងឡូជីស្ទិក ៤៥
ក- ការងារដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងស្ថានអាកាស ៤៥
ខ- ការងារអាកាសចរណ៍ស៊ីវិល ៤៨
គ- ការងារប្រៃសណីយ៍និងទូរគមនាគមន៍ ៤៨
២.២- វិស័យថាមពលនិងវិស័យទឹកស្អាត ៤៨
ក- ការផ្គត់ផ្គង់អគ្គិសនី ៤៨
ខ- ការងារផលិតទឹកស្អាត ៤៩
**៣- ការកែលម្អបរិយាកាសធុរកិច្ចនិងការវិនិយោគ** ៤៩
**៤- ការពង្រឹងប្រសិទ្ធភាពនិងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្ម សួនកសិឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក** ៤៩
ក- គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ៤៩
ខ- ទុនវិនិយោគក្នុងវិស័យឧស្សាហកម្ម ៥០
**៥- ការធ្វើនវានុវត្តន៍ យន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ** ៥០
ការងារមូលបត្រ ៥០

**បញ្ចកោណយុទ្ធសាស្ត្រទី៣**
**«ការអភិវឌ្ឍវិស័យឯកជននិងការងារ»**

**១- ការអភិវឌ្ឍវិស័យឯកជននិងការងារ** ៥១
ក- ការបង្កើតការងារ ៥១
ខ- ការដំឡើងប្រាក់ឈ្នួលអប្បបរមា ៥១
គ- ការធានាលក្ខខណ្ឌការងារល្អប្រសើរ ៥១

ឃ- ការពង្រីកទីផ្សារការងារ ការការពារផលប្រយោជន៍ពលករ និងផ្សព្វផ្សាយព័ត៌មានទីផ្សារការងារនៅបរទេស ៥២
ង- ការងារលើកកម្ពស់សុវត្ថិភាពនិងសុខភាពការងារ ៥២
**២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ** ៥២
**៣- ការពង្រឹងភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន** ៥៣
**៤- ការពង្រឹងការប្រកួតប្រជែង** ៥៤
ក- ការងាររៀបចំនិងការដាក់ចេញយន្តការការពារសិទ្ធិអ្នកប្រើប្រាស់ ៥៤
ខ- ការងារត្រួតពិនិត្យស្តង់ដា គុណភាព សុវត្ថិភាព និងផលិតផលទំនិញ ៥៥
គ- ការងារចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្តានីយ ៥៥
**៥- ការពង្រឹងប្រព័ន្ធធនាគារនិងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ** ៥៦
ក- ការងារធានារ៉ាប់រង ៥៦
ខ- ការងារអាជីវកម្មអចលនទ្រព្យនិងបញ្ចាំ ៥៦
គ- ការងារបរធនបាលកិច្ច ៥៦

**បញ្ចកោណយុទ្ធសាស្ត្រទី៤**
**“ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន”**

**១- ការធ្វើបរមភាវូបនីយកម្មផលលាភប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ** ៥៧
ក- ការងារសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យនិងក្មេង និងការអនុវត្តកម្មវិធីគាំពារសង្គមនិងលើកកម្ពស់អាហារូបត្ថម្ភនៃគ្រួសារក្រីក្រ ស្ត្រីមានផ្ទៃពោះនិងកុមារ ៥៧
ខ- ការងារគោលនយោបាយជាតិប្រជាជន ៥៨
គ- ការងារពង្រឹងសមភាពយេនឌ័រ ៥៨
**២- ការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព** ៥៩
២.១- ការងារធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ ៥៩
ក- ការងារកែទម្រង់ព្រៃឈើ ៥៩
ខ- ការងារថែរក្សាប្រព័ន្ធអេកូឡូស៊ី ការការពារជីវៈចម្រុះ និងការការពារតំបន់ធម្មជាតិ ៥៩
គ- ការងារការពារសម្បត្តិវប្បធម៌ ការអភិរក្ស និងការអភិវឌ្ឍតំបន់រមណីយដ្ឋានវប្បធម៌ ៦០
២.២- ការងារទេសចរណ៍ប្រកបដោយចីរភាព ៦១
ក- ការងារអាជ្ញាបណ្ណរមណីយដ្ឋានទេសចរណ៍ និងសេវាកម្មបន្តទេសចរណ៍ ៦១
ខ- ស្ថិតិភ្ញៀវទស្សនាសារមន្ទីរនិងមណ្ឌលវប្បធម៌តាមបណ្តាខេត្ត ៦២

**៣- ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ** ៦២
ក- ការងារផលិតកម្មដំណាំស្រូវនិងដំណាំឧស្សាហកម្មរួមផ្សំ ៦២
ខ- ការងារធនធានទឹកនិងឧតុនិយម ៦៣
គ- ការងារអភិវឌ្ឍន៍ជនបទ ៦៦
**៤- ការពង្រឹងការគ្រប់គ្រងនិងការធ្វើទំនើបកម្មនគរូបនីយកម្ម** ៦៧
ក- ការងារសុរិយោដី ៦៧
ខ- ការងារសំណង់ ៦៨
គ- ការងារគណៈវិស្វករកម្ពុជា ៦៩
**៥- ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង** ៦៩
ក- ការងារកសាងហេដ្ឋារចនាសម្ព័ន្ធទឹក រួមទាំងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ៦៩
ខ- ការងារប្រើប្រាស់បច្ចេកវិទ្យាភាគបរិស្ថាននិងភាគអាកាសធាតុ ៧០
គ- ការងារគ្រប់គ្រងសំណល់រឹង រាវ ទាំងនៅទីក្រុងនិងទីប្រជុំជន ៧០

**បញ្ចកោណយុទ្ធសាស្ត្រទី៥**
**«ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល»**

**១- ការកសាងរដ្ឋាភិបាលឌីជីថលនិងពលរដ្ឋឌីជីថល** ៧១
**២- ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តន៍ឌីជីថល** ៧៨
**៣- ការកសាងនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល** ៧៩
ក- អ៊ីនធឺណិតចល័តនិងអចល័ត ៧៩
ខ- ទូរសព្ទចល័តនិងអចល័ត ៧៩
គ- ការសន្ទនាតាមទូរស័ព្ទ ៧៩
ឃ កិច្ចព្រមព្រៀងប្រើប្រាស់Verify.gov.kh ៨០
**៤- ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល** ៨០
**៥- ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ** ៨១

**វឌ្ឍនភាពនៃការអនុវត្តកម្មវិធីគោលនយោបាយជាអាទិភាពទាំង៦ និងវឌ្ឍនភាពនៃការអនុវត្តវិធានការគន្លឹះទាំង៥** ៨២
**សន្និដ្ឋាន** ៨៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០៣.សបក.ចរ**

*ថ្ងៃ ច័ន្ទ ១២កើត ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២៦*

# របាយការណ៍

# ស្តីពី

# សកម្មភាពការងាររបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# ប្រចាំខែមករា ឆ្នាំ២០២៦

តាងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទូលព្រះបង្គំជាខ្ញុំសូមក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសូមព្រះរាជានុញ្ញាតទូលថ្វាយនូវរបាយការណ៍ស្តីពីសកម្មភាពការងាររបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំខែមករា ឆ្នាំ២០២៦ ដូចខាងក្រោមៈ

ប្រជាពលរដ្ឋខ្មែររួមជាមួយប្រជាជននៅលើពិភពលោក ចូលរួមស្វាគមន៍ទិវាបុណ្យចូលឆ្នាំសកល ឆ្នាំ២០២៦ ប្រកបដោយសុខសន្តិភាពពេញលេញនៅទូទាំងប្រទេស និងទិវាជ័យជម្នះ ៧មករា លើកទី៤៧ (៧-១-១៩៧៩/៧-១-២០២៦) កាលពីថ្ងៃពុធ ៤រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៧ ខែមករា ឆ្នាំ២០២៦។

**ទូលព្រះបង្គំជាខ្ញុំ** បានចូលរួមនិងធ្វើជាអធិបតីក្នុងពិធីចំនួន**៣លើក**ៈ

១- កិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព សកម្មភាពការងាររបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា នៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃពុធ ១១រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៦

២- កិច្ចប្រជុំពិសេសស្តីពីការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា នៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃពុធ ៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦

៣- ជួបសំណេះសំណាល សួរសុខទុក្ខ និងចែកអំណោយជូនប្រជាពលរដ្ឋភៀសខ្លួនចំនួន១ ២៨២ **គ្រួសារ** នៅមណ្ឌលសុវត្ថិភាពវត្តកំពង់សង្កែ ក្នុងខេត្តព្រះវិហារ កាលពីថ្ងៃសៅរ៍ ១៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦។

ក្រៅពីនេះ **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** ដែលជាតំណាងទូលព្រះបង្គំជាខ្ញុំ បានអញ្ជើញជាអធិបតីក្នុង៖

- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារសុខាភិបាល ឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា កាលពីថ្ងៃអង្គារ ៩កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងល្ងាចថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦

- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថាន ឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ នៅទីស្តីការក្រសួងបរិស្ថាន កាលពីថ្ងៃសុក្រ ១២កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦។

ទន្ទឹមនេះ **ទូលព្រះបង្គំជាខ្ញុំ** បានអនុញ្ញាត**៣លើក** ជូន៖

១- ឯកឧត្តម **ម៉ៃឃើល ចច ដេសូមប្រេ**( Michael George DeSombre ) ឧបការីរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ទទួលបន្ទុកតំបន់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃសៅរ៍ ៧រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២៦

២- ឯកឧត្តមនាយឧត្តមនាវី **សាំយូអែល ជេ.បាបារ៉ូ**( Samuel Paparo ) មេបញ្ជាការនៃបញ្ជាការដ្ឋានឥណ្ឌូប៉ាស៊ីហ្វិក នៃសហរដ្ឋអាមេរិក ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃចន្ទ ៨កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងព្រឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦

៣- ឯកឧត្តមបណ្ឌិត **លីខហាំ ដួងសាវ៉ាន់**( Linkham Douangsavanh ) រដ្ឋមន្ត្រីក្រសួងកសិកម្មនិងបរិស្ថាន នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃចន្ទ ៨កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងព្រឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦។

## ស្ទួលនៃយុទ្ធសាស្ត្របញ្ចកោណ
## «ការកែទម្រង់និងការពង្រឹងអភិបាលកិច្ច»

### ១- ការពង្រឹងនិងការកែទម្រង់ស្ថាប័ន

**ក- ការងារពង្រឹងសមត្ថភាពនៃភាពជាអ្នកដឹកនាំ**

**ក្រសួងមុខងារសាធារណៈ៖**

- បានផ្តល់ទិដ្ឋាការជូនក្រសួង ស្ថាប័នលើការផ្ទេរក្របខ័ណ្ឌ៤នាក់ កែតម្រូវសលាកបត្រព័ត៌មាន ៤នាក់(ស្រី៣នាក់) តែងតាំង**២១នាក់**(ស្រី១១នាក់) កែតម្រូវថ្ងៃខែឆ្នាំកំណើត**៤នាក់**(ស្រី២នាក់) ដាក់ឱ្យចូលនិវត្តន៍តាមអាយុកំណត់**៣៨៤នាក់** ដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់**៤០នាក់**(ស្រី១៨នាក់) មន្ត្រីមរណភាព**១៦នាក់**(ស្រី២នាក់) និងប្រាក់បំណាច់មន្ត្រីខុទ្ទកាល័យ៩នាក់(ស្រី៣នាក់)។

**ខ- ការងារវិមជ្ឈការនិងវិសហមជ្ឈការ**

**ក្រសួងមហាផ្ទៃ៖**

- បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានរាជធានី**១** ខេត្ត**២៤** ក្រុង**៣៣** ស្រុក**១៦៣** ខណ្ឌ**១៤** (ក្រុង ស្រុក ខណ្ឌ**២១០**) ឃុំ**១ ៣៧៨** សង្កាត់**២៧៤**(ឃុំ សង្កាត់**១ ៦៥២**) និងភូមិ**១៤ ៥៨១**។ បានប្រកាសដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាជាផ្លូវការក្រុង ស្រុក មកទល់ពេលនេះ មាន**១៦០**ក្រុង ស្រុក នៃខេត្តចំនួន**២០**

**វឌ្ឍនភាពនៃការរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងការអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានជាអាទិ៍៖**

- ការកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ(២០២៥-២០២៩) របស់រដ្ឋបាលក្រុង ស្រុកចំនួន **១៩៦** នៃរដ្ឋបាលខេត្តចំនួន**២៤** មកទល់ពេលនេះបានបញ្ចប់ជាស្ថាពរ

- ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៦-២០២៨) របស់រដ្ឋបាលក្រុង ស្រុកចំនួន**១៩៦** នៃរដ្ឋបាលខេត្តចំនួន**២៤** ជាលទ្ធផល ក្រុង ស្រុកចំនួន**១៩៦** ស្មើ**១០០%** បានបញ្ចប់ជំហានទី១ ជាស្ថាពរ ខណៈក្រុង ស្រុកចំនួន**១៨៩** ស្មើនឹង**៩៦%** បានអនុវត្តចប់ជំហានទី២ និងក្រុង ស្រុកចំនួន**១២៣** ស្មើនឹង **៦៣%** បានអនុវត្តចប់ជំហានទី៣

- ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៦-២០២៨) របស់រដ្ឋបាលឃុំ សង្កាត់ទាំង **១ ៦៥២** ជាលទ្ធផល ឃុំ សង្កាត់ចំនួន**១ ៦៥២** ស្មើនឹង**១០០%** បានបញ្ចប់ជំហានទី១ ជាស្ថាពរ ខណៈឃុំ សង្កាត់ចំនួន**១ ៦១០** ស្មើនឹង**៩៧%** បានអនុវត្តចប់ជំហានទី២ និងក្រុង ស្រុកចំនួន**១ ០៧៦** ស្មើនឹង **៦៥%** បានអនុវត្តចប់ជំហានទី៣

**វឌ្ឍនភាពនៃការរៀបចំនិងអនុវត្តគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មានជាអាទិ៍៖**

- រដ្ឋបាលរាជធានី ខេត្ត បានរៀបចំនិងទទួលបានអនុលោមភាពលើគម្រោងអភិវឌ្ឍន៍ ឆ្នាំ២០២៥ ចំនួន**៤៧គម្រោង** មានទឹកប្រាក់សរុប**១៩៥ ៦០៦ ០០០ ០០០**រៀល និងគម្រោងអភិវឌ្ឍន៍ឆ្នាំ២០២៦ ចំនួន**១គម្រោង** មានទឹកប្រាក់ចំនួន**៨ ០០០ ០០០ ០០០**រៀល ។ ចំពោះរដ្ឋបាលខណ្ឌ ពុំបានរៀបចំនិងស្នើសុំអនុលោមភាពលើគម្រោងអភិវឌ្ឍន៍សម្រាប់ឆ្នាំ២០២៦ នៅឡើយ

- រដ្ឋបាលក្រុង ស្រុក បានរៀបចំនិងអនុវត្តគម្រោងអភិវឌ្ឍន៍ឆ្នាំ២០២៥ សរុប**៥៧៤គម្រោង** (បញ្ចប់ការសិក្សារួចរាល់) គិតជាទឹកប្រាក់ចំនួន**២០៥ ៤៥៤ ១៦៦ ៥៩៧រៀល**។ ក្នុងចំណោមគម្រោងដែលបានបញ្ចប់ការសិក្សា មាន**៥៧២គម្រោង** បានចុះកិច្ចសន្យាជាមួយអ្នកម៉ៅការរួចរាល់ ក្នុងនោះអនុវត្តបាន**១០០%** មាន**៥៦៥គម្រោង** និងមិនទាន់អនុវត្តមាន**៧គម្រោង**

- រដ្ឋបាលឃុំ សង្កាត់ បានរៀបចំនិងអនុវត្តគម្រោងក្នុងឆ្នាំ២០២៥ ចំនួន**២ ៤១៦គម្រោង**(បញ្ចប់ការសិក្សារួចរាល់) គិតជាទឹកប្រាក់ចំនួន**៦៣៣ ៧៦៥ ៧៩៨ ២០៣រៀល**។ ក្នុងចំណោមគម្រោងដែលបានបញ្ចប់ការសិក្សាមាន**២ ៣៤៥គម្រោង** បានចុះកិច្ចសន្យាជាមួយអ្នកម៉ៅការរួចរាល់ ក្នុងនោះអនុវត្តបាន**១០០%** មាន**១ ៣៥៩គម្រោង** និងមិនទាន់អនុវត្តមាន**៩៨៦គម្រោង**

- អង្គភាពច្រកចេញចូលតែមួយនៃរាជធានី ខេត្តទាំង**២៥គោលដៅ** បានផ្ដល់សេវារដ្ឋបាលសរុប**៦៣ ៤៩១សេវា** លើ**១៤វិស័យ** និងការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុក ខណ្ឌ បានផ្ដល់សេវារដ្ឋបាលសរុប**២៣៤ ៦៣២សេវា** លើ**១៧វិស័យ**។

**គ- ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ**

**គ.១- ការកែទម្រង់កងយោធពលខេមរភូមិន្ទ**

**ក្រសួងការពារជាតិ៖**

- ដំឡើងឋានន្តរសក្តិជូនយោធិននៃកងយោធពលខេមរភូមិន្ទចំនួន**២នាក់** ដំឡើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈចំនួន**៤៧នាក់** តែងតាំងមុខងារចំនួន**៣៤នាក់** ប្រកាសដាក់យោធិនអាជីពឱ្យនៅស្ថានភាពក្រៅក្របខ័ណ្ឌដើមចំនួន**១នាក់** បញ្ចូលក្របខ័ណ្ឌ-ប្រគល់ឋានន្តរសក្តិចំនួន**១៣ ៣៥០នាក់** និងធ្វើបច្ចុប្បន្នភាពទិន្នន័យយោធិនក្នុងប្រព័ន្ធកុំព្យូទ័របានចំនួន**៤ ៥៩៨នាក់**

- បានទទួលសំណុំលិខិតយោធិនពលីមរណៈចំនួន**៤២នាក់** ជនមានពិការភាព**១នាក់** បានលើកសំណើសុំបញ្ចេញយោធាពលីមរណៈចំនួន**៩៧នាក់** និងជនមានពិការភាព**២នាក់** និងត្រៀមបើកប្រាក់គោលនយោបាយជូនយោធិនសោធននិវត្តន៍ចំនួន**៤៤៨នាក់**។

**គ.២- ការកែទម្រង់កងកម្លាំងនគរបាលជាតិ**

- **ក្រសួងមហាផ្ទៃ** ក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ បានកាត់ចេញពីក្របខ័ណ្ឌចំនួន**៥២៨នាក់** (ចូលនិវត្តន៍៥០០នាក់ លុបឈ្មោះពីក្របខ័ណ្ឌ១៤នាក់ បាត់បង់សមត្ថភាព៤នាក់ លាឈប់ពីការងារ៩នាក់ និងផ្ទេរចេញទៅក្រសួង ស្ថាប័នផ្សេង១នាក់) ផ្ទេរមកពីក្រសួង ស្ថាប័នផ្សេងចំនួន**៣នាក់**(ស្រី១នាក់) ផ្ទេរភារកិច្ច សម្រួលភារកិច្ច តែងតាំងមុខតំណែង និងដំឡើងឋានន្តរសក្តិសរុប**១៣១នាក់**(ស្រី១៧នាក់) (កិច្ចបច្ឆាមរណៈ២នាក់)។ រៀបចំនីតិវិធីអនុវត្តវិន័យចំពោះមន្ត្រីនគរបាលជាតិប្រព្រឹត្តកំហុសឆ្គងចំនួន**៤៤នាក់**(បណ្ដេញចេញពីក្របខ័ណ្ឌចំនួន**១២នាក់** ដកហូតមុខតំណែងចំនួន**១នាក់** ដកហូតមុខតំណែង និងបន្ថយឋានន្តរសក្តិ១ថ្នាក់-២ថ្នាក់ ចំនួន**៥នាក់** បន្ថយឋានន្តរសក្តិ១ថ្នាក់ ចំនួន**២នាក់** ផ្អាកការងារ និងបៀវត្សបណ្ដោះអាសន្នចំនួន**៥នាក់** ផ្អាកការងារឱ្យបង្ហាញមុខរៀងរាល់ម៉ោងធ្វើការចំនួន**៦នាក់** និងព្រមានជាលាយលក្ខណ៍អក្សរចំនួន**១៣នាក់** ។

## ២- ការលើកកម្ពស់សមត្ថភាពធនធានមនុស្សនិងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ

ក្រសួងមុខងារសាធារណៈ៖

**ក- ការងារកែតម្រូវស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលនៅក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធព័ត៌មានវិទ្យា**

- បានបោះពុម្ពតារាងទូទាត់បៀវត្សនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបានកែតម្រូវស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលនៅក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធព័ត៌មានវិទ្យា សរុប៦ **៧៨២ករណី**

- បានបង្វែរប្រាក់បៀវត្សដែលបានបើកលើសចូលរដ្ឋវិញសរុប១ **៤១៣លានរៀល** ក្នុងនោះ ថ្នាក់ជាតិចំនួន**២២៣លានរៀល** និងថ្នាក់ក្រោមជាតិចំនួន១ **១៩០លានរៀល**។

**ខ- ការងារគ្រប់គ្រងក្របខ័ណ្ឌ និងអភិវឌ្ឍអាជីពមន្ត្រីរាជការស៊ីវិល**

មន្ត្រីនៅទូទាំងប្រទេសសរុប**២៣៥ ២៧៨នាក់**(ស្រី១០០ ៩៨៥នាក់) ក្នុងនោះ ថ្នាក់ជាតិ**៥៥ ៥២០នាក់**(ស្រី១៧ ០៩១នាក់) ស្មើនឹង**២៣,៦០%** និងថ្នាក់ក្រោមជាតិ**១៧៩ ៧៥៨នាក់**(ស្រី៨៣ ៨៩៤នាក់) ស្មើនឹង**៧៦,៤០%**។

## ៣- ការលើកកម្ពស់និងការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

**ក- ការងារយន្តការទទួលនិងដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ**

**ក.១- ក្រសួងមហាផ្ទៃ**

- អគ្គាធិការដ្ឋាននៃក្រសួងមហាផ្ទៃ ទទួលបានពាក្យបណ្តឹងសរុប**៤៦សំណុំរឿង**(ផ្នែករដ្ឋបាលចំនួន១៦សំណុំរឿង និងផ្នែកនគរបាលចំនួន៣០សំណុំរឿង) ក្នុងនោះ ពាក់ព័ន្ធការអនុវត្ត តួនាទី ភារកិច្ចរបស់មន្ត្រីរាជការចំនួន**៣១សំណុំរឿង** និងទំនាស់រវាងប្រជាពលរដ្ឋជាមួយមន្ត្រីរាជការចំនួន**១៥សំណុំរឿង** បើគិតទាំងបណ្តឹងដែលនៅសល់ពីខែធ្នូ ឆ្នាំ២០២៥ ចំនួន**១៨៣សំណុំរឿង** សរុបចំនួន**២២៩សំណុំរឿង** ដោយឡែក ជុំវិញរបាយការណ៍បំភ្លឺពីបណ្តាអង្គភាពពាក់ព័ន្ធ ក្រសួងទទួលបានចំនួន**១៥របាយការណ៍** (ផ្នែករដ្ឋបាលចំនួន៣របាយការណ៍ និងផ្នែកនគរបាលចំនួន១២របាយកាណ៍)។ ជាលទ្ធផល ក្រសួងបានដោះស្រាយបញ្ចប់ និងបង្វែរបណ្តឹងជូនទៅស្ថាប័នពាក់ព័ន្ធ និងសាមីបណ្តឹងវិញចំនួន**៧០សំណុំរឿង** (ដោះស្រាយបញ្ចប់១៣សំណុំរឿង និងបង្វែរបណ្តឹង៥២សំណុំរឿង និងរក្សាទុកតាមដានបន្ត៥សំណុំរឿង) រីឯបណ្តឹងដែលនៅសល់កំពុងធ្វើការអង្កេតស្រាវជ្រាវដោះស្រាយ។

- ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ទទួលពាក្យបណ្តឹង និងព័ត៌មានផ្សេងៗសរុប**១៦១បណ្តឹង** ក្នុងនោះ ពាក្យបណ្តឹងពាក់ព័ន្ធសមត្ថកិច្ចក្រសួងមហាផ្ទៃចំនួន**២៦បណ្តឹង**(ដោះស្រាយបាន១៩បណ្តឹង) រីឯ **១៣៥បណ្តឹង**ទៀត ជាបណ្តឹងក្រៅសមត្ថកិច្ច សំណូមពរ ការសរសើរ ការសាកសួរព័ត៌មានផ្សេងៗបានធ្វើការចាត់ចែងដោះស្រាយនិងបកស្រាយរួចរាល់ និងការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ទទួលពាក្យបណ្តឹងនិងព័ត៌មានផ្សេងៗចំនួន**៣ ៨៣៤បណ្តឹង** ក្នុងនោះ បណ្តឹងពាក់ព័ន្ធសមត្ថកិច្ចក្រសួងមហាផ្ទៃ**៤៣បណ្តឹង**(ដោះស្រាយរួចរាល់បាន៣៩បណ្តឹង) រីឯ **៣ ៧៩១បណ្តឹង**ទៀត ជាបណ្តឹងក្រៅសមត្ថកិច្ច សំណូមពរ ការសរសើរនិងការសាកសួរព័ត៌មានផ្សេងៗ បានធ្វើការចាត់ចែងដោះស្រាយនិងបកស្រាយរួចរាល់

ក.២- **ក្រសួងអធិការកិច្ច**

- **ការងារដោះស្រាយពាក្យបណ្តឹងតវ៉ា**(នៅថ្នាក់កណ្តាល) បានទទួលពាក្យបណ្តឹងតវ៉ាចំនួន**២ករណី**(ឆ្នាំ២០២៦) បណ្តឹងកំពុងពិនិត្យចំនួន**២ករណី**(ឆ្នាំ២០២៦) បណ្តឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួងចំនួន**៤ករណី**(ឆ្នាំចាស់) បណ្តឹងត្រៀមបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយចំនួន**១ករណី**(ឆ្នាំចាស់) បណ្តឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយចំនួន**១១ករណី**(ឆ្នាំចាស់) បណ្តឹងដែលជាសមត្ថកិច្ចក្រសួងចំនួន**២ករណី**(ឆ្នាំចាស់) បណ្តឹងកំពុងសម្របសម្រួលថ្នាក់ក្រសួងចំនួន**១ករណី**(ឆ្នាំចាស់) បណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវចំនួន**២៩ករណី**(ឆ្នាំចាស់) និងបណ្តឹងត្រៀមចុះអង្កេតស្រាវជ្រាវចំនួន**៦ករណី**(ឆ្នាំចាស់)។ **ការងារដោះស្រាយពាក្យបណ្តឹងបរិហារ**(ថ្នាក់កណ្តាល) មានបណ្តឹងកំពុងពិនិត្យចំនួន**២ករណី**(ឆ្នាំចាស់) បណ្តឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួងចំនួន**៣ករណី**(ឆ្នាំចាស់) បណ្តឹងបានធ្វើលិខិតស្នើសុំព័ត៌មានឬលទ្ធផលនៃការដោះស្រាយចំនួន**១ករណី**(ឆ្នាំចាស់) បណ្តឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយចំនួន**១ករណី**(ឆ្នាំចាស់) បណ្តឹងកំពុងរង់ចាំការឆ្លើយតបពីស្ថាប័ន និងអង្គភាពពាក់ព័ន្ធចំនួន**៣ករណី**(ឆ្នាំចាស់) បណ្តឹងថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកចំនួន**៣ករណី**(ឆ្នាំចាស់) បណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវចំនួន**៥ករណី**(ឆ្នាំចាស់) និងបណ្តឹងបានទទួលការឆ្លើយតបចំនួន**៦ករណី**(ឆ្នាំចាស់)

- **ការងារដោះស្រាយពាក្យបណ្តឹងតវ៉ា**(មន្ទីររាជធានី ខេត្ត) ទទួលពាក្យបណ្តឹងតវ៉ាចំនួន**២ករណី**(ឆ្នាំ២០២៦) បណ្តឹងដែលម្ចាស់បណ្តឹងសុំដកវិញចំនួន**១ករណី**(ឆ្នាំចាស់) បណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវចំនួន**១១ករណី**(ឆ្នាំចាស់) បណ្តឹងបានរាយការណ៍គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកណ្តាលចំនួន**១ករណី**(ឆ្នាំ២០២៦) បណ្តឹងបានដាក់របាយការណ៍គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកណ្តាលពិនិត្យ និងសម្រេចចំនួន**១ករណី**(ឆ្នាំ២០២៦) បណ្តឹងបានបញ្ចប់ការដោះស្រាយចំនួន**៣ករណី**(ឆ្នាំចាស់ចំនួន១ករណី ឆ្នាំ២០២៦ ចំនួន២ករណី)។ **ការងារដោះស្រាយពាក្យបណ្តឹងបរិហារ**(មន្ទីររាជធានី ខេត្ត) ទទួលពាក្យបណ្តឹងបរិហារចំនួន**១ករណី**(ឆ្នាំ២០២៦) បណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវ ចំនួន**១ករណី**(ឆ្នាំចាស់) និងបណ្តឹងបានបញ្ចប់ការដោះស្រាយចំនួន**១ករណី**(ឆ្នាំ២០២៦)។

ក.៣- **ក្រសួងពាណិជ្ជកម្ម** អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ(ក.ប.ប.) ជាសេនាធិការបានទទួលពាក្យបណ្តឹងចំនួន**១បណ្តឹង** និងបានដោះស្រាយបញ្ចប់រួចរាល់។

ក.៤- **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** មានសំណុំឯកសារបណ្តឹងតវ៉ាកំពុងដំណើរការចំនួន**១ ៣៤៥ករណី** ដែលក្នុងនោះបានទទួលពាក្យស្នើសុំថ្មីចំនួន**៧២ករណី** និងសល់យោងគ្រាមុនចំនួន**១ ២៧៣ករណី**។ ជាលទ្ធផល បានដោះស្រាយសំណុំឯកសារបណ្តឹងតវ៉ាចំនួន**៨១ករណី** មានប្រាក់ពន្ធចំនួន**៧០,១៩ប៊ីលានរៀល**។ បំណុលពន្ធបានបង់ក្នុងខែមានចំនួន**១,៣៣ប៊ីលានរៀល** ប្រៀបធៀបនឹងខែដូចគ្នាឆ្នាំមុនថយចុះចំនួន៣៦,៥២ប៊ីលានរៀល។ គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦ សំណុំឯកសារនៅសល់ចុងគ្រាសរុបចំនួន១ ២៦៤ឯកសារ។

ក.៥- **ក្រសួងយុត្តិធម៌** បានទទួលពាក្យបណ្តឹងថ្មីពីប្រជាពលរដ្ឋ**៥រឿង** សល់ពីមុនចំនួន**១២រឿង** សរុប**១៧រឿង** ក្នុងនោះ ចាត់ការរួចពាក្យបណ្តឹងចាស់និងថ្មី**១រឿង** កំពុងចាត់ការពាក្យបណ្តឹងចាស់និងថ្មី**១៦រឿង**។

**ខ- ការងារអធិការកិច្ចនិងសវនកម្ម**

**ខ.១- ក្រសួងអធិការកិច្ច**

- បានបញ្ចប់ការចុះធ្វើអធិការកិច្ចលើ (១) ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (២) ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំសំណង់ ហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២៤ និងបណ្តាផ្នាំពាក់ព័ន្ធ នៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី មន្ទីរផែនការ មន្ទីរមុខងារសាធារណៈ មន្ទីរបរិស្ថាន លេខាធិការដ្ឋានសាលាដំបូងខេត្ត និងតាមដានវិធានការរបស់គណៈប្រតិភូក្រសួងអធិការកិច្ច ដែលបានលើកឡើងក្នុងការធ្វើអធិការកិច្ចការិយបរិច្ឆេទ២០២៣ នៅខេត្តក្រចេះ កំពត ស្វាយរៀង និងខេត្តតាកែវ

- បានចុះធ្វើអធិការកិច្ចលើការផ្តល់សេវាសាធារណៈ នៅរដ្ឋបាលស្រុកសណ្តាន់ ខេត្តកំពង់ធំ ដើម្បីលើកសរសើរអំពីលទ្ធផលដែលសម្រេចបានក្នុងការផ្តល់សេវារដ្ឋបាលបានល្អ និងធ្វើការកែលម្អចំណុចខ្វះខាតក្នុងការផ្តល់សេវា ដើម្បីជំរុញការផ្តល់សេវាឱ្យកាន់តែមានភាពល្អប្រសើរ តាមតម្រូវការជាក់ស្តែងរបស់អតិថិជន។

**ខ.២- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តាមរយៈអគ្គនាយកដ្ឋានពន្ធដារ បានធ្វើសវនកម្មគ្រប់ប្រភេទលើសហគ្រាសចំនួន៨០៨ករណី មានប្រាក់ពន្ធចំនួន**៣៤២,០១ប៊ីលានរៀល**(ប្រមាណជា៨៥,២៩លានដុល្លារអាម៉េរិក) បើធៀបនឹងខែដូចគ្នាឆ្នាំមុន ថយចុះ**៣០៦ករណី** ស្មើនឹង**២៥,៨០%** ហើយប្រាក់ពន្ធថយចុះចំនួន**១ ២៨២,២៥ប៊ីលានរៀល**(ប្រមាណជា៣១៩,៧៦លានដុល្លារអាម៉េរិក) ស្មើនឹង**៧៨,៩៤%**។

**គ- ការងារពង្រឹងយន្តការគ្រប់គ្រងនិងផ្តល់សេវាសាធារណៈ**

**ក្រសួងយុត្តិធម៌** បានចេញព្រឹត្តិបត្រថ្កោលទោសថ្មីជូនប្រជាពលរដ្ឋចំនួន**១០ ៥៣៥ច្បាប់** សល់ពីមុនចំនួន**៦ ១២៣ច្បាប់** សរុប**១៦ ៦៥៨ច្បាប់** ចាត់ការរួចព្រឹត្តិបត្រថ្កោលទោសចាស់និងថ្មីចំនួន **៩ ៦៥៥ច្បាប់** និងកំពុងចាត់ការព្រឹត្តិបត្រថ្កោលទោសចាស់និងថ្មីចំនួន**៧ ០០៣ច្បាប់**។

**ឃ- ការងារលើកកម្ពស់ការគោរពច្បាប់និងការផ្តល់សេវាជំនួយផ្នែកច្បាប់**

**ក្រសួងយុត្តិធម៌** ប្រឹក្សាយោបល់ផ្នែកច្បាប់ជូនប្រជាពលរដ្ឋ នៅនាយកដ្ឋាន ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានក្រុង ស្រុក ខណ្ឌ(អតីតមណ្ឌលសេវាកម្មយុត្តិធម៌) និងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ចំនួន**១៨៦ករណី**។

**ង- ការងារជំរុញការរៀបចំក្របខ័ណ្ឌគតិយុត្ត និងយន្តការសម្រុះសម្រួលនិងផ្សះផ្សាវិវាទទាំងក្នុងប្រព័ន្ធតុលាការនិងក្រៅប្រព័ន្ធតុលាការ**

**ក្រសួងយុត្តិធម៌** តាមរយៈការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ បានទទួល និងធ្វើការសម្រុះសម្រួលវិវាទចូលថ្មីចំនួន **៣០៧ករណី** សល់ពីមុនចំនួន**៨៥៧ករណី** សរុប**១ ១៦៤ករណី** ចាត់ការរួចចំនួន**៣១៧ករណី** និងកំពុងសម្រុះសម្រួលចំនួន**៨៤៧ករណី**។

## ៤- ការលើកកម្ពស់និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌

### ក- ការពង្រឹងនីតិរដ្ឋ

**ទីស្តីការគណៈរដ្ឋមន្ត្រី៖**

**ក.១- ការងាររៀបចំកិច្ចប្រជុំផ្សេងៗ និងការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត**

- រៀបចំកិច្ចប្រជុំជំនាញបច្ចេកទេសចំនួន**៥លើក** និងកិច្ចប្រជុំអន្តរក្រសួងចង្អៀតចំនួន**២លើក**

- បញ្ជូនសេចក្តីព្រាងច្បាប់ចំនួន១ ទៅស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីពិនិត្យនិងអនុម័ត គឺអត្ថបទបកប្រែអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ជាភាសាខ្មែរដោយបន្ថែមខ្លឹមសារដែលខ្វះក្នុងមាត្រា២៩៨

- រាជរដ្ឋាភិបាលបានក្រាបបង្គំទូលថ្វាយ សូមព្រះករុណា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ព្រះរាជទានព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ចំនួន៥ ក្រោយពីស្ថាប័ននីតិប្បញ្ញត្តិបានអនុម័តរួចរួមមាន (១) ច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា (២) ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុបនិងរដ្ឋសមាជិករបស់ខ្លួន (៣) ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១ និងទី១២ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម (៤) ច្បាប់ស្តីការអនុម័តយល់ព្រមលើពិធីសារទី៣ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥រវាងភាគីចុះកិច្ចព្រមព្រៀងក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និង(៥) ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។

- រាជរដ្ឋាភិបាលបានក្រាបបង្គំទូលថ្វាយ សូមព្រះករុណា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ព្រះរាជទានព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់បន្ទាប់ពីស្ថាប័ននីតិប្បញ្ញត្តិបានអនុម័តរួចចាប់តាំងពីឆ្នាំ១៩៩៣ដល់ខែមករា ឆ្នាំ២០២៦ សរុប**៦៩១ច្បាប់**។

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចេញអនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ**១០** ជាឯកត្តកូត**១២៤** និងសេចក្តីសម្រេច**១២**។

**ក.២- ការងារបោះពុម្ពចែកចាយនិងផ្សព្វផ្សាយសៀវភៅរាជកិច្ច** បាន (១) រៀបចំឯកសារគតិយុត្តរបស់ក្រសួង ស្ថាប័ននានាសរុបចំនួន**២៥៣ច្បាប់** និង(២) បោះពុម្ពសៀវភៅរាជកិច្ចចំនួន**១៤ ៥៨៦ក្បាល** និងចែកសៀវភៅរាជកិច្ចជូនថ្នាក់ដឹកនាំនិងអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី និងតាមបណ្តាក្រសួង ស្ថាប័ន និងត្រៀមបម្រុងសរុបចំនួន**១៤ ៥៨៦ក្បាល**។

**ក.៣- ការងារបណ្ណសារដ្ឋានជាតិ** (១) បញ្ចូលទិន្នន័យផែនទីប្លង់**១០**ផ្ទាំង (២)ចុះលេខទំព័រឯកសារហ្មងក្រុមប្រឹក្សារដ្ឋមន្ត្រី**៧៧៩ទំព័រ** (៣) ចុះលេខទំព័រឯកសារហ្មងសម័យអាណាព្យាបាលបារាំង (១៨៦៣-១៩៥៥) ចំនួន**៨៤៥ទំព័រ** (៤) ត្រួតពិនិត្យគុណភាព និងបញ្ចូលទិន្នន័យស្តែនសម័យអាណាព្យាបាលបារាំង(១៨៦៣-១៩៥៤) ចំនួន**១២ ០៤៤ទំព័រ** (៥)រៀបចំសៀវភៅបោះត្រានិងដាក់ក្នុងប្រអប់ចំនួន**១០៦ក្បាល** និង(៦) ជួសជុលផែនទីនិងអ៊ិតប្លាស្ទិកផែនទី ប្លង់ចំនួន**១០ផ្ទាំង**។

ទទួលភ្ញៀវជាតិ និងអន្តរជាតិ ដែលមកសិក្សាស្រាវជ្រាវសរុប**៣៤នាក់** ក្នុងនោះ ភ្ញៀវជាតិចំនួន**២៧នាក់** និងភ្ញៀវអន្តរជាតិចំនួន**៧នាក់**។

ក.៤- រាជបណ្ឌិត្យសភាកម្ពុជា៖

**១- ការងារសិក្សាស្រាវជ្រាវនិងចងក្រង**

អនុវត្តគម្រោងស្រាវជ្រា ស្តីពី «**វេយ្យាករណ៍ពិស្តារ**» អនុវត្តគម្រោងស្រាវជ្រាវស្តីពី «**ការអភិរក្សព្រៃឈើនិងអភិរក្សធនធានធម្មជាតិ នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រើប**» សិក្សាស្រាវជ្រាវ ស្តីពី «**អក្សរសិល្ប៍ខ្មែរពីឆ្នាំ១៩៧៩-ឆ្នាំ១៩៩៣**» ប្រមូលរឿងបានចំនួន**២០ចំណងជើង** ចងក្រងអត្ថបទស្រាវជ្រាវ ជំពូកទី១ ស្តីពី «**គណិតវិទ្យាអនុវត្ត(Applied Mathematics)**» សរុបចំនួន**៥ទំព័រ** ចងក្រងអត្ថបទស្រាវជ្រាវ ស្តីពី «**ពហុអាំងតេក្រាល**» សរុបចំនួន**៥ទំព័រ** បន្តចងក្រងអត្ថបទស្រាវជ្រាវជំពូកទី២ ស្តីពី «**គណិតវិទ្យាសម្រាប់សេដ្ឋកិច្ច**» ភាគទី១ សរុបចំនួន**៦៥ទំព័រ**។

**២- ការងារភាសានិងអក្សរសាស្ត្រជាតិ**

- ការសម្រេចពាក្យរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ៖ ការសម្រេចពាក្យរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរសរុបចំនួន**៣៥ពាក្យ**។ ការសម្រេចពាក្យបច្ចេកទេសរបស់គណៈកម្មការបច្ចេកទេសទាំង១៧ សរុបចំនួន**២២២ពាក្យ**។ សមាជិកគណៈកម្មការភាសាវិទ្យាខ្មែរនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បានពិនិត្យផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធនិងកែសម្រួលអត្ថបទផ្សេងៗ សរុបចំនួន**៣៨៩ទំព័រ** និងចូលរួមប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី សរុបចំនួន**១២លើក**។

- ចងក្រង «ន័យវិទ្យាក្នុងវេយ្យាករណ៍ឧប្បត្តិ (Semantics in Generative Grammar)» បានចំនួន**៥ទំព័រ**

- ចងក្រង «ការស្រាវជ្រាវនិងរៀបរៀងបច្ចេកសព្ទសេដ្ឋកិច្ចនិងរដ្ឋបាលជាមួយនិយមន័យ» បានចំនួន**៦៥ពាក្យ**

- បន្តចងក្រង «សទ្ទានុក្រមរដ្ឋបាលនិងសង្គមកិច្ច» បានចំនួន**២០ពាក្យ**

- បន្តចងក្រង «សទ្ទានុក្រមពាក្យឫសនិងពាក្យកម្លាយ(ភាគ២)» បានចំនួន**៥ទំព័រ**

- បន្តចងក្រង «**វចនានុក្រមភាសាខ្មែរបច្ចុប្បន្ន ភាគទី២**» បានចំនួន៤៣ពាក្យ

- ប្រមូល និងចងក្រង «ប្រវត្តិនិងទំនៀមប្រពៃណីខ្មែរ» បានចំនួន**២ទំព័រ**

- រៀបរៀងវចនានុក្រមអង់គ្លេស-បាលីពីពាក្យ Belonging to ដល់ betoken ចំនួន**១០០ពាក្យ**។

**ខ- ការងារពង្រឹងវិស័យយុត្តិធម៌**

**ក្រសួងយុត្តិធម៌**

**ខ.១-** បានទទួលសាលក្រមនិងសាលដីកាព្រហ្មទណ្ឌពីតុលាការគ្រប់ជាន់ថ្នាក់(សម្រាប់ធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ប្រជាពលរដ្ឋដែលមកស្នើសុំព្រឹត្តិបត្រថ្កោលទោស) សរុប**១៤ ៤៣៩រឿង** ក្នុងនោះ សាលក្រមនិងសាលដីកាព្រហ្មទណ្ឌថ្មីចំនួន**៥១១រឿង** សល់ពីមុនចំនួន**១៣ ៩២៨**រឿង។

**ខ.២- ការបន្ធូរបន្ថយទោស និងការលើកលែងទោសដល់ទណ្ឌិត**

យោងតាមសំណើរបស់ទូលព្រះបង្គំជាខ្ញុំ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ព្រះរាជទានបន្ធូរបន្ថយទោស និងលើកលែងទោសក្នុងទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ បន្ថយ

រយៈពេលទទួលរងទោស៣ខែ ឱ្យទណ្ឌិត៤១៣នាក់ បន្ថយរយៈពេលទទួលរងទោស៦ខែ ឱ្យទណ្ឌិត៨៧នាក់ បន្ថយរយៈពេលទទួលរងទោស៩ខែ ឱ្យទណ្ឌិត២៣នាក់ បន្ថយរយៈពេលទទួលរងទោស១២ខែ ឱ្យទណ្ឌិត **៣នាក់** និងបន្ថយរយៈពេលទទួលរងទោសមួយជីវិត មក៣០ឆ្នាំ ឱ្យទណ្ឌិត**២នាក់** តាមព្រះរាជក្រឹត្យលេខ នស/រកត/០១២៦/០២៤ ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០២៦។

**៥- ការពង្រឹងអភិបាលកិច្ចវិស័យឯកជននិងធុរកិច្ច**

**ការងារបង្កើនប្រសិទ្ធភាពនិងតម្លាភាពនៃអធិការកិច្ចវិស័យឯកជននិងធុរកិច្ច**

**១- ក្រសួងបរិស្ថាន** បានចេញលិខិតអនុញ្ញាតពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង រាវ គុណភាពខ្យល់ សំឡេងនិងរំញ័រ សារធាតុគ្រោះថ្នាក់ និងសេវាវិភាគសំណាកនៅមន្ទីរពិសោធន៍សរុប**៦០៩លិខិត** និងសេវាផាកពិន័យសរុប**៨លិខិត**។

**២- ក្រសួងពាណិជ្ជកម្ម**

- បានធ្វើការវិភាគលើគំរូសំណាកគុណភាពទំនិញចំនួន**២៧គំរូ** ដើម្បីស្វែងរកភាពមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស។ ផ្តល់វិញ្ញាបនបត្រវិភាគគុណភាពទំនិញចំនួន**៦៤វិញ្ញាបនបត្រ** ជូនដល់អ្នកស្នើសុំ។ ទទួលពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដាផលិតផលហាឡាលកម្ពុជាចំនួន **១១ពាក្យ**។ សហការជាមួយក្រុមឯកទេសផលិតផលហាឡាលកម្ពុជាចុះត្រួតពិនិត្យ និងវាយតម្លៃលក្ខណៈបច្ចេកទេសស្តង់ដាផលិតផលហាឡាលកម្ពុជាជូនក្រុមហ៊ុន និងសប្បកម្មចំនួន**៥ទីតាំង**។

- ផ្សព្វផ្សាយច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ និងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់កម្មវិធីCCF Complaint App ផលប៉ះពាល់នៃគ្រឿងញៀន និងណែនាំឱ្យមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការទទួលទានភេសជ្ជៈដែលមានជាតិស្ករខ្ពស់ និងមានជាតិផ្អែមខ្លាំង ព្រោះបណ្តាលឱ្យកើតជំងឺលើសសម្ពាធឈាម និងជំងឺទឹកនោមផ្អែមដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស តាមបណ្តារាជធានី ខេត្ត បានចំនួន**១៦លើក** មានអ្នកចូលរួមចំនួន**៥ ៤៤១នាក់**។ ធ្វើការចុះផ្សព្វផ្សាយអំពីសារធាតុគីមីបន្ថែមក្នុងចំណីអាហារ និងសុវត្ថិភាពអនាម័យម្ហូបអាហារនៅតាមបណ្តាទីផ្សារក្នុងរាជធានី/ខេត្ត ដល់អាជីវករចំនួន**១៥លើក** មានអ្នកចូលរួមចំនួន**៣០នាក់**

- ទទួលការហៅចូលតាមប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្មចំនួន**១ ២៦៦នាក់** ដើម្បីឆ្លើយតបនូវសំណួរ សំណូមពរ មតិយោបល់ និងដំណោះស្រាយបញ្ហាប្រឈមនានារបស់ធុរជន និងសាធារណជន បានចំនួន**៨២២លើក**។

**៣- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះអធិការកិច្ចការងារសរុប**៥៥លើក** ក្នុងនោះ អធិការកិច្ចតាមដានការដាក់កំហិតចំនួន **៣លើក** និងអធិការកិច្ចការងារពិសេសចំនួន**៥២លើក** ព្រមទាំងបានដាក់កំហិតចំនួន**៣៨សហគ្រាស** និងបានចេញលិខិតផាកពិន័យចំនួន**៧សហគ្រាស**។ ការចុះអធិការកិច្ចការងារពិនិត្យឃើញថា អគ្រាសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលអនុលោមភាពតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យការងារមានចំនួន**៨៧,២៧%**។

## បរិស្ថានគ្រប់ដណ្តប់សម្រាប់ធានាបរិយាកាសអំណោយផល
## ដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

**១- ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

សភាពការណ៍សន្តិសុខផ្ទៃក្នុងនៅព្រះរាជាណាចក្រកម្ពុជា ជាទូទៅនៅតែមានភាពល្អ ស្ថាប័នកំពូលរបស់ជាតិ ព្រះរាជសុវត្ថិភាពព្រះមហាក្សត្រ សុវត្ថិភាពថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ អន្តរជាតិនិងបណ្តាគោលដៅនយោបាយ ការទូត សេដ្ឋកិច្ច វប្បធម៌ វិនិយោគ ពាណិជ្ជកម្ម ទេសចរណ៍ ព្រមទាំងព្រឹត្តិការណ៍នយោបាយនានា ពិសេសទិវាបុណ្យចូលឆ្នាំសកល ខួបអនុស្សាវរីយ៍ទិវាជ័យជម្នះ ៧មករា លើកទី៤៧ ត្រូវបានធានាការពារយ៉ាងគត់មត់។ កម្មវិធីជាតិនិងអន្តរជាតិសរុប**៩៤៧លើក** ត្រូវបានធានាសណ្តាប់ធ្នាប់ និងដំណើរការដោយរលូន និងសកម្មភាពបាតុកម្ម កូដកម្មកើតឡើងចំនួន**១០លើក** កើនឡើងចំនួន**៨លើក** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ កម្លាំងមានសមត្ថកិច្ចបញ្ចៀសបាននូវអំពើភេរវកម្ម និងទប់ស្កាត់បានទាន់ពេលវេលានូវឧបាយកលទុច្ចរិតប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ តាមរយៈបដិវត្តន៍ពណ៌ពីសំណាក់ក្រុមប្រឆាំងជ្រុលនិយមនៅក្នុងនិងក្រៅប្រទេស។

**ក- ការងារគ្រប់គ្រងច្រកទ្វារព្រំដែន សភាពការណ៍សន្តិសុខនៅតាមតំបន់ព្រំដែន និងការងារគ្រប់គ្រងព្រំដែន**

**ក.១- ការងារគ្រប់គ្រងច្រកទ្វារព្រំដែន៖**

ព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារព្រំដែនចំនួន**៨២** ក្នុងនោះ ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន**៣** ច្រកទ្វារកំពង់ផែអន្តរជាតិចំនួន**៥** ច្រកទ្វារព្រំដែនអន្តរជាតិចំនួន**២៦** ច្រកទ្វារព្រំដែនទ្វេភាគីចំនួន**១៤** ច្រកទ្វារតំបន់ព្រំដែនចំនួន**២៥** និងច្រកទ្វារកំពង់ផែសមុទ្រ**៩**។

**ក.២- សភាពការណ៍សន្តិសុខនៅតាមតំបន់ព្រំដែន**

- ព្រំដែនកម្ពុជា-ថៃៈ យោធាថៃនៅតែរំលោភបទឈប់បាញ់នៅតំបន់មួយចំនួន នៅក្នុងខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ និងខេត្តពោធិ៍សាត់។ ក្រុមអ្នកសង្កេតការណ៍អាស៊ាន(AOT) បានចុះសង្កេតការណ៍ ផ្ទៀងផ្ទាត់ និងរាយការណ៍អំពីស្ថានភាពតំបន់នានាដែលរងការខូចខាតធ្ងន់ធ្ងរដោយសារការវាយប្រហារប្រដាប់អាវុធរបស់យោធាថៃ នៅក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ ព្រះវិហារ បន្ទាយមានជ័យ ពោធិ៍សាត់ និងខេត្តបាត់ដំបង។ ដោយឡែក ព្រំដែនកម្ពុជា-វៀតណាម និងព្រំដែនកម្ពុជា-ឡាវ ពុំមានអ្វីគួរឱ្យកត់សម្គាល់។

- កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធបានសហការ និងម្ចាស់ការល្បាតការពារ ត្រួតពិនិត្យបង្គោលសីមាភូមិសាស្ត្រ ក្តាប់សភាពការណ៍នៅតាមខ្សែបន្ទាត់ព្រំដែនបាន**១ ២៧០លើក** ក្នុងនោះ ព្រំដែនកម្ពុជា-ថៃ**៥៩៣លើក** ព្រំដែនកម្ពុជា-វៀតណាម **៤៩១លើក** និងព្រំដែនកម្ពុជា-ឡាវ**១៨៦លើក**។

**ក.៣- ការងារគ្រប់គ្រងព្រំដែន**

**រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**(រ.ក.ព.) សម្រេចបាននូវសមិទ្ធផលជាច្រើនលើបេសកកម្មរបស់ខ្លួនក្នុងការដឹកនាំ និងគ្រប់គ្រងកិច្ចការព្រំដែន ទាំងព្រំដែនគោក និងព្រំដែនសមុទ្រ ដើម្បីសម្រេចបាន

នូវចក្ខុវិស័យឈានទៅកសាងខ្សែព្រំដែនមួយពេញលេញ ច្បាស់លាស់ និងស្ថាពរ ជាព្រំដែនមិត្តភាព សន្តិភាព ស្ថិរភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ជាលទ្ធផល សកម្មភាពការងារសំខាន់ៗដែលរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនសម្រេចបាន ដូចខាងក្រោម៖

**១- ជាមួយព្រះរាជាណាចក្រថៃ** (១) បានចុះត្រួតពិនិត្យទីតាំងបង្គោលបណ្ដោះអាសន្ន និងបានបោះបង្គោលតម្រុយ មុនពេលអនុញ្ញាតឱ្យកងកម្លាំងវិស្វកម្មកម្ពុជាឈូសឆាយផ្លូវព្រំដែន ចាប់ពីបង្គោលលេខ52-56 ក្នុងភូមិសាស្ត្រឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង (២) បានចុះត្រួតពិនិត្យការឈូសឆាយផ្លូវព្រំដែន នៅចន្លោះបង្គោលលេខ52-54 ក្នុងភូមិសាស្ត្រឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង និង(៣) បានចុះពិនិត្យស្ថានការណ៍ជាក់ស្ដែងតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រស្រុកអូរជ្រៅ និងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

**២- ជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ** (១) បានចុះផ្លាស់ប្ដូរបង្គោលព្រំដែនចាស់ដែលបានបោះ កាលពីឆ្នាំ២០០០-២០០៥ ជំនួសដោយបង្គោលព្រំដែនថ្មីចំនួន**២ទីតាំង** ស្មើនឹង**៣បង្គោល** ក្នុងភូមិសាស្ត្រខេត្តព្រះវិហារ-ខេត្តចំប៉ាសាក់ និងខេត្តរតនគិរី-ខេត្តអាត់តាពើ (២) បានចុះកំណត់ទីតាំងបង្គោលព្រំដែនថ្មីបន្ថែមចំនួន**១១ទីតាំង** ស្មើនឹង**១៣បង្គោល** ក្នុងភូមិសាស្ត្រខេត្តព្រះវិហារ-ខេត្តចំប៉ាសាក់ និងខេត្តរតនគិរី-ខេត្តអាត់តាពើ (៣) បានវាស់វែងយកនិយាមកាបង្គោលព្រំដែនបំពេញបន្ថែមចំនួន**១២បង្គោល** ក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង-ខេត្តចំប៉ាសាក់ និង(៤) បានបញ្ចប់ការងារសាងសង់បង្គោលព្រំដែនចំនួន**៨បង្គោល** ក្នុងភូមិសាស្ត្រខេត្តព្រះវិហារ/ស្ទឹងត្រែង-ខេត្តចំប៉ាសាក់។

**៣- ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម** (១) បានរៀបចំកិច្ចប្រជុំក្រុមជំនាញចម្រុះព្រំដែនកម្ពុជា-វៀតណាម វៀតណាម-កម្ពុជា កាលពីថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០២៦ នៅច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍-ប៊ិញហៀប ក្នុងភូមិសាស្ត្រខេត្តស្វាយរៀង-ខេត្តតៃនិញ (២) បានចុះត្រួតពិនិត្យ និងកែសម្រួលទីតាំងបង្គោលសញ្ញាសម្គាល់ខ្សែគ្រប់គ្រងជាក់ស្ដែងនៅចន្លោះបង្គោលលេខ211-213 ចំនួន**៥៦បង្គោល** ក្នុងភូមិសាស្ត្រខេត្តស្វាយរៀង-ខេត្តតៃនិញ (៣) បានចុះត្រួតពិនិត្យភាគីវៀតណាម ជួសជុល ថែទាំ និងកែលម្អបង្គោលព្រំដែនចំនួន**៣បង្គោល** ក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី-ខេត្តដាក់ឡាក់ និង (៤) បានចុះត្រួតពិនិត្យស្ថានភាពគុណភាពបង្គោលព្រំដែននៅកំណាត់ខ្សែព្រំដែន ចន្លោះបង្គោលលេខ 46(1,2,3)-47(1) ក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី-ខេត្តដាក់ឡាក់។ ជាលទ្ធផលឃើញថា មានបង្គោលចំនួន**២៤បង្គោល** បានរងការសឹករេចរឹល បាក់បែក បាក់ស្រុត ស្លែកាន់ រលុបតួអក្សរចារឹកលើបង្គោល និងមានទីតាំងបង្គោលមួយចំនួនបានបាក់ស្រុតមាត់ច្រាំង ដែលត្រូវមានវិធានការជួសជុល ថែទាំ និងកែលម្អឡើងវិញ។

**ខ- ការងារប្រជាធិបតេយ្យនីយកម្ម**

ក្រសួងមហាផ្ទៃ បានសម្រេចអនុញ្ញាតឱ្យគណបក្សនយោបាយចុះបញ្ជីចំនួន**១**គណបក្ស។ បច្ចុប្បន្ន គណបក្សនយោបាយដែលបានបង្កើតនិងចុះបញ្ជីនៅក្រសួងមហាផ្ទៃសរុបចំនួន**៥៧** ក្នុងនោះ គណបក្សនយោបាយបានចុះបញ្ជីមានចំនួន**៥៤**។

ក្រសួងមហាផ្ទៃ បានសម្រេចធ្វើការផ្លាស់ប្ដូរ និងទទួលស្គាល់សមាសភាពក្រុមប្រឹក្សាថ្នាក់ក្រោមជាតិសរុបចំនួន**១៧រូប**(ស្រី១រូប)។

### គ- ការងារទប់ស្កាត់និងការបង្ក្រាបបទល្មើស

**គ.១- លទ្ធផលនៃការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ អំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ បទល្មើសសេដ្ឋកិច្ច បទល្មើសបច្ចេកវិទ្យា សកម្មភាពជនទំនើង និងល្បែងស៊ីសងខុសច្បាប់**

**ក្រសួងមហាផ្ទៃ៖**

- បទល្មើសព្រហ្មទណ្ឌជារួមកើតឡើងចំនួន**២៥៩** បើធៀបនឹងខែកន្លងទៅ**២៣១លើក** កើនឡើង **២៨លើក** ស្មើនឹង**២%** ក្នុងនោះ បង្កឱ្យមនុស្សស្លាប់ចំនួន**២៤នាក់** របួសចំនួន**៧៥នាក់** ព្រមទាំងបាត់បង់មធ្យោបាយ សម្ភារៈ មាស ប្រាក់មួយចំនួន។ ការបង្ក្រាបបទល្មើសព្រហ្មទណ្ឌចំនួន**២៤៨ករណី** ស្មើនឹង៩៦% ឃាត់ខ្លួនចំនួន**៤៥៩នាក់**(ធ្វើតេស្តរកឃើញវិជ្ជមានសារធាតុញៀនចំនួន**១៣៨នាក់** ស្មើនឹង៣០%) រឹបអូសវត្ថុតាងបានអាវុធវែង**២ដើម** អាវុធខ្លី**៧ដើម** កាំបិត-ដាវ**១៣ដើម** រថយន្ត**១៥គ្រឿង** ម៉ូតូ**៩៧គ្រឿង** និងឧបករណ៍សម្ភារៈប្រព្រឹត្តបទល្មើសមួយចំនួនកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត។

- បង្ក្រាបការជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន**១០ករណី** ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី ខេត្តចំនួន**១៧នាក់**(ស្រី១នាក់ ជនបរទេស៤នាក់) និងសង្គ្រោះជនរងគ្រោះបានចំនួន**៨៤នាក់**(បញ្ជូនទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន**៧៤នាក់** និងអាណាព្យាបាលចំនួន**១០នាក់**)។ ចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥ ដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦ ក្រសួងមហាផ្ទៃទទួលបានសំណើសុំអន្តរាគមន៍ជួយសង្គ្រោះតាមរយៈទំព័រហ្វេសប៊ុករបស់ ឯកឧត្តម អភិសន្តិបណ្ឌិត និងពីប្រភពផ្សេងៗចំនួន**១៥២សំណើ** មនុស្សចំនួន**២៩៣នាក់**(ស្រី៤៦នាក់ មាន១៦សញ្ជាតិ)។ សមត្ថកិច្ចបានបើកប្រតិបត្តិការស្រាវជ្រាវស៊ើបអង្កេតចំនួន**៦២សំណើ** មនុស្សចំនួន**១៥២នាក់** (ស្រី២៩នាក់ មាន៨សញ្ជាតិ) ក្នុងនោះ រកឃើញចំនួន**៣៩សំណើ** មនុស្សចំនួន**១០៦នាក់**(ស្រី២២នាក់ មាន៦សញ្ជាតិ) រកពុំឃើញចំនួន**២៣សំណើ** មនុស្សចំនួន**៤៦នាក់**(ស្រី៧នាក់ មាន៨សញ្ជាតិ) រីឯចំនួន **១២៩សំណើ**ផ្សេងទៀត កំពុងបន្តស្រាវជ្រាវ។

- បង្ក្រាបបទល្មើសសេដ្ឋកិច្ចគ្រប់ប្រភេទចំនួន**៣៧លើក** ឃាត់ខ្លួនចំនួន**១០នាក់** បានបញ្ជូនទៅអង្គភាពពាក់ព័ន្ធដើម្បីចាត់ការតាមនីតិវិធី។ ករណីបង្ក្រាបបានខាងលើភាគច្រើនជាបទល្មើសធនធានធម្មជាតិ គ្រឿងឧបភោគ បរិភោគខូចគុណភាព បទល្មើសកម្មសិទ្ធិបញ្ញាជាដើម

- បង្ក្រាបបទល្មើសបច្ចេកវិទ្យាដែលមានតម្រុយពាក់ព័ន្ធOnline Scams ចំនួន**៨ទីតាំង** ឃាត់ខ្លួនក្នុងវង្វង់ប្រតិបត្តិការចំនួន**២ ៥១១នាក់/១០សញ្ជាតិ** និងបានរកឃើញឃាត់ខ្លួនជនបរទេសដែលបានចល័តចេញពីទីតាំងសង្ស័យOnline Scams ឆ្ពោះទៅរាជធានី ខេត្តផ្សេងៗចំនួន**១ ៣៥៣នាក់/១៨សញ្ជាតិ** រៀបចំនីតិវិធីបណ្តេញចេញពីប្រទេសកម្ពុជា

- បង្ក្រាបសកម្មភាពជនទំនើងបានចំនួន**៨៩ករណី** បើធៀបនឹងខែកន្លងទៅ**៨៤ករណី** កើនឡើង **៥លើក** ស្មើនឹង**៥,៩៥%** ឃាត់ខ្លួនចំនួន**២០៦នាក់**(ស្រី៤នាក់) អនុវត្តវិធានការច្បាប់ កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត**២០៦នាក់**(ស្រី៤នាក់) និងអនុវត្តវិធានការរដ្ឋបាល**៨៩នាក់**

- បង្ក្រាបបទល្មើសល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទចំនួន**៤០លើក** បើធៀបនឹងខែកន្លងទៅ **២៥លើក** កើនឡើង**១៥លើក** ស្មើនឹង**៦០%** និងឃាត់ខ្លួនជនសង្ស័យចំនួន**១២៥នាក់** រួមទាំងវត្ថុតាងមានម៉ូតូ**២១គ្រឿង** និងកុំព្យូទ័រ**២គ្រឿង** ដោយអនុវត្តវិធានការច្បាប់ចំនួន**១៨ករណី** មនុស្សចំនួន**៨២នាក់** (ស្រី**២១នាក់**) កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត និងវិធានការរដ្ឋបាលចំនួន**២២ករណី** មនុស្សចំនួន៤៣នាក់(ស្រី**២២នាក់**)។

**គ.២- លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន**

**ការកាត់បន្ថយតម្រូវការគ្រឿងញៀន៖**

- តាមរយៈការព្យាបាលដោយស្ម័គ្រចិត្តនិងផ្អែកលើសហគមន៍ ក្រសួងសុខាភិបាលបានផ្តល់សេវាព្យាបាលដល់អ្នកប្រើប្រាស់និងអ្នកញៀនគ្រឿងញៀនបាន២ **២៣៨នាក់**(ស្រី៧៩នាក់) មានមន្ទីរពេទ្យបង្អែក**៤៧៣នាក់**(ស្រី២៤នាក់) និងមណ្ឌលសុខភាព**១៩នាក់**(ស្រី២នាក់)

- ការព្យាបាលនិងស្តារនីតិសម្បទានអ្នកញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀនរបស់រដ្ឋនិងឯកជនបាន**១២ ១៨៨នាក់** ក្នុងនោះ អ្នកកំពុងស្នាក់នៅក្នុងមជ្ឈមណ្ឌលចំនួន**៨ ៥៥៩នាក់**(ស្រី១៧០នាក់) អ្នកចូលថ្មីចំនួន**១ ៧៣៦នាក់**(ស្រី១០៦នាក់) និងអ្នកធ្វើសមាហរណកម្មចំនួន**១ ៨៩៣នាក់**(ស្រី៨៥នាក់)

- កម្លាំងសមត្ថកិច្ចបានបង្ក្រាបបទល្មើសគ្រឿងញៀនចំនួន**៨៦៥ករណី** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន**៨៥៧ករណី** កើនឡើង**៨ករណី** ស្មើនឹង**០,៩៣%** ចាប់បានជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី ខេត្តចំនួន**២ ១០៨នាក់**(ស្រី១៣០នាក់) បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន**២ ២៦១នាក់** ថយចុះ**១៥៣នាក់** ស្មើនឹង**៦,៧៦%** ក្នុងនោះ ជនជាតិខ្មែរ**២ ០១៤នាក់**(ស្រី១២៣នាក់) វៀតណាម**២៥នាក់**(ស្រី៧នាក់) ចិន**៤២នាក់** ចិនតៃវ៉ាន់**៨នាក់** កូរ៉េខាងត្បូង**១នាក់** អាមេរិក**១នាក់** បារាំង**១នាក់** នេប៉ាល**២នាក់** បង់ក្លាដែស**១នាក់** ឥណ្ឌូណេស៊ី**៨នាក់** និងឥណ្ឌា**៥នាក់**។ រឹបអូសគ្រឿងញៀនសរុប**៥៤១គ.ក្រ.និង៩៥៤,២៦ក្រ.** កញ្ឆាក្រៀម**៦គ.ក្រ.និង៤៣២ក្រ.** សារធាតុគីមីផ្សំ**៦៧៤,៩៦គ.ក្រ.** រថយន្ត**១៨គ្រឿង** ម៉ូតូ**២០២គ្រឿង** ទូរសព្ទ**៩០៣គ្រឿង** ជញ្ជីង**៧២គ្រឿង** អាវុធវែង**១ដើម** អាវុធខ្លី**៧ដើម** និងវត្ថុតាងមួយចំនួនទៀត។ ចំពោះការអនុវត្តវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត បានចុះធ្វើតេស្តរហ័សរកសាធាតុញៀនលើក្រុមគោលដៅ**៧០លើក** លើមុខសញ្ញា**៣២២នាក់**(ស្រី៣២) រកឃើញវិជ្ជមានសារធាតុញៀន**៨៧នាក់** ត្រូវបានសមត្ថកិច្ចបញ្ជូនតាមនីតិវិធីច្បាប់ទៅទទួលយកសេវាបន្សាបនិងព្យាបាល។

**ឃ- ការងារទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់សង្គម និងគ្រោះមហន្តរាយផ្សេងៗ**

**ក្រសួងមហាផ្ទៃ៖**

គ្រោះថ្នាក់ចរាចរណ៍កើតឡើងចំនួន**២៥៦លើក** បើធៀបនឹងខែកន្លងទៅ**២៦២លើក** ថយចុះ**៦លើក** ស្មើនឹង**២%** បណ្តាលឱ្យស្លាប់ចំនួន**១៣៩នាក់** និងរបួសចំនួន**៣៧៩នាក់**។

**ង- លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន**

- **រាំងស្ងួត** រាំងស្ងួតដែលកើតមានគឺទាក់ទងនឹងកង្វះខាតទឹកសម្រាប់ដំណាំកសិកម្ម បន្ទាប់ពីរដូវវស្សា ឆ្នាំ២០២៥ បានបញ្ចប់ បរិមាណទឹកភ្លៀងចុងរដូវមានតិចតួចបំផុតដែលធ្វើឱ្យកម្រិតកម្ពស់ទឹកទន្លេ ស្ទឹង ព្រែក បឹងបួរ មានការស្រកចុះជាបន្តបន្ទាប់ ទោះបីជាស្ថានភាពអាកាសធាតុមិនសូវក្តៅខ្លាំងក្តី។ ស្ថានភាពនៃការខ្វះខាតទឹកស្រោចស្រពសម្រាប់ស្រូវរដូវប្រាំង រួមមាន ខ្វះទឹកសម្រាប់ស្រូវរដូវប្រាំងនៅមូលដ្ឋានខេត្តចំនួន៤ គឺខេត្តពោធិ៍សាត់ ព្រៃវែង តាកែវ និងខេត្តបន្ទាយមានជ័យ។ ស្រូវរដូវប្រាំងខ្វះទឹកកំពុងធ្វើអន្តរាគមន៍បើកបញ្ចេញទឹកសង្គ្រោះ(ទិន្នន័យបឋម) ខេត្តព្រៃវែង មាន**៣ស្រុក** **១៣ឃុំ** មានចំនួន

៩ ៨៨៣ហ.ត. ខេត្តពោធិ៍សាត់ មាន១ស្រុក ២ឃុំ មានចំនួន៣ ០៦០ហ.ត. ខេត្តតាកែវ ១ស្រុក មានចំនួន ៤ ០០០ហ.ត. និងខេត្តបន្ទាយមានជ័យ មាន២ស្រុក ៨ឃុំ មានចំនួន១៧ ១៤៧ហ.ត. អាងស្តុកទឹក និងប្រព័ន្ធធារាសាស្ត្រមួយចំនួន ចាប់ផ្តើមបើកបញ្ចេញទឹកតាមសំណូមពររបស់ប្រជាកសិករក្នុងការប្រើប្រាស់ប្រចាំថ្ងៃ ជាពិសេសការផ្គត់ផ្គង់ស្រូវរដូវប្រាំង។

- **បាក់ច្រាំងទន្លេ ស្ទឹង** កើតមានចំនួន**៣ករណី** នៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។ ស្ថានភាពរងគ្រោះ ផ្ទះរំកិល និងរុះរើចេញចំនួន**១ខ្នង** បាក់ស្រុតច្រាំងទន្លេមេគង្គចំនួន**៣៥០ម.** និងទទឹងពី**៤ម.** ទៅ**១០ម.**

- **អគ្គិភ័យ** កើតមានចំនួន**៨៧លើក** នៅមូលដ្ឋានរាជធានី ខេត្តចំនួន២២ បណ្តាលឱ្យឆេះផ្ទះចំនួន**៨៤ ខ្នង/ល្វែង** ខ្សែនិងតួបលក់ដូរចំនួន**២២** ឆេះឃ្លាំងស្តុកសម្ភារៈចំនួន**៦កន្លែង** រោងចក្រចំនួន**១កន្លែង** កុដិលោកចំនួន**១កន្លែង** និងសិប្បកម្មកែច្នៃចំនួន**៤កន្លែង** ឆេះចម្ការតាដែន ត្របែក ម្រេច និងទុរេនប្រមាណ**៣ហ.ត.** ឆេះទីលានចាក់សំរាមចំនួន**២លើក** ព្រៃស្មៅនិងកក់ចំនួន**៤កន្លែង** និងព្រៃឈើចំនួន**៦កន្លែង** ប្រមាណ**២០ហ.ត.** ឆេះខូចខាតស្រូវជង្រុកចំនួន**១ ៥០០គ.ម.** រថយន្តចំនួន**៣គ្រឿង** ម៉ូតូចំនួន**១១គ្រឿង** រងគ្រោះស្លាប់**២នាក់** និងរងរបួស**៦នាក់**។

**ច- ការងារបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម**

**អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន(អាជ្ញាធរមីន)៖**

- ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម សកម្មភាពបោសសម្អាតមីនដោយប្រតិបត្តិករធំចំនួន៥ រួមមាន មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា អង្គការហាឡូត្រាស់ អង្គការម៉ែក អង្គការដោះមីនកម្ពុជា និងអង្គការអាប៉ូប៉ូ សម្រេចបានផ្ទៃដីចំនួន**១១ ០៧០ ៧០៧ម²** រកឃើញនិងកម្ទេចចោលមីនប្រឆាំងមនុស្សចំនួន**១៩៩គ្រាប់** មីនប្រឆាំងរថក្រោះចំនួន**២គ្រាប់** សំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន**៣ ៥១០គ្រាប់**។ គិតចាប់ពីឆ្នាំ១៩៩២ ដល់ខែមករា ឆ្នាំ២០២៦ បានបោសសម្អាតផ្ទៃដីចំនួន**៣ ៥៥២ ៥១៣ ៥៧៧ម²** រកឃើញនិងកម្ទេចចោលមីនប្រឆាំងមនុស្សចំនួន**១ ២០៧ ៣៣២គ្រាប់** មីនប្រឆាំងរថក្រោះចំនួន**២៦ ៧០២គ្រាប់** សំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន**៣ ២៤៧ ៥៨៨គ្រាប់**

ក្នុងខែមករា ឆ្នាំ២០២៦ ជនរងគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន**៥នាក់** ក្នុងនោះ គ្រោះថ្នាក់ដោយសារមីនចំនួន**១នាក់** និងដោយសារសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន**៤នាក់** បើធៀបនឹងខែដូចគ្នាឆ្នាំមុន ថយចុះ**១នាក់**។

ទន្ទឹមនេះ ខេត្តចំនួន១៥ ដែលបានប្រកាសជាអស់មីន រួមមានរាជធានីភ្នំពេញ ខេត្តកែប ព្រៃវែង ត្បូងឃ្មុំ កំពង់ចាម ស្វាយរៀង ព្រះសីហនុ កំពង់ឆ្នាំង កណ្តាល តាកែវ កំពត ស្ទឹងត្រែង កំពង់ស្ពឺ មណ្ឌលគិរី និងខេត្តក្រចេះ។

**ឆ- ការពង្រឹងការងារអន្តោប្រវេសន៍ និងការងារអត្តសញ្ញាណកម្ម**

**ក្រសួងមហាផ្ទៃ៖**

**ឆ.១. ការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍**

**- ការងារគ្រប់គ្រងវត្តមានជនបរទេស**

**+ ការងារគ្រប់គ្រងជនបរទេសជនបរទេសអន្តោប្រវេសន្ត និងជនភៀសខ្លួន** បានទទួលពាក្យស្នើសុំបណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកដំបូង និងពាក្យស្នើសុំបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍ពី

ជនបរទេសអន្តោប្រវេសន្តសរុប១ ០៤៤ច្បាប់។ ក្រសួងបានប្រគល់បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្តចំនួន៨២៥បណ្ណ ក្នុងនោះ បណ្ណស្នាក់នៅលើកដំបូងចំនួន**៧៣បណ្ណ** និងបណ្ណបន្តសុពលភាពរយៈពេលពីរឆ្នាំម្តងចំនួន**៧៥២បណ្ណ**។ បច្ចុប្បន្ន ជនបរទេសដែលទទួលបានឋានៈជាជនភៀសខ្លួននៅកម្ពុជាមាន**៦៣នាក់**(ស្រី១៧នាក់ មាន៨សញ្ជាតិ) និងអ្នកសុំសិទ្ធិជ្រកកោនមាន**៩នាក់**(ស្រី៣នាក់ មាន៥សញ្ជាតិ)

+ **ការងារគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន៍** បានផ្តល់ទិដ្ឋាការចូលប្រទេសពេលមកដល់ចំនួន**១១១ ៨០៨នាក់**( ទិដ្ឋាការប្រភេទK ចំនួន៣ ១១៩នាក់) ទិដ្ឋាការចូលស្នើសុំតាមប្រព័ន្ធអេឡិចត្រូនិក(e-Visa) ចំនួន**៧៨ ៧៣៧នាក់** និងទិដ្ឋាការចេញចំនួន**១ ០៣២នាក់** និងបានពិនិត្យសម្រេចលើសំណើសុំទិដ្ឋាការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នសរុប**១០៩ ០៧៨នាក់** ដោយបានរកឃើញអ្នកស្នាក់នៅហួសរយៈពេលកំណត់ចំនួន**២៩៦នាក់** ផាកពិន័យជាទឹកប្រាក់ចំនួន**៤៥ ៩២០ដុល្លារអាម៉េរិក** បង់ចូលថវិកាជាតិ។

**- ការងារបច្ចេកវិទ្យាឌីជីថលសម្រាប់គ្រប់គ្រងអន្តោប្រវេសន៍**

+ បានរៀបចំនិងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់គ្រប់គ្រងអន្តោប្រវេសន៍ រួមមានប្រព័ន្ធគ្រប់គ្រងអ្នកដំណើរចេញ ចូលព្រះរាជាណាចក្រកម្ពុជា(TMS) ប្រព័ន្ធច្រកទ្វារឆ្លាតវៃ(Smart Gate) ប្រព័ន្ធទិដ្ឋាការពេលមកដល់ជំនាន់ថ្មី(VOA-Plus) ប្រព័ន្ធអេឡិចត្រូនិកសលាកបត្រចូលព្រះរាជាណាចក្រកម្ពុជា(Cambodia e-Arrival) ប្រព័ន្ធពន្យារទិដ្ឋាការ(Visa Extension System) ប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា(FPCS) ប្រព័ន្ធគ្រប់គ្រងការងារអធិការកិច្ចពលករបរទេស ឬហត្ថពលកម្មបរទេស(FLIS) ប្រព័ន្ធគ្រប់គ្រងមុខសញ្ញាអន្តោប្រវេសន៍(ALS) ប្រព័ន្ធបណ្តេញចេញ (RCMS) ប្រព័ន្ធគ្រប់គ្រងអ្នកដំណើរលក្ខណៈតំបន់ និងទេសភាគី-កាស៊ីណូ(BLTMS-Casino) ប្រព័ន្ធគ្រប់គ្រងជនសង្ស័យជាជនបរទេស(FSMS) ប្រព័ន្ធCambodia v-Pass ប្រព័ន្ធសន្តិសុខសង្គម(SSS) ប្រព័ន្ធទិដ្ឋាការចេញថ្មី(Exit Visa System) និងថ្នាលផ្លាស់ប្តូរទិន្នន័យអគ្គនាយកដ្ឋានអន្តោប្រវេសន៍(IDX)

+ បានបញ្ចូលទិន្នន័យជនបរទេសស្នាក់នៅរយៈពេលវែងទៅក្នុងប្រព័ន្ធFPCSបានចំនួន**២១១ ៧៦៦នាក់** ស្ថិតក្នុងទីតាំងចំនួន**២០ ០០៤ទីតាំង**

+ បានបញ្ចូលក្នុងប្រព័ន្ធALS នូវទិន្នន័យមុខសញ្ញាប្រភេទ(A B C D E) ចំនួន**១ ១៨៩នាក់/៣៥សញ្ជាតិ** និងទិន្នន័យមោឃៈលិខិតឆ្លងដែន(F) ចំនួន**៥៧៥នាក់/២៥សញ្ជាតិ**

+ បានសហការស្រាវជ្រាវប្រវត្តិអ្នកដំណើរចេញចូលប្រទេសពីក្នុងប្រព័ន្ធTMS រកឃើញមុខសញ្ញាឆ្លើយតបទៅក្រសួង ស្ថាប័នជាតិ និងអន្តរជាតិចំនួន**១ ៥១០នាក់/៥១សញ្ជាតិ**។

**- ការងារស៊ើបអង្កេត និងអនុវត្តនីតិវិធី**

+ ជនបរទេសរងគ្រោះដោយឧបទ្ទវហេតុ និងបទល្មើសផ្សេងៗចំនួន**៨០លើក** ស្មើនឹង៨៩នាក់ (ស្រី៩នាក់ មាន១៩សញ្ជាតិ) ក្នុងនោះស្លាប់ដោយសារជំងឺចំនួន**៤៩នាក់**(ស្រី៤នាក់) ដោយធ្វើអត្តឃាតចំនួន**៦នាក់** ដោយឃាតកម្មចំនួន៤នាក់ ដោយឧបទ្ទវហេតុចំនួន**១១នាក់**(ស្រី២នាក់) ដោយគ្រោះថ្នាក់ចរាចរណ៍ចំនួន**៣នាក់**(ស្រី១នាក់) និងរងគ្រោះដោយបទល្មើសផ្សេងៗចំនួន**១៦នាក់**(ស្រី២នាក់)។

+ បើកប្រតិបត្តិការបង្ក្រាបជនបរទេសប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌចំនួន**១៧លើក** ឃាត់ខ្លួនចំនួន**២៥៣នាក់**(ស្រី៤៩នាក់ មាន៦សញ្ជាតិ) និងបទល្មើសអន្តោប្រវេសន៍ចំនួន**៣០លើក** ស្មើនឹង**១៣៤នាក់**(ស្រី១៧នាក់ មាន១៥សញ្ជាតិ)។

+ បានអនុវត្តនីតិវិធីបណ្ដេញជនបរទេសល្មើសច្បាប់ចេញពីប្រទេសចំនួន**១៨១លើក** ស្មើនឹង**១ ៣១៣នាក់** (ស្រី៣១៤នាក់ មាន៣៥សញ្ជាតិ)។

**ធ.២. ការងារអត្តសញ្ញាណកម្ម**

**- ការងារអត្រានុកូលដ្ឋាន**

+ ចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទបានចំនួន**៩៤ ៦៤៣បញ្ជី** ស្មើនឹង**១២៥ ៩៦៥នាក់** (ស្រី៦១ ៨៦៣នាក់) ក្នុងនោះ បញ្ជីកំណើតចំនួន**៥៣ ១១៧បញ្ជី** បញ្ជីអាពាហ៍ពិពាហ៍ចំនួន**៣១ ៣២២បញ្ជី** និងបញ្ជីមរណភាពចំនួន**១០ ២០៤បញ្ជី**។ គិតពីខែសីហា ឆ្នាំ២០០២ ដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦ ចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទបានចំនួន**២២ ២០៦ ៣៩៣បញ្ជី** ស្មើនឹង**២៣ ៩៣១ ៣៤០នាក់** (ស្រី១១ ៤៧២ ៨១៣នាក់)

+ ចេញសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទបានចំនួន**៣១៣ច្បាប់** ស្មើនឹង**១ ៥៨១សន្លឹក** និងទទួលបានសាលក្រមនិងដីកាសម្រេចពីសាលាដំបូងរាជធានី ខេត្ត ចំនួន**៧១៥ច្បាប់**

+ ចេញសេចក្ដីសម្រេចស្ដីពីការកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានបានចំនួន**២ ២៧៦ច្បាប់**(បូកយោងពីដើមគ្រាបានចំនួន១៥៦ ៥០៤ច្បាប់)

+ ចេញសេចក្ដីសម្រេចលើសំណុំឯកសារស្ដីពីការសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេសបានចំនួន**២៥២ច្បាប់** មាន**២០សញ្ជាតិ**(បូកយោងពីដើមគ្រាបានចំនួន២៨ ២២៣ច្បាប់)

+ គិតត្រឹមខែមករា ឆ្នាំ២០២៦ បញ្ចូលទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានកំណើតគ្រប់ប្រភេទទៅក្នុងប្រព័ន្ធ បានចំនួន**៧ ៨៣៩ ៥៥៨បញ្ជី**

+ បានបើកផ្ដល់ជូនរដ្ឋបាលរាជធានី ខេត្តចំនួន៤ នូវសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន**៦២០ក្បាល** និងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន**២៩២ ៥០០សន្លឹក**។

**- ការងារគ្រប់គ្រងការស្នាក់នៅ**

+ប្រជាពលរដ្ឋដែលបានចុះបញ្ជីស្ថិតិសរុប**៤ ២៥៨ ៥៩៧គ្រួសារ** ស្មើនឹង**១៧ ១៦៣ ០៣៦នាក់** (ស្រី៨ ៧៤៧ ២៤១នាក់)

+ផ្ដល់ជូនប្រជាពលរដ្ឋនូវសៀវភៅស្នាក់នៅថ្មីចំនួន**៦ ៧៤៩ក្បាល**(បំបែកគ្រួសារថ្មី២ ៨៦០ក្បាល) ទុតិយតាចំនួន**៤ ៧៣៥ក្បាល** និងសៀវភៅគ្រួសារថ្មីចំនួន**៥ ២៤៨ក្បាល**(បំបែកគ្រួសារថ្មី២ ៣១៩ក្បាល) ទុតិយតាចំនួន**២ ៩០១ក្បាល**។ គិតចាប់ពីឆ្នាំ១៩៩៨ ដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦ បានផ្ដល់សៀវភៅស្នាក់នៅថ្មីចំនួន៣ ៩០០ ៣៣១ក្បាល ទុតិយតាចំនួន៨៥៨ ៩០៣ក្បាល និងផ្ដល់សៀវភៅគ្រួសារថ្មីចំនួន៣ ៥២៨ ៨៥៨ក្បាល ទុតិយតាចំនួន**៥២៧ ៦៧០ក្បាល**

+ការបញ្ចូលទិន្នន័យសៀវភៅស្នាក់នៅនិងសៀវភៅគ្រួសារទៅក្នុងប្រព័ន្ធកុំព្យូទ័រ(សម្រាប់ខេត្តកែប កំពត និងសង្កាត់ទាំង១៤ នៃរាជធានីភ្នំពេញ) រួមមាន សៀវភៅស្នាក់នៅបានចំនួន**៣៤៦គ្រួសារ**

ស្មើនឹង១ ៥០៤នាក់(ស្រី៧៨៤នាក់) និងសៀវភៅគ្រួសារបានចំនួន**១០៧គ្រួសារ** ស្មើនឹង៤២៥នាក់(ស្រី**២១៦នាក់**)។ គិតមកដល់បច្ចុប្បន្ន បញ្ចូលទិន្នន័យសៀវភៅស្នាក់នៅបានចំនួន**២៤ ៩៤៥គ្រួសារ** ស្មើនឹង**១០៣ ៣៩៨នាក់**(ស្រី៥២ ៩៨៨នាក់) និងសៀវភៅគ្រួសារបានចំនួន**៨ ៨៦៥គ្រួសារ** ស្មើនឹង**៣៥ ៦៣៣នាក់**(ស្រី១៨ ១០៨នាក់)

+ បានបើកផ្តល់ឯកសារស្ថិតិប្រជាពលរដ្ឋជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្តចំនួន៤ នូវបញ្ជីស្នាក់នៅ(ក១) ចំនួន**៦០ក្បាល** សៀវភៅស្នាក់នៅ(ក២) ចំនួន**១៩ ០០០ក្បាល** បញ្ជីគ្រួសារ (ក៣) ចំនួន**៦០ក្បាល** សៀវភៅគ្រួសារ(ក៤) ចំនួន**១៥ ០០០ក្បាល** និងលិខិតអនុញ្ញាតផ្លាស់ប្តូរទីលំនៅ(ក៦) ចំនួន**៩០ក្បាល**

+ បានទទួលពលរដ្ឋខ្មែរធ្វើមាតុភូមិនិវត្តន៍ពីសហរដ្ឋអាម៉េរិកចំនួន**២លើក** ស្មើនឹង**២៨នាក់**។ គិតចាប់ពីឆ្នាំ២០០២ មកដល់បច្ចុប្បន្ន ការទទួលពលរដ្ឋខ្មែរដែលធ្វើមាតុភូមិនិវត្តន៍ពីសហរដ្ឋអាម៉េរិកមានចំនួន**៣១៥លើក** ស្មើនឹង**៨៩៦នាក់**(ស្រី២៣នាក់)។

**- ការងារលិខិតឆ្លងដែន និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ**

+ បោះពុម្ពផ្តល់ជូនប្រជាពលរដ្ឋនូវលិខិតឆ្លងដែនចំនួន**១៧ ១៩៧ក្បាល** និងលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសចំនួន**៣០ ៩១០ក្បាល**

+ ទទួលបានទិន្នន័យស្នើសុំអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរគំរូថ្មីចំនួន**២៤៥ ១៦០នាក់** (ទិន្នន័យបានការមាន២៣៧ ១២៩នាក់ ស្នួនខ្មៅដៃ-ខូចមាន៨ ០៣១នាក់) និងពាក្យស្នើសុំបោះពុម្ពឡើងវិញនូវអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតាចំនួន**១៣ ៦៦៥សន្លឹក**

+ បោះពុម្ពអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ(ទាំងទិន្នន័យថ្មី និងទិន្នន័យទុតិយតា) បានចំនួន**២៣៧ ៤២១សន្លឹក** និងប្រគល់ជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្តចំនួន**២៤៩ ៤២៦សន្លឹក**។ ជារួមមកទល់ពេលនេះ ការបោះពុម្ពអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរគំរូថ្មីចំនួន**១៨ ២២២ ៦៨៤សន្លឹក** និងប្រគល់ជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្តចំនួន**១៨ ១១០ ៧៦៥សន្លឹក**

+ ចំពោះការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអស់សុពលភាពជូនប្រជាពលរដ្ឋក្នុងខែមករា ឆ្នាំ២០២៦ ចំនួន**២២១ ១៩៥នាក់**(នៅសល់ចំនួន៤ ៣៤៥ ៦៦៦នាក់ ដែលត្រូវបន្តផ្តល់)។

**- ការងារសញ្ជាតិ**

+ ទទួលបានសំណុំឯកសារស្នើសុំចូលសញ្ជាតិខ្មែរ ទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ និងលះបង់សញ្ជាតិខ្មែរចំនួន**១០នាក់**(ស្រី២នាក់)។ ក្រសួងមហាផ្ទៃបានអនុវត្តនីតិវិធីលើករណីស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មចំនួន**៤នាក់** និងដោយអាពាហ៍ពិពាហ៍ចំនួន**១នាក់**

+ ទទួលបានព្រះរាជក្រឹត្យត្រាស់បង្គាប់ផ្តល់សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មចំនួន**៥៤នាក់** (ស្រី៥នាក់) មាន**៧សញ្ជាតិ** និងដោយអាពាហ៍ពិពាហ៍ចំនួន**៣នាក់** មាន**២សញ្ជាតិ**។ គិតពីឆ្នាំ១៩៩៩ មកដល់បច្ចុប្បន្ន ជនបរទេសសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មសម្រេចបានចំនួន**៣ ១៤៤នាក់** មាន**៥៥សញ្ជាតិ** ទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍សម្រេចបានចំនួន**១៥៣នាក់** មាន**៣៤សញ្ជាតិ** និងស្នើសុំលះបង់សញ្ជាតិខ្មែរសម្រេចបានចំនួន**៣១២នាក់**។

**២- ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់និងឈ្នះឈ្នះ**

ក- ការងារទំនាក់ទំនងទ្វេភាគីនិងពហុភាគី

**ការផ្លាស់ប្តូរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ ចូលរួមកិច្ចប្រជុំ និងជំនួបជាមួយឥស្សរជនបរទេស**

ឯកឧត្តម **ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** បានដឹកនាំគណៈប្រតិភូ និងអនុញ្ញាតឱ្យ៖

- អញ្ជើញទៅចូលរួមកិច្ចប្រជុំចង្អៀត រដ្ឋមន្ត្រីការបរទេសអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ នៅកោះសេប៊ូ ប្រទេសហ្វីលីពីន កាលពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦។ នៅក្នុងអំឡុងពេលប្រជុំ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជួបជាមួយ ឯកឧត្តម **ថងសាវណ្ណ ភុមិវិហាន**(Thongsavan Phomvihane) រដ្ឋមន្ត្រីការបរទេសឡាវ ឯកឧត្តម **ឡេ ហ៍យជុង**(Le Hoai Trung) រដ្ឋមន្ត្រីការបរទេសវៀតណាម ឯកឧត្តម **ដាតូ ស៊ីរីវ៉ាន់ ពេហ៊ីន យូស៊ូហ៍**(Dato Erywan Pehin Yusof) រដ្ឋមន្ត្រីការបរទេសទី២ នៃព្រុយណេដារូសាឡឹម ឯកឧត្តម **ស៊ូហ្គីយ៉ូណូ**(Sugiono) រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ី ឯកឧត្តមបណ្ឌិត **វីវៀន បាឡាគ្រីសណាន**(Vivian Balakrishnan) រដ្ឋមន្ត្រីការបរទេសសិង្ហបុរី ឯកឧត្តម **ដាតុ ស៊េរី យូតាមា ហាជី មហាម៉ាដ ប៊ីន ហាជី ហាហ្សាន** (Dato' Seri Utama Haji Mohamad bin Haji Hasan) រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី លោកជំទាវ **ម៉ា តេរ៉េសា ភី ឡាហ្សារ៉ូ**(Ma. Theresa P. Lazaro) រដ្ឋមន្ត្រីការបរទេសហ្វីលីពីន។

- ឯកឧត្តម **ចូ ស្វយ័រ**(Jo Scheuer) អ្នកសម្របសម្រួលប្រព័ន្ធអ.ស.ប. ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងជម្រាបលា ក្នុងឱកាសដែលឯកឧត្តមបញ្ចប់អាណត្តិបេសកកម្មនៅកម្ពុជា នៅទីស្តីការក្រសួង កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦

- ឯកឧត្តម **ម៉ូហាំម៉ាត់ អ៊ីស្មាអែល អេ. ដាលវី**(Mohammed Ismaeil A.Dahlwy) ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពអារ៉ាប៊ីសាអូឌីត ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងជម្រាបលា នៅទីស្តីការក្រសួង កាលពីថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦

- ឯកឧត្តម **ម៉ៃឃើល ចច ដឺសុមប្រេ** ឧបការីរដ្ឋមន្ត្រីការបរទេសស.រ.អា ទទួលបន្ទុកតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក នៅទីស្តីការក្រសួង កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២៦

- ចុះហត្ថលេខាលើលិខិតប្តូរសារ និងឯកសារពាក់ព័ន្ធចំនួន**២គម្រោង** ជាមួយឯកឧត្តម **យូអ៊ីណូ អាត់ស៊ូស៊ី**(Ueno Atsushi) ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា រួមមាន (១) ហិរញ្ញប្បទានរបស់រដ្ឋាភិបាលជប៉ុន ដែលមានទឹកប្រាក់ចំនួន**១.៧០០.០០០.០០០យ៉េន**(ប្រមាណ ១១,៣លានដុល្លាអាមេរិក) សម្រាប់អនុវត្តគម្រោងសមាហរណកម្មការបោសសម្អាតគ្រាប់មីន និងសង្គ្រោះជនពិការដោយសារគ្រាប់មីន ដំណាក់កាលទី៣ និង(២) ហិរញ្ញប្បទានរបស់រដ្ឋាភិបាលជប៉ុន ដែលមានទឹកប្រាក់**១.១៤២.០០០.០០០យ៉េន**(ប្រមាណ៧,៦លានដុល្លាអាមេរិក) សម្រាប់ជំនួយម៉ាស៊ីនស្កេនកុងតឺន័រនៅចំណតកុងតឺន័រថ្មី កំពង់ផែក្រុងព្រះសីហនុ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២៦

- ឯកឧត្តម **បួរកែវ ភូមិវង្សសៃ**(Buakeo Phumvongsay) ឯកអគ្គរដ្ឋទូតឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងជម្រាបលា ក្នុងឱកាសដែលឯកឧត្តមបានបញ្ចប់បេសកកម្មការទូតនៅកម្ពុជា នៅទីស្តីការក្រសួង កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦

- ឯកឧត្តម **សានតូ ដាម៉ូស៊ូម៉ាតូ**( Santo Darmosumarto ) ឯកអគ្គរដ្ឋទូតឥណ្ឌូណេស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសមនិងជម្រាបលា ក្នុងឱកាសដែលឯកឧត្តមបានបញ្ចប់បេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការក្រសួង កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦

- ឯកឧត្តម **វ៉ាង វិនពីន**( Wang Wenbin ) ឯកអគ្គរដ្ឋទូតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសមនិងពិភាក្សាការងារ នៅទីស្ដីការក្រសួង កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦

- លោកជំទាវ **វ្លាដាំងកា អាន់ទ្រេវ៉ា**( Vladanka Andreeva ) អ្នកសម្របសម្រួលប្រព័ន្ធ អ.ស.ប. តែងតាំងថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសប្រគល់លិខិតសារតាំងរបស់លោកជំទាវ នៅទីស្ដីការក្រសួង កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦

- ឯកឧត្តម **ផ្លាវីយ៉ូ បូណេទី**( Flavio Bonetti ) តំណាងអង្គការយូណេស្កូតែងតាំងថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសប្រគល់លិខិតសារតាំងរបស់ឯកឧត្តម នៅទីស្ដីការក្រសួង កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦

- ឯកឧត្តម **គ្រីស្ទាន ដេសរ៉ូឆេស**( Cristian DesRoches ) ឯកអគ្គរដ្ឋទូតកាណាដា ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសមនិងពិភាក្សាការងារ នៅទីស្ដីការក្រសួង កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦

- លោកជំទាវ **ម៉ាឃីតា កូល ហាជកូវ៉ា**( Markéta Kolc Hájková ) ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពថ្មីនៃសាធារណរដ្ឋឆែក ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសម នៅទីស្ដីការក្រសួង កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦។

**ខ- ការងារការទូតសេដ្ឋកិច្ច វប្បធម៌ ទេសចរណ៍ និងការការពារផលប្រយោជន៍ខ្មែរនៅបរទេស**

- បន្តយកចិត្តទុកដាក់ខ្ពស់ ក្នុងការការពារផលប្រយោជន៍ និងសុខុមាលភាពពលរដ្ឋខ្មែរនៅបរទេសតាមរយៈការផ្ដល់កិច្ចអន្តរាគមន៍ និងជួយសម្របសម្រួលធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរនៅបរទេសឱ្យវិលត្រឡប់មកកម្ពុជាវិញសរុប**១២៦នាក់**( ស្រី៤៧នាក់ និងកុមារ៨នាក់ ) ពីប្រទេសថៃ វៀតណាម និងប្រទេសចិន

- ស្ថានតំណាងកម្ពុជានៅក្រៅប្រទេស និងក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច បាន និងកំពុងដើរតួយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈការចូលរួមយ៉ាងសកម្មក្នុងការងារការទូតសេដ្ឋកិច្ច សំដៅជំរុញពាណិជ្ជកម្មអន្តរជាតិ ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស លើកកម្ពស់វិស័យទេសចរណ៍ និងផ្សព្វផ្សាយវប្បធម៌ រួមទាំងមុខម្ហូបអាហារខ្មែរ។ ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច និងស្ថានតំណាងកម្ពុជានៅបរទេស (១) បានធ្វើចូលរួមពិព័រណ៍ទេសចរណ៍នៅប្រទេសចិន វៀតណាម ឥណ្ឌា និង( ២ ) បញ្ចប់ការបកប្រែសៀវភៅម្ហូប «កេរដំណែលស្នាដៃម្ហូបខ្មែរ ភាគទី២( Taste of Angkor 2 )» ជាភាសាបារាំង និងកំពុងរង់ចាំការសម្រេចជាផ្លូវការដើម្បីត្រៀមបោះពុម្ព។

**គ- ការបន្តអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់អន្តរជាតិ ការបន្តប្រកាន់គោលការណ៍អព្យាក្រឹត្យអចិន្ត្រៃយ៍មិនចូលបក្សសម្ព័ន្ធ និងការបន្តតម្កល់ផលប្រយោជន៍ស្នូលរបស់ជាតិជាចម្បង**

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិៈ

បាននិងកំពុងបំពេញការងារយ៉ាងសកម្មក្នុងការលើកតម្កើងកិត្តិនាមរបស់កម្ពុជា ដោយចូលរួមជាមួយសហគមន៍អន្តរជាតិ ដើម្បីបញ្ជាក់និងពង្រឹងជំហរលើបញ្ហាសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងគោលនយោបាយការបរទេស។ ឈរលើស្មារតីចូលរួមចំណែកក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចពិភពលោក ក៏ដូចជាសមាហរណកម្មកម្ពុជាចូលទៅក្នុងសហគមន៍អន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជា បានឯកភាពជាគោលការណ៍ដាក់បេក្ខភាពកម្ពុជា សម្រាប់តំណែងនៃសមាជិកភាពអង្គការអន្តរជាតិ គិតត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦ កម្ពុជាទទួលបានការគាំទ្រពីប្រទេសចំនួន**៨២** សម្រាប់បេក្ខភាពជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមរបស់អ.ស.ប.(Economic and Social Council-ECOSOC) សម្រាប់អាណត្តិ២០២៨-២០៣០ និងមានប្រទេសចំនួន**២៧** បានសម្រេចគាំទ្របេក្ខភាពកម្ពុជា ជាសមាជិកគណៈកម្មាធិការអន្តររដ្ឋាភិបាលសម្រាប់ការពារបេតិកភណ្ឌអរូបី(Intergovernmental Committee for the Safegarding of Intangible Cultural Heritage-ICS-ICH 2003) ក្រុមIV សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក អាណត្តិ២០២៦-២០៣០។

**ឃ- ការចូលរួមរបស់កងយោធពលខេមរភូមិន្ទ ក្នុងការបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ**

ក្រសួងការពារជាតិៈ

ចាប់ពីឆ្នាំ២០០៦ មកដល់បច្ចុប្បន្ន កម្ពុជាបានបញ្ជូនកងកម្លាំងទៅចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិចំនួន**១០ ៤៤០**នាក់(ស្រី៩៨៨នាក់) នៅចំនួន១០ប្រទេស រួមមានប្រទេសស៊ូដង់ ស៊ូដង់ខាងត្បូង លីបង់ ស៊ីប ឆាដ ស៊ីរី ម៉ាលី អាហ្វ្រិកកណ្តាល យេម៉ែន និងប្រទេសកុងហ្គោ។

បច្ចុប្បន្ន កម្លាំងកងយោធពលខេមរភូមិន្ទដែលកំពុងបំពេញបេសកកម្មក្រោមឆត្រអង្គការសហប្រជាជាតិមានចំនួន**៦២៩**នាក់(ស្រី១៣៥នាក់) នៅ៤ប្រទេសនិង៥បេសកកម្ម មានប្រទេសស៊ូដង់ ស៊ូដង់ខាងត្បូង លីបង់ អាហ្វ្រិកកណ្តាល និងប្រទេសកុងហ្គោ។

## ៣- ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ក- ការងារម៉ាក្រូសេដ្ឋកិច្ច**

- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខបានកើនឡើង**០,៣៨%** បើធៀបនឹងខែកន្លងទៅ និងកើនឡើង**១,២៦%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន

- អត្រាប្តូរប្រាក់គឺ**៤ ០២៦**រៀល ក្នុងមួយដុល្លារអាម៉េរិក ប្រាក់រៀលធ្លាក់ថ្លៃ**០,៣២%** បើធៀបនឹងខែកន្លងទៅ និងធ្លាក់ថ្លៃ**០,០៥%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

**ខ- ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- ចំណូលថវិកាជាតិអនុវត្តបានប្រមាណចំនួន២ ៧២៧,៤១ប៊ីលានរៀល ស្មើនឹងប្រមាណ **៦៧៧,៤៥លានដុល្លារអាម៉េរិក** កើនឡើង**៦,៣៦%** បើធៀបនឹងខែកន្លងទៅ និងកើនឡើង**២៧,៣៧%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯការចំណាយថវិកាជាតិអនុវត្តបានប្រមាណចំនួន**១ ៩០៦,៧០ប៊ីលានរៀល** ស្មើនឹងប្រមាណ**៤៧៣,៦០លានដុល្លារអាម៉េរិក** ថយចុះ**៣៧,៤២%** បើធៀបនឹងខែកន្លងទៅ និងថយចុះ **៦០,៧៥%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន

- តុល្យភាពនៃថវិកាជាតិមានអតិរេកប្រមាណចំនួន៨២០,៧១ប៊ីលានរៀល ស្មើនឹងប្រមាណ ២០៣,៨៥លានដុល្លារអាម៉េរិក។

**គ- ការរក្សាចីរភាពហិរញ្ញវត្ថុសាធារណៈ និងការពង្រឹងការគ្រប់គ្រងការប្រមូលចំណូល**

**គ.១- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

១- **អគ្គនាយកដ្ឋានពន្ធដារ** ប្រមូលចំណូលតាមប្រព័ន្ធអនឡាញចំនួន**១ ៤៣២,១៨ប៊ីលានរៀល** (ប្រមាណជា៣៥៧,១៥លានដុល្លារអាម៉េរិក) ស្មើនឹង**៩,៣៧%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ បើធៀបនឹងខែដូចគ្នាឆ្នាំមុន កើនឡើងចំនួន**១២៩,០៨ប៊ីលានរៀល**(ប្រមាណជា ៣២,១៩លានដុល្លារអាម៉េរិក) ស្មើនឹង**៩,៩១%** បានបង់ចូលថវិកាជាតិចំនួន**១ ៤០៦,២៧ប៊ីលានរៀល** (ប្រមាណជា៣៥០,៦៩លានដុល្លារអាម៉េរិក) ស្មើនឹង**៩,២០%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ក្នុងនោះថវិកាថ្នាក់ជាតិចំនួន**១ ២៥៧,៧៥ប៊ីលានរៀល**(ប្រមាណជា៣១៤,៤៣លានដុល្លារអាម៉េរិក) ថវិកាថ្នាក់ក្រោមជាតិចំនួន**១៤៨,០៤ប៊ីលានរៀល**(ប្រមាណជា៣៦,៩២លានដុល្លារអាម៉េរិក)និងចំណូលមិនមែនសារពើពន្ធចំនួន**០,៤៩ប៊ីលានរៀល**(ប្រមាណជា០,១២លានដុល្លារអាម៉េរិក)។

២- **អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** ប្រមូលចំណូលបានចំនួន**១ ១៤៩ប៊ីលានរៀល** (ប្រមាណជា២៨៥,៥៥លានដុល្លារអាម៉េរិក) ស្មើនឹង**៩,៤៥%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ កើនឡើងចំនួន**២១១,១៩ប៊ីលានរៀល** ត្រូវជាប្រមាណ**២២,៥២%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ទន្ទឹមនេះ បានបង្ក្រាបបទល្មើសគេចពន្ធចំនួន**១ ៨៩១ករណី** កើនឡើងចំនួន**៦១៩ ករណី** ស្មើនឹង**៤៨,៦៦%** បើធៀបនឹងខែកន្លងទៅ ក្នុងនោះករណីធំចំនួន**៧៧ករណី** និងករណីតូចចំនួន **១ ៨១៤ករណី**។ ដោះស្រាយរួចចំនួន**១ ៨៧២ករណី** ហើយប្រាក់ពន្ធអាករនិងពិន័យបានចំនួន**១២,៥២ ប៊ីលានរៀល**។

៣- **អគ្គលេខាធិការដ្ឋានល្បែងពាណិជ្ជកម្មកម្ពុជា**(អ.គ.ល.ក.) បាន (១) ចេញសេចក្តីសម្រេចស្តីពីការស្នើសុំព្យួរអាជ្ញាបណ្ណកាស៊ីណូ និងអាជ្ញាបណ្ណល្បែងផ្សងសំណាងរបស់ក្រុមហ៊ុនចំនួន៤ (២) ចុះត្រួតពិនិត្យ និងវាយតម្លៃផលប៉ះពាល់ចំពោះអាជីវកម្មកាស៊ីណូដែលរងគ្រោះដោយសារបញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃចំនួន**១លើក** (៣) ចុះតាមដាន ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ សកម្មភាពអាជីវកម្ម(ល្បែង និងមិនមែនល្បែង) ដែលដំណើរការក្នុងកាស៊ីណូតាមប្លង់បរិវេណដែលត្រូវបាន និងមិនទាន់ត្រូវបានទទួលស្គាល់ពីគ.ល.ក. សំដៅជំរុញការចូលរួមអនុវត្តបទបញ្ជា០១ បប ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៥ របស់

រាជរដ្ឋាភិបាលឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ស្ថិតនៅក្នុងតំបន់ព្រំដែនកម្ពុជា-វៀតណាម តំបន់ខេត្តជាប់មាត់សមុទ្រ ខេត្តព្រះសីហនុ កំពត និងខេត្តកោះកុង និងខេត្តប៉ៃលិនចំនួន**៣លើក** (៤) ចុះត្រួតពិនិត្យផែកឆេរ លើទីតាំងសង្ស័យថាពាក់ព័ន្ធករណីបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាចំនួន**២២ករណី** ដែលស្ថិតនៅខេត្តព្រះសីហនុ ស្វាយរៀង បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប ពោធិ៍សាត់ កំពង់ស្ពឺ ត្បូងឃ្មុំ ក្រចេះ និងរាជធានីភ្នំពេញ ដែលមានទីតាំងសរុប**៥៦កន្លែង** (៥) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ត្រួតពិនិត្យ តាមដាន ផ្ទៀងផ្ទាត់ និងវាយតម្លៃអនុលោមភាពប្លង់ទីតាំងឧបករណ៍និង/ឬកម្មវិធីល្បែងចំនួន**១៤៥កាស៊ីណូ** និងមានប្រតិបត្តិករកាស៊ីណូចំនួន**១៧៧** បានដាក់ពាក្យស្នើសុំចុះបញ្ជី ដែលគិតជាឧបករណ៍ល្បែង**១៣ ១២៩គ្រឿង** រួមមាន តុល្បែងចំនួន៤ ៣២៣តុ និងម៉ាស៊ីនល្បែងចំនួន៨ ៨០៦គ្រឿង (៦) គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦ បានចុះបិទលតាបត្រចំនួន**៥លើក** សរុប**១៦៤កាស៊ីណូ** ដោយបានបិទលើឧបករណ៍ល្បែងសរុប**៩ ៧៥៤គ្រឿង** ក្នុងនោះ តុល្បែងចំនួន**៣ ៦៩៥តុ** និងម៉ាស៊ីនល្បែងចំនួន**៦ ០៥៩គ្រឿង** និងបានបិទត្រាសុវត្ថិភាពចំនួន**១លើក** លើឧបករណ៍ល្បែងសរុប**១ ៩៣៥គ្រឿង** និង(៧) ចេញលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនFirm614 នាំចូលឧបករណ៍និង/ឬកម្មវិធីល្បែងចំនួន**២លើក** ដែលគិតជាឧបករណ៍ល្បែង រួមមាន ស្លត់ម៉ាស៊ីនចំនួន**៥០គ្រឿង** និងសន្លឹកបៀចំនួន**៥០៤០ហ៊ូ**។

**គ.២- ក្រសួងពាណិជ្ជកម្ម** រកចំណូលបានចំនួន**៦ ៥១៦,១លានរៀល** ស្មើនឹង**១០,៥៦%** នៃផែនការថវិកាឆ្នាំ២០២៦ ចំនួន**៦១ ៧២៥លានរៀល**។

**គ.៣- ក្រសួងរ៉ែនិងថាមពល** រកចំណូលបានចំនួន**៧ ៣១៨ ៣៥៨ ៩០៩រៀល**។

**គ.៤- ក្រសួងបរិស្ថាន** បានប្រមូលចំណូលមិនមែនសារពើពន្ធសរុប**៦ ៤៥៤ ៥១៧ ០៥០រៀល**។

**គ.៥- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ៖**

- ចំណូលពីការផ្តល់សេវាកម្មភាពយន្ត វីដេអូសរុបចំនួន**១៨ ៧៧៥ ០០០រៀល**។ ចំណូលពីការផ្តល់សេវាសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលចំនួន**៩២៥ ០០០រៀល**។ ការផ្តល់សេវាពិនិត្យវត្ថុសិល្បៈនាំចេញទៅបរទេសចំនួន៣០៣វត្ថុ/រូប នាំចូលចំនួន**៦វត្ថុ/រូប** និងទទួលបានចំណូលសរុបចំនួន**៥ ១០២ ៣០០រៀល**

- ចំណូលពីសារមន្ទីរជាតិចំនួន**៥ ៩៩៣ ៥០០រៀល** និងចំនួន**១២៩ ២០៥ដុល្លារអាមេរិក**។ សារមន្ទីរជាតិអង្គរបានចំនួន**១១០ ៨៥១ដុល្លារអាមេរិក**។ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងបានចំនួន**១៦៨ ១៣០ដុល្លារអាមេរិក**

- **រមណីយដ្ឋានអង្គរ** រកចំណូលបានចំនួន**៤ ៥២២ ៧៧៧ដុល្លារអាមេរិក** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមានចំនួន**៦ ៩០៣ ៣៨០ដុល្លារអាមេរិក** ថយចុះចំនួន**២ ៣៨០ ៦០៣ដុល្លារអាមេរិក** ស្មើនឹង**៣៤,៤៨%**។

**គ.៦- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖**

- ចំណូលពីការនាំចេញកសិផល ការប៉ាន់ស្មានតម្លៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលទទួលបានពីការនាំចេញកសិផល(ឯកតាតម្លៃផ្អែកតាមវិក្កយបត្ររបស់អ្នកនាំចេញ) ក្នុង

រយៈពេល១ខែ ឆ្នាំ២០២៦នេះ បាន៤១៨ ០៧៥ ៦៨៦,២៨ដុល្លារអាមេរិក ក្នុងនោះ ការនាំចេញអង្ករ **៧៧ ៨៣៨ ០៥៤,៧៩ដុល្លារអាមេរិក** ការនាំចេញស្រូវ៦៤ ១៨២ ៥៤៨ដុល្លារអាមេរិក និងការនាំចេញកសិផលក្រៅពីស្រូវ អង្ករ**២៧៦ ០៥៥ ០៨៣,៤៩ដុល្លារអាមេរិក**។ ចំពោះការនាំចេញផលិតផលដំណាំទៅប្រទេសថៃតាមផ្លូវទឹកក្នុងខែមករា ឆ្នាំ២០២៦ មានចំនួន៤ ៩៨០,៨៨តោន មានតម្លៃចំនួន២ ៦៨០ ៧៥៤,៩០ដុល្លារអាមេរិក ស្មើនឹង០,៦៤% ធៀបនឹងតម្លៃនៃការនាំចេញសរុប

- ចំណូលពីការនាំចេញជ័រកៅស៊ូនិងឈើកៅស៊ូ សម្រេចបាន**១០១ ២៤០ ៧៦៨ដុល្លារអាមេរិក** ក្នុងនោះ ចំណូលពីការនាំចេញជ័រកៅស៊ូ**៧០ ០៨៥ ៥៤៨ដុល្លារអាមេរិក** និងចំណូលពីការនាំចេញឈើកៅស៊ូ**១ ៤៩៧ ៩៩០ដុល្លារអាមេរិក**។ ជាមួយគ្នានេះ ចំណូលពីការលក់ជ័រកៅស៊ូក្នុងស្រុក**២៩ ៦៥៧ ២៣០ ដុល្លារអាមេរិក**

- ចំណូលពីសេវាផលផលសម្រេចបាន**១២៩ ៣៥៨ ៤៥២រៀល** និងពីវិស័យព្រៃឈើសម្រេចបាន**៦៥ ០២៤,៣៨ដុល្លារអាមេរិក**

- ចំណូលពីការនាំចេញសត្វរស់ ផលិតផលមានដើមកំណើតពីសត្វសរុប**៤០ ៦២៤ ១៧០ ដុល្លារអាមេរិក**។

**គ.៧- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖**

- ប្រមូលចំណូលពីសេវាសាធារណៈ ចូលថវិកាជាតិបានចំនួន**១៧ ៥៩១,៧៧លានរៀល** ពីការផ្តល់បណ្ណឬសៀវភៅការងារដល់ហត្ថពលកម្មជនបរទេស ពន្យារសុពលភាពបណ្ណឬសៀវភៅការងារដល់ហត្ថពលកម្មជនបរទេស ចេញលិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស(កូតា) និងចុះបញ្ជីលើកិច្ចសន្យាការងារឯកជនបរទេស

- បេឡាជាតិសន្តិសុខសង្គម(ប.ស.ស.) ប្រមូលភាគទានសរុបប្រមាណចំនួន**១៧១ ១៩២ លានរៀល**។

**គ.៨- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

- អាជីវកម្មរដ្ឋបាលថ្នាក់កណ្តាល រកចំណូលបានសរុប**៦៦ ៧៤៩ ៧០០រៀល** និង**៧៣ ២៨១ ៥៩១,០៨ដុល្លារអាមេរិក**

- អង្គភាពប្រៃសណីយ៍កម្ពុជា រកចំណូលបានសរុប**៤៥៥ ២២៤ដុល្លារអាមេរិក**

- អង្គភាពនិយ័តករទូរគមនាគមន៍កម្ពុជា រកចំណូលបានសរុប**២ ៣២៣ ៧៥១ ៣០០រៀល**។

- ទូរគមនាគមន៍កម្ពុជា រកចំណូលបានក្នុងខែធ្នូ ឆ្នាំ២០២៥ សរុប**៩៥៥ ៣៥១,៣២ដុល្លារអាមេរិក**

**គ.៩- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** រកចំណូលចូលថវិកាជាតិសរុបចំនួន **៦៩ ១០០ ៥៧៤ ៨៦២រៀល**(ប្រមាណ១៧ ១៤២ ២៩១ដុល្លារអាមេរិក) កើនឡើង**៣,៤៣%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន និងថយចុះ**១១,៨%** បើធៀបនឹងខែធ្នូ ឆ្នាំ២០២៥ ក្នុងនោះ ចំណូលរបស់រដ្ឋបាលកណ្តាលចំនួន**២ ៩៣៥ ៨៥៤ ០០៦រៀល**(ប្រមាណ៧២៨ ៣១៩ដុល្លារអាមេរិក) ចំណូលរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្តចំនួន**៦៦ ១៦៤ ៧២០ ៨៥៦រៀល** (ប្រមាណ១៦ ៤១៣ ៩៧២ដុល្លារអាមេរិក) ក្នុងនោះ ពន្ធប្រថាប់ត្រាប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារចំនួន**៤៩ ៥១៣ ៦៨៧ ០០០រៀល**(ប្រមាណ១២ ២៨៣ ២២៧ដុល្លារអាមេរិក)។

**គ.១០- ក្រសួងសាធារណការនិងដឹកជញ្ជូន៖**

- ចំណូលពីអាជីវកម្មកំពង់ផែស្វយ័តព្រះសីហនុចំនួន**១៥ ៥៧០ ៦៤១ដុល្លារអាមេរិក** បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**១១ ៨៥៨ ៧៧៥ដុល្លារអាមេរិក** កើនឡើង**៣ ៧១១ ៨៦៦ដុល្លារអាមេរិក** ស្មើនឹង**៣១,៣០%**

- ចំណូលពីអាជីវកម្មកំពង់ផែស្វយ័តភ្នំពេញចំនួន**៥ ១២៤ ៣៤៣ដុល្លារអាមេរិក** បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**៣ ៦៨០ ៧១៧ដុល្លារអាមេរិក** កើនឡើង**១ ៤៤៣ ៦២៦ដុល្លារអាមេរិក** ស្មើនឹង**៣៩,២២%**។

សរុបចំណូលអាជីវកម្មកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងកំពង់ផែស្វយ័តភ្នំពេញបានចំនួន**២០ ៦៩៤ ៩៨៤ដុល្លារអាមេរិក** បើធៀបនឹងខែដូចគ្នាឆ្នាំមុន**១៥ ៥៣៩ ៤៩២ដុល្លារអាមេរិក** កើនឡើង**៥ ១៥៥ ៤៩២ដុល្លារអាមេរិក** ស្មើនឹង**៣៣,១៨%**។

- រកចំណូលបានពីមន្ទីរពិសោធន៍សំណង់និងសាធារណការ**១៥១ ៨៣៩ ២០០រៀល** បើធៀបនឹងខែដូចគ្នាឆ្នាំមុន**១៥១ ១០០ ៣០៤រៀល** កើនឡើង**៧៣៨ ៨៩៦រៀល** ស្មើនឹង**០,៤៩%**។

**គ.១១- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖**

តម្លៃសរុបបរិមាណផលិតផលក្នុងវិស័យឧស្សាហកម្មក្នុងខែធ្នូ ឆ្នាំ២០២៥ មានចំនួន**១ ៥០១ ៤៩០ ៥៥៩ដុល្លារអាមេរិក** បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**១ ២១៨ ២៥០ ៤៥៧ដុល្លារអាមេរិក** កើនឡើង**២៨៣ ២៤០ ១០២ដុល្លារអាមេរិក** ស្មើនឹង**២៣,២៥%**។

តម្លៃសរុបបរិមាណផលិតផលក្នុងវិស័យឧស្សាហកម្មក្នុងរយៈពេល១២ខែ គឺខែមករាដល់ខែធ្នូ ឆ្នាំ២០២៥ មាន**១៣ ៥៨៣ ៤២៧ ៧៥៥ដុល្លារអាមេរិក** បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុនមាន**១៥ ១៤៥ ៥១៨ ៦៤៣ដុល្លារអាមេរិក** ថយចុះ**១ ៥៦៦ ០៩០ ៨៨៨ដុល្លារអាមេរិក** ស្មើនឹង**១០,៣៤%**។

**គ.១២- ក្រសួងយុត្តិធម៌** រកចំណូលពីកម្រៃសេវាព្រឹត្តិបត្រថ្កោលទោសចំនួន**៦៤៣ ៩៩០ ០០០ រៀល**។

**គ.១៣- ក្រសួងព័ត៌មាន** រកចំណូលបានចំនួន**២៨ ៩៧៨ ០០០រៀល**។

**គ.១៤- ក្រសួងទេសចរណ៍** រកចំណូលសរុបចំនួន**១៨២ ៦០៩ ០០០រៀល**។

**គ.១៥ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល** រកចំណូលបាន**៤៥១ ៧៥៥,៧៥ដុល្លារអាមេរិក** បើធៀបនឹងខែដូចគ្នាឆ្នាំមុន**២១៥ ១៧៧,៥០ដុល្លារអាមេរិក** កើនឡើង**២៣៦ ៥៧៨,២៥ដុល្លារអាមេរិក** ស្មើនឹង**១០៩,៩៥%**។

**ឃ- ទំហំពាណិជ្ជកម្មអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា**

ទំហំពាណិជ្ជកម្មអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា មានប្រមាណ**២៣ ៦៥៨,៥០ប៊ីលានរៀល** ស្មើនឹងប្រមាណ**៥ ៨៧៦,៤៣លានដុល្លារអាមេរិក** ក្នុងនោះ **ការនាំចេញ** មានតម្លៃប្រមាណចំនួន**១១ ១៩៣,២២ប៊ីលានរៀល** ស្មើនឹងប្រមាណ**២ ៧៨០,២៣លានដុល្លារអាមេរិក** កើនឡើង**២,១២%** បើធៀបនឹងខែកន្លងទៅ និងកើនឡើង**២៩,២០%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការកើនឡើងនៃការនាំចេញមានផលិតផលវាយនភណ្ឌនិងស្បែកជើង**៨,២០%** អង្ករ**១២,៦៣%**ផលិតផលនេសាទ**៥៨,១៧%** និង

ការនាំចេញក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ៨,២០%។ រីឯការថយចុះនៃការនាំចេញមានកៅស៊ូ២៥,៧៥% បើធៀបនឹងខែកន្លងទៅ។ **ការនាំចូល** មានតម្លៃប្រមាណ**១២ ៤៦៥,២៨ប៊ីលានរៀល** ស្មើនឹងប្រមាណ **៣ ០៩៦,១៩លានដុល្លារអាម៉េរិក** ថយចុះ:២,០៥% បើធៀបនឹងខែកន្លងទៅ ប៉ុន្តែកើនឡើង**១៤,០៥%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការកើនឡើងនៃការនាំចូលមានអង្ករ**៧១,៣៧%** ផ្លែឈើនិងបន្លែ**២៩%** ជីកសិកម្ម**១១,៨៦%** ថ្នាំកសិកម្ម**០,៧៣%** និងការនាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ**១,២០%**។ រីឯការថយចុះនៃការនាំចូលមានដែកសំណង់**២,៥៩%** ស៊ីម៉ងត៍**៧០,១០%** ត្រាក់ទ័រនិងគោយន្ត**៨២,៨១%** ស្រូវសាលី**១៧,០៧%** បើធៀបនឹងខែកន្លងទៅ។

ប្រតិបត្តិការជញ្ជីងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា មានឱនភាពប្រមាណ**១ ២៧២,០៦ ប៊ីលានរៀល** ស្មើនឹងប្រមាណ**៣១៥,៩៦លានដុល្លារអាម៉េរិក**។

**៤- ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាបន្ននិងសក្តិសិទ្ធិភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍**

**ក- ការចូលរួមពីសហគមន៍ជាតិនិងអន្តរជាតិ**

**អគ្គនាយកដ្ឋានឥស្សរិយយសនិងគោរមងារ នៃទីស្តីការគណៈរដ្ឋមន្ត្រី៖**

រាជរដ្ឋាភិបាលបានក្រាបបង្គំទូលថ្វាយ សូមព្រះរាជានុញ្ញាតពីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សុំគោរមងារឧកញ៉ាចំនួន**១នាក់** និងបញ្ចប់គោរមងារឧកញ៉ាចំនួន**១នាក់** និងរៀបចំព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ ប្រោសព្រះរាជទានគ្រឿងឥស្សរិយយស និងអនុក្រឹត្យស្តីពីការជូនមេដាយគ្រប់ប្រភេទចំនួន**៩៦លេខ** ដែលមានមេដាយចំនួន**២០ ២៩០គ្រឿង** ជូនឥស្សរជន មន្ត្រីរាជការ ជនបរទេស និងសប្បុរសជនក្នុងនិងក្រៅប្រទេស ដែលមានស្នាដៃនិងគុណបំណាច់ក្នុងការចូលរួមកសាងនិងការពារមាតុភូមិកម្ពុជា។

**ខ- ការងារសង្គមស៊ីវិល**

**ខ.១- ក្រសួងមហាផ្ទៃ៖**

បានសម្រេចចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន៣០(សមាគម២១ អង្គការមិនមែនរដ្ឋាភិបាល៩) លុបឈ្មោះចេញពីបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន៤(សមាគម២ អង្គការមិនមែនរដ្ឋាភិបាល២)។ គិតមកដល់បច្ចុប្បន្ន សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ សរុប**៦ ៧០៨**(សមាគម២ ៩៦៣ អង្គការមិនមែនរដ្ឋាភិបាល៣ ៥៨៩និងសហគមន៍ជនជាតិដើមភាគតិចមានចំនួន**១៥៦**)។

**ខ.២- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**(កបទ.សអ.) ក្នុងនាមជាអាណាព្យាបាលមានសមត្ថកិច្ចផ្តល់ភាពស្របច្បាប់ដល់អង្គការមិនមែនរដ្ឋាភិបាលបរទេសFNGOs ក្រោមទម្រង់នៃការចុះអនុស្សរណៈនៃការយោគយល់គ្នា(MoU) បន្តសុពលភាពMoU បញ្ជាក់លើសំណើបន្តទិដ្ឋាការរបស់បុគ្គលិកអង្គការ និងសំណើប្តូរត្រា រូបសញ្ញា និងឈ្មោះ។ គិតត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦ អង្គការមិនមែនរដ្ឋាភិបាលបរទេសFNGOs ចំនួន**៣៥៥** មានសុពលភាពMoU ជាមួយកបទ.សអ. ក្នុងនោះក្រសួងបានបន្តសុពលភាពឱ្យអង្គការ៤។

**៥- ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅនៅក្នុងតំបន់និងសកលលោក**

**១- ក្រសួងពាណិជ្ជកម្ម៖**

- រៀបចំបូកសរុបរបាយការណ៍ប្រចាំឆ្នាំ២០២៥ ដែលទទួលបានពីអនុព័ន្ធពាណិជ្ជកម្មកម្ពុជាប្រចាំនៅក្រៅប្រទេសចំនួន**១៨ស្ថានតំណាង**

- អនុញ្ញាតបណ្ដោះអាសន្ន ដើម្បីបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា នៅទីក្រុងគុនមិញ ខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន

- អនុញ្ញាតផ្លូវការបន្តសុពលភាពមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា នៅទីក្រុងយានថាយ ខេត្តសានតុង សាធារណរដ្ឋប្រជាមានិតចិន

**២- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

- ព្រះរាជាណាចក្រកម្ពុជា មានទំនាក់ទំនងការទូតជាមួយប្រទេសចំនួន**១៧៥**(១៧០ប្រទេសជាសមាជិកអ.ស.ប. ក្នុងចំណោមសមាជិកអ.ស.ប. ទាំងអស់១៩៣ប្រទេស និងប្រទេសមិនមែនជាសមាជិកអ.ស.ប.ចំនួន៥)

- ស្ថានតំណាងកម្ពុជានៅបរទេសមានចំនួន**៩៦** ក្នុងនោះ មានស្ថានទូតចំនួន**២៩ស្ថានបេសកកម្ម**អចិន្ត្រៃយ៍ចំនួន៤ (ទីក្រុងហ្សឺណែវ ញូវយ៉ក ប៉ារីស និងទីក្រុងហ្សាការតា) ស្ថានអគ្គកុងស៊ុលចំនួន**១៣** (ថៃ២ ឡាវ១ វៀតណាម១ និងចិន៩) ព្រមទាំងមានកុងស៊ុលកិត្តិយសចំនួន៣០ (ប្រទេសអូទ្រីស១ កាណាដា២ បែលហ្ស៊ិក១ បារាំង៣ អាល្លឺម៉ង់១ ឥណ្ឌា១ អ៊ីស្រាអែល១ ជប៉ុន៥ សហរដ្ឋអាម៉េរិក៤ នេប៉ាល់១ ហូឡង់១ ប៉ាគីស្ថាន១ ស្វីស១ តួកគីយ៉េ១ លីបង់១ រ៉ូម៉ានី១ ស៊ីប១ អ៊ីរ៉ង់១ នូវែលសេឡង់១ និងប្រទេសស្រីលង្កា១)។

**៣- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល** បាននិងកំពុងគ្រប់គ្រងក្រុមហ៊ុនអាកាសចរណ៍ក្នុងប្រទេស៤ និងក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិ**៣២** ដែលធ្វើការហោះហើរដឹកជញ្ជូនទំនិញ និងអ្នកដំណើរក្នុងនិងក្រៅប្រទេស

**៤- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ក្នុងខែមករា ឆ្នាំ២០២៦ បាននាំចេញអង្ករទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន**២០ប្រទេស** ប្រទេសចិន អាស៊ានចំនួន**៥ប្រទេស** និងទិសដៅផ្សេងទៀតចំនួន**១៨ប្រទេស**។

**៥- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖**

- ចេញអាជ្ញាបណ្ណបញ្ជាក់មុខសញ្ញានិងស្តង់ដាប្រើប្រាស់សារធាតុគីមីចំនួន**៨៥ច្បាប់** ប្រើសញ្ញាបញ្ជាក់ផលិតផលសម្រាប់សិប្បកម្មផលិតចំនួន**៦មូលដ្ឋានផលិតកម្ម** ចុះបញ្ជីផលិតផលចំនួន**៦៣២ច្បាប់** ប្រើប្រាស់ឬចែកចាយសារធាតុគីមីជាប់បញ្ញត្តិចំនួន**២៦ច្បាប់** និងប្រើសញ្ញាសុវត្ថិភាពសម្រាប់ផលិតផលអគ្គិសនីនិងអេឡិចត្រូនិកចំនួន**៨០ច្បាប់**។

- ចេញវិញ្ញាបនបត្រស្តង់ដារបញ្ជាក់ប្រព័ន្ធសម្រាប់សិប្បកម្មផលិតចំនួន**២មូលដ្ឋានផលិតកម្ម** និងលិខិតបញ្ជាក់គុណភាពសម្រាប់សិប្បកម្មផលិតចំនួន**៦ច្បាប់**។

## បញ្ហាគោលយុទ្ធសាស្ត្រទី១
## «ការអភិវឌ្ឍមូលធនមនុស្ស»

### ១- ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

**ក្រសួងអប់រំ យុវជន និងកីឡា**

**ក- ការងារអប់រំ**

**ក.១- ការងារអប់រំ និងបណ្តុះបណ្តាល**

- ចំនួនសាលារៀនគិតត្រឹមឆ្នាំសិក្សា២០២៥-២០២៦(រួមទាំងទារកដ្ឋាន)

| កម្រិតភូមិសិក្សា | ចំនួនសាលា | ចំនួនសិស្សចូលរៀន(នាក់) | | ចំនួនបុគ្គលិកបង្រៀន(នាក់) | |
|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី |
| ទារកដ្ឋាន | ១០ | ១៣៨ | ៦៧ | ៣៥ | ៣៥ |
| មត្តេយ្យរដ្ឋ | ៨ ០៧៣ | ៣៥៥ ៤៩៩ | ១៧៧ ៩៩០ | ៨ ៦៥៨ | ៨ ២២៩ |
| មត្តេយ្យឯកជន | ៩៦៣ | ៦៩ ៩៧៥ | ៣៣ ៨៨០ | - | - |
| បឋមសិក្សារដ្ឋ | ៧ ៣៩៨ | ២០៧ ៨៤០១ | ៩៩៧ ០០៣ | ៤៥ ៦៨៥ | ២៧ ៦៦៣ |
| បឋមសិក្សាឯកជន | ៨៩០ | ១៨២ ៨១៥ | ៨៨ ៨៧៧ | - | - |
| អនុវិទ្យាល័យរដ្ឋ | ១ ២៤៤ | ៣៣០ ៤២១ | ១៧៣ ១៧៦ | ១៤ ៦៣១ | ៦ ៧៧២ |
| អនុវិទ្យាល័យឯកជន | ១១៤ | ៦ ២៧០ | ៣ ២៦៦ | - | - |
| វិទ្យាល័យរដ្ឋ | ៥៤៦ | ៧១៧ ៩៧៥ | ៣៨៨ ៤៤០ | ២៨ ៦៥៦ | ១២ ០៣១ |
| វិទ្យាល័យឯកជន | ៣២៨ | ៨៧ ៩៧២ | ៤៥ ៣៨៣ | - | - |

គិតត្រឹមឆ្នាំសិក្សា២០២៥-២០២៦ សាលាបឋមសិក្សាចំនួន**១ ១១៤សាលា** បានអនុវត្តកម្មវិធីអាហារតាមសាលារៀនដោយប្រើកសិផលក្នុងសហគមន៍ ដែលមានសិស្សទទួលផលចំនួន**៣០៧ ៥៥៩នាក់** (ស្រី១៤៩ ៨៤៧នាក់) ក្នុងនោះ សាលាចំនួន**៦៨៦សាលា** បានទទួលការគាំទ្រពីថវិកាពីរាជរដ្ឋាភិបាល មានសិស្សទទួលផលចំនួន**១៨៩ ៦០០នាក់**(ស្រី៩២ ១៤០នាក់)។ សាលាបឋមសិក្សាចំនួន**៤២៧សាលា** ផ្សេងទៀត បានទទួលការគាំទ្រពីកម្មវិធីស្បៀងអាហារពិភពលោក មានសិស្សទទួលចំនួន**១១៧ ៩៦៦នាក់** (ស្រី៥៧ ៧០៧នាក់)។

- បោះពុម្ពសៀវភៅចំនួន**៥៣ចំណងជើង** ត្រូវជា**៥៧៣ ០៥៥ច្បាប់** ស្មើនឹង**៨៤ ៩៩៨ ៨៨០ទំព័រ**
- បើកសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងវគ្គបំប៉ន**៨លើក** មានអ្នកចូលរួមសរុប**៨៧៥នាក់** (ស្រី២៤៩នាក់) នៅរាជធានី ខេត្តកំពត ឧត្តរមានជ័យ រតនគិរី កំពង់ចាម និងខេត្តកំពង់ឆ្នាំង
- ប្រមូលទិន្នន័យសិស្សវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសទាំង**៤៩គ្រឹះស្ថានសិក្សា** មានសិស្សចំនួន**៤ ៧១៧នាក់**(ស្រី១ ៦៩៥នាក់) ក្នុងនោះ សាលាអនុវត្តគន្លងអប់រំថ្មីមានចំនួន**២៨សាលា** មានសិស្សចំនួន**៦៣៨នាក់**(ស្រី២៦៨នាក់)។
- ប្រកាសតាំងស៊ប់ក្នុងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន**២ ៤៥១នាក់** ក្នុងនោះ គ្រូបំប៉ន ជំនាន់ទី១៣ ចំនួន**១ ៤២៧នាក់**(ស្រី៦៥៣នាក់) គ្រូបង្រៀនកម្រិតមូលដ្ឋានបរិញ្ញាបត្រ+១ ចំនួន**៥នាក់**(ស្រី១នាក់) គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+៤ ប្តូរក្របខ័ណ្ឌក៣.៤ ចំនួន**១ ០១៩នាក់** និងគ្រូបង្រៀនកម្រិតឧត្តមចំនួន**១៧៩នាក់**(ស្រី៥៩នាក់)។

**ក.២- ការងារឧត្តមសិក្សា និងក្រោយឧត្តមសិក្សា**

- បញ្ជាក់សញ្ញាបត្រមកពីក្រៅប្រទេសសិស្ស និស្សិតចំនួន**៨៤នាក់**(ស្រី២៦នាក់) ក្នុងនោះ ថ្នាក់បណ្ឌិតចំនួន**១នាក់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន**៣៦នាក់**(ស្រី១០នាក់) ថ្នាក់បរិញ្ញាបត្រចំនួន**៣៨នាក់**(ស្រី១០នាក់) ថ្នាក់បរិញ្ញាបត្ររងចំនួន**២នាក់**(ស្រី២នាក់) និងមធ្យមសិក្សាទុតិយភូមិចំនួន**៧នាក់**(ស្រី៤នាក់)

- រៀបចំប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់បណ្ឌិត បរិញ្ញាបត្រជាន់ខ្ពស់ និង បរិញ្ញាបត្រទៅសិក្សានៅប្រទេសចិនសម្រាប់ឆ្នាំ២០២៦ មានបេក្ខជនចូលរួមចំនួន**៥០៨នាក់**(ស្រី២៧៧នាក់) ក្នុងនោះ ថ្នាក់បណ្ឌិតចំនួន**២៦នាក់**(ស្រី៨នាក់) បរិញ្ញាបត្រជាន់ខ្ពស់ចំនួន**៣៦៨នាក់**(ស្រី២០៤នាក់) និងថ្នាក់បរិញ្ញាបត្រចំនួន**១១៤នាក់**(ស្រី៦៥នាក់) ដោយជ្រើសរើសយកចំនួន**៧៥នាក់**(ស្រី៣៧នាក់) និងបេក្ខជនជាប់បម្រុងចំនួន**៣៩នាក់**(ស្រី២៣នាក់) ជូនភាគីមិត្តធ្វើការជ្រើសរើសបន្ត។

**ខ- ការងារយុវជន**

- មជ្ឈមណ្ឌលយុវជនខេត្តសៀមរាប បានរៀបចំកម្មវិធីបណ្តុះបណ្តាលសមមូល អប់រំកម្រិតមូលដ្ឋាន(BEEP) ដែលមានសិស្សសរុប**១០៥នាក់**(ស្រី៤០នាក់) ថ្នាក់កុំព្យូទ័ររដ្ឋបាល និងនវានុវត្តន៍ឌីជីថល ថ្នាក់សិល្បៈតន្ត្រីសម័យ ថ្នាក់តន្ត្រីពុហយាត្រា ថ្នាក់របាំបុរាណនិងប្រពៃណីខ្មែរ និងថ្នាក់យោគៈ ដែលមានសិស្សសរុប**១៦៨នាក់**(ស្រី១០៥នាក់)

- ចុះអត្ថាធិប្បាយជូនសិស្សកៀសសឹកមកពីខេត្តឧត្តរមានជ័យចំនួន**៧០នាក់**(ស្រី៤៣នាក់) និងចែកសម្ភារៈសិក្សាដល់សិស្សចំនួន**២២០នាក់** និងសិស្សជម្លៀសចំនួន**៤៤នាក់** នៅសាលាបឋមសិក្សាកណ្តឹង ខេត្តសៀមរាប កាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៦

- បើកវគ្គសមាជិកភាព និងបំពាក់កន្សែងជូននវកាយរឹទ្ធិជំទង់ចំនួន**៦៤នាក់**(ស្រី៣៦នាក់) នៅវិទ្យាល័យប្រមូលព្រហ្ម ស្រុកព្រះស្តេច ខេត្តព្រៃវែង។ បើកវគ្គសមាជិកភាពជូននវកាយរឹទ្ធិជំទង់ចំនួន**៧២នាក់**(ស្រី៤៨នាក់) នៅវិទ្យាល័យសម្តេច **ជា ស៊ីម អំពិល** ស្រុកមេសហែក ខេត្តព្រៃវែង។

**គ- ការងារកីឡា**

**១- ក្រសួងអប់រំ យុវជន និងកីឡា**

- បញ្ជូនប្រតិភូ កីឡាករ និងកីឡាការិនីចំនួន**៧នាក់**(ស្រី៣នាក់) នៃសហព័ន្ធកីឡាប៊ីយ៉ាកម្ពុជាឱ្យចូលរួមការប្រកួតក្នុងកម្មវិធី 2026 HEYBALL WORLD CUP នៅទីក្រុង Brisbane ប្រទេសអូស្ត្រាលី កាលពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦

- បញ្ជូនប្រតិភូ កីឡាករ និងកីឡាការិនី កីឡាគុនចម្រុះកម្ពុជាចំនួន**៦នាក់** ទៅចូលរួមប្រកួតនៅទីក្រុងLuzhou នៃសាធារណរដ្ឋប្រជាមានិតចិន។

**២-** ក្រសួងមហាផ្ទៃ ក្នុងខែមករា ឆ្នាំ២០២៦ ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃបានចាត់បញ្ជូនកីឡាករ កីឡាការិនីទៅចូលរួមព្រឹត្តិការណ៍ នានានៅក្នុង និងក្រៅប្រទេសចំនួន ១១លើក ដោយទទួលបានមេដាយសរុបចំនួន ៨៤គ្រឿង ដែលមានជាអាទិ៍ ៖

- ការប្រកួតក្នុងប្រទេស មានដូចជាព្រឹត្តិការណ៍ប្រកួតកីឡាវាយកូនឃ្លីលើតុជ្រើសរើសជើងឯកថ្នាក់ជាតិ ឆ្នាំ២០២៥ ព្រឹត្តិការណ៍ប្រកួតកីឡាតេក្វាន់ដូITF ជ្រើសរើសជើងឯកថ្នាក់ជាតិ ឆ្នាំ២០២៥ ព្រឹត្តិការណ៍ប្រកួតកីឡាប្រដាល់សកលជ្រើសរើសជើងឯកថ្នាក់ជាតិ ឆ្នាំ២០២៥ ព្រឹត្តិការណ៍ប្រកួតកីឡា

កាយសម្ព័ន្ធជ្រើសរើសជើងឯកថ្នាក់ជាតិ ឆ្នាំ២០២៥ ព្រឹត្តិការណ៍ប្រកួតកីឡាចំបាប់ជ្រើសរើសជើងឯកថ្នាក់ជាតិ ឆ្នាំ២០២៥ ព្រឹត្តិការណ៍ប្រកួតកីឡាសីដក់ និងសីមេលាង ជ្រើសរើសជើងឯកថ្នាក់ជាតិ ឆ្នាំ២០២៥ ព្រឹត្តិការណ៍ប្រកួតកីឡាអុកចត្រង្គជ្រើសរើសជើងឯកថ្នាក់ជាតិ ឆ្នាំ២០២៥ ព្រឹត្តិការណ៍ប្រកួតកីឡាតេក្វាន់ដូ WT និងព្រឹត្តិការណ៍ប្រកួតកីឡាវាយសីដណ្ដើមពានរង្វាន់៧មករា លើកទី២៥ ឆ្នាំ២០២៦។

- ការប្រកួតក្រៅប្រទេស មានដូចជា ព្រឹត្តិការណ៍ប្រកួតកីឡាគុនចម្រុះ GMA-Gods of Martial Arts និងព្រឹត្តិការណ៍ប្រកួតកីឡាប្រដាល់ The Asian Mixed Martial Arts Association 3rd( AMMA ) Championship។

**២- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស**

ក- ការងារបណ្តុះបណ្តាលធនធានមនុស្សរបស់ក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័នបានបញ្ជូនមន្ត្រីទៅចូលរួមការបណ្តុះបណ្តាលក្នុងប្រទេសសរុប**៣ ២៨៩**នាក់ និងក្រៅប្រទេសសរុប**១៧១**នាក់ ក្នុងនោះ៖

- ក្រសួងមហាផ្ទៃ : ក្នុងប្រទេស**២ ១៥៣**នាក់ និងក្រៅប្រទេស**៥៨**នាក់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ : ក្នុងប្រទេស**១៨២**នាក់ និងក្រៅប្រទេស**១២**នាក់។
- ក្រសួងបរិស្ថាន : នៅក្នុងប្រទេស**៣៨**នាក់
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ : នៅក្នុងប្រទេស**៥៦៧**នាក់ និងក្រៅប្រទេស**៦**នាក់
- ក្រសួងសាធារណការនិងដឹកជញ្ជូន : នៅក្នុងប្រទេស**៣៨៣**នាក់ និងក្រៅប្រទេស**៤**នាក់
- ក្រសួងធនធានទឹកនិងឧតុនិយម : នៅក្នុងប្រទេស**២៥**នាក់ និងក្រៅប្រទេស**៣**នាក់
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ : នៅក្នុងប្រទេស**១៤**នាក់ និងក្រៅប្រទេស**១**នាក់។
- ក្រសួងអប់រំ យុវជន និងកីឡា : នៅក្នុងប្រទេស**៤៣**នាក់ និងក្រៅប្រទេស**១២**នាក់
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ : នៅក្រៅប្រទេស**៨**នាក់
- ក្រសួងអភិវឌ្ឍន៍ជនបទ : នៅក្នុងប្រទេស**១០**នាក់
- ក្រសួងផែនការ : នៅក្នុងប្រទេស**៤០**នាក់ ក្រៅប្រទេស**២**នាក់
- ក្រសួងធម្មការនិងសាសនា : នៅក្នុងប្រទេស**៦**នាក់
- រដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល : ក្នុងប្រទេស**២៦**នាក់និងក្រៅប្រទេស**៥**នាក់
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ : នៅក្នុងប្រទេស**២៦៦**នាក់និងក្រៅប្រទេស**៤**នាក់
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ : នៅក្នុងប្រទេស**១៧១**នាក់ និងក្រៅប្រទេស**១១**នាក់
- ក្រសួងសុខាភិបាល : នៅក្នុងប្រទេស**៩**នាក់ និងក្រៅប្រទេស**១៧**នាក់
- ក្រសួងអធិការកិច្ច : នៅក្នុងប្រទេស**៥៤**នាក់ និងក្រៅប្រទេស**៦**នាក់។
- ក្រសួងកិច្ចការនារី : នៅក្នុងប្រទេស**៥**នាក់
- ក្រសួងមុខងារសាធារណៈ : នៅក្នុងប្រទេស**២**នាក់

- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ : ក្នុងប្រទេស**២៤នាក់** និងក្រៅប្រទេស **២០នាក់**

- ក្រសួងទេសចរណ៍ : នៅក្នុងប្រទេស**៤នាក់**

- ក្រសួងពាណិជ្ជកម្ម : នៅក្នុងប្រទេស**២នាក់**។

**ខ- ការងារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ**

**ខ.១- ក្រសួងមហាផ្ទៃ** បានរៀបចំវគ្គបណ្តុះបណ្តាលៈ

- បាននិងកំពុងធ្វើការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារសរុបចំនួន **១៣ថ្នាក់-វគ្គសិក្សា** មាននិស្សិត សិក្ខាកាម និងសិស្សនគរបាលជាតិសរុប**១ ៤១៨នាក់** (ស្រី៣១៤នាក់) ក្នុងនោះ វគ្គសិក្សាបានបញ្ចប់ជាស្ថាពរចំនួន**១ថ្នាក់**សិក្សា មានសិក្ខាកាមនិងសិស្សនគរបាលជាតិចំនួន **២០៧នាក់**(ស្រី៦៤នាក់) និងវគ្គកំពុងដំណើរការសិក្សាចំនួន**១២ថ្នាក់-វគ្គសិក្សា** មាននិស្សិត សិក្ខាកាម និងសិស្សនគរបាលជាតិសរុប**១ ២១១នាក់**(ស្រី២៥០នាក់) និងបានពង្រឹងសមត្ថភាពគ្រូនគរបាលជាតិ ចំនួន**៤នាក់** តាមរយៈការដាក់ឱ្យចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ លើកទី២ នៅបណ្ឌិត្យសភានគរបាលកម្ពុជា

- រៀបចំឱ្យទណ្ឌិតចំនួន**៨៥នាក់** ចូលរួមវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខរបរនូវមុខជំនាញ ដូចជា កាត់ដេរ សំអាងការ ការងារសំណង់ ជំនាញប្រើប្រាស់និងជួសជុលកុំព្យូទ័រ ឧបករណ៍អេឡិចត្រូនិក បរិក្ខារត្រជាក់ គ្រឿងយន្ត។ល។ ក្រៅពីនោះ មានទណ្ឌិតចំនួន**២ ៨៦៧នាក់**(ស្រី៣៣៧នាក់) ស្មើនឹង **៣៤,៦៨%** ត្រូវបានរៀបចំឱ្យចូលរួមអនុវត្តសាកល្បងលើផ្នែកផលិតកម្មមួយចំនួនដែលជាកត្តារួមផ្សំ សម្រាប់ផ្គត់ផ្គង់ជីវភាពជនជាប់ឃុំនិងតម្រូវការផ្សេងៗក្នុងពន្ធនាគារ

- បានរៀបចំឱ្យជនជាប់ឃុំចូលរៀនថ្នាក់អក្ខរកម្ម ឬថ្នាក់សមមូល និងថ្នាក់ភាសាបរទេសចំនួន **៥៦៥នាក់**(ស្រី៤៧នាក់) ស្មើនឹង**១០០%** នៃជនជាប់ឃុំ ដែលមានតម្រូវការរៀនសូត្រថ្នាក់ទាំងនេះ ខណៈ មានជនជាប់ឃុំចំនួន**៧៤%** នៃជនជាប់ឃុំសរុប(គិតទាំងចំនួនដែលបានដោះលែង) ត្រូវបានរៀបចំឱ្យ ចូលរួមសកម្មភាពអប់រំអំពីបទបញ្ជាផ្ទៃក្នុងពន្ធនាគារ អប់រំតាមបែបសាសនា អប់រំអំពីសីលធម៌សង្គម អប់រំ តាមបែបសាសនា អប់រំអំពីផលប៉ះពាល់នៃការសេពគ្រឿងញៀន និងអប់រំតាមរយៈការអានសៀវភៅនៅ បណ្ណាល័យ និងកម្មវិធីNomadlab។

**ខ.២- ក្រសួងការពារជាតិ៖**

បានការហ្វឹកហ្វឺនជំនាញផ្សេងៗដល់កងយោធពលខេមរភូមិន្ទនៅក្នុងប្រទេសចំនួន**១១៩វគ្គ** ស្មើនឹង**៨ ៧៩៧នាក់**(វគ្គបណ្តុះបណ្តាល១០៥វគ្គ ស្មើនឹង៤ ៩៤៣នាក់ វគ្គបំប៉ន១៤វគ្គ ស្មើនឹង៣ ៨៥៤ នាក់) សិក្សាបង់ថ្លៃនៅវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទចំនួន**៣ ២០៥នាក់**។ សិក្ខាកាមបញ្ជូនទៅសិក្សានៅក្រៅប្រទេសមានចំនួន**៣ ០២៣នាក់** ស្មើនឹង**១២ប្រទេស** ក្នុងនោះបញ្ចប់ ការសិក្សាត្រឡប់មកវិញចំនួន**៣៣៩នាក់**។ ធ្វើការអប់រំចិត្តសាស្ត្រនយោបាយនិងការងារសតិអារម្មណ៍កង ទ័ពការងារផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ច្បាប់ផ្សេងៗ និងសភាពការណ៍ថ្មីៗបានចំនួន**១ ៨២៩លើក** ស្មើនឹង**១២២ ៤៨៧លើក/នាក់**។

**ខ.៣- ក្រសួងពាណិជ្ជកម្ម** បានរៀបចំវគ្គបណ្តុះបណ្តាលភាសាចិនថ្នាក់មូលដ្ឋានគ្រឹះ កម្រិត១ ចំនួន២ថ្នាក់ មានរយៈពេលសិក្សា១ឆ្នាំ ដែលមានសិក្ខាកាមចូលរួមចំនួន៦៧នាក់(ស្រី៣៦នាក់)។

**ខ.៤- ក្រសួងផែនការ** បានបើកវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួន**៣លើក** មានអ្នកចូលរួមសរុប**៥៨នាក់**(ស្រី១១នាក់)។

**ខ.៥- ក្រសួងអធិការកិច្ច**

- បានចុះផ្សព្វផ្សាយច្បាប់នៅមន្ទីររាជធានី ខេត្តចំនួន**៦លើក** មានអ្នកចូលរួមសរុប**១ ២១៧**នាក់ (ស្រី៥៧៨នាក់)

- បានផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន(អំពីទោសទណ្ឌនៃការប្រើប្រាស់ និងជួញដូរគ្រឿងញៀន) នៅភូមិ ឃុំ សង្កាត់មានសុវត្ថិភាព តាមរយៈវិទ្យុជាតិFM 92.5 ភ្នំប្រុស ភ្នំស្រីចំនួន **៤២០លើក** និងបានតាមដានពីវឌ្ឍនភាពនៃការផ្សព្វផ្សាយច្បាប់តាមរយៈវីដេអូឃ្លីបចំនួន**២៣វីដេអូឃ្លីប** (១៦ច្បាប់)។

**ខ.៦- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍៖**

**-វគ្គបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី៖** (១) បាននិងកំពុងបណ្តុះបណ្តាលជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការមកពីក្រសួង ស្ថាប័ន លើមុខជំនាញឌីជីថលចាំបាច់ ប្រតិបត្តិការសន្តិសុខសាយប័រ គ្រប់គ្រងបណ្តាញកុំព្យូទ័រ និងអភិវឌ្ឍន៍កម្មវិធីសុសវែរ សរុប**៣០៣នាក់** (២) បានបណ្តុះបណ្តាលរយៈពេលខ្លីលើជំនាញ «ជំរុញការប្រើប្រាស់ និងអភិបាលកិច្ចបញ្ញាសិប្បនិម្មិត» និង «ការប្រើប្រាស់បញ្ញាសិប្បនិម្មិត ដើម្បីប្រសិទ្ធភាពការងារ» ជូនមន្ត្រីរាជការមកពីស្ថាប័នថ្នាក់ក្រោមជាតិ ដែលមានសិក្ខាកាមសរុប**៦១៨នាក់** និង(៣) បានរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗជូននិស្សិត និងសាធារណជន ដែលមានអ្នកចូលរួមសរុប**៣៩០នាក់**

**- ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលវែង៖** បណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ទី៩ ដល់ទី១១ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២ ឆ្នាំសិក្សា២០២៥-២០២៦ ដែលកំពុងសិក្សាលើ៦ជំនាញ ដែលមាននិស្សិតសរុប**១ ២៤៥នាក់**(ស្រី៤០៣នាក់) លើមុខជំនាញសិក្សា វិទ្យាសាស្ត្រកុំព្យូទ័រ វិស្វកម្មសុសវែរ វិទ្យាសាស្ត្រទិន្នន័យ ពាណិជ្ជកម្មអេឡិចត្រូនិក សន្តិសុខសាយប័រ និងទូរគមនាគមន៍ និងបណ្តាញ។

**ខ.៧- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ៖**

- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បាននិងកំពុងបណ្តុះបណ្តាលនិស្សិតសរុប**២ ២៦២នាក់** (ស្រី១ ០៩៥នាក់) សម្រាប់ឆ្នាំសិក្សា២០២៦-២០២៧ លើជំនាញស្ថាបត្យកម្មនិងនគរូបនីយវិទ្យា បុរាណវិទ្យា តូរ្យតន្ត្រី សិល្បៈនាដសាស្ត្រ និងសូនរូប

- សាលាមធ្យមវិចិត្រសិល្បៈបាននិងកំពុងបណ្តុះបណ្តាលសិស្សសរុបចំនួន**៧៣៣នាក់**(ស្រី៤០០នាក់) សម្រាប់ឆ្នាំសិក្សា២០២៦-២០២៧ លើជំនាញ តូរ្យតន្ត្រី របាំ ល្ខោន សៀក និងសូនរូប

- សាលាវិចិត្រសិល្បៈភូមិភាគ ខេត្តសៀមរាប បានបន្តបង្ហាត់របាំក្បាច់បុរាណ របាំប្រពៃណី ភ្លេងបុរាណ និងគំនូរ ដែលមានសិស្សសរុបចំនួន**១៩៧នាក់**(ស្រី១២៩នាក់)

- បន្តបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូចតាដល់សិស្សមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យសរុបចំនួន**២១៤នាក់**។

**ខ.៨- ក្រសួងកិច្ចការនារី** បានបើកសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលចំនួន**៣លើក** នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ដែលមានការចូលរួម**១៩១នាក់**(ស្រី ១៤០នាក់)។

**ខ.៩- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖**

- **វិទ្យាស្ថានជាតិការងារ** បានរៀបចំវគ្គបណ្តុះបណ្តាល (១) អធិការការងារនិងមន្ត្រីផ្សះផ្សាវិវាទការងារចំនួន២វគ្គ មានអ្នកចូលរួមចំនួន**៨១នាក់**(ស្រី១៩នាក់) (២) ការបណ្តុះបណ្តាលលិខិតបទដ្ឋានគតិយុត្តដល់រដ្ឋបាលរោងចក្រ សហជីព និងប្រតិភូបុគ្គលិកចំនួន៥វគ្គ មានអ្នកចូលរួមចំនួន**៩៨៤នាក់**(ស្រី៤១៧នាក់)

- **គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(ធីវេត)** បានបន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់សយុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ (១,៥លាននាក់) កម្រិតC1 តាមប្រព័ន្ធTVET 1.5M (១) គិតត្រឹមខែមករា ឆ្នាំ២០២៦នេះ មានអ្នកស្នើចុះឈ្មោះចូលរៀនចំនួន**១៥៦ ៤៧០នាក់**(ស្រី៦៨ ៨៣០នាក់) ដោយមានសិស្សកំពុងសិក្សាចំនួន**១២ ២៥៨នាក់**(ស្រី៥ ៨១៥នាក់) និងសិស្សបានបញ្ចប់ការសិក្សាមានចំនួន**៨២ ២៥៥នាក់**(ស្រី៣៧ ១៤៦នាក់) ដោយមានសិស្សទទួលបានការងារធ្វើចំនួន**៥៤ ៣៣០នាក់**(ស្រី២៤ ៨៩២នាក់) (២) ជំរុញការអភិវឌ្ឍសមត្ថភាពរបស់កម្លាំងពលកម្មដែលនៅក្នុងទីផ្សារការងារ និងត្រៀមចូលទីផ្សារការងារតាមរយៈការអនុវត្តការហ្វឹកហ្វឺនកូនជាង មានសិស្សកំពុងសិក្សាឬបណ្តុះបណ្តាលចំនួន**១០ ៦៥១នាក់**(ស្រី៦ ៦៩០នាក់) និងកូនជាងបានបញ្ចប់ការហ្វឹកហ្វឺនចំនួន**៤ ៥៩១នាក់**(ស្រី២ ៦៦៧នាក់) និង (៣) ផ្តល់សិស្សនិស្សិតចុះកម្មសិក្សា ទស្សនកិច្ចសិក្សានៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រចំនួន**៤៦** មានសិក្ខាកាមចូលរួមចំនួន**១៤៨នាក់**(ស្រី៣៥នាក់)។

**ខ.១០- ក្រសួងទេសចរណ៍**

រៀបចំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ រួមមាន (១) គ្រូបង្គោលជាតិនៃសេវាកម្មសណ្ឋាគារស្របតាមស្តង់ដាអាស៊ាន (២) ជំនាញចុងភៅ (៣) ជំនាញគេហកិច្ច (៤) ជំនាញការិយាល័យជួរមុខ (៥) ជំនាញសេវាកម្មម្ហូបអាហារនិងភេសជ្ជៈ សរុបមានសិក្ខាកាមចូលរួមចំនួន**១៣២នាក់**(ស្រី៥០នាក់) និងវគ្គបណ្តុះបណ្តាល «Ticketing Fare Amadeus & Airline Rule» ថ្នាក់ភាសាចិន កម្រិត HSK១ និងថ្នាក់ភាសាកូរ៉េ សម្រាប់បដិសណ្ឋារកិច្ចទេសចរណ៍ មានសិក្ខាកាមចំនួន**៦៦នាក់**។

**ខ.១១- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** តាមរយៈវិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ បានរៀបចំវគ្គបណ្តុះបណ្តាលភាសាបារាំង ចិន និងភាសាជប៉ុន ដែលមានសិក្ខាកាមចូលរួមសរុប**១៤៧**នាក់ និងបានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពី «Cambodia-China Media Strategy: Role of Media in Foreign Affairs and International Relation» ក្រោមកិច្ចសហប្រតិបត្តិការជាមួយស្ថានទូតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា និងសហការជាមួយស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា រៀបចំបទបង្ហាញ ស្តីពី «ទំនាក់ទំនងកម្ពុជា-ជប៉ុន» ជូនដល់មន្ត្រីរាជការនៅកបទ.សអ.។

**ខ.១២- ក្រសួងមុខងារសាធារណៈ**

តាមរយៈសាលាភូមិន្ទរដ្ឋបាល៖

- បណ្តុះបណ្តាលរយៈពេលវែង៖ បញ្ចប់វគ្គបណ្តុះបណ្តាលក្រិតការមន្ត្រីជាន់ខ្ពស់ និងក្រិតការមន្ត្រីមធ្យមឆ្នាំ២០២៥ សរុប**៧៤៧នាក់**(ស្រី១៣៣នាក់ និងព្រះសង្ឃ៣២អង្គ)។ បាននិងកំពុងចាប់ផ្តើមបណ្តុះបណ្តាលសិស្សមន្ត្រីក្រមការ ជំនាន់ទី១២ ចំនួន**២០៥នាក់**(ស្រី៦៥នាក់)។

- បណ្តុះបណ្តាលរយៈពេលខ្លី តាមប្រព័ន្ធអនឡាញសរុប**៩៧៩នាក់**(ស្ត្រី២៥៧នាក់) លើជំនាញ (១) ការតាក់តែងលិខិតរដ្ឋបាលនិងលិខិតបទដ្ឋានគតិយុត្ត (២) វគ្គការងារការិយាល័យ វគ្គអក្សរ(៣) សាស្ត្រខ្មែរក្នុងរដ្ឋបាលសាធារណៈ (៤) វគ្គក្រមសីលធម៌មន្ត្រីរាជការ (៥) វគ្គយុទ្ធសាស្ត្រ បញ្ញាកោណ និងកំណែទម្រង់រដ្ឋបាលសាធារណៈ និង(៦) វគ្គការគ្រប់គ្រងពេលវេលានិងប្រសិទ្ធភាពនៃកិច្ចប្រជុំ។

**ខ.១៣- ក្រសួងសាធារណការនិងដឹកជញ្ជូន** តាមរយៈវិទ្យាស្ថានតេជោសែនសាធារណការនិងដឹកជញ្ជូន បានកំពុងបណ្តុះបណ្តាលនិស្សិត**៣៨៣នាក់** លើឯកទេសសំណង់សាធារណការ ឯកទេសគ្រប់គ្រងការដឹកជញ្ជូននិងភស្តុភារកម្ម និងឯកទេសនាវាចរណ៍។

**ខ.១៤- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** តាមរយៈវិទ្យាស្ថានជាតិសង្គមកិច្ច បាននិងកំពុងបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សា សរុប**៦៦៩នាក់** ក្នុងនោះ និស្សិតបានចុះឈ្មោះចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ក្នុងឆ្នាំសិក្សា២០២៥-២០២៦ ចំនួន**២៨១នាក់**។

**ខ.១៥- ក្រសួងអភិវឌ្ឍន៍ជនបទ** តាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ បានបើកវគ្គបណ្តុះបណ្តាល ចំនួន**៤៣វគ្គ** ដែលមានសិក្ខាកាមចូលរួម**៨៦០នាក់**។

**ខ.១៦- រាជបណ្ឌិត្យសភាកម្ពុជា** បាននិងកំពុងបណ្តុះបណ្តាលថ្នាក់បណ្ឌិតសរុប**១០៧នាក់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សរុប**៨៣នាក់** ថ្នាក់បរិញ្ញាបត្រសរុប**១ ២៤៣នាក់** និងបានថ្នាក់បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈTVET ដូចជា (១) វិជ្ជាជីវៈជំនាញចុងភៅ មានសិក្ខាកាមសរុប**៦០នាក់**(បានបញ្ចប់ចំនួន៥១នាក់ កំពុងសិក្សាបន្តចំនួន៩នាក់ និងចុះឈ្មោះចូលថ្មីចំនួន៣នាក់) និង(២) ជំនាញគេសជ្ជៈនិងលីងគ្រាប់កាហ្វេ មានសិក្ខាកាមសរុប**៦៤នាក់**(បានបញ្ចប់ចំនួន៦៤នាក់ និងចុះឈ្មោះចូលថ្មីចំនួន៥នាក់)។

## ៣- ការលើកកម្ពស់សុខភាពនិងសុខុមាលភាពប្រជាជន

### ក- ការងារពិនិត្យនិងពិគ្រោះព្យាបាលជំងឺទូទាំងប្រទេស

#### ក.១- ក្រសួងសុខាភិបាល

- សេវាពិគ្រោះជំងឺក្រៅនៅមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជនសរុប**១ ៩២៩ ៤០៥ករណី** ក្នុងនោះ ការពិនិត្យនៅមណ្ឌលសុខភាពចំនួន**៩៧៣ ៧១០ករណី** នៅមន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣ ចំនួន**២៦៨ ៩៨០ករណី** នៅមន្ទីរពេទ្យជាតិចំនួន**៤៧០ ៧៦៦ករណី** និងនៅមូលដ្ឋានសុខាភិបាលឯកជនចំនួន**២១៥ ៩៤៩ករណី**។ ជាមួយគ្នានេះ ការពិគ្រោះជំងឺក្រៅករណីថ្មីសរុប**១ ៣០៦ ៩៨៤ករណី** ដោយបានពិនិត្យនៅមណ្ឌលសុខភាពចំនួន**៨៦៩ ៩១៤ករណី** នៅមន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣ ចំនួន**១៥៩ ៤០៣ករណី** នៅមន្ទីរពេទ្យជាតិចំនួន**១៥២ ៨១៤ ករណី** និងនៅមូលដ្ឋានសុខាភិបាលឯកជនចំនួន**១២៤ ៨៥៣ករណី**

- អ្នកជំងឺសម្រាកព្យាបាលនៅមន្ទីរពេទ្យសាធារណៈ និងមណ្ឌលសុខភាពមានគ្រែទូទាំងប្រទេសចំនួន**១៤៦ ៩៣៣នាក់** ក្នុងនោះ សម្រាកព្យាបាលនៅមណ្ឌលសុខភាពមានគ្រែចំនួន**៦៦កន្លែង** ចំនួន**៥ ០៧៦នាក់** នៅមន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣ ចំនួន**៧១ ៦១២នាក់** និងនៅមន្ទីរពេទ្យជាតិចំនួន**៧០ ២៤៥នាក់**។ អត្រាមធ្យមប្រើប្រាស់គ្រែក្នុងទូទាំងប្រទេសបានចំនួន**១០៣%** នៃចំនួន

គ្រែសរុប១៦ ៩១២គ្រែ(ដោយមិនរាប់បញ្ចូលគ្រែសម្រាប់អ្នកជំងឺរបេង) នៅខែមករា។ ករណីវះកាត់ធំបាន **១៨ ៦៥៤ករណី** ក្នុងនោះ ការវះកាត់បន្ទាន់**៧ ៤៤៦ករណី** និងការវះកាត់ដាក់កម្មវិធី**១១ ២០៨ករណី** រីឯករណីវះកាត់តូច**៨ ០៨៩ករណី**។

**ក.២- ក្រសួងការពារជាតិ** ដែលមានមន្ទីរពេទ្យ និងគិលានដ្ឋានតាមបណ្តាអង្គភាព បានទទួលពិនិត្យ ពិគ្រោះ ព្យាបាលជំងឺជូនកងទ័ព និងគ្រួសារកងទ័ពចំនួន**៨ ៤៨៩នាក់** ពិនិត្យវិភាគវេជ្ជសាស្ត្រចំនួន**៨ ៧៩៤វិភាគ** និងទទួលអ្នកជំងឺសម្រាកព្យាបាលក្នុងមន្ទីរពេទ្យចំនួន**៣ ៩០១នាក់**។

**ក.៣- ក្រសួងមហាផ្ទៃ** ក្រុមគ្រូពេទ្យនៃក្រសួងមហាផ្ទៃបានពិនិត្យសុខភាព និងព្យាបាលជំងឺនៅតាមគោលដៅនានាសរុបចំនួន**៤ ៩០០នាក់** ក្នុងនោះ ពិនិត្យ ព្យាបាលជំងឺជូនកងកម្លាំងនគរបាលជាតិនៅតំបន់ប្រាសាទព្រះវិហារចំនួន**៤៥២នាក់** និងនៅមន្ទីរពេទ្យ ១៦ឧសភា ចំនួន**៣៦៤នាក់** ។

**ខ- មូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជនទូទាំងប្រទេស**

**១- មូលដ្ឋានសុខាភិបាលសាធារណៈ**

មូលដ្ឋានសុខាភិបាលសាធារណៈទូទាំងប្រទេសមានចំនួន**១ ៥៦៤** ក្នុងនោះ មន្ទីរពេទ្យជាតិចំនួន**១២** គ្លីនិកជាតិព្យាបាលជំងឺអេដស៍ សើស្បែក និងកាមរោគចំនួន**១** មន្ទីរពេទ្យ រាជធានី ខេត្តចំនួន**២៥** មន្ទីរពេទ្យបង្អែក(ក្រុង ស្រុក)ចំនួន**៩៩** មណ្ឌលសុខភាព(មានគ្រែ)ចំនួន**៦៦** មណ្ឌលសុខភាព(គ្មានគ្រែ)ចំនួន**១ ២៤៥** ប៉ុស្តិ៍សុខភាពចំនួន**១១៥** និងប៉ុស្តិ៍សុខភាពពន្ធនាគារចំនួន**១៦**។

**២- មូលដ្ឋានសុខាភិបាលឯកជន**

- មន្ទីរពេទ្យឯកជនចំនួន**៣០កន្លែង** ពហុព្យាបាលចំនួន**១១៦កន្លែង** សម្រាកព្យាបាលចំនួន**៧៩២កន្លែង** សម្រាកព្យាបាលជំងឺកុមារចំនួន**៧កន្លែង** និងសម្ភព-រោគស្ត្រីចំនួន**១៣កន្លែង**

- មន្ទីរព្យាបាលជំងឺ(មាត់ធ្មេញ ភ្នែក សើស្បែក និងផ្លូវចិត្ត)ចំនួន**៨៩កន្លែង** និងមន្ទីរពិសោធន៍វេជ្ជសាស្ត្រចំនួន**១២៤កន្លែង**

- មជ្ឈមណ្ឌលកែសម្ផស្ស និងថែរក្សាសម្ផស្សចំនួន**២៦៧កន្លែង**

- បន្ទប់ពិគ្រោះ ព្យាបាលជំងឺ(ទូទៅ ត្រចៀក ច្រមុះ បំពង់ក ភ្នែក មាត់-ធ្មេញ សើស្បែក ផ្លូវចិត្ត ស្ត្រីមានផ្ទៃពោះ ព្យាបាលដោយចលនា) បន្ទប់ថែទាំជំងឺនិងបន្ទប់ថែទាំធ្មេញចំនួន**១៩ ៧២៨កន្លែង**

- ឱសថស្ថាន ឱសថស្ថានរង «ក» និងឱសថស្ថានរង «ខ» ចំនួន**៤ ៤០២កន្លែង**

- អគារលក់ឱសថបុរាណចំនួន**៩៤កន្លែង**

- គ្រឹះស្ថានផលិត(ឱសថ ឧបករណ៍បរិក្ខារពេទ្យ គ្រឿងសម្អាង ផលិតផលជំនួយសុខភាព) ចំនួន**៤៨កន្លែង** និងគ្រឹះស្ថានអាហារ័ណ នីហរ័ណឱសថ និងគ្រឿងសម្អាងចំនួន**១ ២៧៣កន្លែង**

-ការិយាល័យតំណាងគ្រឹះស្ថានផលិតឱសថក្រៅប្រទេសចំនួន**៤កន្លែង**។

**៣- ការងារផ្តល់ឈាម**

- ការផ្តល់អំណោយឈាម៖ អ្នកស្ម័គ្រចិត្តផ្តល់ឈាមសរុប**១០ ៤៥៤នាក់** ក្នុងនោះ អ្នកស្ម័គ្រចិត្តផ្តល់ឈាមតាមក្រុមចល័តចំនួន**១ ៧៧៦នាក់** អ្នកស្ម័គ្រចិត្តផ្តល់ឈាមនៅមជ្ឈមណ្ឌលជាតិផ្តល់ឈាមចំនួន**១ ១៤១នាក់** និងអ្នកផ្តល់ឈាមដែលជំនួសដោយក្រុមគ្រួសារអ្នកជំងឺចំនួន**៧ ៥៣៧នាក់**

- ការផ្គត់ផ្គង់ឈាមៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ក្នុងការសង្គ្រោះបន្ទាន់ចំពោះអ្នកជំងឺដែលសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យនានា មជ្ឈមណ្ឌលជាតិផ្តល់ឈាមបានផ្តល់ជូនឈាមទាំងស្រុង (Whole Blood) គ្រាប់ឈាមក្រហម( Red Cell ) ប្លាស្មា(Fresh Frozen Plasma ) និងប្លាកែត(Platelets) សរុប**១៣ ៥០២ប្លោក**

- សុវត្ថិភាពឈាមៈ ឈាមដែលទទួលបានទាំងអស់ត្រូវធ្វើវិភាគរកជំងឺឆ្លង ដូចជា មេរោគហ៊ីវ **២០ប្លោក** ជំងឺរលាកថ្លើមប្រភេទបេ**១០៧ប្លោក** ជំងឺរលាកថ្លើមប្រភេទសេ**១៧ប្លោក** និងជំងឺស្វាយ**២៣២ប្លោក**។

៤- ជំងឺអេដស៍និងជំងឺកាមរោគៈ អ្នកផ្ទុកមេរោគអេដស៍ បានទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នៅគ្លីនិកជាតិព្យាបាលជំងឺអេដស៍ សើស្បែក និងកាមរោគចំនួន**៧២ ០៩៧នាក់**។ គិតត្រឹមចុងខែមករា ឆ្នាំ២០២៦ អ្នកផ្ទុកមេរោគអេដស៍សកម្មចំនួន**១០ ៣៥៤នាក់**(ស្រី៤ ២២៩នាក់)។

៥- ជំងឺគ្រុនចាញ់ គ្រុនឈាម និងគ្រុនឈឹកៈ ករណីជំងឺគ្រុនចាញ់**១នាក់**(ករណីនាំចូល) ករណីជំងឺគ្រុនឈាមចំនួន**១ ៤៤៧នាក់** ករណីជំងឺគ្រុនឈឹក**មិនមាន**។

៦- ការលើកកម្ពស់សុខភាពបន្តពូជ មាតា ទារក និងកុមារ និងអាហារូបត្ថម្ភ

- ការថែទាំមុនសម្រាល សម្រាល និងក្រោយសម្រាលៈ (១) ការពិនិត្យថែទាំគភ៌មុនសម្រាលលើកទី២ ចំនួន**២៣ ៨៧៥នាក់** និងការពិនិត្យថែទាំគភ៌មុនសម្រាលលើកទី៤ ចំនួន**១៩ ៦១៨នាក់** ដោយបានស្រាវជ្រាវរកឃើញស្ត្រីចំនួន៣ **១០២នាក់** បម្រុងមានគ្រោះថ្នាក់ ក្នុងនោះ មានបញ្ហាធ្លាក់ឈាម **៥១នាក់** ស្លេកស្លាំង**៩៧៩នាក់** និងបញ្ហាផ្សេងៗទៀត**២ ០៧២នាក់** និង(២) ស្ត្រីបានសម្រាលកូនសរុប **២០ ៩៨២នាក់** ក្នុងនោះ សម្រាលនៅមណ្ឌលសុខភាព**៧ ២២៤នាក់** សម្រាលនៅមន្ទីរពេទ្យបង្អែក **១២ ៩៩០នាក់** និងនៅផ្ទះដោយបុគ្គលិកសុខាភិបាល**៧៦៨នាក់**។ រីឯស្ត្រីដែលបានទទួលការពិនិត្យថែទាំក្រោយសម្រាលលើកទី១ ចំនួន**១៥ ៥២០នាក់** លើកទី២ ចំនួន**១១ ៦៧២នាក់** លើកទី៣ ចំនួន**៩ ០៤១នាក់** និងលើកទី៤ ចំនួន**២ ២៩៤នាក់**

- ការពិនិត្យពិគ្រោះនិងព្យាបាលជំងឺកុមារៈ ការពិនិត្យជំងឺក្រៅករណីថ្មីលើកុមារអាយុក្រោម ៥ឆ្នាំ ចំនួន**៣៦៨ ៤៦៥នាក់** និងសម្រាកព្យាបាលចំនួន**២៣ ២០៦នាក់**

- កម្មវិធីជាតិផ្តល់ថ្នាំបង្ការៈ កុមារចំណុចអាយុក្រោមមួយឆ្នាំចំនួន**៦៣ ៥៩៣នាក់** ដែលបានទទួលថ្នាំបង្ការតាមប្រភេទវ៉ាក់សាំង រួមមាន វ៉ាក់សាំងបង្ការរបេង(BCG) ចំនួន**២៤ ៧៣៤នាក់** វ៉ាក់សាំងបង្ការរលាកថ្លើមប្រភេទបេ <២៤ម៉ោង(Hep B) ចំនួន**២១ ៩៣៦នាក់** វ៉ាក់សាំងបង្ការគ្រុនស្វិតដៃជើង ៣ដូសចំនួន**២៥ ១៩១នាក់** វ៉ាក់សាំងបង្ការជំងឺខាន់ស្លាក់-ក្អកមាន់-តេតាណូស-រលាកថ្លើមប្រភេទបេ-រលាកសួត-រលាកស្រោមខួរ(DPT-HepB-Hib3) ៣ដូសចំនួន**២៥ ១៦៥នាក់** វ៉ាក់សាំងបង្ការជំងឺកញ្ជ្រឹល-ស្អូច(MR9) ចំនួន**២៣ ២៦៧នាក់** វ៉ាក់សាំងបង្ការជំងឺរលាកខួរក្បាល(JE)ចំនួន**២៣ ០៥៤នាក់** និងវ៉ាក់សាំងបង្ការជំងឺរលាកសួត និងស្រោមខួរក្បាល(PCV3) ៣ដូសចំនួន**២៥ ១៧៤នាក់**។

**៧- ការបង្ការ និងការគ្រប់គ្រងជំងឺមិនឆ្លង**

- ជំងឺទឹកនោមផ្អែមៈ ករណីថ្មីជំងឺទឹកនោមផ្អែមដែលបានមកពិនិត្យព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈចំនួន**២៥ ៨៦៧ករណី** ក្នុងនោះ អ្នកជំងឺទឹកនោមផ្អែមប្រភេទ១ ចំនួន១ ៣៧៨

**ករណី** (ស្រី៨៧៩ករណី) ប្រភេទ២ ចំនួន**២៤ ៤៨៩ករណី** (ស្រី១៥ ៧៩៤ករណី) និងលើស្ត្រីមានគភ៌**១០ករណី**។ រីឯអ្នកជំងឺសម្រាកពេទ្យចំនួន**១ ៥១១នាក់** ក្នុងនោះ អ្នកជំងឺទឹកនោមផ្អែមប្រភេទ១ ចំនួន**៧២នាក់**(ស្រី៤៣នាក់) និងប្រភេទ២ ចំនួន**១ ៤៣៩នាក់**(ស្រី៩០៣នាក់) និងស្ត្រីមានគភ៌**១នាក់**

- ជំងឺឡើងសម្ពាធឈាម និងជំងឺបេះដូងសរសៃឈាម៖ ករណីថ្មីជំងឺឡើងសម្ពាធឈាម ដែលបានមកពិនិត្យព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈចំនួន**៤១ ៧១៧ករណី** ក្នុងនោះ ជំងឺឡើងសម្ពាធឈាមដំបូងចំនួន**២៩ ០៦៩ករណី** និងជំងឺឡើងសម្ពាធឈាមមានផលវិបាកផ្សេងៗចំនួន**១២ ៦៤៨ករណី**។ អ្នកជំងឺសម្រាកព្យាបាលចំនួន**៣ ៦៨៣ករណី** ក្នុងនោះ អ្នកជំងឺឡើងសម្ពាធឈាមដំបូង**១ ៨៤៩ករណី** និងជំងឺឡើងសម្ពាធឈាមមានផលវិបាកផ្សេងៗចំនួន**១ ៨៣៤ករណី**។ ដោយឡែក អ្នកជំងឺបេះដូងសរសៃឈាមដែលបានមកពិនិត្យជំងឺចំនួន**១ ៤២០ករណី** និងសម្រាកព្យាបាលចំនួន**២ ៣៤០នាក់**។

៨- ជំងឺផ្លូវចិត្តនិងការញៀនគ្រឿងញៀន៖ អ្នកជំងឺផ្លូវចិត្តទទួលសេវាពិនិត្យពិគ្រោះនិងព្យាបាលជំងឺផ្លូវចិត្តសរុប**៣១ ៥៥២នាក់**(ស្រី១៨ ៧៨២នាក់) ក្នុងនោះ ករណីពិនិត្យពិគ្រោះជំងឺក្រៅចំនួន**៣០ ៧០២នាក់**(ស្រី១៨ ២៤២នាក់) ករណីសម្រាកពេទ្យចំនួន៨៥០នាក់(ស្រី៥៤០នាក់) និងអ្នកញៀនគ្រឿងញៀនបានទទួលសេវាពិនិត្យពិគ្រោះ និងព្យាបាលសរុប**២ ២៣៨នាក់**(ស្រី៧៩នាក់)។

## ៤- ការពង្រឹងប្រព័ន្ធគាំពារសង្គមនិងប្រព័ន្ធស្បៀង

### ក- ការងារជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ការអនុវត្តរបបសន្តិសុខសង្គម

### ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖

**ក.១- ការងារសង្គមកិច្ច** បានទទួលជនរងគ្រោះដែលនិរទេសពីប្រទេសថៃចំនួន**៦៦នាក់** និងទទួលជនរងគ្រោះ និងងាយរងគ្រោះស្នាក់នៅក្នុងមណ្ឌលសំចតសរុប**២នាក់**។

**ក.២- ការងារស្តារលទ្ធភាពពលកម្ម**

- បានផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនជនមានពិការភាពចំនួន**៦ ៣៩៥នាក់** ក្នុងនោះ សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាចំនួន**៣ ៤៧៣នាក់** និងស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រចំនួន**២ ៩២២នាក់**

- បានផ្តល់ប្រាក់របបសន្តិសុខសង្គមជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន**៥៧ ៤៥៤នាក់** និងអ្នកនៅក្នុងបន្ទុកចំនួន**៤៣ ៦៦៨នាក់**

- បានផ្តល់អវយវៈសិប្បនិម្មិត រណប និងឧបករណ៍ជំនួយរាងកាយចំនួន**៩៤៧គ្រឿង/រាយ** ផ្តល់រទេះរុញចំនួន**១៩៩គ្រឿង** ជួសជុលអវយវៈសិប្បនិម្មិត រណប និងឧបករណ៍ជំនួយរាងកាយចំនួន**១ ១១២គ្រឿង/រាយ** ព្យាបាលដោយចលនាចំនួន**១ ០៩៩នាក់** ស្មើនឹងចំនួនព្យាបាល**៧ ៤៦៩លើក** ព្យាបាលអ្នកជំងឺរបួសខួរឆ្អឹងខ្នងចំនួន**១០នាក់** ផ្តល់សេវាស្តារលទ្ធភាពពលកម្មពីចម្ងាយOpen Tele-Rehab ចំនួន**៩០នាក់** និងផ្តល់ការស្នាក់នៅក្នុងមជ្ឈមណ្ឌលអំឡុងពេលទទួលសេវាជូនដល់ជនមានពិការភាពបានចំនួន**៣៩១នាក់** និងអ្នកកំដរចំនួន**១១៨នាក់**។

**ក.៣- ការងារអតីតយុទ្ធជន**

ទទួលអតីតយុទ្ធជនដែលផ្ទេរពីក្រសួងមហាផ្ទៃចំនួន**៥០៤នាក់** និងក្រសួងការពារជាតិចំនួន**៦៥៨នាក់** លុបឈ្មោះនិវត្តជន និងផ្តល់ប្រាក់ធានារ៉ាប់រងសង្គមចំនួន**១២៥នាក់** ផ្ទេរអតីតយុទ្ធជនតាម

សាខាមូលនិធិជាតិជំនួយសង្គម(មជជ) រាជធានី ខេត្តចំនួន**១២នាក់** ផ្តល់ប្រាក់ឧបត្ថម្ភជូនជនមានពិការភាពចំនួន**១នាក់** លុបឈ្មោះជនពិការទទួលស្គាល់ជាជនពលីចំនួន**៣៣នាក់** លុបឈ្មោះជនពលីចំនួន**២៩នាក់** និងលុបឈ្មោះជនមរណៈចំនួន**៤នាក់**។

រាជរដ្ឋាភិបាលបានចំណាយថវិកាចំនួន**៨៧ ៩៤៣ ៧១៨ ១៦៧រៀល** សម្រាប់បើកប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារ មានជនមានពិការភាពចំនួន**២៩ ០៣០នាក់** និវត្តជនចំនួន**៤៧ ៧៣១នាក់** ជនពលីចំនួន**២៦ ៦៤៧នាក់** ជនមរណៈចំនួន**១១ ៧៥៧នាក់** និងជនបាត់បង់សមត្ថភាពការងារចំនួន**១ ៣៥១នាក់**។

**ក.៤- ការងារយុវនីតិសម្បទា** មជ្ឈមណ្ឌលរដ្ឋ មណ្ឌលឯកជននិងអង្គការ**១៩កន្លែង** បានទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនចំនួន**១ ៧៤៣នាក់**(ស្រី១០៦នាក់) ឱ្យស្នាក់នៅបន្សាបព្យាបាល និងស្តារនីតិសម្បទា និងបញ្ចេញជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនចំនួន**១ ៩០២នាក់**(ស្រី៨៥នាក់) នៅសល់ជាក់ស្តែងចំនួន**៨ ៦២៩នាក់**(ស្រី៤៧៣នាក់)។

**ខ- ការងារអនុវត្តរបបជាតិសន្តិសុខសង្គម**

**ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ខ.១- ការងារពង្រឹងនិងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ**

ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះបញ្ជិកាសមាជិកថ្មីលើវិស័យឯកជននិងវិស័យសាធារណៈមានសមាជិកចំនួន**៣១ ៤៩១នាក់**(ស្រី១៤ ៧១៦)។ គិតត្រឹមខែមករា ឆ្នាំ២០២៦ នេះ មានសមាជិកចំនួន**២ ៤៨៤ ៥២៦នាក់**(ស្រី១ ៤០៥ ១០១នាក់)។

**ខ.២- ការងារពង្រឹងនិងការពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព**

ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (១) បានចុះបញ្ជិកាសមាជិកថ្មីសរុប**៥៩ ២៤៣នាក់**(ស្រី៣១ ២០៣នាក់) ក្នុងនោះ តាមរបបភាគទានជាកាតព្វកិច្ចមានសមាជិកចំនួន**៣១ ៥៥៤នាក់**(ស្រី១៤ ៧២៧នាក់) និងសមាជិកតាមរបបភាគទានដោយស្ម័គ្រចិត្តចំនួន**២៧ ៦៨៩នាក់**(ស្រី១៦ ៤៧៦នាក់)។ គិតត្រឹមខែមករា ឆ្នាំ២០២៦ សមាជិកប.ស.ស. សរុបចំនួន**៣ ៥៧៩ ០៣៩នាក់**(ស្រី១ ៩៦៥ ០៥៣នាក់) ក្នុងនោះ សមាជិកតាមរបបភាគទានជាកាតព្វកិច្ចមានចំនួន**២ ៦៩៥ ៧០៩នាក់**(ស្រី១ ៤៣៥ ៤៦២នាក់) និងសមាជិកតាមរបបភាគទានដោយស្ម័គ្រចិត្តមានចំនួន**៨៨៣ ៣៣០នាក់**(ស្រី៥២៩ ៥៩១នាក់) និង(២) បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលជាដៃគូរបស់ប.ស.ស. ទូទាំងរាជធានី ខេត្តសរុប**១ ៦២១** ក្នុងនោះ មូលដ្ឋានសុខាភិបាលសាធារណៈចំនួន**១ ៤៤៥** និងមូលដ្ឋានសុខាភិបាលឯកជនចំនួន**១៧៦**។

**ខ.៣- ការងារពង្រឹងនិងការពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន**

ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះបញ្ជិកសមាជិកថ្មី តាមរបបភាគទានជាកាតព្វកិច្ចមានសមាជិកបានចំនួន**៣១ ១៨២នាក់**(ស្រី១៤ ៥៨២នាក់) និងសមាជិកថ្មីតាមរបបភាគទានដោយស្ម័គ្រចិត្ត មានសមាជិកចំនួន**១២៩នាក់**(ស្រី៧៣នាក់)។ គិតត្រឹមខែមករា ឆ្នាំ២០២៦ នេះ តាមរបបភាគទានជាកាតព្វកិច្ចមានសមាជិកចំនួន**២ ៦៦០ ៣៤៦នាក់**(ស្រី១ ៥៥៩ ៩០០នាក់) និងសមាជិកតាមរបបភាគទានដោយស្ម័គ្រចិត្ត មានសមាជិកចំនួន**២ ០៣១នាក់**(ស្រី១ ០៦៩នាក់)។

ខ.៤- ការងាររបបសន្តិសុខសង្គមលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ប.ស.ស. នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបោះពុម្ពបណ្ណមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមគោលដៅរួមមាន កម្មករនិយោជិតក្រៅប្រព័ន្ធ សិល្បករ សិល្បការិនី កីឡាករ កីឡាការិនី សមាគម កម្មករស៊ីក្លូ អ្នករត់ម៉ូតូ ឌុបនិងម៉ូតូកង់បី និងបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធសរុប១៣៩ ០៦០នាក់(ស្រី៧៧ ៩៧៦នាក់)។

គ- ការជំរុញនិងការបង្កើនសុខុមាលភាពនៃគ្រួសារក្រីក្រ គ្រួសារយុទ្ធជនមានពិការភាព ពលីមរណៈ និងគ្រួសារអតីតយុទ្ធជន

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** គិតពីចាប់ផ្តើមអនុវត្តដល់ខែមករា ឆ្នាំ២០២៦ កម្មវិធីសម្បទានដីសង្គមកិច្ចគ្រប់ប្រភេទសម្រេចផ្តល់ដីសរុបទំហំ**១ ៣៦២ ១៨២,៥៨**ហ.ត.ជូនប្រជាពលរដ្ឋសរុប**៤៩០ ១៥២**គ្រួសារ និងសាងសង់ផ្ទះជូនប្រជាពលរដ្ឋសរុប**៨ ៩៩១ខ្នង**។ បច្ចុប្បន្ននេះ សម្បទានិកចូលស្នាក់នៅសរុបចំនួន**៧ ១៣៥ខ្នង** ស្មើនឹង**៧៩,៣៦%**។

ឃ- ការងារលើកកម្ពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

**ឃ.១- ក្រសួងពាណិជ្ជកម្ម** តាមរយៈក្រុមហ៊ុនហ្គ្រីនត្រេដ បានថែរក្សាទុកដាក់សន្និធិស្បៀងត្រៀមបម្រុងយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាលកម្ពុជា នៅតាមបណ្តាឃ្លាំងស្តុកនានា មានអង្ករចំនួន **១ ១៦៨តោន** ទឹកត្រីចំនួន**១៥ ០០០យួរ** ទឹកស៊ីអ៊ីវចំនួន**១៥ ០០០យួរ** មីជាតិចំនួន**១៥ ០០០កេស** ត្រីខកំប៉ុងចំនួន**៨ ៥០០យួរ** និងស្តុកទឹកសុទ្ធចំនួន**៦៥ ០០០កេស**។

**ឃ.២- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖**

- ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបាន**១៣៥ ០៦៣ហ.ត.** លើផ្ទៃដីអនុវត្តស្រូវសរុប **៧៦០ ៦៣៦ហ.ត.** ដោយទទួលបានបរិមាណផលសរុប**៦៤០ ១៩៧តោន** តិចជាងឆ្នាំមុន**១៩០ ៤៥៧តោន** ទិន្នផលមធ្យមស្រូវប្រាំងឆ្នាំ២០២៦ ស្មើនឹង**៤,៧៤០តោន/ហ.ត.**

- **ការងារវារីវប្បកម្ម** (១) ចិញ្ចឹមត្រីអនុវត្តបានចំនួន**៥ ៦៧៨តោន** ស្មើនឹង**១,៦៧%** នៃផែនការចំនួន**៣៤០ ០០០តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុន ថយចុះ**១១ ០១៧តោន** (២) ចិញ្ចឹមក្រពើអនុវត្តបាន **២០ ៤៦០ក្បាល** ស្មើនឹង**៦,៨២%** នៃផែនការចំនួន**៣០០ ០០០ក្បាល** បើធៀបនឹងខែដូចគ្នាឆ្នាំមុន ថយចុះ**២៩០ក្បាល** និង(៣) ភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន**១១ ០០០ ០០០កូន** ស្មើនឹង**៣,៧៩%** នៃផែនការចំនួន**២៩០ ០០០ ០០០កូន** បើធៀបនឹងខែដូចគ្នាឆ្នាំមុន ថយចុះ**៨០០ ០០០កូន**

- **ការងារអាជីវកម្មវិស័យជលផល** (១) នេសាទទឹកសាបអនុវត្តបាន**៧៥ ៤៥០តោន** ក្នុងនោះ នេសាទដាយត្រីអនុវត្តបាន**១១ ២៧០តោន** នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបាន**៥៨ ៩០៥តោន** និងនេសាទគ្រួសារក្នុងវាលស្រែអនុវត្តបានចំនួន**៥ ២៧៥តោន** ស្មើនឹង**១៦,៦២%** នៃផែនការចំនួន **៤៥៤ ០០០តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុន ថយចុះ**៨៦០តោន** (២) ផលនេសាទសមុទ្រអនុវត្តបាន **៧ ៩៩០តោន** ក្នុងនោះ នេសាទសិប្បកម្មអនុវត្តបាន**៧ ២៦០តោន** និងនេសាទលក្ខណៈគ្រួសារក្នុងដែននេសាទអនុវត្តបាន**៧៣០តោន** ស្មើនឹង**៦,១៥%** នៃផែនការចំនួន**១៣០ ០០០តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុន ថយចុះ**៤ ៧៦៣តោន**

- **ការកែច្នៃផល** នេសាទទឹកសាបអនុវត្តបាន**៤ ៩៧០តោន ស្មើនឹង៥,១៣%** និងផលនេសាទសមុទ្រអនុវត្តបាន**៦៣០តោន** ស្មើនឹង**០,៧១%** ធៀបផលផលិតផលជលផលសរុប**៨៩ ១១៨តោន** និងការផលិតទឹកត្រីអនុវត្តបាន**៦ ២០០តោន**

**ឃ.៣- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ផលិតកម្មអំបិល : ស្រែអំបិលនៅក្នុងខេត្តកំពតនិងខេត្តកែប មានបរិមាណផលិតផលអំបិលសរុប**៣៦តោន**(ក្នុងនោះ៣,៧៣៤តោនមានស្តុកនៅក្នុងឃ្លាំងអំបិល)។

## ៥- ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន

**ក- ការលើកកម្ពស់ការយល់ដឹងពីអត្តសញ្ញាណជាតិ ការអភិរក្ស ការអភិវឌ្ឍវប្បធម៌ជាតិ**

**១- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ៖**

- ចុះផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ នៅខេត្តត្បូងឃ្មុំ

- បន្តចុះបោះបង្គោលការពារបុរាណដ្ឋានចំនួន**១៦ទីតាំង** នៅខេត្តកណ្តាល ខេត្តកំពង់ធំ និងខេត្តកំពង់ស្ពឺ។ បន្តធ្វើកំណាយបង្ការបុរាណដ្ឋាននៅស្រុកអង្គរបុរី ខេត្តតាកែវ

- ការិយាល័យរដ្ឋបាលរាជធានី ខេត្តចំនួន៣ បានផ្តល់សេវាសាធារណៈក្នុងវិស័យវប្បធម៌ និងវិចិត្រសិល្បៈសរុបចំនួន**១០ច្បាប់** ក្នុងនោះ ខេត្តសៀមរាប៧ ស្វាយរៀង២ និងខេត្តមណ្ឌលគិរី១។

**២- រាជបណ្ឌិត្យសភាកម្ពុជា៖**

**ការងារអភិរក្ស និងអភិវឌ្ឍន៍ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប**

- ការងារអភិរក្សធនធានវប្បធម៌ : សិក្សារៀបចំផែនទីទេសភាពធនធានធម្មជាតិ និងវប្បធម៌តំបន់ឡស្លដែកបុរាណនៅក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប

- ការងារអភិវឌ្ឍ : បង្កើតកសិដ្ឋានចិញ្ចឹមសត្វសម្រាប់ការសិក្សានិងស្រាវជ្រាវ ដែលមានចិញ្ចឹមមេគោរីតទឹកដោះចំនួន**៤៣ក្បាល** គោធើមចំនួន**១២ក្បាល** គោបង្កាត់ចំនួន**១១ក្បាល** គោស្ងួតទឹកដោះចំនួន**៦ក្បាល** គោញីជំទង់ចំនួន**១១ក្បាល** កូនគោញីអាយុក្រោម៦ខែ ចំនួន**៧ក្បាល** ពពែសរុបចំនួន**១៦ក្បាល**(ឈ្មោល៥ក្បាល) ចៀមសរុបចំនួន**៤៦ក្បាល**(ឈ្មោល១៣ក្បាល) គោសាច់សរុបចំនួន**១០២ក្បាល**(ឈ្មោល១៨ក្បាល) គោទឹកដោះឈ្មោលចំនួន**២ក្បាល** ក្របីសរុប**២០៦ក្បាល**(ឈ្មោល៥៥ក្បាល) ក្របីឃ្លៀចចំនួន**៦៥ក្បាល**(ឈ្មោល១៤ក្បាល)។

**ខ- ការបណ្តុះទស្សនៈមនសិការជាតិ ឧត្តមគតិវិជ្ជមាន ការពង្រឹងប្រសិទ្ធភាពនៃការស្រាវជ្រាវ ការចងក្រង និងការផ្សព្វផ្សាយគុណតម្លៃប្រវត្តិសាស្ត្រ**

**ខ.១- ក្រសួងការពារជាតិ៖**

- **ការងារប្រវត្តិសាស្ត្រយោធា** បានសហការជាមួយបណ្តាអង្គភាពធ្វើបច្ចុប្បន្នភាពលើខ្លឹមសារទាក់ទិននឹងមាគ៌ាស្វែងរកសន្តិភាពតាមរយៈនយោបាយឈ្នះ ឈ្នះ និងវិធានការជាយុទ្ធសាស្ត្រក្នុងការការពារដែនអធិបតេយ្យជាតិបូរណភាពទឹកដីសម្រាប់តម្កល់តឹកតាងជាសក្ខីភាព។ បានបន្តសហការផ្លាស់ប្តូរព័ត៌មាននិងប្រមូលរបាយការណ៍ទី៤ និងទី៥ ស្តីពីការរៀបចំនិងថែទាំទីស្នាក់ការតំបន់ប្រវត្តិសាស្ត្រយោធានៅ

យោធភូមិភាគទី៣ និងបន្តតាមដានតំបន់ប្រវត្តិសាស្ត្រយោធាមួយចំនួន ដែលកំពុងក្លាយជាតំបន់យុទ្ធសាស្ត្រដ៏រឹងមាំ។ បានសហការជាមួយរដ្ឋបាលខេត្តក្នុងការផ្តល់ការប្រឹក្សាសម្រាប់ការកសាងសួនតេជោសន្តិភាពនៅតាមបណ្តាខេត្ត។

- **ការងារវិមានឈ្នះ ឈ្នះ** បាននផលិតផ្ទាំងរូបភាព វីដេអូនិងខ្លឹមសារនយោបាយឈ្នះ ឈ្នះ វិមានឈ្នះ ឈ្នះផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គមផ្លូវការជាប្រចាំ។ បានធ្វើការថែទាំជួសជុលបានទទួលគណៈប្រតិភូជាតិ អន្តរជាតិ មកបំពេញទស្សនកិច្ចនៅវិមានឈ្នះ ឈ្នះចំនួន**១៥លើក** ស្មើនឹង៣ ១០៩នាក់ និងព្រឹត្តិការណ៍ផ្សេងៗ។

**ខ.២- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ៖**

- បន្តសិក្សាស្រាវជ្រាវ និងរៀបចំបញ្ជីត្រៀម ដើម្បីស្នើសុំចុះមរតកវប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជាដែលមានសក្តានុពល ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ រួមមាន៖ (១) ក្រុមប្រាសាទបន្ទាយឆ្មារ (២) ក្រុមប្រាសាទបេងមាលា (៣) ក្រុមប្រាសាទព្រះខ័នកំពង់ស្វាយ (៤) រមណីយដ្ឋានអង្គរបុរី និងភ្នំដា (៥) រមណីយដ្ឋានភ្នំគូលែន និង(៦) រមណីយដ្ឋានឧដុង្គ

- បន្តសិក្សាស្រាវជ្រាវនិងចងក្រងឯកសារ (១) ទស្សនាទានអំពី«គម្រោងបណ្តុះបណ្តាលជំនាញជូនតាខ្មែរឆ្នាំ២០២៤-២០២៨» (២) ជីវប្រវត្តិអ្នកនិពន្ធ**១នាក់** (៣) សម្លៀកបំពាក់អាពាហ៍ពិពាហ៍ខ្មែរ (៤) ស្ករត្នោតខ្មែរ និង(៥) ចម្លាក់ក្បាលយក្សនិងទេវតានៅក្រុងអង្គរធំ ប្រាសាទព្រះខ័ន និងប្រាសាទបន្ទាយឆ្មារ។

**គ- ការលើកកម្ពស់ការយល់ដឹងនិងការជំរុញតួនាទីព្រះពុទ្ធសាសនា**

**ក្រសួងធម្មការនិងសាសនា៖**

**គ.១- ព្រះពុទ្ធសាសនា**

- ទទួលសំណើសុំអនុញ្ញាតច្បាប់ធ្វើបុណ្យបញ្ចុះខណ្ឌសីមាចំនួន**១ច្បាប់**

- ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត លទ្ធផលសិក្សាប្រចាំខែរបស់សមណសិស្ស សិស្សចំនួន**៦០៩អង្គ/នាក់** ក្នុងនោះ និទ្ទេសល្អប្រសើរ៤២អង្គ/នាក់ ល្អណាស់១២០អង្គ/នាក់ ល្អ១១៣អង្គ/នាក់ ល្អបង្គួរ៧៣អង្គ/នាក់ មធ្យម៤៨អង្គ/នាក់ និងខ្សោយ(ធ្លាក់)ចំនួន២១៣អង្គ/នាក់

- ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជទាំង**៣ទីតាំង** សមណនិស្សិត និស្សិតចូលសិក្សាស្រាវជ្រាវ និងអានសៀវភៅនៅបណ្ណាល័យរបស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជទាំងបីទីតាំងមានចំនួន**៦០២អង្គ/នាក់** និងខ្ចីសៀវភៅចំនួន**១២៨ក្បាល**

- ពុទសាសនបណ្ឌិត្យ បានទទួលស្នាដៃពានរង្វាន់អក្សរសិល្ប៍ពុទ្ធសាសនបណ្ឌិត្យលើកទី៩ ឆ្នាំ២០២៦ ក្រោមប្រធានបទ «យុវជននិងការកសាងរបងសន្តិភាព» ផ្នែកកំណាព្យរឿងខ្លីចំនួន**២រឿង** និងរឿងខ្លីចំនួន**៥រឿង**។ បញ្ចូលអត្ថបទទៅក្នុងគេហទំព័រពុទ្ធសាសនបណ្ឌិត្យ និងផេកហ្វេសប៊ុកចំនួន**៧ចំណងជើង**។ អ្នកចូលអាននៅក្នុងបណ្ណាល័យមានចំនួន**១៦២អង្គ/នាក់**។

**គ.២- ពាហិរសាសនា**

បានទទួលសំណើ និងលិខិតផ្សេងៗចំនួន**១១ច្បាប់**។

## បញ្ហាគោលយុទ្ធសាស្ត្រទី២

## «ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការបង្កើនភាពប្រកួតប្រជែង»

### ១- ការអភិវឌ្ឍវិស័យគន្លឹះនិងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច

ក- ការងារពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស

ក្រសួងពាណិជ្ជកម្ម៖

ក.១- ការងារពាណិជ្ជកម្មក្នុងប្រទេស

- តាមដានថ្លៃប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ និងបានគណនាកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយក្នុងរយៈពេល**១០ថ្ងៃ/ម្តង** និងបានចេញថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយចំនួន**៣លើក**

- តាមដាន និងវិភាគថ្លៃទំនិញ**១១៩មុខ** ពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃ ដើម្បីធានាបានការធ្វើអន្តរាគមន៍ទាន់ពេលវេលាឆ្លើយតបតម្រូវការទីផ្សារ និងការឡើងឬចុះថ្លៃខ្លាំងខុសពីប្រក្រតី

- តាមដានសន្និធិស្រូវ អង្ករតាមបណ្តាខេត្ត ថ្លៃប្រេងឥន្ធនៈនៅរាជធានីភ្នំពេញ សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារទាំង៥ នៅរាជធានីភ្នំពេញ**២០លើក**

ក.២- ការងារពាណិជ្ជកម្មក្រៅប្រទេស

ការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញដូចជាទំនិញវាយនភណ្ឌ ស្បែកជើង កាបូបម្ហូក កង់ និងផលិតផលកសិកម្ម ព្រមទាំងអាជ្ញាបណ្ណផ្សេងៗសម្រាប់នាំចេញទៅកាន់ទីផ្សារ៖

| ល.រ. | បរិយាយ | មករា ២០២៥ | មករា ២០២៦ | បម្រែបម្រួល | ភាគរយ |
|---|---|---|---|---|---|
| ១ | អាស៊ាន | $៤៥២,១៩៩,៣៦២ | $៥៦៣,២៥៩,១៩៧ | $១១១,០៥៩,៨៣៦ ▲ | ២៤.៥៦%▲ |
| ២ | អូស្ត្រាលី | $១៧,២១៣,៦៣៦ | $១៨,៥០៥,១៥៤ | $១,២៩១,៥១៨▲ | ៧.៥០%▲ |
| ៣ | កាណាដា | $៩៣,៧១៣,២៦៧ | $១១៨,៤៨២,០៥៧ | $២៤,៧៦៨,៧៩០▲ | ២៦.៤៣% ▲ |
| ៤ | សាធារណរដ្ឋប្រជាមានិតចិន | $១១៨,៣២៥,៨៤៤ | $១៨៨,៣៩១,៤៣៤ | $៧០,០៦៥,៥៩០▲ | ៥៩.២១%▲ |
| ៥ | សហភាពអឺរ៉ុប | $៣០១,១២៩,៨១៥ | $៣៦០,២០៥,៤០៤ | $៥៩,០៧៥,៥៨៨▲ | ១៩.៦២%▲ |
| ៦ | ឥណ្ឌា | $១១,៩១២,៧១១ | $១៩,២៩៤,៦២៨ | $៧,៣៨១,៩១៧▲ | ៦១.៩៧%▲ |
| ៧ | ជប៉ុន | $១៤៨,៧៩២,២៦៤ | $១៤៤,៤៥៥,៤៧៧ | $៤,៣៣៦,៧៨៧ ▼ | ២.៩១%▼ |
| ៨ | សាធារណរដ្ឋកូរ៉េ | $២៨,៩១៨,០៣០ | $២៩,៣១១,៦៤០ | $៣៩៣,៦១០▲ | ១.៣៦%▲ |
| ៩ | នូវែលសេឡង់ | $១,៩៤៤,៤៤៤ | $១,៨១៨,៤៤៦ | $១២៥,៩៩៨ ▼ | ៦.៤៨%▼ |
| ១០ | អេមីរ៉ាតអារ៉ាប់រួម | $៥,៣៥៦,៤៦១ | $៤,៣៥៨,៧៤៥ | $៩៩៧,៧១៦ ▼ | ១៨.៦៣%▼ |
| ១១ | ចក្រភពអង់គ្លេស | $៧១,៦៧៨,៥៦០ | $៧២,៤៩៦,៦៤៣ | $៨១៨,០៨៣▲ | ១.១៤%▲ |
| ១២ | សហរដ្ឋអាមេរិក | $៧០៧,៣៦៥,០២៥ | $១,០៥៨,៨៧៨,៩៣៤ | $៣៥១,៥១៣,៩០៩▲ | ៤៩.៦៩%▲ |
| ១៣ | ទីផ្សារគោលដៅផ្សេងៗ | $៧៤,៣១៨,៥៣៩ | $៧៦,៨១៨,០០៤ | $២,៤៩៩,៤៦៦▲ | ៣.៣៦%▲ |

ខ- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖

ខ.១- ការនាំចេញឈើ នាំចូលឈើ និងសត្វព្រៃ

- ផ្តល់លិខិតអនុញ្ញាតក្រុមហ៊ុនចំនួន១ នាំចេញផលិតផលរានទេវតាទៅក្រៅប្រទេស ដែលមានបរិមាណ១២ម³ និងបានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១ មានផលិតផលជ័រទឹកចំនួន **១៦តោន**

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១ មានផលិតផលឈើមូលប្រភេទស្រល់ចំនួន**៥៥៥ម³**

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្តជូនក្រុមហ៊ុនចំនួន៣ ដែលមានរណារយន្តសរុប**២២គ្រឿង** និងយានយន្តសរុប**៤៦គ្រឿង** គឺ ១/-ក្រុមហ៊ុនបរទេសសៃហួន ភីអិន អ៊ិនវេសមិន ឧបភើរ៉េសិន ស្ថិតនៅខេត្តក្រចេះ ២/-ក្រុមហ៊ុន ណេងណា អ៊ិនវេសមិន ឯ.ក និង៣/-ក្រុមហ៊ុនរ៉ូយ៉ាល់ ជ័ញស្តុក ស្ថិតនៅខេត្តមណ្ឌលគិរី

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន១ ដែលមានអុសចម្រុះចំនួន**១៤ ៦១៨ស្ទែរ**

- ចេញលិខិតអនុញ្ញាតនាំចូល-នាំចេញសត្វព្រៃមានចំនួន៣សន្លឹក ក្នុងនោះ **២សន្លឹក** សម្រាប់នាំចេញសត្វស្វាក្តាមសរុប២ **២៨០ក្បាល** និង**១សន្លឹក** សម្រាប់នាំចូលរោមសត្វជាប់ស្បែកទម្ងន់៦៤០គ.ក្រ.។ ទន្ទឹមនឹងនេះ បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃចំនួន**៣សន្លឹក** ក្នុងនោះ **២សន្លឹក** សម្រាប់ដឹកជញ្ជូនសត្វស្វាក្តាមនាំចេញចំនួន២ **២៨០ក្បាល** និង**១សន្លឹក**សម្រាប់ដឹកជញ្ជូន រោមសត្វជាប់ស្បែកនាំចូលទម្ងន់៦៤០គ.ក្រ.។

ខ.២- ការនាំចេញផលិតផលសំខាន់ៗ

ការនាំចេញកសិផលបាន**១ ៥០១ ២៧៤,៧៨តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុន កើនឡើង **១៤,៤៥%** ក្នុងនោះ អង្ករចំនួន**១១៥ ៧៨៤តោន** ស្រូវចំនួន**៣២២ ៤៨៨តោន** ចំណិតដំឡូងមីក្រៀមចំនួន**៣៥១ ០៥៣តោន** ដំឡូងមីស្រស់ចំនួន**៥៣៩ ១៥០តោន** គ្រាប់ស្វាយចន្ទីចំនួន**៣១ ៩៨៦តោន** ផ្លែស្វាយស្រស់ចំនួន**៥១ ៩១៣តោន** ផ្លែចេកស្រស់ចំនួន**២៧ ២៥៧,៥៥តោន** ពោតចំនួន**៥ ៦៥១,៦៥តោន** ផ្លែមៀនស្រស់ចំនួន**៣ ៧១៥.៤៧តោន** និងកសិផលចំនួន៤៣មុខផ្សេងទៀតចំនួន**៥២ ២៧៥,៣៧តោន**។

ខ.៣- ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូមានចំនួន**៤១ ១៦១តោន** កើនឡើង**២ ២៨៨តោន** ស្មើនឹង **៥,៨៩%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន និងបរិមាណបញ្ចេញលក់ឈើកៅស៊ូចំនួន**៦ ៨៤៣ម³** កើនឡើង **៤ ៨៩៧តោន** ស្មើនឹង**២៥២%**

- តម្លៃលក់ជ័រកៅស៊ូជាមធ្យមក្នុងខែមករា គឺ**១ ៧០៣ដុល្លារអាម៉េរិក/តោន** ថយចុះ**២៣០ដុល្លារអាម៉េរិក/តោន** ស្មើនឹង**១១,៩២%** បើធៀបនឹងឆ្នាំមុន និងតម្លៃលក់ឈើកៅស៊ូ**២១៩ដុល្លារអាម៉េរិក/ម³**

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារ គឺទឹកជ័រ(DRC១០០%) គឺ**៦ ៤០០រៀល** ដល់**៧ ៣០០រៀល/គ.ក្រ.** និងជ័រកក(DRC ៥០%) គឺ**៣ ០០០រៀល** ដល់**៣ ៥០០រៀល/គ.ក្រ.**។

បរិមាណជ័រកៅស៊ូប្រើប្រាស់ក្នុងស្រុកចំនួន**១៦ ៧០៥តោន** កើនឡើង**៦ ៥៩៥តោន** ស្មើនឹង **៦៥,២%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ តម្លៃលក់ជ័រកៅស៊ូក្នុងស្រុកគិតជាមធ្យមតម្លៃ**១ ៧៧៥ដុល្លារ/តោន**។

**ខ.៤- ការនាំចេញផលនេសាទ** ការនាំចេញផលនេសាទស្រស់សរុប**១៥៤,៨៨តោន**។

**គ- ការងារលើកកម្ពស់វិស័យទេសចរណ៍**

**១- ក្រសួងមហាផ្ទៃ៖**

- ពលរដ្ឋខ្មែរធ្វើដំណើរចេញពីប្រទេសចំនួន**៩៤ ៣៧៣នាក់** បើធៀបនឹងខែកន្លងទៅមានចំនួន **២១៤ ៦៨២នាក់** ថយចុះ**១២០ ៣០៩នាក់** ស្មើនឹង**៥៦,០៤%** និងចូលមកវិញចំនួន**៩៧ ៨១៤នាក់** បើធៀបនឹងខែកន្លងទៅមានចំនួន**២១១ ៥៨៧នាក់** ថយចុះ**១១៣ ៧៧៣នាក់** ស្មើនឹង**៥៣,៧៧%**។ ដោយឡែក ពលរដ្ឋខ្មែរដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកវិញ(ក្រោមមូលហេតុស្នាក់នៅឬធ្វើការខុសច្បាប់)ចំនួន**២៦៩នាក់**(ស្រី១១៨នាក់ និងកុមារ៦នាក់)។

- ភ្ញៀវបរទេសចូលមកព្រះរាជាណាចក្រកម្ពុជា ចំនួន**៤០៧ ៤៦៦នាក់** បើធៀបនឹងខែកន្លងទៅមានចំនួន**៦៧៩ ៦២៤នាក់** ថយចុះ**២៧២ ១៥៨នាក់** ស្មើនឹង**៤០,០៥%** និងចេញវិញចំនួន**៤១៣ ៣០២នាក់** បើធៀបនឹងខែកន្លងទៅ**៦៩១ ៣១៤នាក់** ថយចុះ**២៧៨ ០១២នាក់** ស្មើនឹង**៤០,២២%**។

**២- ក្រសួងទេសចរណ៍** ចលនាទេសចរណ៍ផ្ទៃក្នុងដែលបានធ្វើដំណើរកម្សាន្តនៅទូទាំងប្រទេសរួមមាន (១) ទេសចរជាតិប្រមាណ**២ ២៦៤ ៧៦០នាក់** កើនឡើង**៤០,៦%** និង (២) ទេសចរបរទេសប្រមាណ**៣៨៦ ២៨៤នាក់** ថយចុះ**១៦,៣%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**ឃ- ការងារលើកកម្ពស់វិស័យសេវាកម្ម**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ៖**

- ការផ្តល់អាជ្ញាបណ្ណ (១) បើកផលិតកម្មថ្មីចំនួន**១** (២) បន្តច្បាប់ផលិតកម្មចំនួន**១** និង(៣) ផ្ទេរសិទ្ធិបណ្តោះអាសន្នចំនួន**២** និង(៤) អាជ្ញាបណ្ណអាជីវកម្មភាពយន្តឬវីដេអូរឿងសម្រាប់បញ្ចាំងតាមរោងភាពយន្តចំនួន**២៤ចំណងជើង**

- ការផ្តល់លិខិតអនុញ្ញាតថតផលិតភាពយន្តឬវីដេអូខ្មែរ (១) ភាពយន្តវីដេអូរឿងចំនួន**១ចំណងជើង** (២) ឯកសារចំនួន**១៥ចំណងជើង** (៣) ខារ៉ាអូខេចំនួន**២ចំណងជើង** និង(៤) ផលិតកម្មភាពយន្ត វីដេអូបរទេសចំនួន**១ចំណងជើង** និងឯកសារចំនួន**២ចំណងជើង**

- ផ្តល់ទិដ្ឋាការភាពយន្តស្ពាដែភាពយន្ត ឬវីដេអូខ្មែរខ្នាតវែងសម្រាប់បញ្ចាំងតាមរោងភាពយន្តចំនួន**១១ចំណងជើង**

- ចុះបញ្ជីស្លាដែភាពយន្តឬវីដេអូបរទេសចំនួន**១៦ចំណងជើង**។ ការបញ្ចូលពាក្យសន្ទនាជាភាសាខ្មែរក្នុងភាពយន្តឬវីដេអូរឿងចំនួន**១៤ចំណងជើង** ការរក្សាពាក្យសន្ទនាជាភាសាដើម ឬដាក់ចំណងជើងរងជាភាសាខ្មែរក្នុងភាពយន្តឬវីដេអូរឿងចំនួន**១១ចំណងជើង**

- ផ្តល់លិខិតអនុញ្ញាតសុំសិទ្ធិធ្វើអាជីវកម្មលើស្នាដៃតន្ត្រីគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ ដោយផលិតបន្តនូវតន្ត្រីមានទំនុកច្រៀងឬគ្មានទំនុកច្រៀងចំនួន**១បទ** ដោយផ្សព្វផ្សាយជាសាធារណៈតាមវិធីផ្សេងៗនូវស្នាដៃតន្ត្រី មានទំនុកច្រៀងឬគ្មានទំនុកច្រៀងជាសកលចំនួន**១បទ**

- ចុះបញ្ជីការពារស្នាដៃសៀវភៅចំនួន**៣ស្នាដៃ** និងសោតទស្សន៍ចំនួន**៦ស្នាដៃ**។ ផ្តល់លិខិតអនុញ្ញាតបោះពុម្ពសៀវភៅចំនួន**៤ស្នាដៃ**។ ចុះបញ្ជីសៀវភៅចំនួន**៥២ចំណងជើង**។ ផ្តល់លេខដល់អ្នកបោះពុម្ពផ្សាយចំនួន**៧២លេខ**

- ទទួលភ្ញៀវជាតិ អន្តរជាតិចូលអានសៀវភៅនៅបណ្ណាល័យជាតិចំនួន**១ ៩៩៩នាក់**(អន្តរជាតិ**៦៥៤នាក់**)។

**ង- ការងារកសាងមូលដ្ឋានឧស្សាហកម្ម**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** : រោងចក្របង្កើតថ្មី៣៨រោងចក្រ បើធៀបនឹងខែដូចគ្នាឆ្នាំមុន៣០រោងចក្រ កើនឡើង៨រោងចក្រ ស្មើនឹង**២៦,៦៦%** ក្នុងនោះ កម្មន្តសាលវាយនភណ្ឌ២ កម្មន្តសាលសម្លៀកបំពាក់(កាត់ដេរ)៤ កម្មន្តសាលកាបូប២ កម្មន្តសាលស្បែកជើង១ កម្មន្តសាលផលិតផលពីប្លាស្ទិក៦ កម្មន្តសាលបរិក្ខារអគ្គិសនី៣ កម្មន្តសាលគីមីនិងផលិតផលគីមី៤ កម្មន្តសាលលោហៈមូលដ្ឋាននិងដែកថែប២ កម្មន្តសាលគ្រឿងសង្ហារិម១ កម្មន្តសាលក្រដាសនិងផលិតផលពីក្រដាស២ កម្មន្តសាលពីលោហៈកែច្នៃ២ កម្មន្តសាលបរិក្ខារអេឡិចត្រូនិក២ កម្មន្តសាលគ្រឿងម៉ាស៊ីនសម្ភារៈបរិក្ខារឧស្សាហកម្ម១ និងកម្មន្តសាលដទៃទៀត៦ និងបង្កើតការងារថ្មីឱ្យពលករ**៧ ៤៦៨នាក់** បើធៀបនឹងខែដូចគ្នាឆ្នាំមុន**១០ ២៤២នាក់** ថយចុះ**២ ៧៧៤នាក់** ស្មើនឹង**២៧,០៨%**។

គិតត្រឹមដំណាច់ខែមករា ឆ្នាំ២០២៦នេះ មានរោងចក្រសរុប**៣ ១១២រោងចក្រ** និងពលកម្មសរុប**១ ២៧០ ១៣១នាក់**។ រោងចក្របិទទ្វារ៩រោងចក្រ និងប៉ះពាល់កម្លាំងពលកម្ម**៤ ៩១០នាក់**។

## ២- ការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូននិងឡូជីស្ទិក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល

**២.១- វិស័យដឹកជញ្ជូននិងឡូជីស្ទិក**

**ក្រសួងសាធារណការនិងដឹកជញ្ជូន៖**

**ក- ការងារដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងស្ពានអាកាស**

**ក.១- ការងារដឹកជញ្ជូនផ្លូវគោក**

ក្រសួងសាធារណការនិងដឹកជញ្ជូនសហការជាមួយរដ្ឋបាលរាជធានី ខេត្តពាក់ព័ន្ធ បានស្តាបនាស្តារ ជួសជុលផ្លូវជាតិ លូ និងស្ពាន ដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឥណទាន និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍអន្តរជាតិ ដូចជា៖

**ក.១.១- គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់និងស្ពានប្រើប្រាស់ថវិកាជាតិ**

- ថែទាំប្រចាំផ្លូវជាតិ និងផ្លូវខេត្ត ប្រវែងសរុប១៣ ៨១៧,៧៤គ.ម.
- ថែទាំប្រចាំស្ពានធំៗ ចំនួន២០ ប្រវែងសរុប១៥,៨៩គ.ម.
- ស្ពានឆ្លងកាត់ទន្លេមេគង្គជីឥដ្ឋ ថ្មគរ ពីឃុំជីឥដ្ឋ ស្រុកកៀនស្វាយ ទៅឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្តាល ប្រវែង១ ៦០០ម. ទទឹង២៦ម. និងផ្លូវតភ្ជាប់ប្រវែង២ ១០០ម. សម្រេចបាន៣៩,២៩%។

**ក.១.២- គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន៖**

- សាងសង់ពង្រីកនិងលើកកម្រិតផ្លូវជាតិលេខ៧ ចាប់ពីរង្វង់មូលស្គន់ ស្រុកជើងព្រៃ ដល់ក្រុងកំពង់ចាម ខេត្តកំពង់ចាម ជាប្រភេទផ្លូវក្រាលបេតុងកៅស៊ូAC មានប្រវែងសរុប**៤៥,៤៨៩គ.ម.** ទទឹង**១២ម.** សម្រេចបាន**៨៤,៤៨%**

- ស្ពានមិត្តភាពកម្ពុជា-ចិន មេគង្គក្រចេះ ពីស្រុកចិត្របុរីទៅស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ប្រវែង១ ៧៦១ម. និងផ្លូវតភ្ជាប់ប្រវែង៣១,៦៩គ.ម. សម្រេចបាន៩១,៩២%

- ស្ពានឆ្លងកាត់ទន្លេបាសាក់ ពីសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ទៅសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រវែង៨៤៥,៧០ម. ទទឹង២៧ម. និងផ្លូវតភ្ជាប់ប្រវែង៨០៤,៣០ម. សម្រេចបាន៥៨,២២%។

**ក.១.៣- គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយប្រទេសជប៉ុន៖**

កំណាត់ផ្លូវជាតិលេខ៥ ភាគកណ្តាល ពីថ្លាម្អម ខេត្តពោធិ៍សាត់ ដល់ខេត្តបាត់ដំបង និងពីក្រុងសិរីសោភ័ណ ដល់ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាប្រភេទផ្លូវក្រាលបេតុងកៅស៊ូAC មានប្រវែង ១៤៦,០៤គ.ម. ទទឹង២៣ម. មាន៤គន្លង(២គន្លងទៅ ២គន្លងមក) សម្រេចបាន៨២,១៨%។

**ក.១.៤- គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយធនាគារពិភពលោក(WB)៖**

- ជួសជុលនិងថែទាំផ្លូវជាតិលេខ៤ ចាប់ពីឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ដល់ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជាប្រភេទផ្លូវក្រាលបេតុងកៅស៊ូAC ប្រវែងសរុប១៩៦,២០គ.ម. ទទឹង១១ម. សម្រេចបាន៨៩,៦៧%

**ក.១.៥- គម្រោងក្នុងក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋនិងឯកជន(PPP)៖**

- ផ្លូវល្បឿនលឿនពីភ្នំពេញទៅក្រុងបាវិត ដែលមានប្រវែង១៣៥,១០គ.ម. ទទឹង២៤,៥០ម. ជាប្រភេទផ្លូវក្រាលបេតុងកៅស៊ូAC មាន៤គន្លង(២គន្លងទៅ ២គន្លងមក) ចាប់ពីឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្តាល ដល់សង្កាត់ប្រកម្ពស ក្រុងបាវិត ខេត្តស្វាយរៀង សម្រេចបាន០,៣១%

- គម្រោងសាងសង់ព្រែកជីកហ្វូណនតេជោ(តភ្ជាប់ពីព្រែកតាកែវនៃទន្លេមេគង្គ ដល់សមុទ្រខេត្តកែប) ប្រវែង១៨០គ.ម. បច្ចុប្បន្នកំពុងស្ថិតក្នុងនីតិវិធីនៃការដោះស្រាយផលប៉ះពាល់។

**ក.១.៦- ការងារចុះបញ្ជីយានយន្ត៖**

- ចុះបញ្ជីយានយន្ត៤៦ ៣៥១គ្រឿង បើធៀបនឹងខែដូចគ្នាឆ្នាំមុន៤០ ៤៣៣គ្រឿង កើនឡើង ៥ ៩១៨គ្រឿង ស្មើនឹង១៤,៦៣% ក្នុងនោះរថយន្ត៩ ៣៨៥គ្រឿង បើធៀបនឹងខែដូចគ្នាឆ្នាំមុន៦ ០១៨គ្រឿង កើនឡើង៣ ៣៦៧គ្រឿង ស្មើនឹង៥៥,៩៤% និងម៉ូតូ៣៦ ៩៦៦គ្រឿង បើធៀបនឹងខែដូចគ្នាឆ្នាំមុន ៣៤ ៤១៥គ្រឿង កើនឡើង២ ៥៥១គ្រឿង ស្មើនឹង៧,៤១% និងយានយន្តអគ្គិសនី១ ៣៦៥គ្រឿង (ទោចក្រយានយន្តនិងត្រីចក្រយានយន្ត១៨៣គ្រឿង និងរថយន្ត១ ១៨២គ្រឿង)។ គិតត្រឹមដំណាច់ខែមករា ឆ្នាំ២០២៦នេះ ការចុះបញ្ជីយានយន្តសរុប៨ ២២៩ ៩៩២គ្រឿង ក្នុងនោះ រថយន្ត១ ២៤៥ ២២៦គ្រឿង និងម៉ូតូ៦ ៩៨៤ ៧៦៦គ្រឿង និងចុះបញ្ជីយានយន្តអគ្គិសនីសរុប១៤ ៥៨៥គ្រឿង

- ចុះបញ្ជីរថយន្តដែលបំពាក់ស្លាកលេខពិសេសផ្ទាល់ខ្លួនចំនួន២ ៣០៧គ្រឿង និងសម្រាប់នីតិបុគ្គលឬសហកម្មសិទ្ធិចំនួន៣៨គ្រឿង

- ត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តចំនួន៤១ ១៤៤គ្រឿង

- ចេញបណ្ណអាជីវកម្មរថយន្តគ្រប់ប្រភេទចំនួន៣ ២៣១បណ្ណ

- ចេញបណ្ណបើកបរបាន២៣ ២៩៤បណ្ណ បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន១៧ ៧២៩បណ្ណ កើនឡើង៥ ៥៦៥បណ្ណ ស្មើនឹង៣១,៣៨% ក្នុងនោះ រថយន្ត២២ ២៦៥បណ្ណ បើធៀបនឹងខែដូចគ្នាឆ្នាំមុន១៦ ៥៧៨បណ្ណ កើនឡើង៥ ៦៨៧បណ្ណ ស្មើនឹង៣៤,៣០% និងម៉ូតូ១ ០២៩បណ្ណ បើធៀបនឹងខែដូចគ្នាឆ្នាំមុន១ ១៥១បណ្ណ ថយចុះ១២២បណ្ណ ស្មើនឹង១០,៥៩%។

**ក.១.៧- ការងារពិសោធន៍សំណង់និងសាធារណការ៖**

ធ្វើពិសោធន៍**១៣៦ករណី** បើធៀបនឹងខែដូចគ្នាឆ្នាំមុន**១៣២ករណី** កើនឡើង៤ករណី ស្មើនឹង **៣,០៣%**។

**ក.២- ការងារដឹកជញ្ជូនផ្លូវដែក៖**

- ដឹកជញ្ជូនទំនិញសរុប**១៧២ ១៧៧តោន**( ទំនិញនាំចូល១២០ ៩៧៧តោន និងទំនិញនាំចេញ ៥១ ២០០តោន )

- ដឹកជញ្ជូនអ្នកដំណើរសរុប១០ ៥៥៤នាក់( អ្នកដំណើរភ្នំពេញ ព្រះសីហនុ៧ ៦០៩នាក់ និងអ្នកដំណើរភ្នំពេញ ប៉ោយប៉ែត២ ៩៤៥នាក់ )។

**ក.៣- ការងារដឹកជញ្ជូនផ្លូវទឹកនិងកំពង់ផែ៖**

- គម្រោងជីកស្តារផ្លូវនាវាចរណ៍ប្រវែង៣ ៩៥៥ម. ជម្រៅទឹក៤ម. និងសាងសង់បង្គោលសញ្ញាជំនួយនាវាចរណ៍ នៅខេត្តកោះកុង សម្រេចបាន**៥៧%**

- គម្រោងសាងសង់កំពង់ផែទេសចរណ៍កំពង់ចាម មានទំហំ**១២ម**.គុណនឹង**៣៦ម.** នៅខេត្តកំពង់ចាម សម្រេចបាន**៣%**

- គម្រោងអភិវឌ្ឍន៍ផែកុងតឺន័រទឹកជ្រៅថ្មី ជំហានទី១ ប្រវែង**៣៥០ម.** ជម្រៅទឹក**១៤,៥០ម.** នៅខេត្តព្រះសីហនុ សម្រេចបាន**៥៧,៤០%**។

**ក.៣.១- ការងារចុះបញ្ជីជលយាន៖**

- ត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន**១៥គ្រឿង** ផ្តល់លិខិតអនុញ្ញាតនាវាដឹកជញ្ជូនទំនិញ**២០ច្បាប់** ផ្តល់លិខិតអនុញ្ញាតនាវាដឹកជញ្ជូនឆ្លងដែន**៨ច្បាប់** ផ្តល់លិខិតអាជីវកម្មដឹកជញ្ជូនទេសចរណ៍ស្នាក់នៅ**៥ច្បាប់** ត្រួតពិនិត្យលក្ខណៈបច្ចេកទេសទេសចរណ៍មានបន្ទប់**៥គ្រឿង** ផ្តល់លិខិតអាជីវកម្មដឹកជញ្ជូនដចម្លង**២ច្បាប់** និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសដចម្លង**២គ្រឿង**

- ចុះបញ្ជីនាវា**៣គ្រឿង** ផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញ**៧ច្បាប់** ផ្តល់សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា**៣ច្បាប់** ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មនាវា**៤ច្បាប់** និងផ្តល់លិខិតអនុញ្ញាតអាជីវកម្មក្រុមហ៊ុនជើងសារសេវាកម្ម**១ច្បាប់**

- ពន្យារលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ៣ច្បាប់។

គិតត្រឹមដំណាច់ខែមករា ឆ្នាំ២០២៦នេះ ការចុះបញ្ជីនាវាសរុប**១ ៤៣០គ្រឿង** ក្នុងនោះ ផ្លូវសមុទ្រ**៤៩៣គ្រឿង** និងផ្លូវទឹក**៩៣៧គ្រឿង**។

**ក.៤.- ការងារដឹកជញ្ជូនផ្លូវទឹក**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ** មាននាវាចូលចតចំនួន**១៧២គ្រឿង** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន**១៥១គ្រឿង** កើនឡើង**២១គ្រឿង** ស្មើនឹង**១៣,៩១%** ទំនិញនាំចូលចំនួន**៨៥១ ៥៥៣តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន**៧៣១ ៨៦៣តោន** កើនឡើង**១១៩ ៦៩០តោន** ស្មើនឹង**១៦,៣៥%** ទំនិញនាំចេញចំនួន**៣៦១ ៥៧០តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន**២៣៣ ១៤៥តោន** កើនឡើង **១២៨ ៤២៥តោន** ស្មើនឹង**៥៥,០៨%** ប្រេងឥន្ធនៈនាំចូលចំនួន**២០៤ ២២០តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន១៩១ ០០៧តោន កើនឡើង១៣ ២១៣តោន ស្មើនឹង៦,៩២% និងហ្គាសនាំចូល២៣ ៤៣១ តោន បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន១៦ ៨៣៨តោន ថយចុះ៦ ៥៩៣តោន ស្មើនឹង៣៩,១៦%។

**កំពង់ផែស្វយ័តភ្នំពេញ** មាននាវាចូលចតចំនួន**២៥៩គ្រឿង** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន**២៥៧គ្រឿង** កើនឡើង**២គ្រឿង** ស្មើនឹង០,៧៨% ទំនិញនាំចូលចំនួន**២៥១ ៧៨៩តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន**២៦២ ៧៦៥តោន** ថយចុះ**១០ ៩៧៦តោន** ស្មើនឹង៤,១៨% ទំនិញនាំចេញចំនួន**១៣៣ ៨៥២តោន តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន**១១៤ ៦០៩តោន** កើនឡើង**១៩ ២៤៣តោន** ស្មើនឹង**១៦,៧៩%** និងប្រេងឥន្ធនៈនាំចូលចំនួន**៧២ ៣០១តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន**៧៣ ៧៣០តោន** ថយចុះ**១ ៤២៩តោន** ស្មើនឹង១,៩៤%។

សរុបប្រេងឥន្ធនៈនាំចូលចំនួន**២៧៦ ៥២១តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន**២៦៤ ៧៣៧តោន** កើនឡើង**១១ ៧៨៤តោន** ស្មើនឹង៤,៤៥%។

សរុបឧស្ម័នហ្គាសនាំចូលចំនួន**២៣ ៤៣១តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុនមាន**១៦ ៨៣៨តោន** កើនឡើង**៦ ៥៩៣តោន** ស្មើនឹង៣៩,១៦។

**ខ- ការងារអាកាសចរណ៍ស៊ីវិល**

**រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល** ដែលធ្វើការហោះហើរដឹកជញ្ជូនទំនិញនិងអ្នកដំណើរក្នុងនិងក្រៅប្រទេសមាន៖

- ជើងហោះហើរក្នុងប្រទេស**៦៥៣ជើង** អន្តរជាតិ**៥ ៥៩០ជើង** និងឆ្លងកាត់**៨ ០៤៦ជើង** សរុប **១៤ ២៨៩ជើង** បើធៀបនឹងខែដូចគ្នាឆ្នាំមុន**១៣ ៥៣០ជើង** កើនឡើង**៧៥៩ជើង** ស្មើនឹង**៥,៦១%**
- ដឹកភ្ញៀវក្នុងប្រទេស**៣០ ៦៣១នាក់** និងក្រៅប្រទេស**៦៤៩ ២៤៨នាក់** សរុប**៦៧៩ ៨៧៩នាក់** បើធៀបនឹងខែដូចគ្នាឆ្នាំមុន**៦៨៣ ៦៨៨នាក់** ថយចុះ**៣ ៨០៩នាក់** ស្មើនឹង**០,៥៦%**
- ដឹកទំនិញក្រៅប្រទេស**៨ ៥៧៨តោន** បើធៀបនឹងខែដូចគ្នាឆ្នាំមុន**៥ ៧៤៤តោន** កើនឡើង **២ ៨៣៤តោន** ស្មើនឹង៤៩,៣៤%។

**គ- ការងារប្រៃសណីយ៍និងទូរគមនាគមន៍**

- បញ្ញើក្នុងប្រទេសសរុប**១៣ ៥៤៥បញ្ញើ** បញ្ញើក្រៅប្រទេសសរុប**៣០ ១៧៨បញ្ញើ**
- បញ្ញើទទួល សរុបចំនួន**២០ ៦៣៣បញ្ញើ** ទម្ងន់ចំនួន**១១ ៥៩៧,៩៦គីឡូក្រាម**
- បញ្ញើបញ្ជូន សរុបចំនួន**២៣ ០៩០បញ្ញើ** ទម្ងន់ចំនួន**២០ ៨២៣,៤៤គីឡូក្រាម**

**២.២- វិស័យថាមពលនិងវិស័យទឹកស្អាត**

**ក្រសួងរ៉ែនិងថាមពល៖**

**ក- ការផ្គត់ផ្គង់អគ្គិសនី**

- ការផលិត និងនាំចូលអគ្គិសនីសរុប**១ ១៣៨,៧០លានគីឡូវ៉ាត់ម៉ោង** រួមមាន ប្រភពក្នុងប្រព័ន្ធ**៩០២,១១លានគីឡូវ៉ាត់ម៉ោង**និងប្រភពនាំចូល**២៣៦,៥៩លានគីឡូវ៉ាត់ម៉ោង**
- ប្រភពក្នុងប្រព័ន្ធសរុប**៩០២,១១លានគីឡូវ៉ាត់ម៉ោង** មានប្រភពថាមពលស្អាត(វារីអគ្គិសនី ថាមពលពន្លឺព្រះអាទិត្យ និងជីវម៉ាស) សរុប**២៦២,២៦លានគីឡូវ៉ាត់ម៉ោង** និងប្រភពថាមពលផ្សេងៗ (ដុតប្រេងនិងធ្យូងថ្ម)ចំនួន**៦៣៩,៨៥លានគីឡូវ៉ាត់ម៉ោង**

- ប្រភពនាំចូលសរុប**២៣៦,៥៩លានគីឡូវ៉ាត់ម៉ោង** មាននាំចូលពីប្រទេសវៀតណាម**៧១,៤៧លានគីឡូវ៉ាត់ម៉ោង** និងនាំចូលពីប្រទេសឡាវ**១៦៥,១២លានគីឡូវ៉ាត់ម៉ោង**

- ការប្រើប្រាស់អគ្គិសនីសរុប**៧៤៧,២៩លានគីឡូវ៉ាត់ម៉ោង** និងតម្រូវការអានុភាពអតិបរមា **៣ ២០១,០៧មេហ្គាវ៉ាត់**។

**ខ- ការងារផលិតទឹកស្អាត**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖**

បរិមាណផលិតទឹកស្អាតរបស់អង្គភាពរដ្ឋាករទឹកសាធារណៈនិងរដ្ឋាករទឹកឯកជនទូទាំងប្រទេសផលិតបានសរុប៤៩ ១១០ ៣៣២ម$^{៣}$ ក្នុងនោះ៖

**ខ.១- រដ្ឋាករទឹកសាធារណៈរាជធានី ខេត្ត** ផលិតទឹកស្អាតបាន**៣១ ៣៨៧ ៥១៣ម$^{៣}$** បើធៀបនឹងខែដូចគ្នាឆ្នាំមុន៣៣ ៥៥១ ៩៦៦ម$^{៣}$ ថយចុះ២ ១៦៤ ៤៥៣ម$^{៣}$ ស្មើនឹង៦,៤៥% និងការងារពង្រីកបណ្តាញដាក់បំពង់មេនិងបណ្តាញចែកចាយ បានប្រវែង៩,៤៩១គ.ម.។

**ខ.២- រដ្ឋាករទឹកឯកជនទូទាំងប្រទេស** ផលិតទឹកស្អាតបាន**១៧ ៧២២ ៨១៩ម$^{៣}$** បើធៀបនឹងខែដូចគ្នាឆ្នាំមុន**១៥ ២៣៦ ១៥៩ម$^{៣}$** កើនឡើង២ ៤៨៦ ៦៦០ម$^{៣}$ ស្មើនឹង**១៦,៣២%** និងការងារពង្រីកបណ្តាញដាក់បំពង់មេនិងបណ្តាញចែកចាយ បានប្រវែង**៣១,២៨១**គ.ម.។

**ខ.៣-** ថ្លៃលក់ទឹកស្អាតត្រូវបានកំណត់ទៅតាមសហគ្រាសសាធារណៈរបស់រដ្ឋ និងប្រតិបត្តិករឯកជនក្នុងក្រុង( ទីរួមខេត្ត ) និងរាជធានី តម្លៃចាប់ពី**៤០០រៀល/ម$^{៣}$** ទៅ**៣៤០០រៀល/ម៣** អាស្រ័យលើកម្រិតនៃការប្រើប្រាស់និងប្រភេទអតិថិជន។ ថ្លៃទឹកស្អាត ត្រូវបានកំណត់តាមគោលនយោបាយផ្គត់ផ្គង់ទឹកនិងអនាម័យ ព្រមទាំងប្រកាសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលត្រូវគិតគូរដល់ជ្រុងនិរន្តរភាពរយៈពេលវែងរបស់ផលិតកម្ម ធានានូវប្រសិទ្ធភាពដំណើរការ ធានានូវការប្រើប្រាស់របស់ប្រជាជនតាមកម្រិតជីវភាព តាមបរិមាណការប្រើប្រាស់ ជាពិសេសបម្រើដល់បរិបទនយោបាយរបស់ប្រទេសផង។

**៣- ការកែលម្អបរិយាកាសធុរកិច្ចនិងការវិនិយោគ**

**ក្រសួងពាណិជ្ជកម្ម** បានទទួលការតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានាតាមរយៈប្រព័ន្ធអនឡាញ http://www.setfo.gov.kh/ ចំនួន**១ ១០០លិខិត**។

**៤- ការពង្រឹងប្រសិទ្ធភាពនិងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលទាំងសួនឧស្សាហកម្ម សួនកសិឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក**

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖**

**ក- គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន**

ក្នុងខែមករា ឆ្នាំ២០២៦នេះ រាជរដ្ឋាភិបាលអនុញ្ញាតឱ្យក្រុមហ៊ុនវិនិយោគលើគម្រោងថ្មី និងគម្រោងពង្រីកផលិតកម្មចំនួន**៤៣គម្រោង** មានទុនវិនិយោគសរុប**៧៥១ ៤៥០ ០១៦ដុល្លារអាម៉េរិក** និងអាចបង្កើតការងារបាន**២៥ ៩៥៧កន្លែង**។ គម្រោងវិនិយោគទាំង៤៣ មានគម្រោង៣១ បានវិនិយោគលើទីតាំងថ្មី និងគម្រោង១២ បានវិនិយោគលើទីតាំងនិងសំណង់អគារដែលមានស្រាប់។

ការអនុម័តគម្រោងវិនិយោគមានការថយចុះចំនួន**២៥គម្រោង** ខណៈទុនវិនិយោគកើនឡើងប្រមាណចំនួន**៣៤លានដុល្លារអាម៉េរិក** ស្មើនឹងប្រមាណ០,៤៥% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

**ក.១- ការវិនិយោគនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស**

គម្រោងវិនិយោគថ្មីមាន**៣១គម្រោង** មានទុនវិនិយោគ**៤៤៨ ០១៣ ០០២ដុល្លារអាម៉េរិក** និងអាចបង្កើតការងារបានចំនួន**២២ ៧៦៨កន្លែង** និងគម្រោងពង្រីកផលិតកម្មមាន**៤គម្រោង** មានទុនវិនិយោគ**១៧ ៣១៩ ៤៧៩ដុល្លារអាម៉េរិក** និងអាចបង្កើតការងារបាន**៧៦២កន្លែង**។

**ក.២- ការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស**

គម្រោងវិនិយោគថ្មីមាន**៨គម្រោង** មានទុនវិនិយោគចំនួន**២៨៦ ១១៧ ៥៣៥ដុល្លារអាម៉េរិក** និងអាចបង្កើតការងារ**២ ៤២៧កន្លែង** ។

ប្រភពទុនវិនិយោគមកពីប្រទេសចិនឈរលំដាប់លេខរៀងទី១ ដែលមានទុនវិនិយោគប្រមាណ **៣៥,៩០%** ម៉ាឡេស៊ីឈរលំដាប់លេខរៀងទី២ និងប្រភពទុនវិនិយោគក្នុងស្រុកលំដាប់លេខរៀងទី៣។

គម្រោងវិនិយោគដែលបានចុះបញ្ជីដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត មានចំនួន**២០គម្រោង** ស្ថិតក្នុងវិស័យឧស្សាហកម្ម និងមានប្រភពទុនវិនិយោគមកពីប្រទេសចិន ប្រមាណ **៤៤,៥លានដុល្លារអាម៉េរិក** និងប្រភពទុនវិនិយោគក្នុងស្រុកប្រមាណ**៤,២លានដុល្លារអាម៉េរិក**។

**ក.៣- ការចុះបញ្ជីគម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេស**

គណៈកម្មាធិការវិនិយោគកម្ពុជា(គ.វ.ក) បានចុះបញ្ជីគម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេស**៣តំបន់** ក្នុងទំហំទុនវិនិយោគ**២៦០លានដុល្លារអាម៉េរិក**និងអាចបង្កើតការងារបានប្រមាណជាង ៨៦៨កន្លែង។

**ខ- ទុនវិនិយោគក្នុងវិស័យឧស្សាហកម្ម**

ទុនវិនិយោគសរុបចំនួនជាង**២៥,៧១៩លានដុល្លារអាម៉េរិក** កើនឡើងជាង៥,០៧៦លានដុល្លារអាម៉េរិក ស្មើនឹង**២៤,៥៩%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ទុនវិនិយោគក្នុងស្រុកចំនួនជាង៤,១៩៨លានដុល្លារអាម៉េរិក ស្មើនឹង**១៦,៣២%** នៃទុនវិនិយោគសរុប។

## ៥- ការធ្វើនវានុវត្តន៍ យន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ការងារមូលបត្រ**

បានពិនិត្យនិងផ្តល់យោបល់ (១)ការអនុវត្តកាតព្វកិច្ចនៃការបង្ហាញព័ត៌មានទាន់ពេល ចំនួន **១១ករណី** (២) ការអនុវត្តកាតព្វកិច្ចនៃការបង្ហាញព័ត៌មានតាមការស្ម័គ្រចិត្តចំនួន**៣ករណី** (៣) ឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីឯកតាមូលនិធិ និង/ឬការអនុវត្តកាតព្វកិច្ចរបស់មូលនិធិចំនួន**១ករណី** (៤) ឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីឯកតាមូលនិធិ និង/ឬការអនុវត្តកាតព្វកិច្ចរបស់មូលនិធិចំនួន**១ករណី** (៥) រៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងប្រកាស ស្តីពី «ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិសម្រាប់និយោជិត» ចំនួន**១ករណី** (៦) ការបង្កើតប្រព័ន្ធជួញដូរមូលបត្របំណុលជាឯកជនចំនួន**២ ករណី** និង (៧) លើឯកសារពាក់ព័ន្ធការផ្តល់ភ្នាក់ងារវាយតម្លៃលទ្ធភាពសងចំនួន**១ករណី**។

# បញ្ចកោណយុទ្ធសាស្ត្រទី៣
# «ការអភិវឌ្ឍវិស័យឯកជននិងការងារ»

## ១- ការអភិវឌ្ឍវិស័យឯកជននិងការងារ

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖

ក- ការបង្កើតការងារ

- សហគ្រាស ក្រុមហ៊ុន រោងចក្របើកថ្មីសរុបចំនួន**១៥៩សហគ្រាស** មានកម្មករនិយោជិតសរុប**២៦ ២៦៦នាក់**(ស្រី១២ ២៦៤នាក់) ក្នុងនោះ វិស័យកាត់ដេរចំនួន**៣២សហគ្រាស** មានកម្មករនិយោជិតចំនួន**១៨ ៧៩១នាក់**(ស្រី៨ ៩៤៤នាក់) និងវិស័យក្រៅពីកាត់ដេរចំនួន**១២៧** មានកម្មករនិយោជិតចំនួន**៧ ៤៧៥នាក់**(ស្រី៣ ៣២០នាក់)។ គិតត្រឹមខែមករា ឆ្នាំ២០២៦នេះ សហគ្រាស ក្រុមហ៊ុន រោងចក្រសរុបមានចំនួន**៤៦ ៧៤៦សហគ្រាស** មានកម្មករនិយោជិតសរុបចំនួន**២ ២៦៩ ១៤៥នាក់** (ស្រី១ ២៩៣ ៦៨១នាក់)

- ជនទេសន្តរប្រវេសន៍ការងារខ្មែរទៅធ្វើការនៅក្រៅប្រទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងគណៈកម្មាធិការបណ្តុះបណ្តាលនិងបញ្ជូនពលករទៅបរទេស(គ.ប.ប.ព.ប.) សរុប**៩៧៨នាក់**(ស្រី៣៦៤នាក់) ទៅតាមវិស័យ ដូចជាឧស្សាហកម្ម កសិកម្ម សំណង់ ការងារផ្ទះ និងការងារផ្សេងៗ ក្នុងនោះ សាធារណរដ្ឋកូរ៉េចំនួន**៣៣៦នាក់**(ស្រី១០៩នាក់) ជប៉ុនចំនួន៦០៣នាក់(ស្រី២៤៤នាក់) ប្រទេសសិង្ហបុរីមានពលការិនីចំនួន**២នាក់** និងរដ្ឋអ៊ីស្រាអែលចំនួន**៣៧នាក់**(ស្រី៩នាក់)។ គិតត្រឹមខែមករា ឆ្នាំ២០២៦នេះ មានជនទេសន្តរប្រវេសន៍ការងារខ្មែរកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេសសរុបចំនួន **៤៣៣ ៤៣៣នាក់**(ស្រី១៥០ ៣៥៦នាក់)។

ខ- ការដំឡើងប្រាក់ឈ្នួលអប្បបរមា

បានដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២៦ ជូនដល់បងប្អូនកម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូបដល់ចំនួន**២០៨ដុល្លារអាម៉េរិក** ដោយបូកបន្ថែមចំនួន**២ដុល្លារអាម៉េរិក** ដែល **សម្តេចធិបតី** បានផ្តល់ជូននាំឱ្យប្រាក់ឈ្នួលអប្បបរមាបានកើនដល់ **២១០ដុល្លារអាម៉េរិក** ដូច្នេះ ដោយបូករួមទាំងប្រាក់អត្ថប្រយោជន៍ជាកាតព្វកិច្ចផ្សេងៗទៀត កម្មករនិយោជិតទទួលបានប្រាក់ឈ្នួលទាបបំផុតចន្លោះពី**២២៧ដុល្លារអាម៉េរិក** ដល់**២៣៨ដុល្លារអាម៉េរិក** ក្នុង១ខែ។

គ- ការធានាលក្ខខណ្ឌការងារល្អប្រសើរ

- បានដោះស្រាយវិវាទសរុបចំនួន**១៩៩ករណី** ក្នុងនោះ សះជាចំនួន**១៨៦ករណី** ស្មើនឹង **៩៣,៤៧%** មិនសះជាចំនួន**១៣ករណី** ស្មើនឹង**៦,៥៣%** អត្រាសះជានៃការដោះស្រាយវិវាទការងារ រួមទាំងនៅកម្រិតមន្ត្រីផ្សះផ្សា និងក្រុមប្រឹក្សាអាជ្ញាកណ្តាលចំនួន **៩៧,៣០%**

- ពង្រឹងយន្តការដោះស្រាយកូដកម្ម បាតុកម្មក្នុងវិស័យការងារតាមរយៈការពង្រឹងគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ដោយបានអន្តរាគមន៍ដោះស្រាយសរុប **២៩សហគ្រាស** ស្មើនឹង**២៩ករណី** ក្នុងនោះ កូដកម្មចំនួន**២៦សហគ្រាស** ស្មើនឹង**២៦ករណី** ដោះស្រាយសះជាបានចំនួន **១០០%** និងបាតុកម្មចំនួន**៣សហគ្រាស** ស្មើនឹង**៣ករណី** ដោះស្រាយសះជាបានចំនួន **១០០%**

ឃ-ការងារពង្រីកទីផ្សារការងារនៅក្រៅប្រទេសនិងការការពារផលប្រយោជន៍ពលករខ្មែរនៅបរទេស ពង្រឹងយន្តការវេទិកាការងារ បង្កើនការប្រមូលផ្សព្វផ្សាយនិងបញ្ជ្រាបព័ត៌មានទីផ្សារការងារ

- ចុះឈ្មោះអ្នកស្វែងរកការងារសរុប**៣ ៨០៦នាក់**(ស្រី១៧៧៨នាក់) ជួយស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋតាមរយៈយន្តការផ្ទូផ្គង និងបញ្ជូនអ្នកស្វែងរកការងារទៅនិយោជកចំនួន**៥ ៤២២ដង/នាក់**(ស្រី២ ៣៣៣ដង/នាក់) និងបានរៀបចំវេទិកាការងារ ពិព័រណ៍ចល័តចំនួន**១៣ដង** អ្នកចូលរួមសរុបចំនួន**៤ ៩១០នាក់**(ស្រី២ ៨៧២នាក់) និងបានចុះផ្តល់សេវាការងារ ព័ត៌មានទីផ្សារការងារតាមរយៈមជ្ឈមណ្ឌលការងារដែលមានស្រាប់ និងមជ្ឈមណ្ឌលការងារចល័តនៅតាមមូលដ្ឋានចំនួន**៣៦ដង** អ្នកចូលរួមសរុបចំនួន**១ ០៤៦នាក់**(ស្រី៦០៩នាក់)

- ផ្តល់សៀវភៅការងារនិងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរសរុបចំនួន**១៧ ៥៧៧នាក់**(ស្រី១០ ៣៤៤នាក់) ប្តូរសៀវភៅការងារពីទម្រង់ចាស់មកថ្មីចំនួន**៣០នាក់**(ស្រី១៥នាក់) បច្ចុប្បន្នកម្មទិដ្ឋាការចូលចំនួន**១២ ៣១១នាក់**(ស្រី៨ ៥៨១នាក់) និងទិដ្ឋាការចេញចំនួន**១៦ ៨៧៥នាក់**(ស្រី១១ ០៨១នាក់)

- ផ្តល់បណ្ណឬសៀវភៅការងារថ្មីដល់ហត្ថពលកម្មជនបរទេសចំនួន**៥ ៧៩១នាក់**(ស្រី១ ២៦៦នាក់) ពន្យារសុពលភាពបណ្ណឬសៀវភៅការងារដល់ហត្ថពលកម្មជនបរទេសចំនួន**៣៦ ៣៦២នាក់**(ស្រី៨ ៤៧២នាក់) ចេញលិខិតអនុញ្ញាតប្រើប្រាស់ហត្ថាពលកម្មបរទេស(កូតា) ចំនួន៨៤៥ក្រុមហ៊ុន និងចុះបញ្ជីលើកិច្ចសន្យាការងារឯកជនបរទេសចំនួន**៩ ១៣៩នាក់**(ស្រី២ ៦៩៨នាក់)។

ង- ការងារលើកកម្ពស់សុវត្ថិភាពនិងសុខភាពការងារ

- បានផ្តល់សេវាពិនិត្យកាយសម្បទាជូនកម្មករនិយោជិតខ្មែរនិងជនបរទេស តាមរយៈនាយកដ្ឋានពេទ្យការងារផ្ទាល់ ការចុះពិនិត្យកាយសម្បទានៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ និងមន្ទីរពេទ្យជាដៃគូសរុបចំនួន**៧៧ ៥២២នាក់**(ស្រី៣៧ ៣៤០នាក់) និងបានពិនិត្យសុខភាពពលករខ្មែរ ដែលទៅធ្វើការនៅប្រទេសជប៉ុនចំនួន៩នាក់(ស្រី៤នាក់)

- បានពង្រីកសេវាពិនិត្យកាយសម្បទា ដោយបានចុះកិច្ចព្រមព្រៀងរវាងមូលដ្ឋានសុខាភិបាលឯកជនជាដៃគូជាមួយនាយកដ្ឋានពេទ្យការងារ ដែលបច្ចុប្បន្នកម្មមានចំនួន**១៥៥មន្ទីរពេទ្យ** ក្នុងនោះ រាជធានីភ្នំពេញចំនួន**៦០មន្ទីរពេទ្យ** និងថ្នាក់ខេត្តចំនួន**៩៥មន្ទីរពេទ្យ**។

**២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖

- សហគ្រាសធុនតូច មធ្យម និងសិប្បកម្មបង្កើតថ្មីចំនួន**១០៩មូលដ្ឋាន** បើធៀបនឹងខែដូចគ្នាឆ្នាំមុន៩៥មូលដ្ឋាន កើនឡើង**១៤មូលដ្ឋាន** ស្មើនឹង**១៤,៧៣%** ក្នុងនោះ ផ្នែកអាហារ កេសជ្ជៈ និងបារី **៥៦មូលដ្ឋាន** ផ្នែកឧស្សាហកម្មតម្បាញ កាត់ដេរ**១០មូលដ្ឋាន** ផ្នែកឧស្សាហកម្មគីមី កៅស៊ូ និងប្លាស្ទិក **២៨មូលដ្ឋាន** ផ្នែកផលិតកម្មពីរ៉ែមិនមែនលោហៈ**២មូលដ្ឋាន** ផ្នែកឧស្សាហកម្មកែច្នៃលោហៈ**៨មូលដ្ឋាន** ផ្នែកគ្រឿងសង្ហារិម**៤មូលដ្ឋាន** និងផ្នែកក្រដាស ផលិតផលពីក្រដាស និងបោះពុម្ពផ្សេងៗ លើកលែងសម្លៀកបំពាក់**១មូលដ្ឋាន** និងបង្កើតការងារថ្មីឱ្យពលករសរុប**២ ០១៧នាក់** បើធៀបនឹងខែដូចគ្នាឆ្នាំមុន **១ ៤១៧នាក់** កើនឡើង៦០០នាក់ ស្មើនឹង៤២,៣៤%។

- គិតត្រឹមដំណាច់ខែមករា ឆ្នាំ២០២៦នេះ មានសហគ្រាសធុនតូច មធ្យម និងសិប្បកម្មសរុប **៤៤ ៨៩៨មូលដ្ឋាន** និងពលកម្មសរុប**៤៩៣ ៩៣២នាក់**។ សហគ្រាសធុនតូច មធ្យម និងសិប្បកម្មបិទទ្វារ **៦មូលដ្ឋាន** និងប៉ះពាល់កម្លាំងពលកម្ម**២១៦នាក់**។

- គិតត្រឹមខែមករា ឆ្នាំ២០២៦ នេះចំនួនអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលបានចុះឈ្មោះផ្លូវការក្នុងប្រព័ន្ធសរុបចំនួន**២៨៥ ៨០៦សំណើ**។ នៅក្នុងខែមករានេះ ក្រសួងទទួលបានសំណើរសុំចុះឈ្មោះចំនួន **២៦ ១៤១សំណើ** កើនឡើងប្រមាណ**៨៣៦,៥%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន ចុះឈ្មោះចំនួន**៣ ១២៥**។

**៣- ការពង្រឹងភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន**

**១- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖**

**គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា** បានទទួលដោះស្រាយសំណើសុំនាំចូលសម្ភារៈបរិក្ខារដោយការបង់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋ សម្រាប់អនុវត្តគម្រោងជាជំនួយទ្វេភាគី ពហុភាគី និងជំនួយអង្គការមិនមែនរដ្ឋាភិបាលសរុប**៧០សំណើ** មានទឹកប្រាក់សរុប**៤ ៧២០ ០៤០,៦២ដុល្លារអាមេរិក** ក្នុងនោះ ជំនួយទ្វេភាគីចំនួន**៤០សំណើ** ទឹកប្រាក់សរុប**២ ៨៩៥ ៥៧៣,៨០ដុល្លារអាមេរិក** ជំនួយពហុភាគីចំនួន**១១សំណើ** ទឹកប្រាក់សរុប**១ ១២៤ ៩៣៥,៨២ដុល្លារអាមេរិក** និងជំនួយអង្គការមិនមែនរដ្ឋាភិបាលចំនួន**១៩សំណើ** ទឹកប្រាក់សរុប**៦៩៩ ៥៣៥ដុល្លារអាមេរិក**។

**២- ក្រសួងពាណិជ្ជកម្ម៖**

- បានបង្កើតបង្គោមអាជីវកម្មនៃក្រុមអ្នកផលិត និងពិនិត្យលើតម្រូវការមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ ក្រោមគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច(AIMS) នៅខេត្តកែប កំពត និងខេត្តតាកែវ

- ស្ថិតិផ្សារសរុបនៅទូទាំងរាជធានី ខេត្តក្នុងប្រទេសកម្ពុជាមានចំនួន**២ ៣១១**

- សម្របសម្រួលជាមួយក្រុមហ៊ុនVINAFOOD 1 ក្នុងការចុះកិច្ចព្រមព្រៀងទិញ លក់ ជំឡូងមីស្ងួតជាមួយកម្ពុជាចំនួន**៥០០ ០០០តោន** ក្នុង១ឆ្នាំ

- បានរៀបចំសភាពាណិជ្ជកម្មរាជធានី-ខេត្ត

| លរ | សភាពាណិជ្ជកម្ម | អាណត្តិបច្ចុប្បន្ន | កាលបរិច្ឆេទផុតអាណត្តិ |
|---|---|---|---|
| ១ | ប៉ៃលិន | អាណត្តិទី១ លើកទី១ | ៤ មីនា ២០២៣ |
| ២ | ពោធិ៍សាត់ | អាណត្តិទី៣ លើកទី១ | ២៧ ធ្នូ ២០២៥ |
| ៣ | បាត់ដំបង | អាណត្តិទី១ លើកទី២ | ៤ មករា ២០២៦ |
| ៤ | រាជធានីភ្នំពេញ | អាណត្តិទី៥ លើកទី២ | ១១ មករា ២០២៦ |
| ៥ | សភាពាណិជ្ជកម្មកម្ពុជា | អាណត្តិទី៥ | ១១ មករា ២០២៦ |
| ៦ | ព្រះសីហនុ | អាណត្តិទី៣ លើកទី១ | ២៥ មីនា ២០២៦ |
| ៧ | ត្បូងឃ្មុំ | អាណត្តិទី១ លើកទី១ | ២៩ មីនា ២០២៦ |
| ៨ | កោះកុង | អាណត្តិទី៣ លើកទី១ | ៩ មេសា ២០២៦ |
| ៩ | តាកែវ | អាណត្តិទី១ លើកទី២ | ១៩ មេសា ២០២៦ |
| ១០ | ព្រៃវែង | អាណត្តិទី២ លើកទី២ | ២៥ មេសា ២០២៦ |
| ១១ | កំពង់ស្ពឺ | អាណត្តិទី៣ លើកទី១ | ២៨ មេសា ២០២៦ |
| ១២ | ស្វាយរៀង | អាណត្តិទី២ លើកទី១ | ១៧ ឧសភា ២០២៦ |

| | | |
|---|---|---|
| ១ | កំពត | (មិនទាន់បានបោះឆ្នោតអាណត្តិថ្មី) |
| ២ | កែប | (មិនទាន់បានបោះឆ្នោតអាណត្តិថ្មី) |
| ៣ | ក្រចេះ | (មិនទាន់បានបោះឆ្នោតអាណត្តិថ្មី) |
| ៤ | ស្ទឹងត្រែង | (មិនទាន់បានបោះឆ្នោតអាណត្តិថ្មី) |
| ៥ | កណ្ដាល | (មិនទាន់បានបោះឆ្នោតអាណត្តិថ្មី) |
| ៦ | កំពង់ឆ្នាំង | (មិនទាន់បានបោះឆ្នោតអាណត្តិថ្មី) |
| ៧ | កំពង់ធំ | (មិនទាន់បានបោះឆ្នោតអាណត្តិថ្មី) |
| ៨ | ព្រះវិហារ | (មិនទាន់បានបោះឆ្នោតអាណត្តិថ្មី) |
| ៩ | សៀមរាប | (មិនទាន់បានបោះឆ្នោតអាណត្តិថ្មី) |
| ១០ | ឧត្ដរមានជ័យ | (មិនទាន់បានបោះឆ្នោតអាណត្តិថ្មី) |

- បានរៀបចំការិយាល័យតំណាងសភាពាណិជ្ជកម្មនៅក្រៅប្រទេស

| ល.រ | ការិយាល័យតំណាង | អាណត្តិ | កាលបរិច្ឆេទបោះឆ្នោត | កាលបរិច្ឆេទ ផុតអាណត្តិ |
|---|---|---|---|---|
| 1 | តូរ៉ុនតូ ខេត្តអុនតារីយ៉ូ កាណាដា | អាណត្តិទី១ លើកទី១ | ២៨ ឧសភា ២០២២ | ២៨ ឧសភា ២០២៥ |
| 2 | តំបន់សេនដៃ ជប៉ុន | អាណត្តិទី១ លើកទី១ | ២៤ កុម្ភៈ ២០២៣ | ២៤ កុម្ភៈ ២០២៦ |
| 3 | ស៊ីដនី អូស្ត្រាលី | អាណត្តិទី១ លើកទី១ | ៧ ឧសភា ២០២៣ | ៧ ឧសភា ២០២៦ |
| 4 | មែលបន អូស្រាលី | អាណត្តិទី១ លើកទី១ | ៦ ឧសភា ២០២៣ | ៦ ឧសភា ២០២៦ |
| 5 | ម៉ុងរ៉េអាល់ ខេត្តកេបិច កាណាដា | អាណត្តិទី១ លើកទី១ | ៦ វិច្ឆិកា ២០២៣ | ៦ វិច្ឆិកា ២០២៦ |
| 6 | ប្រចាំរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក | អាណត្តិទី១ លើកទី១ | ៨ វិច្ឆិកា ២០២៣ | ៨ វិច្ឆិកា ២០២៦ |
| 7 | ភើត អូស្ត្រាលី | អាណត្តិទី១ លើកទី១ | មិនទាន់រៀបចំបោះឆ្នោត | មិនទាន់រៀបចំបោះឆ្នោត |
| 8 | ហ្វ្លរិនស៍ អ៊ីតាលី | អាណត្តិទី១ លើកទី១ | មិនទាន់រៀបចំបោះឆ្នោត | មិនទាន់រៀបចំបោះឆ្នោត |

## ៤- ការពង្រឹងការប្រកួតប្រជែង

### ក- ការងាររៀបចំនិងការដាក់ចេញយន្តការការពារសិទ្ធិអ្នកប្រើប្រាស់

**ក្រសួងពាណិជ្ជកម្ម៖**

- ចុះត្រួតពិនិត្យគុណភាព សុវត្ថិភាពទំនិញ និងម្ហូបអាហារនៅតាមទីផ្សារបានចំនួន៤៦លើក ស្មើនឹង**៣១៨ទីតាំង** បានដកហូតទំនិញដែលមិនមានអនុលោមភាពសរុបចំនួន៤៣១គ.ក្រ.

- សហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះត្រួតពិនិត្យទីតាំងផលិតមី**១ទីតាំង** នៅសាខាខេត្ត

កណ្តាល រកឃើញផលិតផលមីទាំងនោះ បានប្រើប្រាស់ស្លាកសញ្ញាហាឡាលកម្ពុជា ដោយពុំមានវិញ្ញាបនបត្រទទួលស្គាល់។ សហការជាមួយនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច និងអាជ្ញាធរមូលដ្ឋានខេត្តកណ្តាល ចុះត្រួតពិនិត្យសិប្បកម្មផលិតស្រាស **១ទីតាំង** រកឃើញសិប្បកម្មនេះ ពុំបានសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្មនោះទេ។ សហការជាមួយអាជ្ញាធរពាក់ព័ន្ធ និងតំណាងក្រុមហ៊ុនNABATI FOOD CAMBODIA CO., LTD បានកិនបំបែក ដុត និងកាយកប់ក្នុងរណ្តៅដី លើផលិតផលប្រភេទនំ-មីដែលហួសកាលបរិច្ឆេទប្រើប្រាស់ ខូចគុណភាព គ្មានសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ចំនួន **១០ ៧៤៨កេស ស្មើនឹង៣៦តោន និង៥៩៤គ.ក្រ.**។ សហការជាមួយអាជ្ញាធរពាក់ព័ន្ធរៀបចំពិធីកម្ទេចចោលផលិតផលខូចគុណភាពចំនួន **៣៩៧,៤៨គ.ក្រ.** ក្នុងឆ្នាំ២០២៥ នៅទីលានចាក់សំរាមខេត្តព្រះសីហនុ។

- សហការជាមួយនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច និងមន្ទីរសុខាភិបាល ចូលរួមត្រួតពិនិត្យផលិតផលថ្នាំដុសធ្មេញColgate និងSogate ចំនួន **២ទីតាំង** នៅខណ្ឌច្បារអំពៅ និងខណ្ឌពោធិ៍សែនជ័យ ដោយបានរកឃើញថា ជាថ្នាំដុសធ្មេញក្លែងក្លាយ

- ត្រួតពិនិត្យនិងតាមដានតម្លៃថ្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ/ដេប៉ូប្រេងបានចំនួន **២ ៤០៨លើក**

- បិទផ្ទាំងរូបភាពផ្សព្វផ្សាយ អំពីរបៀបពិនិត្យស្លាកសញ្ញាផលិតផលម្ហូបអាហារដែលមានសុវត្ថិភាពនៅតាមទីផ្សារ និងទីសាធារណៈចំនួន **២ ១២៦ផ្ទាំង**។ ចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការប្រើប្រាស់ស្លាកសញ្ញាហាឡាលមិនត្រឹមត្រូវ(មិនអនុលោម) តាមលិខិតបទដ្ឋានគតិយុត្ត នៅតាមភោជនីយដ្ឋានអាហារដ្ឋាន និងតូបលក់អាហារបាន **៨៥សន្លឹក**។

**ខ- ការងារត្រួតពិនិត្យស្តង់ដា គុណភាព សុវត្ថិភាព និងផលិតផលទំនិញ**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖**

**ការងារមាត្រាសាស្ត្រជាតិ**

- ចេញព្យាសកម្មឧបករណ៍មាត្រាសាស្ត្រ **៧៤គ្រឿង**

- ចេញវិញ្ញាបនបត្រព្យាសកម្ម **៧៦ច្បាប់** ស្តង់ដាប្រតិបត្តិ **៨ច្បាប់** និងចុះបញ្ជីមាត្រាសាស្ត្រថ្មី **២៩មូលដ្ឋាននិងពន្យារ៣០មូលដ្ឋាន**។

- មន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានអភិវឌ្ឍខ្លួនជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយផ្តោតលើការធានាគុណភាពតេស្តវិភាគឱ្យមានសុក្រឹតភាព ទំនុកចិត្ត និងស្តង់ដាអន្តរជាតិ។ កន្លងមក ស្ថាប័នបានពង្រីកវិសាលភាពបន្ថែមប៉ារ៉ាម៉ែត្រថ្មី និងបច្ចុប្បន្នមានប៉ារ៉ាម៉ែត្រសរុបចំនួន **២០២** ព្រមទាំងបានពង្រឹងសមត្ថភាពអនុលោមភាពតាមរយៈISO/IEC 17025)។ ពង្រឹងសមត្ថភាពអនុលោមភាពតាមរយៈISO/IEC 17025)។ ជាមួយនេះ បានផ្តល់សេវាវិភាគលើគំរូសំណាក **៨៧៦** និងប៉ារ៉ាម៉ែត្រ **៣,៣២៦** ដំឡើងឧបករណ៍ទំនើបGC-MSMS , Spectrophotometer, Viscoticy និងធានាការព្យាសកម្មឧបករណ៍តាមស្តង់ដារ។ ក៏បានបណ្តុះបណ្តាលបច្ចេកទេសជាមួយដៃគូអន្តរជាតិ បន្តអភិវឌ្ឍមន្ទីរពិសោធន៍វិស័យមេកានិក អគ្គិសនី និងអេឡិចត្រូនិក ព្រមទាំងជំរុញកម្មវិធីវ័យក្មេង។ បន្ថែមពីនេះ បានបង្កើតគេហទំព័រ ផ្តល់វិញ្ញាបនបត្រឌីជីថលមានQR Code និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ ដើម្បីលើកកម្ពស់សមត្ថភាពតេស្តវិភាគ។

**គ- ការងារចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយ**

**ក្រសួងរ៉ែនិងថាមពល** ចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយសរុប៣៦។

## ៥- ការពង្រឹងប្រព័ន្ធធនាគារនិងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖

**ក- ការងារជានាវ៉ាប់រង**

- គ្រប់គ្រងការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងនិងសោធននឯកជន និងកិច្ចការគតិយុត្តបានចំនួន**៧ក្រុមហ៊ុន**

- ការគ្រប់គ្រងការអភិវឌ្ឍទីផ្សារធានារ៉ាប់រងនិសោធននឯកជនបានចំនួន**៥ក្រុមហ៊ុន**។

**ខ- ការងារអាជីវកម្មអចលនទ្រព្យនិងបញ្ចាំ**

- ផ្តល់និងបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន និងអគារសហកម្មសិទ្ធិ និងការផ្លាស់ប្តូរផ្សេងៗចំនួន**១៨គម្រោង**

- ផ្តល់អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍន៍ដីឡូត៍បានចំនួន**១គម្រោង**

- ផ្តល់និងបន្តសុពលភាពអាជ្ញាបណ្ណ វិញ្ញាបនបត្រវិជ្ជាជីវៈក្រុមហ៊ុន សេវាកម្មវាយតម្លៃ និងអចលនវត្ថុ និងការផ្លាស់ប្តូរផ្សេងៗចំនួន**១៤ក្រុមហ៊ុន**

- ផ្តល់និងបន្តអាជ្ញាបណ្ណអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទានសរុប**៣៤ក្រុមហ៊ុន/សហគ្រាស**

- ចុះត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍលំនៅឋាន និងអគារសហកម្មសិទ្ធិ អាជីវកម្មសេវាកម្មវាយតម្លៃនិងភ្នាក់ងារអចលនវត្ថុ អាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន បាន**១៥ក្រុមហ៊ុន/សហគ្រាស**។

**គ- ការងារបរធនបាលកិច្ច**

- បានពិនិត្យនិងផ្តល់ (១) អាជ្ញាបណ្ណបរធនបាលរូបវន្តបុគ្គល**២ករណី** ត្រឹមខែមករា ឆ្នាំ២០២៦ ចំនួន**៤៨ករណី** (២) ការបញ្ចប់បរធនបាលកិច្ចចំនួន**២ករណី** (៣) ការបន្តអាជ្ញាបណ្ណប្រតិបត្តិករបរធនបាល**១ករណី** (៤) ការចុះបញ្ជីបរធនបាលកិច្ចចំនួន**៤៨ករណី** (៥) ការបញ្ចប់បរធនបាលកិច្ចចំនួន**១៤ករណី** និង(៦) ការបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីចំនួន**១០ករណី**

- បានចុះត្រួតពិនិត្យដល់ទីកន្លែងលើប្រតិបត្តិការបរធនបាលកិច្ចចំនួន**១លើក** ចុះត្រួតពិនិត្យដល់ទីកន្លែងការស្នើសុំបន្តអាជ្ញាបណ្ណចំនួន**២ករណី** និងចុះត្រួតពិនិត្យដល់ទីកន្លែងលើការស្នើសុំផ្លាស់ប្តូរទីស្នាក់ការក្រុមហ៊ុនសវនកម្មចំនួន**១លើក**។

## បញ្ហាគោលយុទ្ធសាស្ត្រទី៤
## «ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន»

### ១- ការធ្វើបរមភាវូបនីយកម្មផលលាភប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ

ក- ការងារសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យនិងក្មេង និងការអនុវត្តកម្មវិធីគាំពារសង្គមនិងការលើកកម្ពស់អាហារូបត្ថម្ភនៃគ្រួសារក្រីក្រ ស្ត្រីមានផ្ទៃពោះនិងកុមារ

ក.១- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖

កម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ បានទទួលយុវជនចូលមកសិក្សាចំនួន២ ៨៥២នាក់ ដែលចំណាយថវិកាសរុប៤៨៣ ៨០២ ០០០រៀល។

រាជរដ្ឋាភិបាល បានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារគោលដែលបានចុះឈ្មោះក្នុងកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសាររួមមាន៖

| ល.រ | ប្រភេទអ្នកទទួលផល | **ទិន្នន័យថ្មី** | **ចំនួនការអនុវត្តលក្ខខណ្ឌ** | **ថវិកាចំណាយ(៛)** |
|---|---|---|---|---|
| ១ | គ្រួសារគោល | ៧១២ ២៩៦ | - | ២៤ ២១៨ ០៦៤ ០០០ |
| | ជនចាស់ជរា | ៣៧៤ ៧៥៩ | - | ១ ៦៤៩ ៧៣២ ០០០ |
| | ជនពិការ | ៥៨ ៩១៩ | - | ១០ ៤៩៣ ២៥២ ០០០ |
| | អ្នកផ្ទុកមេរោគ/ជំងឺអេដស៍ | ៦ ២២៩ | - | ១៧៤ ៤១២ ០០០ |
| | សិស្សានុសិស្ស | ៣៩០ ៦៨១ | - | ៨ ០១៥ ៧៨០ ០០០ |
| ២ | ស្ត្រីមានផ្ទៃពោះ | ៤ ១១៨ | ៩ ៦០៨ | ៧៦៨ ៦៤០ ០០០ |
| | សម្រាល | ៣ ៤២៣ | | ១ ៣៧៥ ៤០០ ០០០ |
| ៣ | កុមារអាយុ០-២ឆ្នាំ | ១៧ ០៦៧ | ២៨ ៤២៦ | ២ ២៧៤ ០៨០ ០០០ |
| | | | សរុប | ៤៨ ៩៦៩ ៣៦០ ០០០ |

ក.២- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់របស់រាជរដ្ឋាភិបាល សម្រាប់សមាជិកប.ស.ស. ជាស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ។ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិកប.ស.ស. ចំនួន**៣២ ៧៣១នាក់** ជាស្ត្រីមានផ្ទៃពោះ និងចំនួន**៣៩ ៧១៦នាក់** ជាកុមារអាយុក្រោម២ឆ្នាំ ព្រមទាំងបានចំណាយថវិកាប្រមាណ**៩ ៩៩៥លានរៀល**។ បើគិតត្រឹមខែមករា ឆ្នាំ២០២៦នេះ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិកប.ស.ស. ចំនួន**៧២៩ ៤៨២នាក់** ជាស្ត្រីមានផ្ទៃពោះ និងចំនួន**៧៧១ ៨៣៩នាក់** ជាកុមារអាយុក្រោម២ឆ្នាំ ព្រមទាំងបានចំណាយថវិកាសរុបប្រមាណ**៤១៩ ៩៥៩លានរៀល**។

### ការបើកប្រាក់ឧបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម២ឆ្នាំ

| បរិយាយ | ឯកតា | ខែមករា ឆ្នាំ២០២៥ | ខែមករា ឆ្នាំ២០២៦ | កំណើន | ថយចុះ |
|---|---|---|---|---|---|
| ម្តាយ | នាក់ | ៣១ ១៦៥ | ៣២ ៧៣១ | ១ ៥៦៦ | - |
| កូន | នាក់ | ៣៥ ៩៥៥ | ៣៩ ៧១៦ | ៣ ៧៦១ | - |
| ប្រាក់ឧបត្ថម្ភ | លានរៀល | ៩ ២៩៧ | ៩ ៩៩៥ | ៦៩៨ | - |

ប្រភព៖ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្គាល់៖ ទិន្នន័យស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ គឺជាទិន្នន័យកំណត់ID។

**ខ- ការងារគោលនយោបាយជាតិប្រជាជន**

**ក្រសួងផែនការ៖**

- ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ លទ្ធផលក្នុងការអនុវត្តកម្មវិធីអត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅរាជធានី ខេត្តទាំង២៥ មានគ្រួសារក្រីក្រកម្រិត១ ចំនួន**៣ ៧០៦គ្រួសារ** គ្រួសារក្រីក្រកម្រិត២ ចំនួន**១៧ ០៥១គ្រួសារ** និងគ្រួសារងាយរងហានិភ័យមានចំនួន**១២ ៤២៥គ្រួសារ**
- **ការងារលើកកម្ពស់អាហារូបត្ថម្ភ** យោងរបាយការណ៍របស់អនុគណៈកម្មការជាតិលុបបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូដនៅកម្ពុជា និងអនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនៅកម្ពុជា នៃក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ បានសហការនិងជំរុញការផលិតអាហារបញ្ចូលមីក្រូសារជាតិ ដែលអំបិលអ៊ីយ៉ូដម៉ត់ផលិតបានចំនួន**៩៧៩តោន** និងអង្ករបញ្ចូលមីក្រូសារជាតិ(វីតាមីនA, B1, B3, B6, B12, Folic Acid, Iron Zinc) បានចំនួន**១៤២តោន** ផ្តល់ឱ្យសិស្សចំនួន**៨០ ០៣២នាក់** នៅខេត្តសៀមរាប កំពង់ធំ និងខេត្តពោធិ៍សាត់។

**គ- ការងារពង្រឹងសមភាពយេនឌ័រ**

**១- ក្រសួងកិច្ចការនារី៖**

- បើកវេទិកាស្តីពីយេនឌ័រ និងសុខភាពភ្នែកចំនួន**២លើក** ដល់ប្រជាពលរដ្ឋចំនួន**៥២៩នាក់**(ស្ត្រី៣២៩នាក់) ក្នុងនោះ អ្នកមានពិការភាពចំនួន៦នាក់(ស្ត្រី៤នាក់) បានទទួលវ៉ែនតាចំនួន**២៩៥នាក់**(ស្ត្រី១៧៦នាក់) និងបានចេញលិខិតបញ្ជូនអ្នកមានបញ្ហាភ្នែកចំនួន**៤៩នាក់**(ស្ត្រី៣២នាក់) ទៅទទួលសេវាវះកាត់បាយភ្នែក កន្ទុយថ្លែនភ្នែក និងជំងឺភ្នែកផ្សេងទៀត នៅមូលដ្ឋានសុខាភិបាល ដោយឥតគិតថ្លៃ នៅខេត្តព្រះសីហនុ និងខេត្តកណ្តាល គាំទ្រដោយមូលនិធិហ្វ្រេដហូឡូ(FHF)
- បានផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ ដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ចំនួន**២ករណី**
- សម្របសម្រួល និងផ្តល់សេវាជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ សរុបចំនួន**១៩ករណី** ក្នុងនោះ អំពើហិង្សាក្នុងគ្រួសារចំនួន**៧ករណី** និងការរំលោភបំពានផ្លូវភេទលើស្ត្រីនិងក្មេងស្រ្តីចំនួន**១២ករណី** ដែលកើតឡើងនៅខេត្តកណ្តាល កំពង់ស្ពឺ ពោធិ៍សាត់ កំពង់ចាម សៀមរាប ព្រះវិហារ ក្រចេះ ព្រៃវែង និងខេត្តព្រះសីហនុ។ ទន្ទឹមនេះ ជនល្មើសដែលពាក់ព័ន្ធនឹងករណីរំលោភបំពានផ្លូវភេទចំនួន**១២នាក់** ត្រូវបានសមត្ថកិច្ចចាប់ខ្លួន កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត។

**២- ក្រសួងមហាផ្ទៃ៖** បានសម្រេចតែងតាំងមុខតំណែង ផ្ទេរភារកិច្ច ប្រគល់ភារកិច្ច និងផ្លាស់ប្តូរកន្លែងធ្វើការមន្ត្រីពន្ធនាគារសរុប**១០នាក់** និងមន្ត្រីនគរបាលជាតិចំនួន**១៧នាក់**។

## ២- ការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ ប្រកបដោយចីរភាព

### ២.១- ការងារធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖

ក- ការងារកែទម្រង់ព្រៃឈើ

**ក.១- ការដាំដើមឈើ** បានកំពុងថែទាំចម្ការឈើចាស់លើផ្ទៃដីសរុបទំហំ**៧២៥ហ.ត.** ក្នុងនោះមានចម្ការឈើដាំថ្មី ចម្ការពូជក្នុងស្រុក ចម្ការឡូត៍បង្ហាញកសិរុក្ខកម្ម និងចម្ការរុក្ខទិវា ស្ថិតនៅក្នុងខេត្តកំពង់ធំ កំពង់ឆ្នាំង តាកែវ ពោធិ៍សាត់ កំពង់ចាម និងខេត្តបាត់ដំបង និងថែទាំកូនឈើនៅក្នុងថ្នាល ព្រមទាំងបានបណ្ដុះកូនផ្កាស្បៃរឿងចំនួន**៣ ០០០ដើម** ស្ថិតនៅថ្នាលវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ-សត្វព្រៃ។

**ក.២- ការងារចិញ្ចឹមសត្វព្រៃ** បានទទួលសង្គ្រោះសត្វថ្មីចំនួន**៣១ក្បាល** និងព្យាបាលសត្វព្រៃចំនួន**៥០ក្បាល**។ គិតត្រឹមខែមករា ឆ្នាំ២០២៦ ឧទ្យានសួនសត្វព្រៃការពារ និងសួនកូតគាម «ភ្នំតាម៉ៅ» បានចិញ្ចឹមថែរក្សា និងព្យាបាលសត្វព្រៃសរុបចំនួន**២ ២១៣ក្បាល**។ ដោយឡែក សត្វព្រៃកំពុងចិញ្ចឹមថែរក្សាក្នុងស្តុក មានចំនួនសរុប**២ ២០៥ក្បាល**។

**ក.៣- លទ្ធផលនៃការបង្ក្រាបបទល្មើសព្រៃឈើ**

- កសាងសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលពីរដ្ឋបាលព្រៃឈើ **៦ករណី** ក្នុងនោះ សំណុំរឿងបទល្មើសព្រៃឈើត្រូវបញ្ជូនទៅតុលាការ**៥ករណី** សំណុំរឿងនិងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍**១ករណី**
- ចាប់ឃាត់និងដកហូត រួមមាន ឈើអារចំនួន**៣ម³** ធ្យូង**២ ០០០គ.ក្រ.** ផ្ទៃដីព្រៃឈើដែលបានកាប់រានទំហំ**៨ហ.ត.** ព្រមទាំងឧបករណ៍សម្ភារៈផ្សេងៗមួយចំនួនទៀត។

ខ- ការងារថែរក្សាប្រព័ន្ធអេកូឡូស៊ី ការការពារជីវៈចម្រុះ និងការការពារតំបន់ធម្មជាតិ

ក្រសួងបរិស្ថាន៖

**ខ.១- ការអភិរក្សធនធានជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព**

មន្ត្រីឧទ្យានុរក្ស បានចុះល្បាតជាប្រចាំក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានចំនួន**១ ០៩១លើក** និងបានបង្ក្រាបបទល្មើសធនធានធម្មជាតិបានចំនួន**១៣៨ករណី** មានជាអាទិ៍ បទល្មើសព្រៃឈើចំនួន**៤៨ករណី** បទល្មើសសត្វព្រៃចំនួន**៤២ករណី** បទល្មើសរុករានទន្ទ្រានដីរដ្ឋចំនួន**២៧ករណី** បទល្មើសនេសាទចំនួន**១៨ករណី** និងបទល្មើសធនធានរ៉ែចំនួន**៣ករណី**។

**ខ.២- ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ**

សហគមន៍ទេសចរណ៍ចំនួន**៣៨** ក្នុងចំណោមសហគមន៍ទាំង**៥៣** បាននិងកំពុងផ្ដល់សេវាកម្មដោយទទួលបានភ្ញៀវទេសចរជាតិចំនួន**២១ ៩៣៩នាក់** និងទេសចរអន្តរជាតិចំនួន**១ ០៦៩នាក់** ដោយសហគមន៍បានទទួលចំណូលជាថវិកាសរុប**២១ ៨៦៦ដុល្លារអាម៉េរិក** ពីការផ្ដល់សេវាកម្មនានា ដូចជា ការលក់សំបុត្រចូលទស្សនា ចំណត អាហារ ការស្នាក់នៅ និងមគ្គុទេសក៍ទេសចរណ៍។

**គ- ការងារការពារសម្បត្តិវប្បធម៌ ការអភិរក្ស និងការអភិវឌ្ឍតំបន់រមណីយដ្ឋានវប្បធម៌**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ៖**

បន្តរៀបចំស្រាវជ្រាវនិងរៀបចំឯកសារដើម្បីស្នើសុំចុះបញ្ជី **«ពិធីអាពាហ៍ពិពាហ៍ប្រពៃណីខ្មែរ» «មហាសង្រ្កាន្ត»** និង **«នំបញ្ចុក»** ទៅក្នុងបញ្ជីបេតិកភណ្ឌអរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ។

**គ.១- ការងារជួសជុលនិងអភិរក្សសំណង់បេតិកភណ្ឌ**

- បន្តជួសជុល (១) ព្រះវិហារកោកណ្តាល ខេត្តក្រចេះ (២) អគារពុទ្ធិកវិទ្យាល័យ(បណ្ណាល័យ) វត្តសារាវ័នតេជោ រាជធានីភ្នំពេញ និង(៣) សម្ភារៈចំនួន២ គឺព្រះព្រហ្ម(N.2134) និងព្រះពុទ្ធចូលនិព្វាន (N.1717) នៅសារមន្ទីរជាតិអង្គរ។ ជួសជុលវត្ថុបុរាណចំនួន**៧វត្ថុ** នៅសារមន្ទីរជាតិ

- ចុះបញ្ជីសារពើភណ្ឌវត្ថុបុរាណក្រៅឃ្លាំងនៅទីតាំងដែលងាយរងការបំផ្លិចបំផ្លាញខ្លាំងនៅខេត្តកណ្តាល និងខេត្តតាកែវចំនួន**១៧០ដុំ/រូប** និងសិក្សាប្រមូលទិន្នន័យចងក្រងធ្វើបញ្ជីអំពីវត្ថុបុរាណខ្មែរដែលមានប្រភពនៅរមណីយដ្ឋានប្រាសាទកោះកេរ។ ទទួលវត្ថុបុរាណចំនួន**១០វត្ថុ/រូប**។

**គ.២- អាជ្ញាធរជាតិអប្សរា៖**

**រមណីយដ្ឋានអង្គរ៖**

- ជួសជុលនិងអភិរក្សផ្នែកនៃសំណង់បុរាណចំនួន**១៧ទីតាំង** និងបន្តធ្វើកំណាយស្រាវជ្រាវចំនួន**២ទីតាំង**

- បណ្តុះកូនឈើគ្រប់ប្រភេទបានចំនួន**៨ ៩១០ដើម**។ ដាំកូនឈើគ្រប់ប្រភេទក្នុងតំបន់ឧទ្យានអង្គរចំនួន**១ ២៤៥ដើម**។ កាត់ដកហូត និងកាត់សម្អាតដើមឈើដែលមានហានិភ័យនៅក្នុងឧទ្យានអង្គរចំនួន**៧១ដើម**

- ទទួលពាក្យស្នើសុំសាងសង់លំនៅឋាន(សំណើសុំថ្មី)ចំនួន**៤០៤ច្បាប់** អនុញ្ញាតសាងសង់លំនៅដ្ឋានចំនួន**៩ច្បាប់** និងចុះទប់ស្កាត់ការសាងសង់សំណង់ខុសច្បាប់ចំនួន**៥៦១ករណី**

- ទទួលវត្ថុបុរាណចំនួន**១០៥ដុំ/បំណែក/ផ្ទាំង**។

**រមណីយដ្ឋានវប្បធម៌នៅក្រៅតំបន់អង្គរ៖**

ការអភិរក្សក្រៅពីការជួសជុលនៅប្រាសាទបេងមាលា ប្រាសាទចៅស្រីវិបុល ប្រាសាទវត្តចេតិយ ប្រាសាទទ័ពជ័យ ស្ពានបុរាណព្រះទិស ស្ពានតាអោង រមណីយដ្ឋានក្បាលស្ពាន និងរមណីយដ្ឋានភ្នំគូលែន។

**គ.៣- អាជ្ញាធរជាតិព្រះវិហារ៖**

- បន្តចុះពិនិត្យវាយតម្លៃការខូចខាតប្រាសាទព្រះវិហារ ដែលបណ្តាលមកពីសកម្មភាពឈ្លានពានរបស់ថៃ ព្រមទាំងរៀបចំផែនការត្រៀមជួសជុលនិងអភិរក្ស

- បន្តចាត់វិធានការឆ្លើយតបចំពោះសកម្មភាពឈ្លានពានរបស់ថៃដែលធ្វើឱ្យប៉ះពាល់ដល់ប្រាសាទព្រះវិហារដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក ក្នុងទិដ្ឋភាពការទូត និងច្បាប់ រួមទាំងនៅលើវេទិកាអន្តរជាតិ

- ស្នើសុំមជ្ឈមណ្ឌលកម្ចាត់មីនកម្ពុជាបោសសម្អាតសំណល់អាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះចេញពីប្រាសាទព្រះវិហារ និងតំបន់ជុំវិញរមណីយដ្ឋានប្រាសាទព្រះវិហារទាំងមូលដើម្បីធានាសុវត្ថិភាពដល់មន្ត្រីបំពេញការងារ ភ្ញៀវទេសចរ និងប្រជាជននៅក្នុងតំបន់

- ត្រៀមស្តារហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ឡើងវិញ ដើម្បីបម្រើដល់ភ្ញៀវដែលមកទស្សនានាពេលអនាគត។ល។

- **រមណីយដ្ឋានប្រាសាទកោះកេរ** បន្តចុះទប់ស្កាត់និងហាមឃាត់សំណង់ខុសច្បាប់ក្នុងរមណីយដ្ឋានប្រាសាទកោះកេរ។ សិក្សាស្រាវជ្រាវ និងចងក្រងឯកសារលំនៅឋានខ្មែរ នៅរមណីយដ្ឋានប្រាសាទកោះកេរ(ដំណាក់កាលទី១)។

**គ.៤- អាជ្ញាធរជាតិសំបូរព្រៃគុក៖**

- បន្តអភិរក្សវត្ថុសិល្បៈនិងរៀបចំសាលពិព័រណ៍សំបូរព្រៃគុក។ ធ្វើកំណាយសម្អាតនៅខ្លោងទ្វារខាងក្រៅទិសខាងកើតS15 នៃក្រុមប្រាសាទយាយព័ន្ធ សម្រេចបាន**៥%** និងសិក្សា អភិរក្ស បង្ការ និងលើកតម្កើងក្រុមប្រាសាទបេងរមាស ក្រុមប្រាសាទស្រីគ្រប់ល័ក្ខណ៍ សម្រេចបាន**៩០%**

- ទទួលពាក្យស្នើសុំសាងសង់លំនៅដ្ឋានចំនួន**១៩ច្បាប់** ដោយមិនទាន់ឆ្លើយតប និងចុះទប់ស្កាត់ការសាងសង់សំណង់ខុសច្បាប់ចំនួន**១២ទីតាំង**។

**២.២- ការងារទេសចរណ៍ប្រកបដោយចីរភាព**

**ក- ការងារអាជ្ញាបណ្ណរមណីយដ្ឋានទេសចរណ៍ និងសេវាកម្មភ្នាក់ទេសចរណ៍ក្រសួងទេសចរណ៍**

អាជីវកម្មទេសចរណ៍បានស្នើសុំអាជ្ញាបណ្ណថ្មី និងបន្ត តាមប្រព័ន្ធអនឡាញរបស់ក្រសួងសរុបចំនួន**១០៥**អាជីវកម្ម(បន្ត**១០១** និងថ្មី**៤**) ថ្នាលបច្ចេកវិទ្យាព័ត៌មានCamDx សរុបចំនួន**៥៨អាជីវកម្ម** (បន្ត៤៤ និងថ្មី១៤) និងរមណីយដ្ឋានទេសចរណ៍សរុបចំនួន៨ (បន្ត៧ និងថ្មី១) រួមមាន៖

| ល.រ. | ប្រភេទអាជីកម្ម | ប្រព័ន្ធអនឡាញក្រសួង | | ប្រព័ន្ធថ្នាលCamDx | |
|---|---|---|---|---|---|
| | | ថ្មី | បន្ត | ថ្មី | បន្ត |
| ១ | សណ្ឋាគារ | | ៣៩ | ៣០ | ៨ |
| ២ | ភោជនីយដ្ឋាន | | ១៦ | ១៤ | ៤ |
| ៣ | ផ្ទះភ្ញៀវ | | ៣៥ | ១ | ១ |
| ៤ | ម៉ាស្សា-ស្ប៉ា | ៤ | ១១ | | |
| ៥ | ទេសចរណ៍ម៉ាយ(MICE) | | | ២ | |
| ៦ | កីឡាទេសចរណ៍ | ២ | | | |
| ៧ | រមណីយដ្ឋានទេសចរណ៍ | ១ | ៧ | | |
| ៨ | ចំណាត់ថ្នាក់សណ្ឋាគារ | ៣ | ៣ | | |
| ៩ | China Ready | ១ | ១ | | |

ខ- ការងារស្ថិតិភ្ញៀវទេសចរណ៍ចូលទស្សនារមណីយដ្ឋាននិងសារមន្ទីរនានា

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

**ខ.១- ស្ថិតិភ្ញៀវទេសចរអន្តរជាតិទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរសៀមរាប**

រមណីយដ្ឋានអង្គរលក់សំបុត្រជូនភ្ញៀវទេសចរអន្តរជាតិចូលទស្សនារមណីយដ្ឋានអង្គរសៀមរាបបានចំនួន៩៣ ៤៩១នាក់ បើធៀបនឹងខែដូចគ្នាឆ្នាំមុនមានចំនួន១៤៦ ១៤០នាក់ ថយចុះចំនួន៥២ ៦៤៩នាក់ ស្មើនឹង៣៦,០៣%។

**ខ.២- ស្ថិតិភ្ញៀវទេសចរចូលទស្សនារមណីយដ្ឋានប្រាសាទកោះកេរ**

បានទទួលភ្ញៀវចូលទស្សនាចំនួន៥ ៥៦៨នាក់(ភ្ញៀវអន្តរជាតិ២ ១៦១នាក់) បើធៀបនឹងខែដូចគ្នាឆ្នាំមុនមានចំនួន១៤ ៦១២នាក់ ថយចុះចំនួន៩ ០៤៤នាក់ ស្មើនឹង៦១,៨៩%។

**ខ.៣- ស្ថិតិភ្ញៀវទេសចរចូលទស្សនារមណីយដ្ឋានសំបូរព្រៃគុក**

បានទទួលភ្ញៀវចូលទស្សនាសរុបចំនួន៥ ៥០១នាក់(ភ្ញៀវអន្តរជាតិ២ ៦៧៣នាក់) បើធៀបនឹងខែដូចគ្នាឆ្នាំមុនមានចំនួន៦ ១៧១នាក់ ថយចុះចំនួន៦៧០នាក់ ស្មើនឹង១០,៨៦%។

**ខ.៤- ស្ថិតិភ្ញៀវទេសចរចូលទស្សនាសារមន្ទីរ និងមណ្ឌលវប្បធម៌**

- សារមន្ទីរជាតិរាជធានីភ្នំពេញមានភ្ញៀវចូលទស្សនាសរុប**២៧ ៩៥៥នាក់**(ភ្ញៀវអន្តរជាតិ**១៣ ០៩៣នាក់**) បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**៣១ ២១៥នាក់** ថយចុះ**៣ ២៦០នាក់** ស្មើនឹង**១០,៤៤%**
- សារមន្ទីរជាតិអង្គរមានភ្ញៀវចូលទស្សនាសរុប**១១ ៩២៥នាក់**(ភ្ញៀវអន្តរជាតិ**១០ ០៦១នាក់**) បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**១៨ ៩៩៧នាក់** ថយចុះ**៧ ០៧២នាក់** ស្មើនឹង**៣៧,២៣%**
- សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងមានភ្ញៀវចូលទស្សនាសរុប**៤៥ ១៨៧នាក់** (ភ្ញៀវអន្តរជាតិ**៣៣ ៩៧២នាក់**) បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**៥០ ៤៦៨នាក់** ថយចុះ**៥ ២៨១នាក់** ស្មើនឹង**១០,៤៦%**
- សារមន្ទីរជើងឯកមានភ្ញៀវចូលទស្សនាសរុប**១៧ ៥៥១នាក់**(ភ្ញៀវអន្តរជាតិ**១៤ ០៦២នាក់**) បើធៀបនឹងខែដូចគ្នាឆ្នាំមុនមានចំនួន**២២ ៤១៩នាក់** ថយចុះ**៤ ៨៦៨នាក់** ស្មើនឹង**២១,៧១%**
- មណ្ឌលវប្បធម៌វត្តភ្នំមានភ្ញៀវចូលទស្សនាចំនួន**៥៤ ៦០៤នាក់**(ភ្ញៀវអន្តរជាតិ**១២ ៦៨៩នាក់**) បើធៀបនឹងខែដូចគ្នាឆ្នាំមុនមានចំនួន**៤២ ៩៩៤នាក់** កើនឡើង**១១ ៦១០នាក់** ស្មើនឹង**២៧%**។

## ៣- ការលើកស្ទួយកសិកម្មនិងការអភិវឌ្ឍជនបទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖

ក- ការងារផលិតកម្មដំណាំស្រូវនិងដំណាំឧស្សាហកម្មរួមផ្សំ

**ក.១- ការបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០២៦**

ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន៧៦០ ៦៣៦ហ.ត. ស្មើនឹង១០៩,៣៨% នៃការព្យាករផ្ទៃដីដាំដុះចំនួន៦៩៥ ៤៣០ហ.ត. តិចជាងឆ្នាំមុនចំនួន១០៣ ៣៩៣ហ.ត.។

ក.២- ការបង្កបង្កើនផលដំណាំរួមផ្សំរដូវប្រាំង

- ផ្ទៃដីដាំដុះដំណាំស្បៀងរួមផ្សំ(ពោតស ដំឡូងផ្វា បន្លែគ្រប់មុខ ឪឡឹក និងដំណាំស្បៀងរួមផ្សំផ្សេងៗ) អនុវត្តចំនួន៣០ ០៥១ហ.ត. ស្មើនឹង៧០,៣១% នៃការព្យាករផ្ទៃដីដាំដុះចំនួន៤២ ៧៤០ហ.ត. លើសឆ្នាំមុនចំនួន៩៩៣ហ.ត.

- ផ្ទៃដីដាំដុះដំណាំទ្រទ្រង់សេដ្ឋកិច្ច(ពោតក្រហម ដំឡូងមី សណ្តែកបាយ សណ្តែកដី សណ្តែកសៀង ល្ង អំពៅ ឈូក ថ្នាំជក់ និងដំណាំផ្សេងៗ) អនុវត្តបានចំនួន**៨៨ ១៩៦ហ.ត.** **ស្មើនឹង៦៥,២៦%** នៃការព្យាករផ្ទៃដីដាំដុះចំនួន**១៣៥ ១៥០ហ.ត.** តិចជាងឆ្នាំមុនចំនួន**៥ ៥៩២ហ.ត.**។

**ក.៣- ការងារផលិតកម្មដំណាំសក្ដានុពល**

**ដំណាំកៅស៊ូ**

- ផ្ទៃដីកៅស៊ូសរុប**៤៤៨ ០៥១ហ.ត.** ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្ម**៤៦ ៤០៣ហ.ត.** ស្មើនឹង**១០%** ផ្ទៃដីចម្ការកៅស៊ូសម្បទានសេដ្ឋកិច្ច**១៧៦ ៩៣៦ហ.ត.** ស្មើនឹង**៤០%** និងផ្ទៃដីចម្ការកៅស៊ូគ្រួសារ**២២៤ ៧១១ហ.ត.** ស្មើនឹង**៥០%**

- ផ្ទៃដីចៀរជ័រ**៣៤៦ ៨៤២ហ.ត.** ស្មើនឹង**៧៧%** និងផ្ទៃដីថែទាំ**១០១ ២០៨ហ.ត.** ស្មើនឹង**២៣%**

- ផលិតផលជ័រកៅស៊ូ**៤៦ ២០៨តោន** កើនឡើង**៤ ៨៧៥តោន** ស្មើនឹង**១១,៨០%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន និងផលិតផលឈើកៅស៊ូ**៧ ៦៨៥ម៣** កើនឡើង**៦ ៨៤៣តោន** ស្មើនឹង**២២៤%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

- **ដំណាំស្វាយចន្ទី** ផ្ទៃដីស្វាយចន្ទីប៉ាន់ស្មាន ឆ្នាំ២០២៥ មានចំនួន**៧៦១ ៥២០ហ.ត.** ផ្ទៃដីប្រមូលផលចំនួន**៦៩៦ ១៤០ហ.ត.** ទិន្នផល**១,៥៣តោន/ហ.ត.** បរិមាណផលចំនួន**១ ០៦២ ៦៧៥តោន**។

- **ដំណាំស្វាយ** ផ្ទៃដីស្វាយប៉ាន់ស្មាន ឆ្នាំ២០២៥ មានចំនួន**១៥៩ ៤៦៤ហ.ត.** ផ្ទៃដីប្រមូលផល **១២៥ ៥៣៥ហ.ត.** ទិន្នផល**១៩,៣២តោន/ហ.ត.** បរិមាណផលចំនួន**២ ៤២៤ ៨៣៧តោន**។

**ក.៤- ការងារត្រួតពិនិត្យនិងបង្ក្រាបបទល្មើសនេសាទ** មានសំណុំរឿងបទល្មើសជលផលចំនួន **២៤២ករណី** ក្នុងនោះ បទល្មើសទឹកសាបចំនួន**២៣៧ករណី** និងសមុទ្រចំនួន**៥ករណី**។

**ក.៥- ការងារផលិតកម្មសត្វ**

- មានបរិមាណផលិតផលសាច់(សត្វពិឃាត) សរុប**១៥ ០៥៦តោន** ក្នុងនោះ គោ**២ ៧៥៦តោន** ជ្រូក**១០ ០២២តោន** និងមាន់**២ ២៨៨តោន**។ ជាមួយគ្នានេះ ការនាំចូលបន្ថែមផលិតផលសាច់សត្វ **៣ ៧៨៣,៥៦៩តោន**។

- **ការងារចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ** នៅរាជធានី ខេត្តទាំង២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាព ដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន**២០ ៩៧៤លើក** នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

- **ការងារស្រាវជ្រាវសុខភាពសត្វ** បានចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ឬនៅតាមសត្តឃាតដ្ឋានចំនួន**១ ៧៤០វត្ថុវិភាគ** ដើម្បីវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្តាសាយបក្សី(H5N1) ជំងឺប៉េស្តជ្រូកអាហ្វ្រិក(ASF) និងជំងឺដុំពកស្បែកគោ ក្របី(LSD)។

**ខ- ការងារធនធានទឹកនិងឧតុនិយម**

**ក្រសួងធនធានទឹកនិងឧតុនិយម៖**

**ខ.១-ការងារជួសជុល និងសាងសង់ប្រព័ន្ធធារាសាស្ត្រ**

- ក្រសួងបានកំពុងបញ្ជូនគម្រោងសម្រាប់ធ្វើការជួសជុល និងសាងសង់ប្រព័ន្ធធារាសាស្ត្រ បញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសុំធានាចំណាយថវិកាសម្រាប់ដំណើរការជួសជុល សាងសង់ និង

កិច្ចដំណើរការជួសជុលថែទាំជាប្រចាំ និងជួសជុលខួបក្នុងការបង្កើនលទ្ធភាពស្រោចស្រពដល់ដំណាំស្រូវ ដំណាំរួមផ្សំ ទប់ស្កាត់ទឹកជំនន់ទឹកប្រៃក្នុងឆ្នាំ២០២៦ ព្រមទាំងរក្សានិរន្តរភាពនៃលទ្ធភាពស្រោចស្រព

- ជួសជុល ថែទាំទំនប់ នៅខេត្តស្ទឹងត្រែងចំនួន**៣កន្លែង** ប្រវែង**៦៥ ម**

- ថែទាំ ស្តារប្រឡាយនៅខេត្តស្វាយរៀង **ចំនួន២ខ្សែ** មានប្រវែង**២ ៩០០ ម**

- ថែទាំ ជួសជុលសំណង់សិល្បការនៅខេត្តស្ទឹងត្រែងនិងខេត្តតាកែវ មានទ្វារទឹកចំនួន**៥កន្លែង**។

**ខ.២- ការងារអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវ ដំឡើង ជួសជុលស្ថានីយបូមទឹក និងម៉ាស៊ីនបូមទឹក**

មន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត បានអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវរដូវប្រាំង ឆ្នាំ២០២៥-២០២៦ ជូនកសិករនៅខេត្តសៀមរាប ស្វាយរៀង និងខេត្តព្រៃវែង សរុប**៦ ៥៨៩ ហ.ត.** និង ស្រោចស្រពដោយបង្ហូរចេញពីប្រព័ន្ធធារាសាស្ត្រចំនួន**៨ ៥៧៥ហ.ត.**។

**ខ.៣- ការងារសហគមន៍កសិករប្រើប្រាស់ទឹក** បានបន្តចុះពង្រឹងគាំទ្របច្ចេកទេសក្នុងការថែទាំ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ ដល់សហគមន៍កសិករប្រើប្រាស់ទឹក និងធ្វើការបណ្តុះបណ្តាលស្តីពី ការជួសជុលថែទាំប្រព័ន្ធធារាសាស្ត្រ ការគ្រប់គ្រងទឹក ការបិទ បើកទ្វារទឹក និងការងារប្រមូលសេវាប្រើប្រាស់ ទឹកសរុប**៦២កន្លែង** ទាំង១៥រាជធានី ខេត្ត។

**ខ.៤- ការងារទឹកស្អាត និងអនាម័យ**

- បន្តចុះសិក្សាស្រាវជ្រាវ និងបង្កើតអនុគមន៍កំណត់នូវបម្រែបម្រួលនីវ៉ូស្តាទិកទឹកក្រោមដីតាម អណ្តូងពិសោធន៍ នៅខេត្តព្រៃវែងចំនួន**២២អណ្តូង** ស្វាយរៀងចំនួន**១២អណ្តូង** និងខេត្តកំពង់ស្ពឺចំនួន**៥ អណ្តូង** និងខេត្តកំពង់ធំចំនួន**១អណ្តូង**

- បានបន្តចុះតាមដានស្ថានភាពទឹកក្រោមដី ដោយវាស់កម្ពស់ទឹកអណ្តូងចំនួន**៥ទីតាំង** នៅ ខេត្តកំពង់ស្ពឺ។

**ខ.៥-ការងារគ្រប់គ្រង និងអភិរក្សធនធានទឹក** បានធ្វើការកំណត់ព្រំអាងទឹកសរុបបាន**២៩កន្លែង** នៅខេត្តកំពង់ធំ មណ្ឌលគិរី ស្ទឹងត្រែង និងខេត្តរតនគិរី។

**ខ.៦- ការងារជលសាស្ត្រ និងច្រាំងទន្លេ**

- ក្រសួងបានប្រមូលទិន្នន័យកម្ពស់ទឹក ពីបណ្តាស្ថានីយជលសាស្ត្រសំខាន់ៗទាំង**១៥** នៅ តាមដងទន្លេមេគង្គ ទន្លេសាប ទន្លេបាសាក់ ទន្លេសេកុង ទន្លេសេសាន ទន្លេស្រែពក ដើម្បីពិនិត្យស្ថានភាព ជលសាស្ត្រប្រចាំថ្ងៃ និងបានព្យាករសម្រាប់ស្ថានភាពទឹកជំនន់ឆ្នាំ២០២៦ រួចបញ្ចូលទៅក្នុងកុំព្យូទ័រ ព្រមទាំង ផ្តល់ជូនស្ថាប័នពាក់ព័ន្ធMRC, FMMC និងបណ្តាញព័ត៌មានដើម្បីផ្សព្វផ្សាយជូនដល់សាធារណជន

- បានជួសជុល ថែទាំជាប្រចាំស្ថានីយជលសាស្ត្រស្វ័យប្រវត្តិបាន**១កន្លែង** នៅខេត្តស្ទឹងត្រែង

- ក្រសួងបានចុះយកគំរូទឹកនៅតាមស្ថានីយជលសាស្ត្រចំនួន**១៩កន្លែង** នៅនៅតាមដងទន្លេ មេគង្គ ទន្លេសេសាន ទន្លេស្រែពក ទន្លេសេកុង ទន្លេបាសាក់ ទន្លេសាប និងបឹងទន្លេសាប និងសិក្សាពី កំហាប់កករដី ទំហំប្រភេទកករ កករមានចលនា និងកករគ្មានចលនានៅបាតទន្លេ មកធ្វើការវិភាគគំរូទឹក នៅក្នុងមន្ទីរពិសោធន៍ ដោយធ្វើការវិភាគចំនួន**១៨ប៉ារ៉ាម៉ែត្រ** ឧបត្ថម្ភដោយMRC។

ខ.៧- ការងារឧតុនិយម

បន្ទាប់ពីធ្វើការតាមដាន វិភាគ និងព្យាករស្ថានភាពអាកាសធាតុរួចមក ក្រសួងធនធានទឹក និងឧតុនិយម បានជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបអំពីស្ថានភាពអាកាសធាតុ នៅក្នុងរដូវប្រាំង ឆ្នាំ២០២៦ ដោយផ្អែកទៅលើបាតុភូតសកល និងស្ថានភាពវិវត្តនៃសីតុណ្ហភាពនៅលើផ្ទៃមហាសមុទ្រប៉ាស៊ីហ្វិកខាងលិច មហាសមុទ្រឥណ្ឌា និងតំបន់អេក្វាទ័រ បានបង្ហាញឱ្យឃើញថា បាតុភូតឡានីញ៉ា(La Nina) និងបន្តរហូតដល់ខែកុម្ភៈក្នុងកម្រិត៥០% និងជំនួសមកវិញនូវបាតុភូតអែនសូអព្យាក្រឹត(ENSO-Neutral) កើនឡើង៩០% នៅក្នុងមេសានិង៨០% នៅក្នុងខែឧសភា ឆ្នាំ២០២៦។ ដោយឡែកបាតុភូតអាយអូឌី(IOD) ស្ថិតនៅអព្យាក្រឹត(IOD-Neutral)។

**ខ.៨- ការងារជួសជុលនិងដំឡើងឧបករណ៍ឧតុនិយម** បានធ្វើការជួសជុល ថែទាំស្ថានីយឧតុនិយមស្វ័យប្រវត្តិចំនួន៤កន្លែង នៅខេត្តមណ្ឌលគិរី និងខេត្តរតនគិរី។

ខ.៩- ការងារសហប្រតិបត្តិការអន្តរជាតិ

១- អង្គការ JICA

- ស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹកភាគនិរតីនៃរាជធានីភ្នំពេញ រួមមានខេត្តកណ្តាល កំពង់ស្ពឺ និងខេត្តតាកែវ សម្រេចបាន៩៤%
- រៀបចំស្តង់ដារបទដ្ឋានបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹក សម្រេចបាន៧៥%។

២- សាធារណរដ្ឋប្រជាមានិតចិន

- បានសហការការងារសាងសង់អាងទឹកដងកាំបិត នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ សម្រេចបាន៦៦%
- បានសហការលើគម្រោងអភិវឌ្ឍន៍ធនធានទឹកជុំគិរី ខេត្តកំពត(ចាប់ផ្តើមសិក្សា)
- បានសហការលើគម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងស្ទោង ដំហាន២(ចាប់ផ្តើមសិក្សា)

៣- សាធារណរដ្ឋកូរ៉េ

- បានសហការការងារគម្រោងកាត់បន្ថយទឹកជំនន់ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ជំហានទី២ នៅខេត្តបន្ទាយមានជ័យ សម្រេចបាន៧៨%
- បានសហការលើគម្រោងគ្រប់គ្រងធនធានទឹកចម្រុះភាគខាងកើតទន្លេមេគង្គ(ដៃលតា) សម្រេចបាន៣៣%
- បានសហការលើគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្របរវេល និងកាត់បន្ថយទឹកជំនន់ ខេត្តបាត់ដំបង សម្រេចបាន៣៣%
- បាននិងកំពុងបន្តសហការ ក្នុងការសិក្សាគ្រោងប្លង់ទីតាំងភូមិសាស្ត្រ តំបន់ធារាសាស្ត្រសម្រាប់អនុវត្តតាមផែនការបន្តក្នុងបណ្តាឆ្នាំខាងមុខ។

៤- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB+OPEC+NORDIC FUND+ Australian Aid)

- សហការលើគម្រោងកែលម្អវិស័យធារាសាស្ត្រកសិកម្ម សម្រេចបាន៩៥%
- សហការក្នុងការរៀបចំគម្រោងសម្រាប់ស្នើសុំឥណទានសម្បទាន ពីធនាគារ នាឆ្នាំខាងមុខ។

**៥- ប្រទេសឥណ្ឌា** សហការការងារកសាងគម្រោងទំនប់ស្ទឹងស្វាហាប់ ខេត្តកំពង់ស្ពឺ(កំពុងធ្វើការសិក្សាបន្ថែម) និងសហការលើការសិក្សាទឹកក្រោមដី នៅតាមបណ្តាខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា។

**៦-ភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD)**

- គម្រោងស្តារ និងគ្រប់គ្រងស្ទឹងស្វាយចេក ខេតបន្ទាយមានជ័យ(ចាប់ផ្តើមសិក្សា)
- បាននឹងកំពុងបន្តសហការការងារលើការរៀបចំបញ្ជីសារពើភណ្ឌប្រព័ន្ធធារាសាស្ត្រ នៅកម្ពុជា។

**៧-ធនាគារពិភពលោក (WB)**

- គម្រោងពិពិធកម្មកសិកម្មកម្ពុជា សម្រេចបាន**៩៤%**
- គម្រោងកែលម្អសន្តិសុខទឹកកម្ពុជា សម្រេចបាន**២៩%**។

**គ- ការងារអភិវឌ្ឍន៍ជនបទ**

**ក្រសួងអភិវឌ្ឍន៍ជនបទ៖**

-ថែទាំផ្លូវលក្ខណៈខួប សម្រេចបាន**៥,៥០%** នៃផែនការសរុប**៣១៥គ.ម.** និងថែទាំផ្លូវលក្ខណៈប្រចាំ សម្រេចបាន**៨,៨០%** នៃផែនការសរុប**២ ៩៥១គ.ម.**

- គម្រោងស្តាបនា និងកែលម្អផ្លូវជនបទដោយប្រើប្រាស់ថវិកាជាតិ សម្រេចបាន**៥,៥០%** នៃផែនការប្រចាំឆ្នាំប្រវែង**១៧៩គ.ម.** និងប្រើប្រាស់ថវិកាហិរញ្ញប្បទានដៃគូអភិវឌ្ឍ សម្រេចបាន**២,៥៤%** នៃផែនការប្រចាំឆ្នាំប្រវែង**៨៤៤គ.ម.**

- ស្រង់ទិន្នន័យ និងធ្វើបច្ចុប្បន្នភាពផ្លូវជនបទចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាប្រវែង**២០គ.ម.**

- ការងារអភិវឌ្ឍន៍តំបន់រុនតាឯក សម្រេចបាន**១០០%** និងការងារអភិវឌ្ឍន៍តំបន់ពាក់ស្នែង សម្រេចបាន**៦៥%** នៅខេត្តសៀមរាប

- គម្រោងស្តាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទដោយប្រើប្រាស់ថវិកាជាតិ សម្រេចបាន **០,៤៩%** នៃផែនការប្រចាំឆ្នាំ និងប្រើប្រាស់ថវិកាហិរញ្ញប្បទានដៃគូអភិវឌ្ឍ សម្រេចបាន**១៤,៣៥%** នៃផែនការប្រចាំឆ្នាំ

- គម្រោងអភិវឌ្ឍន៍សហគមន៍ជនបទដោយប្រើប្រាស់ថវិកាហិរញ្ញប្បទានដៃគូអភិវឌ្ឍ សម្រេចបាន**៦,៨៣%** នៃផែនការប្រចាំឆ្នាំ

- ចុះប្រគល់លិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចកួយ និងគ្រឹង **៣សហគមន៍** នៅខេត្តកំពង់ធំនិងខេត្តរតនគិរី

- ការងារត្រើវិស័យកសិកម្មទឹកជនបទ មានសហគមន៍គោលដៅសរុប**១០ទីតាំង** បានអនុវត្តសកម្មភាព ក្នុងនោះ សហគមន៍គោលដៅចំនួន៣ បាននិងកំពុងដំណើរការចាក់បំពេញតួផ្លូវ រួមមាន សហគមន៍កសិកម្មទំនើបបន្លែផ្ទះសំណាញ់ត្រាំកក់ ខេត្តតាកែវ សហគមន៍កសិកម្មសំបូរមានជ័យ ខេត្តកំពង់ចាម និងសហគមន៍កសិកម្មអភិវឌ្ឍន៍ក្រង់តេះ ខេត្តមណ្ឌលគិរី និងសហគមន៍គោលដៅចំនួន៣ បាននិងកំពុងដំណើរការសម្អាតមីនតួផ្លូវនិងកាយសម្អាតតួផ្លូវ រួមមាន សហគមន៍កសិកម្មទំនើបស្រូវនាងអំ ខេត្តសៀមរាប សហគមន៍កសិកម្មតាសីសាមគ្គី ខេត្តបាត់ដំបង និងសហគមន៍កសិកម្មទំនើបស្វាយចន្ទីប្រាសាទសំបូររុងរឿង ខេត្តកំពង់ធំ

- ផ្តល់ឥណទានជនបទសរុបមាន**១៦០ ១៧០ ៥០០រៀល** មានអ្នកខ្ចីសរុប**១៥៣នាក់** នៅភូមិគោលដៅ**២៧ភូមិ ១៤ឃុំ ៧ស្រុក** ក្នុងខេត្តគោលដៅ៩។ អង្គភាពគ្រប់គ្រងគម្រោងនិងអង្គភាពអនុវត្តគម្រោងមានទ្រព្យសកម្មសរុបចំនួន**៣ ៧៧៦ ៨០៣ ១៩៣រៀល**

- ពិសោធសំណាក**៤៥សំណាក** ក្នុងនោះ ផ្នែកដី ថ្ម និងខ្សាច់**២៥សំណាក** ផ្នែកបេតុង ស៊ីម៉ងត៍ និងដែក**១១សំណាក** ផ្នែកកៅស៊ូ**៧សំណាក** និងផ្នែកពិសោធការដ្ឋាន**២សំណាក** សម្រេចបាន**១០០%**។

### ៤- ការពង្រឹងការគ្រប់គ្រងនិងការធ្វើទំនើបកម្មនគរូបនីយកម្ម

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖

ក- ការងារសុរិយោដី

ក.១- **ការងារចុះបញ្ជីដំបូង** មានលក្ខណៈជាប្រព័ន្ធ សម្រេចបាន**៣៩ ៧៧១បណ្ណ**(កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី) និងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ សម្រេចបាន**៤៧១បណ្ណ**(ដីឯកជន)។

ក.២- **ការងារចុះបញ្ជីបន្ត** អំពីការផ្ទេរសិទ្ធិចំនួន**១២ ២៥០ករណី** សិទ្ធិប្រាតិភោគ(ដាក់បញ្ចាំ/ហ៊ីប៉ូតែក)ចំនួន**៤ ៨២២ករណី** សិទ្ធិជួលអចិន្ត្រៃយ៍ចំនួន**២បណ្ណ** ស្មើនឹង**១៣ហ.ត. ៧៤អា** បំបែកក្បាលដីបុរីចំនួន**២បុរី** ស្មើនឹង**៥៤៦បណ្ណ**។

ក.៣- **ការចុះបញ្ជីដីធ្លីតាមប្រភេទទ្រព្យ** ទ្រព្យខាងប្ដី**៩%** ទ្រព្យខាងប្រពន្ធ**១៨%** ទ្រព្យអ្នកនៅលីវ**១០%** ទ្រព្យរួមប្ដីប្រពន្ធ**៦០%** និងទ្រព្យផ្សេងៗ **៣%**។

ក.៤- **ការងារចុះបញ្ជីអគារសហកម្មសិទ្ធិ** ផ្ទេរសិទ្ធិចំនួន**៤៧១បណ្ណ** ក្នុងនោះ ជនជាតិខ្មែរចំនួន**១៥៧បណ្ណ** ជនបរទេសចំនួន**៣១៤បណ្ណ** ។

ក.៥- **ការអនុវត្តវិធានការបង្ក្រាបការទន្ទ្រានដីរដ្ឋក្នុងដែនព្រៃលិចទឹកនៃតំបន់ទន្លេសាប** គិតពីចាប់ផ្តើមអនុវត្តដល់ខែមករា ឆ្នាំ២០២៦ សម្រេចបាន ១) សម្រេចកែសម្រួលផ្ទៃដីទំហំ**២ ៩៨៨ហ.ត.** ចេញពីតំបន់៣ បញ្ចូលមកក្នុងតំបន់១ និងផ្តល់ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន៩ ៦៣៩គ្រួសារ ២) កែសម្រួលផ្ទៃដីទំហំ**៨៤ ៩៦៧ហ.ត.** ចេញពីតំបន់២ បញ្ចូលមកតំបន់១ និងផ្តល់ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន**៥៤ ៨៧៥គ្រួសារ** និង៣) កែសម្រួលផ្ទៃដីទំហំ**៧៩ ១២៦ហ.ត.** ចេញពីតំបន់៣ ទៅជាតំបន់២ និងផ្តល់សិទ្ធិកាន់កាប់និងអាស្រ័យផលជូនប្រជាពលរដ្ឋចំនួន**២៨ ០៧៥គ្រួសារ**។ ដោយឡែក ក្រោយការកែសម្រួលរួចផ្ទៃដីតំបន់៣ នៅសល់ប្រមាណ**៥៦ម៉ឺនហ.ត.**, ផ្ទៃដីតំបន់២ មានទំហំប្រមាណ**៣៨ម៉ឺនហ.ត.**និងផ្ទៃដីតំបន់១ មានទំហំប្រមាណ**៤៦ម៉ឺនហ.ត.**។ លទ្ធផលនៃការចុះបញ្ជីដីតំបន់ទន្លេសាប មានដូចខាងក្រោម ដីតំបន់៣(ដីរដ្ឋ)៖ បានចុះបញ្ជីដីតំបន់៣ជាដីរដ្ឋ រួចរាល់ជាស្ថាពរសម្រាប់ខេត្តកំពង់ឆ្នាំងទំហំ**៧០ ៥៧៤ ហ.ត.**, ខេត្តបន្ទាយមានជ័យទំហំ**៨ ៨៣៨ហ.ត.** និងខេត្តកំពង់ធំទំហំ**១០៨ ៥៥២ហ.ត.** ដីតំបន់២(ដីរដ្ឋ) បាន (១) ចុះបញ្ជីតំបន់២ ជាដីរដ្ឋរួចរាល់ជាស្ថាពរសម្រាប់ខេត្តកំពង់ឆ្នាំងទំហំ**៨២ ៩០៦ហ.ត.** និងខេត្តបន្ទាយមានជ័យទំហំ**២០ ៨០១ហ.ត.** និង(២) វាស់វែងដីដែលប្រជាពលរដ្ឋប្រើប្រាស់និងអាស្រ័យផលក្នុងតំបន់២ ចំនួន**១៨៩ ៧០១ក្បាលដី** ស្មើនឹង**១០០%** និងវាស់វែងដីដែលប្រជាពលរដ្ឋប្រើប្រាស់និងអាស្រ័យផលក្នុងតំបន់២ ចប់ទាំងស្រុង**១០០%** លើក្បាលដីចំនួន**១៩១ ៨៩០ក្បាលដី** ដីតំបន់១ (កម្មសិទ្ធិឯកជន) បានវាស់វែងរួចចំនួន**១ ០៧៣ ០៤៨/១ ០៨៧ ១៣០ក្បាលដី** ស្មើនឹង**៩៨%** និងចេញបណ្ណរួចចំនួន**៦៣៨ ៥៧៤/១ ០៩៤ ៥៣៤ក្បាលដី** ស្មើនឹង**៦០%**។

ខ- ការងារសំណង់

**ខ.១- ទិន្នន័យសំណង់ទូទាំងប្រទេស**

ទិន្នន័យសំណង់ទូទាំងប្រទេសមានចំនួន**៣២៥គម្រោង** មានផ្ទៃក្រឡាកម្រាលសំណង់សរុបចំនួន**២ ១៨៤ ៩៤០ម²** តម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ**៨៦៤ ៩៨៧ ៤៣៥ដុល្លារអាមេរិក** បើធៀបនឹងខែដូចគ្នាឆ្នាំមុខ មានចំនួន**៣៦១គម្រោង** មានផ្ទៃក្រឡាកម្រាលសំណង់ចំនួន**១ ៥៧០ ១០៧ម²** តម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ**៥៩៤ ៩២០ ៩៣៤ដុល្លារអាមេរិក** កើនឡើង៤៥,៤០%។ បើធៀបនឹងខែកន្លងទៅមានចំនួន**២៨៩គម្រោង** មានផ្ទៃក្រឡាកម្រាលសំណង់ចំនួន**១ ៣៩៩ ៤២៦ម²** តម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ**៥៩៦ ២០៦ ៥៤៨ដុល្លារ** កើនឡើង៤៥,០៨%។

**ខ.២- ទិន្នន័យសំណង់តាមប្រភេទអគារ**

- គម្រោងអគារខ្ពស់ៗចាប់ពី**៥ជាន់ឡើង** មានចំនួន**២១គម្រោង** ស្មើនឹង**៣៧អគារ** (នៅរាជធានីភ្នំពេញ មានចំនួន១៦គម្រោង ស្មើនឹង៣២អគារ ខេត្តព្រះសីហនុមានចំនួន៣គម្រោង ស្មើនឹង៣អគារ និងខេត្តបន្ទាយមានជ័យមានចំនួន១គម្រោង ស្មើនឹង១អគារ និងនៅតាមបណ្ដាខេត្តផ្សេងៗទៀតមានចំនួន១អគារ) ក្នុងនោះ អគារពី**៥ទៅ៩ជាន់** មានចំនួន**៣៣អគារ** អគារពី១០ទៅ១៩ជាន់ មានចំនួន**២អគារ** និងអគារពី**២០ទៅ២៩ជាន់** មានចំនួន**២អគារ**

- សំណង់លំនៅឋានមានចំនួន**២៤១គម្រោង** ផ្ទៃក្រឡាកម្រាលសំណង់សរុប**៧០០ ៨៨១ម²** តម្លៃប៉ាន់ស្មានទុនទុនវិនិយោគ**២៧២ ៣៤០ ៣៤៩ដុល្លារអាមេរិក** ក្នុងនោះ (១) បុរីលំនៅឋាននិងបណ្ដុំលំនៅឋានមានលក្ខណៈជាបុរីមានចំនួន**៤គម្រោង** ស្មើនឹង**១ ៨៩៧ខ្នង** ផ្ទៃក្រឡាកម្រាលសំណង់ចំនួន**៥១៨ ៤៨៩ម²** តម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ**១៨១ ៥២៩ ៤៣៨ដុល្លារអាមេរិក** (២) អគារផ្ទះល្វែងមានចំនួន**២ ១៨៣ល្វែង/ខ្នង** ផ្ទៃក្រឡាកម្រាលសំណង់**៥៩៧ ២៣៧ម²** តម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ**២១២ ០៧៤ ៥៩២ដុល្លារអាមេរិក** និង(៣) អគារស្នាក់នៅរួមមានចំនួន**១០គម្រោង** ផ្ទៃក្រឡាកម្រាលសំណង់**១០៣ ៦៤៣ម²** តម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ**៦០ ២៦៥ ៧៥៧ដុល្លារអាមេរិក**

- សំណង់អគារពាណិជ្ជកម្មចំនួន**១៨គម្រោង** ផ្ទៃក្រឡាកម្រាលសំណង់សរុប**១១៩ ៩១៩ម²** មានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ**៦៩ ០៥៧ ៥៤១ដុល្លារអាមេរិក**

- សំណង់អគាររោងចក្រមានចំនួន**២៥គម្រោង** ផ្ទៃក្រឡាកម្រាលសំណង់**១ ០៥៤ ៣៧៨ម²** មានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ**៣៦៩ ៥៨៩ ៧៧៩ដុល្លារអាមេរិក**

- សំណង់អគារពហុមុខងារចំនួន៣គម្រោង មានផ្ទៃក្រឡាកម្រាលសំណង់សរុប**៨៦ ០៤១ម²** មានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ**៥១ ៦២៤ ៥៥២ដុល្លារ**។

គិតចាប់ផ្ដើមអនុវត្តដល់ខែមករា ឆ្នាំ២០២៦ មាន (១) គម្រោងអគារខ្ពស់ៗ ចាប់ពី**៥ជាន់**ឡើងនៅទូទាំងប្រទេសមានចំនួន**៣ ៣២៥អគារ**(នៅរាជធានីភ្នំពេញចំនួន២ ០០៣អគារ ខេត្តព្រះសីហនុចំនួន៧៧៩អគារ នៅខេត្តបន្ទាយមានជ័យចំនួន៤១១អគារ និងនៅតាមបណ្ដាខេត្តផ្សេងៗទៀតមានចំនួន១៣២អគារ) ក្នុងនោះ អគារខ្ពស់ចាប់ពី**៥ជាន់ ទៅ៩ជាន់** មានចំនួន**១ ៩៥៨អគារ** អគារចាប់ពី**១០ជាន់**

**ទៅ១៩ជាន់** មានចំនួន**៨៦៤អគារ** អគារចាប់ពី**២០ជាន់ទៅ២៩ជាន់** មានចំនួន**២៨០អគារ** អគារចាប់ពី**៣០ជាន់ទៅ៣៩ជាន់** មានចំនួន**១៥៧អគារ** អគារចាប់ពី**៤០ជាន់ឡើង** មានចំនួន**៦៦អគារ** (២) គម្រោងបុរីលំនៅឋាននិងបណ្តុំលំនៅឋានមានលក្ខណៈជាបុរីមានចំនួន**៧០៦គម្រោង** (៣) អគារផ្ទះល្វែងមានចំនួន**១២៤ ០៨៧ខ្នង** (៤) អគារស្នាក់នៅរួមមានចំនួន**៨២២គម្រោង** (៥)សំណង់លំនៅឋានមានចំនួន**៤៣ ៦៣៧គម្រោង** ៦)សំណង់អគារសណ្ឋាគារមានចំនួន**១ ១៧០គម្រោង** (៧) សំណង់អគារពាណិជ្ជកម្មមានចំនួន**៣ ៨០៧គម្រោង** (៨) សំណង់អគាររោងចក្រមានចំនួន**១១ ២៥២គម្រោង** និង(៩) សំណង់អគារពហុមុខងារមានចំនួន**៤២៤គម្រោង**។

**គ- ការងារគណៈវិស្វករកម្ពុជា**

***ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ*** ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈអគ្គលេខាធិការដ្ឋាននៃគណៈវិស្វករកម្ពុជាបានត្រួតពិនិត្យនិងវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យ ដោយបានចុះបញ្ជីវិស្វករថ្មីសរុបចំនួន**១៤០នាក់**(ស្រី២០នាក់)។ គិតត្រឹមខែមករា ឆ្នាំ២០២៦ នេះ គណៈវិស្វករកម្ពុជាបានត្រួតពិនិត្យ និងវាយតម្លៃតាមលក្ខណវិនិច្ឆ័យចំនួន**១០ ៣១២នាក់**(ស្រី៤៩៥នាក់) ក្នុងនោះវិស្វករជាតិចំនួន**១០ ២៦៧នាក់**(ស្រី៤៩៥នាក់) និងវិស្វករបរទេសចំនួន**៤៥នាក់**។

## ៥- ការធានានិរន្តរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង

**ក្រសួងសាធារណការនិងដឹកជញ្ជូន៖**

**ក- ការងារកសាងហេដ្ឋារចនាសម្ព័ន្ធទឹក រួមទាំងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់**

**ក.២.១- គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយធនាគារពិភពលោក(WB)**

គម្រោងលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ(សាងសង់លូខ្វែងនិងខ្វែងរងប្រវែង**២២ គ.ម.** ការងារធ្វើឱ្យប្រសើរឡើងវិញស្ថានីយបូមទឹកកខ្វក់និងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ និងការងារពង្រឹងនិងអភិវឌ្ឍស្ថាប័ន) ក្រុងសៀមរាប ខេត្តសៀមរាប សម្រេចបាន**៩៧,៩០%**។

**ក.២.២- គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយសាធារណរដ្ឋកូរ៉េ** គម្រោងអភិវឌ្ឍន៍ប្រព័ន្ធចម្រោះទឹកកខ្វក់ ក្រុងតាខ្មៅ ខេត្តកណ្តាល សម្រេចបាន**១៨,៣២%**។

**ក.២.៣- គម្រោងហិរញ្ញប្បទានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី(ADB)**

- គម្រោងអភិវឌ្ឍន៍ក្រុងរបៀង ជំហាន៤ រួមមានក្រុងកំពង់ចាម ខេត្តកំពង់ចាម សាងសង់ប្រព័ន្ធលូរំដោះទឹកកខ្វក់និងស្ថានីយចម្រោះទឹកកខ្វក់ សម្រេចបាន**៩៧,១៥%** ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង សាងសង់ប្រព័ន្ធលូរំដោះទឹកកខ្វក់និងស្ថានីយចម្រោះទឹកកខ្វក់ សម្រេចបាន**៩៧,៨៥%** និងសាងសង់ប្រព័ន្ធលូរំដោះទឹកភ្លៀង និងស្ថានីយបូម នៅក្រុងក្រចេះ ខេត្តក្រចេះ សម្រេចបាន**៦៨,០១%**

- គម្រោងកែលម្អគ្រប់គ្រងបរិស្ថានក្រុងជុំវិញបឹងទន្លេសាប ជំហាន២ រួមមាន ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ សាងសង់ប្រព័ន្ធលូរំដោះទឹកកខ្វក់ ប្រព័ន្ធលូរំដោះទឹកភ្លៀងនិងស្ថានីយចម្រោះទឹកកខ្វក់ សម្រេចបាន**៩១,០៨%**

- គម្រោងអភិវឌ្ឍន៍ទីក្រុងដ៏គួរឱ្យចង់រស់នៅ(សាងសង់ទីលានកប់សំរាម) សម្រេចបាន**៩៥%** និង(សាងសង់ប្រព័ន្ធលូរំដោះទឹកកខ្វក់ ប្រព័ន្ធលូរំដោះទឹកភ្លៀង និងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់) សម្រេចបាន**១៤%** នៅក្រុងបាវិត ខេត្តស្វាយរៀង

- គម្រោងកម្មវិធីអភិវឌ្ឍន៍វិស័យថាមពល អនុកម្មវិធីទី១(ប្តូរនិងដំឡើងអំពូលអិលអ៊ីឌី) ក្រុងកំពត ខេត្តកំពត និងក្រុងកែប ខេត្តកែប សម្រេចបាន**៩៨%**។

**ក.២.៤- គម្រោងហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលកម្ពុជា**

- សាងសង់ថ្មីបណ្តាញលូគ្រប់ប្រភេទ(លូរំដោះទឹកភ្លៀង) ប្រវែងសរុប១៤ ៥៨៦ម. នៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ធំ កំពត កណ្តាល ព្រះវិហារ និងខេត្តតាកែវ សម្រេចបាន **៩៧,០៨%** (ថវិកាឆ្នាំ២០២៥)

- សាងសង់ថ្មីបណ្តាញលូគ្រប់ប្រភេទ(លូរំដោះទឹកភ្លៀង) ប្រវែងសរុប១៨ ០៥៥ម. នៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ធំ កណ្តាល ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ សៀមរាប ព្រះសីហនុ ស្វាយរៀង តាកែវ និងខេត្តប៉ៃលិន សម្រេចបាន**០,០១%** (ថវិកាឆ្នាំ២០២៦)។

**ខ- ការងារប្រើប្រាស់បច្ចេកវិទ្យាភាគបរិស្ថាននិងភាគអាកាសធាតុ**

- បានចុះពិនិត្យតាមដានគុណភាពទឹកសាធារណៈ(ទឹកទន្លេ បឹងទន្លេសាប ស្ទឹង អាងស្តុកទឹក បឹង ជ្រោះ និងសមុទ្រ) ដោយបានសហការជាមួយមន្ទីរបរិស្ថានរាជធានី ខេត្តទាំង២៥ លើទីតាំងអាទិភាពទាំង**៦៣ទីតាំង** និងបានយកសំណាកទឹកចំនួន៦៣សំណាកមកវិភាគ។ យោងតាមលទ្ធផលពីមន្ទីរពិសោធន៍ និងការវាយតម្លៃសន្ទស្សន៍គុណភាពទឹក បង្ហាញថា ស្ថានភាពគុណភាពទឹកសាធារណៈ មានសភាពថ្លា ស្ថិតក្នុងចំណាត់ថ្នាក់ល្អ ពុំមានអ្វីប្រែប្រួល ឬបង្កឱ្យមានការបំពុលគួរឱ្យកត់សម្គាល់នោះទេ

- បានតាមដានត្រួតពិនិត្យគុណភាពខ្យល់សាធារណៈជាប្រចាំ នៅរាជធានីភ្នំពេញចំនួន**១០ ទីតាំង** និងតាមបណ្តាខេត្តទូទាំងប្រទេសចំនួន**៤៩ទីតាំង**។ ជាលទ្ធផល តាមរយៈការត្រួតពិនិត្យគុណភាពខ្យល់ពីឧបករណ៍ និងស្ថានីយដែលបានដំឡើងនៅទូទាំងប្រទេស បង្ហាញថា គុណភាពខ្យល់នៅរាជធានីភ្នំពេញនិងបណ្តាខេត្ត ក្នុងខែមករា ឆ្នាំ២០២៦នេះ ស្ថិតក្នុងកម្រិតល្អបើធៀបទៅនឹងស្តង់ដាគុណភាពខ្យល់សាធារណៈ។ ដោយឡែក បើធ្វើការប្រៀបធៀបគុណភាពខ្យល់រវាងខែធ្នូ ឆ្នាំ២០២៥ និងខែមករា ឆ្នាំ២០២៦ បង្ហាញថា កម្រិតភាគល្អិតនិចលPM2.5 មានការកើនឡើងតិចតួចនៅក្នុងខែមករា(ខែធ្នូ ស្មើនឹង ១២,៥២µg/m3 និងខែមករា ស្មើនឹង២០,០១µg/m3)។

**គ- ការងារគ្រប់គ្រងសំណល់រឹង រាវ ទាំងនៅទីក្រុងនិងទីប្រជុំជន**

បានសហការជាមួយក្រុមហ៊ុន Ecobatt ប្រមូលសំណល់ថ្មពិលចំនួន**១៣២គីឡូក្រាម** សំណល់អាគុយចំនួន**២៨៣គ.ក្រ.** និងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកចំនួន**១៨៧,៥គ.ក្រ.** ដើម្បីធ្វើការកែច្នៃ។

## បញ្ចកោណយុទ្ធសាស្ត្រទី៥
## «ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល»

### ១- ការកសាងរដ្ឋាភិបាលឌីជីថលនិងពលរដ្ឋឌីជីថល

**ការងារឌីជីថលការូបនីយកម្មសេវាសាធារណៈ**

**ការប្រើប្រាស់ប្រព័ន្ធឌីជីថល**

**១- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** បានផលិតកម្មវិធីអប់រំរឿងភាគចំនួន**១៩រឿង** និងសកម្មភាពថ្នាក់ដឹកនាំផ្សព្វផ្សាយក្នុងទំព័រហ្វេសប៊ុក(Facebook) របស់ក្រសួងបានចំនួន**១៨លើក** មានអ្នកចូលចិត្ត(Like)ចំនួន**១០ ១៦៤នាក់** អ្នកចូលរួមមតិយោបល់(Comments)ចំនួន**៤ ៦៧នាក់** អ្នកចូលរួមចែករំលែកព័ត៌មានបន្ត(Share)ចំនួន**៣ ២៥២នាក់** និងអ្នកតាមដានទំព័រ(Follow page)ចំនួន**៣ ០២០នាក់**។

តាមរយៈបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា បើកកិច្ចប្រជុំផ្ទៃក្នុង សិក្ខាសាលា និងការបណ្តុះបណ្តាលជាមួយក្រសួងស្ថាប័នតាមប្រព័ន្ធអនឡាញបានចំនួន**៣លើក** ផ្សព្វផ្សាយក្នុងទំព័រហ្វេសប៊ុក(Facebook)របស់បណ្ឌិត្យសភាបានចំនួន**៩លើក** អ្នកចូលចិត្ត(Like)ចំនួន**១ ០២២នាក់** អ្នកចូលរួមមតិយោបល់(Comments)ចំនួន**៦៣នាក់** អ្នកចែករំលែកព័ត៌មានបន្ត(Share)ចំនួន**១២៤នាក់** និងអ្នកតាមដានទំព័រ(Follow page)ចំនួន**៥១ ៦១៨នាក់**។

**២- ក្រសួងព័ត៌មាន** ធ្វើការផ្សព្វផ្សាយព័ត៌មាននិងសកម្មភាពការងារនានា តាមរយៈហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួង(www.facebook.com/TheMinistryofinformation) ដែលមានអ្នកតាមដានសរុបជាង**១,៧លាននាក់** ។

**៣- ទីស្តីការគណៈរដ្ឋមន្ត្រី** បានបង្កើតនិងគ្រប់គ្រងគេហទំព័រផ្លូវការរបស់ទីស្តីការគណៈរដ្ឋមន្ត្រីមានឈ្មោះwww.ocm.gov.kh ដោយបានបង្ហោះមាតិការាជកិច្ច បណ្ណសារ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលមានអ្នកចូលទស្សនា(Number of Visits)ចំនួន**២៩៥ ៣២៥នាក់** Page View ចំនួន**៤ ៥៥២ ៦៦០លើក** និងមានការទាញយកឯកសារចេញចំនួន**៧០ ៣៧៥ឯកសារ**។ ការងារគ្រប់គ្រងFacebook Page របស់ទីស្តីការគណៈរដ្ឋមន្ត្រី មានPage Reachចំនួន**១ ១៣៥ ៨០៦នាក់** Post Engagementចំនួន**២ ០៨៤ ៦៦៥លើក** និងPage Followerចំនួន**៧ ៤៦៦**។ បច្ចុប្បន្នFacebook Page នេះ មានPage Followerចំនួន**១១៨ ៦៥២**។ ការងារគ្រប់គ្រងYouTube Channel របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងឆ្នាំ២០២៤ មានViewsចំនួន**៧២៤** Subscribersចំនួន**៥១០** និងUploaded Video ចំនួន**១០**។ ការងារគ្រប់គ្រងបណ្តាញTelegram របស់ទីស្តីការគណៈរដ្ឋមន្ត្រី មានTotal Followersចំនួន និង Total Subscriberចំនួន**១៤ ៣៦៧**។

**- ក្រុមប្រឹក្សាអ្នកច្បាប់** ហ្វេសប៊ុកផេក(Facebook page)របស់ក្រុមប្រឹក្សាអ្នកច្បាប់មានឈ្មោះថា «**ក្រុមប្រឹក្សាអ្នកច្បាប់**» ដែលមានចំនួនអ្នកចូលចិត្តទំព័រសរុប(Page Likes) ចំនួន**៥១ ០៣៩នាក់** និងអ្នកតាមដានសរុប (Page Follower)ចំនួន**៥១ ០៣៩នាក់** សារបង្ហោះទៅដល់(Page Reach) មាន**១៤២ ០៣៤លើក** អ្នកចូលមើលទំព័រ(Page Visit)**៤ ៧៦៩លើក** ការចូលរួម(Page Engagement) ចំនួន**១៤ ៧២៩លើក** និងអ្នកតាមដានថ្មីនិងចូលចិត្តផេក(New Likes and Follows) ចំនួន**២០០នាក់**

- **ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** បានផ្សព្វផ្សាយតាមហ្វេសប៊ុកផេក(Facebook Page)មានអ្នកចូលចិត្ត(Like page)ចំនួន**៨ ២០៦នាក់** ចំនួនអ្នកចូលចិត្តថ្មី(NewLike)ចំនួន**៤៦៥នាក់** អត្ថបទបង្ហោះ(post)សរុប**៩៧អត្ថបទ**

- **នាយកដ្ឋានបណ្ណសារដ្ឋានជាតិនៃទីស្ដីការគណៈរដ្ឋមន្ត្រី** បានផ្សព្វផ្សាយតាមហ្វេសប៊ុកផេក (Facebook Page) មានសារបង្ហោះ(Page Visit)ចំនួន**៦៧៣នាក់** អ្នកចូលមើល(Page View) ចំនួន**៧ ៤៧៣ដង** ការចូលរួម(Page Engagement)ចំនួន**៧៣៦នាក់** ការចែករំលែក(Share)ចំនួន **៦២ដង** អ្នកតាមដានថ្មី(New Follower)ចំនួន**៦២នាក់** និងអ្នកចូលចិត្ត(Like Page)ចំនួន**៦១នាក់**។ បច្ចុប្បន្ន ហ្វេសប៊ុកផេក(Facebook Page) មានអ្នកចូលចិត្ត(Like)ចំនួន**៣ ០៨២នាក់** និងអ្នកតាមដាន (Follower)ចំនួន**៤ ០៧៧នាក់**

- **មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)** មានហ្វេសប៊ុកផេក(Facebook Page) មានឈ្មោះថា«មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអ.វ.ត.ក.LDC» មានអ្នកចូលចិត្ត(Like Page)ចំនួន**៥ ៩៤១នាក់** អ្នកតាមដាន(Follower)ចំនួន **៥ ៩៨០នាក់** អ្នកចូលចិត្តមើល(Page Visit)ចំនួន**២៣ ១១៩លើក** និងបានផ្សព្វផ្សាយ ចំនួន**៣ ៦៦០ លើក**។

-**គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១** បានផ្សព្វផ្សាយទំព័រហ្វេសប៊ុកផេក (Facebook Page) មានចំនួនអ្នកតាមដានPage ចំនួន**២ ២០០នាក់** អ្នកចូលLike ចំនួន**២ ២០០នាក់** និងFollower ចំនួន**២ ៨០០នាក់**

- **រាជបណ្ឌិត្យសភាកម្ពុជា** រាជបណ្ឌិត្យសភាកម្ពុជា បានធ្វើការផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពការងារនានា តាមរយៈ៖ (១) ហ្វេសប៊ុកផេកផ្លូវការ(www.facebook.com/rac.gov.kh) ដែលមានអ្នកតាមដាន(Follower)សរុបចំនួន១៤៥K Follower (២)តេឡេក្រាមឆាណែល RAC Media(https://t.me/racnews) ដែលមានអ្នកជាវ(Subscriber) សរុបប្រមាណ**៤ ២៤១នាក់** និង(៣)គេហទំព័រផ្លូវការរាជបណ្ឌិត្យសភាកម្ពុជា(http://rac.gov.kh/)។

- **អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន(អាជ្ញាធរមីន)** បានផ្សព្វផ្សាយតាមហ្វេសប៊ុកផេក(Facebook Page) មានសារបង្ហោះទៅដល់(Page Reach) ចំនួន**៣១ ១២០លើក** អ្នកចូលមើលទំព័រ(Page Visit) ចំនួន**៥ ០០០លើក** ការចូលរួម(Page Engagement) ចំនួន**១១ ៤៦១លើក** ការចែករំលែក(Share) ចំនួន**៣៥៧**ដង និងអ្នកតាមដានថ្មីនិងចូលចិត្តផេក(New Likes and Follows) **ចំនួន១២០នាក់**។ បច្ចុប្បន្ន អ្នកចូលចិត្តទំព័រសរុប(Page Follower) ចំនួន**៤៤ ១៦៧នាក់** និងអ្នកតាមដានសរុប(Page Following)ចំនួន**១១០ ០០០នាក់**

- **វេទិកាសម្ព័ន្ធសង្គមស៊ីវិល(វ.ស.ស.)** ហ្វេសប៊ុកផេក(Facebook Page) របស់វេទិកាសម្ព័ន្ធសង្គមស៊ីវិល មានឈ្មោះថា «CSAF - វសស» មានអ្នកតាមដាន(Followers) ចំនួន**៩ ១៣២** ចំនួនអ្នកចូលចិត្ត(Likes) សរុប**៨ ៧១០** សារបង្ហោះទៅដល់អ្នកមើល(Page reach) ចំនួន**៣៣ ៩០០លើក** ចំនួន Content Interactions(ដូចជាLike, Share, and Comment) មាន**៤៦០០លើក** និងមានអ្នកតាមដាន និងចូលចិត្តផេក(New Likes and Followers) ចំនួន**៤៥១**

- **អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល** អ.អ.រ. បានផលិតនិងផ្សព្វផ្សាយវីដេអូ សរុប**៦៨វីដេអូ**។ ជាមួយគ្នានេះ អ.អ.រ.បានធ្វើការផ្សព្វផ្សាយនិងធ្វើការចែករំលែកការផ្សព្វផ្សាយចេញពីបណ្តាញសង្គមផ្លូវការរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងៗលើFacebook Page និងTelegram Channel របស់អ.អ.រ. ចំនួន**៨៤លើក** ជាទម្រង់វីដេអូ**៨៣លើក** ផ្សាយបន្តផ្ទាល់**៣៦លើក** ប្រព័ន្ធYoutube Channel ជាទម្រង់វីដេអូចំនួន ៨៣លើក ផ្សាយបន្តផ្ទាល់ចំនួន**៣៦លើក** ប្រព័ន្ធTiktok ជាទម្រង់វីដេអូចំនួន**៨៣លើក** និងCool App ផ្សាយចំនួន**៨៤លើក** ជាទម្រង់វីដេអូចំនួន**៨៣លើក**។ បច្ចុប្បន្ន Facebook Page ទទួលបានPage Viewsចំនួន**១.៦លាននាក់** Post Engagement ចំនួន **៣៥.៤ពាន់ដង** និងPage Followers ចំនួន**២.៤ពាន់នាក់**។ YouTube Channel មានViews សរុប **៤២.៧ពាន់នាក់** Subscribers ចំនួន**៥១៨នាក់**។ Telegram មានSubscribers ចំនួន**១៩ ០៥៣នាក់**។ Cool Ap មានSubscribers ចំនួន**២៧៥នាក់**។ គេហទំព័រផ្លូវការ http://rgsu.gov.kh របស់ អ.អ.រ. មានអ្នកចូលទស្សនាប្រចាំថ្ងៃជាមធ្យមចំនួន**១០០ ទៅ២០០ដង**

- **អង្គភាពព័ត៌មាននិងប្រតិកម្មរហ័ស** បាននិពន្ធ ផលិត និងផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ក្នុងនោះ Facebook Page ផ្លូវការមាន Follower សរុប**៣២០ ១៥៥នាក់** និង Page ក្រៅផ្លូវការចំនួន៧ទៀត មានFollower សរុប**៤៩១ ១១៣នាក់**។ ដោយឡែកក្នុងខែមករា ឆ្នាំ២០២៦ មានអ្នកFollower ផេកផ្លូវការបានកើនឡើងចំនួន**៩៥៩៣នាក់**, Comment មានចំនួន**៨២ ០១១**, Like មានចំនួន**៣១៧ ០១៤** និងView មានចំនួន**២៣ ៤៦០ ៤៤៤**។ គណនីTikTok ផ្លូវការនិងក្រៅផ្លូវការមានFollower សរុប**៥៧ ៥៦៥** និងPost សរុប**៧៣៤** វីដេអូដែលទទួលបានView ចំនួន**២១៣ ៩១៨**។ Websites ផ្លូវការនិងក្រៅផ្លូវការមានចំនួន៤ សរុប Post មាន**៥៤៧ប្រធានបទ**។ Youtubeផ្លូវការនិងក្រៅផ្លូវការមាន**៥Channels** បង្ហោះវីដេអូបាន**១ ១១៧វីដេអូ**។ Telegram ផ្លូវការនិងក្រៅផ្លូវការមាន៦Channels បង្ហោះសរុបបាន**៣៦៤៥ប្រធានបទ**, Share បាន**១០០ ៦៨០** និងទទួលបាន View សរុប **១ ២៩៥ ៧៩៩នាក់**។ CoolApp មានចំនួន៣Accounts, Post បានចំនួន**៩៩០ប្រធានបទ**។ X(Twritter) មាន**៤Accounts**, Post បានចំនួន**១ ៧៦៧ប្រធានបទ**។

- ***លេខាធិការដ្ឋាននៃគណកម្មាធិការជាតិប្រឆាំងភេរវកម្ម*** បានបកប្រែនិងផ្សព្វផ្សាយព័ត៌មានភេរវកម្ម ព័ត៌មានសន្តិសុខបច្ចេកវិទ្យា**៧០០ព័ត៌មាន** នៅលើគេហទំព័រ(www.nctc.gov.kh) និងទំព័រហ្វេសបុកផ្លូវការរបស់ខ្លួន បន្តការងារស្ទួលក្នុងការអភិវឌ្ឍSoftware និងហ្វេសបុកផ្លូវការNational Counter Terrorism Committee ដែលមានអ្នកតាមដាន(follower) ចំនួន**៣២ ៣៨១នាក់**។

**៤- ក្រសួងមហាផ្ទៃ**

- បានតាមដាន និងទប់ស្កាត់ការព្យាយាមជ្រៀតចូលតាមរយៈបណ្តាញណិតវើកពីមជ្ឈដ្ឋានខាងក្រៅចំនួន**១០៤លើក**

- បានបញ្ចូលបន្ថែមទិន្នន័យមន្ត្រីរាជការទៅក្នុងប្រព័ន្ធវិភាគទម្រង់មុខចំនួន **១០៧នាក់**(ស្រី ១៧នាក់)

- បានតាមដាន ស្រាវជ្រាវរកឃើញបទល្មើសនានានៅលើបណ្តាញសង្គម រួមមាន ការបង្ហោះខ្លឹមសារបង្កចលាចលក្នុងសង្គមចំនួន**១៥៥ករណី** ឧបទ្ទវហេតុសាយប័រចំនួន**៤៧ករណី** និងឧក្រិដ្ឋកម្ម

បច្ចេកវិទ្យាចំនួន**៤៧ករណី**។ ទន្ទឹមនេះ ធ្វើការស្រាវជ្រាវ កំណត់សាវតារធានៃលកម្មីអនឡាញបានចំនួន **២០ធានៃល**(បូកយោងពីដើមគ្រាបានចំនួន១៩៦ធានៃល) និងល្បែងអនឡាញខុសច្បាប់បានចំនួន **១៤០ធានៃល**(បូកយោងពីដើមគ្រាបានចំនួន៩៩០ធានៃល)

- បានផ្សាយតាមវិទ្យុ**៣០ផ្ទាល**(ទាំងលើបណ្តាញទំនាក់ទំនងសង្គម និងកម្មវិធីទូរសព្ទដៃ) និងធ្វើការចាក់ផ្សាយ**១ ៩៩១កម្មវិធី/អត្ថបទ/វីដេអូ**។ សហការរៀបចំចាក់ផ្សាយនាទីសន្តិសុខមាតុភូមិនៅតាមបណ្តាទូរទស្សន៍ជាតិនិងឯកជន**៣២លើក** ស្មើនឹងអត្ថបទព័ត៌មាន**៧៧អត្ថបទ**

- ក្រសួងមហាផ្ទៃបាននិងកំពុងដំណើរការប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្លូវការរបស់ខ្លួនតាមរយៈ ១. គេហទំព័រនិងកម្មវិធីទូរសព្ទដៃក្រសួងមហាផ្ទៃ(www.interior.gov.kh, MOI Mobile App) ២. គេហទំព័រនិងកម្មវិធីទូរសព្ទដៃទូរទស្សន៍មហាផ្ទៃ(MoiTV Cambodia) ៣. ផ្ទាលទូរទស្សន៍ផ្កាយរណបរបស់វិទ្យុនិងទូរទស្សន៍មហាផ្ទៃ ៤. ផ្ទាលទូរទស្សន៍អង់តែនឌីជីថលរបស់វិទ្យុនិងទូរទស្សន៍មហាផ្ទៃ ៥. ផ្ទាលឌីជីថលOTT/IPTV របស់វិទ្យុនិងទូរទស្សន៍មហាផ្ទៃ ៦. បណ្តាញទូរទស្សន៍ខ្សែកាបតាមគេហដ្ឋានរបស់វិទ្យុនិងទូរទស្សន៍មហាផ្ទៃ ៧. អង់តែនឌីជីថលរបស់វិទ្យុមហាផ្ទៃ(FM90.3 ភ្នំពេញ, FM92.3 នៅខេត្តបាត់ដំបង) ៨. ប្រព័ន្ធទំនាក់ទំនងសង្គម(Facebook, Telegram, Youtube, Tiktok និង CoolApp) និង៩. ទស្សនាវដ្តីក្រសួងមហាផ្ទ និងទស្សនាវដ្តីមិត្តនគរបាលជាទម្រង់សៀវភៅនិងឌីជីថល

- បណ្តាញហ្វេសប៊ុកផ្លូវការរបស់ក្រសួងមហាផ្ទៃ រួមមាន(១) ផេកក្រសួងមហាផ្ទៃ(Ministry of Interior) មានអ្នកតាមដានផេក(Follower)ចំនួន**៦៧០ពាន់នាក់** (២) ហ្វេសប៊ុកផេកអគ្គនាយកដ្ឋានអន្តោប្រវេសន៍(General Department of Immigration-GDI) មានអ្នកតាមដានផេក(Follower)ចំនួន **១៦៣ពាន់នាក់** (៣) ហ្វេសប៊ុកផេកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានអ្នកតាមដានផេក(Follower) ចំនួន**២២៦ពាន់នាក់** (៤) ហ្វេសប៊ុកផេកទូរទស្សន៍មហាផ្ទៃ(MOI TV) មានអ្នកតាមដានផេក(Follower) ចំនួន**៧១ពាន់នាក់** និង(៥) ហ្វេសប៊ុកផេកបណ្ឌិតសភានគរបាលកម្ពុជា មានអ្នកតាមដានផេក(Follower) ចំនួន**១៧៦ពាន់នាក់**។

### ៥- ក្រសួងការពារជាតិ

បានធ្វើការផ្សព្វផ្សាយព័ត៌មានផ្សេងៗតាមវិទ្យុនិងទូរទស្សន៍ខកម ប៉ុស្តិ៍លេខ៥ រួមមាន សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភារដ្ឋសភារាជរដ្ឋាភិបាលចំនួន**៩០ដំណឹង** សកម្មភាពថ្នាក់ដឹកនាំក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាននិងសកម្មភាពកងយោធពលខេមរភូមិន្ទចំនួន**១៩៥ដំណឹង** សាររំលែកទុក្ខចំនួន**២សារ** សេចក្តីថ្លែងការណ៍ពិសេសចំនួន**១៣លើក** សុន្ទរកថាទាំងស្រុងសម្តេចធិបតីនាយករដ្ឋមន្ត្រីចំនួន**៣លើក** សារថ្វាយព្រះពរនិងជូនពរចំនួន**១៧សារ** សេចក្តីប្រកាសព័ត៌មាននិងសេចក្តីជូនដំណឹងចំនួន**២២ដំណឹង** បទយកការណ៍និងឯកសារផ្សេងៗចំនួន**៤៥លើក** ព្រមទាំងព័ត៌មានអន្តរជាតិចំនួន**៤២៨ដំណឹង**។ ធ្វើការផ្សព្វផ្សាយព័ត៌មានតាមFacebook Page រួមមាន បង្ហោះព័ត៌មានចំនួន**២៤៧ព័ត៌មាន** បង្ហោះវីដេអូចំនួន **២៥៤វីដេអូ** មានអ្នកចូលមើលចំនួន**៥២១ ៩៨២នាក់** អ្នកCommentចំនួន**៧ ៧១២នាក់** អ្នកLikeចំនួន **២២៣ ៥៣២នាក់** និងអ្នកShareចំនួន**៣៧ ០៩១នាក់**។ សារលិខិតចំនួន**៣០លិខិត** ផ្សព្វផ្សាយព័ត៌មាន

តាមគេហទំព័រក្រសួងការពារជាតិ រួមមាន វេបសាយការពារជាតិចំនួន**២៨១ព័ត៌មាន** បង្ហោះព័ត៌មានចំនួន **២៣១ព័ត៌មាន** **វីដេអូចំនួន១៦វីដេអូ** សេចក្ដីប្រកាសព័ត៌មាននិងសេចក្ដីជូនដំណឹងចំនួន**៤ករណី**។

**៦- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** បានផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពថ្នាក់ដឹកនាំតាមហ្វេសប៊ុក(Facebook Page) មានអ្នកតាមដាន(Followers) ចំនួន**៣៦៦ ៩១៣**នាក់ ហើយបណ្ដាញតេឡេក្រាមរបស់ក្រសួង មានអ្នកតាមដាន(Subscribers) ចំនួន**១៧ ៧៥៣**នាក់។

**៧- ក្រសួងអប់រំ យុវជន និងកីឡា** ធ្វើការផ្សព្វផ្សាយព័ត៌មានតាមទំព័រហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា(www.facebook.com/moeys.gov.kh) ដែលមានអ្នកតាមដានសរុប(Followers)ចំនួនជាង**៤,៧លាននាក់** និងហ្វេសប៊ុកគ្រូ(www.facebook.com/krou.moeys.gov.kh) មានអ្នកតាមដានសរុប(Followers)ចំនួនជាង**៩៣៩ពាន់នាក់**។ ចំនួនសាលាដែលមានសេវាអ៊ីនធឺណែតសម្រាប់បម្រើការងាររដ្ឋបាល និងការរៀននិងបង្រៀនក្នុងឆ្នាំសិក្សា២០២៥-២០២៦ បឋមសិក្សាចំនួន**១ ៦៤១សាលា** មធ្យមសិក្សាបឋមភូមិចំនួន**៤៥១សាលា** និងមធ្យមសិក្សាទុតិយភូមិចំនួន**៤៦៣សាលា**។

**៨- ក្រសួងសុខាភិបាល** តាមហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួង(https://www.facebook.com/MinistryofHealthofCambodia) ដែលមានអ្នកតាមដាន(Followers) សរុបចំនួន**១ ៦០៩ ៤៤៣នាក់** មានសារបង្ហោះទៅដល់(Page Views) ចំនួន**១៧៩ ៣៣៤ ៨៦០ដង** ការចូលរួម(Page Engagement) មានចំនួន**៤ ៦៨៧ ៦៤៨លើក**។ តាមChannel Telegram របស់ក្រសួងឈ្មោះ(ក្រសួងសុខាភិបាល Ministry of Health) មានអ្នកSubscribe ចំនួន**២៤ ៧១៥នាក់**។ តាមYouTube Channel មានអ្នកSubscribeចំនួន**៥ ៤០៥Subscribers**។ តាមTikTok មានអ្នកតាមដានសរុបចំនួន៨ ៦៧៤នាក់ មានអ្នកចូលចិត្ត(Like)ចំនួនជាង**២២ ៣៩៦នាក់**។

**៩- ក្រសួងសាធារណការនិងដឹកជញ្ជូន** បានធ្វើការផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពការងារនានា តាមរយៈហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួង(www.facebook.com/mpwt.gov.kh) មានអ្នកតាមដានសរុបជាង**១,៦លាននាក់**។

**១០- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** បានធ្វើការផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពការងារនានា តាមរយៈហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួង (www.facebook.com/MISTI Cambodia) ដែលមានអ្នកតាមដានសរុបប្រមាណ**៩២៣ពាន់នាក់**។

**១១- ក្រសួងទេសចរណ៍** បានផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំ ព្រមទាំងសេចក្ដីប្រកាសព័ត៌មាន សេចក្ដីជូនដំណឹង ព្រឹត្តិការណ៍ផ្សព្វផ្សាយសកម្មភាពទេសចរណ៍ រូបភាព វីដេអូ និងព័ត៌មានសំខាន់ផ្សេងៗទៀត សរុប**១៣៦មាតិកា** នៅលើបណ្ដាញសង្គមFacebook ផ្លូវការរបស់ក្រសួងទេសចរណ៍ ទទួលបានការទស្សនា(Views) សរុប**១០លានដង** ក្នុងនោះមានការទទួលបានReach សរុប**៦,៣០លាន** Post Engagement សរុប**៥៦០ ០០០** ការចូលទៅមើលទំព័រ(Page Visits) សរុប**១០៦ ០០០នាក់** និងអ្នកតាមដានថ្មី(New Page Followers) បន្ថែមចំនួន**១០ពាន់នាក់**។ ជាលទ្ធផលនេះធ្វើឱ្យបណ្ដាញសង្គម Facebook របស់ក្រសួងទេសចរណ៍ ចំនួនអ្នកតាមដានសរុប(Total Followers) ចំនួន**៤៥៥ ០០០**។

**១២- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖**

- បានពិនិត្យនិងអនុម័តលើឯកសារស្នើសុំចុះបញ្ជីពន្ធដារចំនួន១ **១៣៨សហគ្រាស**(ពន្ធធំ៦០ ពន្ធមធ្យម៥៩៨ ពន្ធតូច៤៨០)។ ការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសចំនួន**១ ៤៨៤ករណី**(ពន្ធធំ៥០៦ ពន្ធមធ្យម៨៣៦ ពន្ធតូច១៤២)

- បានធ្វើបច្ចុប្បន្នកម្មព័ត៌មានសហគ្រាស ថតរូប ស្កេនម្រាមដៃសហគ្រាសដែលបានចុះបញ្ជីតាមថ្នាលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបានមកធ្វើបច្ចុប្បន្នកម្មព័ត៌មាន ថតរូប ស្កេនម្រាមដៃមាន**៧៥១សហគ្រាស** (ពន្ធធំ៨៩ ពន្ធមធ្យម៣២៧ ពន្ធតូច៣៣៥)។

**១៣- ក្រសួងអភិវឌ្ឍន៍ជនបទ** បានធ្វើការផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពការងារនានា តាមរយៈហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួង(www.facebook.com/mrdcambodia) ដែលមានអ្នកតាមដានសរុបប្រមាណ**២២១ពាន់នាក់**។

**១៤- ក្រសួងពាណិជ្ជកម្ម** បានធ្វើការផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពការងារនានារបស់ក្រសួងតាមរយៈគេហទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង(https://www.facebook.com/moc.gov.kh) ដែលមានអ្នកតាមដានសរុបប្រមាណជាង**៧៥១ពាន់នាក់**។ ប្រមូលចងក្រងព័ត៌មានរបស់ថ្នាក់ដឹកនាំ សេចក្តីជូនដំណឹង កិច្ចប្រជុំ កិច្ចព្រមព្រៀង សេចក្តីប្រកាសព័ត៌មាន ទូទៅ សារលិខិត និងសិក្ខាសាលា ដាក់បញ្ចូលទៅក្នុងគេហទំព័រផ្លូវការបានចំនួន**១២០ព័ត៌មាន**។ បានរៀបចំបន្ថែមមុខងារប្រើប្រាស់អំពីបណ្ណាល័យអេឡិចត្រូនិកលើគេហទំព័ររបស់វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ នៃក្រសួងពាណិជ្ជកម្ម។

**១៥- ក្រសួងផែនការ** បានធ្វើការផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពការងារនានាតាមរយៈគេហទំព័រហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួង(www.facebook.com/mop.gov.kh) ដែលមានអ្នកតាមដានសរុបប្រមាណជាង**៣៦ពាន់នាក់**។

**១៦- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានផ្សព្វផ្សាយសារអប់រំពាក់ព័ន្ធនឹងអំពើហិង្សានៅលើបណ្តាញផេកហ្វេសប៊ុក នៃយុទ្ធនាការគ្រួសាររឹងមាំ(Strong Family Facebook Page) ចំនួន**៣លើក** បានផ្សព្វផ្សាយដល់អ្នកប្រើប្រាស់គណនេយ្យហ្វេសប៊ុកទូទាំងប្រទេសចំនួន**៧៨០**នាក់ មានអ្នកចូលទស្សនាចំនួន១ **០៣៣លើក** ការមានប្រតិកម្មត្រឡប់ចំនួន**១៨០លើក** និងអ្នកចែករំលែកបន្តចំនួន**២លើក**។

**១៧- ក្រសួងបរិស្ថាន** បានផ្សព្វផ្សាយព័ត៌មានបរិស្ថាន នៅលើបណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួងបរិស្ថានរួមមាន៖ ការផ្សព្វផ្សាយនៅលើបណ្តាញទំនាក់ទំនងសង្គមតាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយការផ្សព្វផ្សាយនៅលើបណ្តាញទំនាក់ទំនងសង្គមតាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយ៖ ១- ទំព័រហ្វេសប៊ុក(Ministry of Environment) មានអ្នកតាមដានចំនួន**៤៦១ ១៨៩នាក់** និងអ្នកទស្សនាចំនួន**២ ៩៨៣ ១០០នាក់** ដោយបានចុះផ្សាយ រួមមាន រូបភាព ចំនួន**២៦៨រូបភាព** និង អត្ថបទចំនួន**៣១៤** និងជាវីដេអូចំនួន**៥៤វីដេអូ** ២- គេហទំព័រ(www.moe.gov.kh) បានចុះផ្សាយព័ត៌មានចំនួន**១១អត្ថបទ** ៣- ទំព័រយូធូប (ក្រសួងបរិស្ថាន Ministry of Environment) មានអ្នក Subscribe ចំនួន**៣ ២៦៩នាក់** អ្នកទស្សនា**២ ១៨៥នាក់** ៤- បណ្តាញសង្គមTik Tok ដែលមានឈ្មោះថា Ministry of Environment មានអ្នកតាមដានចំនួន**៤៥ ៦០០នាក់** និងអ្នកចូលចិត្តចំនួន**៣ ០១១ ៩៨៥នាក់** ដោយបានផុសវីដេអូចំនួន**៤៥វីដេអូ** ៥- Telegram Channel ដែលមានឈ្មោះថា (MoE News) បានចុះផ្សាយព័ត៌មានចំនួន**១៦រូបភាព** និងអត្ថបទ និងផ្សាយវីដេអូចំនួន**៩វីដេអូ**។

**១៨- ក្រសួងយុត្តិធម៌** បានធ្វើការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការក្នុងវិស័យយុត្តិធម៌ និងលិខិតបទដ្ឋានផ្សេងៗ នៅក្នុងគេហទំព័រ(Website) និងហ្វេសប៊ុកផេក(Facebook Page) របស់ក្រសួងបាន**៦៣លើក** ដោយមានអ្នកចូលចិត្ត(Like Post) ចំនួន**២៩ ០៩៣នាក់** អ្នកចូលរួមមតិ(Comment) ចំនួន**១ ៦២៤នាក់** អ្នកចែករំលែកព័ត៌មាន(Share) ចំនួន**៥ ២៩៧នាក់** និងអ្នកតាមដាន(Follow Page) ចំនួន **២៨៦ ៨៣៧នាក់**។

**១៩- ក្រសួងអធិការកិច្ច** បានផ្សព្វផ្សាយតាមហ្វេសប៊ុកផេក(Facebook Page) សកម្មភាពរបស់ថ្នាក់ដឹកនាំ រួមមាន ១)ផេកហ្វេសបុកក្រសួងអធិការកិច្ច(Ministry of Inspection) មានអ្នកតាមដាន(Follower)ចំនួន**៧០៣ន់នាក់** (២) ផេកហ្វេសបុកអគ្គនាយកដ្ឋានដោះស្រាយបណ្តឹង (៣) ផេកហ្វេសបុកនាយកដ្ឋានអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ (៤) ផេកហ្វេសបុកApsara TV11 (៥) ផេកហ្វេសបុកទូរទស្សន៍ជាតិកម្ពុជា(**ទទក-TVK**)។

**២០- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** បានធ្វើការផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពការងារនានាតាមរយៈហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួង(www.facebook.com/KhmerCultureMinistry) ដែលមានអ្នកតាមដានសរុបប្រមាណ**៤០១៣ន់នាក់**។

**២១- ក្រសួងធម្មការនិងសាសនា** បានធ្វើការផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពនានាតាមទំព័រហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួង(www.facebook.com/mocar.gov.kh) ដែលមានអ្នកតាមដានសរុបជាង**១១៥៣ន់នាក់**។ ពុទ្ធសាសនបណ្ឌិត្យបានចែកសៀវភៅជូនសាធារណជន សរុប**២០០ក្បាល**។

**២២- ក្រសួងកិច្ចការនារី** បានធ្វើការផ្សព្វផ្សាយព័ត៌មានសារអប់រំ និងសកម្មភាពថ្នាក់ដឹកនាំក្នុងហ្វេសប៊ុកផេក(Facebook Page) ផ្លូវការរបស់ក្រសួងបានចំនួន**៥៧លើក** មានអ្នកទស្សនា(View) ចំនួន **៦៦១ ៣០០ដង** ចំនួនអ្នកចូលចិត្តបញ្ចេញមតិ និងចែករំលែក(Content Interactions) មានចំនួន **១៦ ១៩២នាក់** អ្នកតាមដាន(Follow Page) ចំនួន**១៩២ ៥៣៦នាក់** យូធូប(Youtube) ចំនួន**២ ២៧៧** នាក់ តេលេក្រាម (Telegram Channel) ចំនួន**១ ០៤៤នាក់** និងតិកតុ(Tiktok) ចំនួន**៤២៥នាក់**។

**២៣- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន**៨៧ ៣៦១កន្លែង** និងបានផ្សព្វផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមដែលមានអ្នកតាមដានសរុបប្រមាណជាង**២,៥លាននាក់** ក្នុងនោះ ទំព័រFacebook មាន**២,៤លាននាក់**, តេលេក្រាម(Telegram Channel) មាន**៩ម៉ឺននាក់**, TikTok មាន**៣ម៉ឺននាក់** និង YouTube មាន**៣,៦៣ន់នាក់**។ បន្ថែមពីនេះ បានផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពរបស់ថ្នាក់ដឹកនាំ និងលិខិតបទដ្ឋានផ្សេងៗនៅលើហ្វេសប៊ុកក្រសួងបានចំនួន**១៣៤លើក** ដោយមានអ្នកចូលចិត្ត(Like Post) ចំនួន**១៣,៥ម៉ឺននាក់** អ្នកចូលរួមមតិ(Comment) ចំនួន**៨,៧៣ន់នាក់** អ្នកចែករំលែកព័ត៌មាន(Share) ចំនួន**១,៧ម៉ឺននាក់**។

**២៤- ក្រសួងមុខងារសាធារណៈ**បានផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពរបស់ថ្នាក់ដឹកនាំ និងលិខិតបទដ្ឋានផ្សេងៗនៅលើគេហទំព័រ និងលើហ្វេសប៊ុកក្រសួងបាន**១៣៤លើក** ដោយមានអ្នកចូលចិត្ត(Like Post) ចំនួន**២៦១ ៤៥៥នាក់** អ្នកចូលរួមមតិ(Comment) ចំនួន**២១ ៥៧៧នាក់** អ្នកចែករំលែកព័ត៌មាន (Share) ចំនួន**៣២ ៥១៨នាក់** អ្នកតាមដាន(Follow Page) ចំនួន**៥១៧ ២៤៥នាក់** យូធូប(Youtube) ចំនួន២ ៩៤២នាក់ តេលេក្រាម(Telegram Channel) ចំនួន៩០ ១៨៨នាក់ និងតិកតុ(Tiktok) ចំនួន១៤ ១៧០នាក់។

**២៥- ក្រសួងធនធានទឹកនិងឧតុនិយម** បានផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពរបស់ថ្នាក់ដឹកនាំ ព្រឹត្តិបត្រព័ត៌មាន និងព្យាករណ៍កម្ពស់ទឹកប្រចាំថ្ងៃ ស្ថានភាពធាតុអាកាសនៅព្រះរាជាណាចក្រកម្ពុជាប្រចាំថ្ងៃ និងលិខិតបទដ្ឋានផ្សេងៗ នៅលើគេហទំព័រ និងលើហ្វេសប៊ុកក្រសួង(https://mowram.gov.kh/https://www.facebook.com/mowramcambodia/) បានចំនួន**១៩៦លើក** ដោយមានអ្នកចូលចិត្ត (Like Post) ចំនួន**៧៤ ៦៣៦**នាក់ អ្នកចូលរួមមតិ(Comment) ចំនួន**៣ ៦៧០នាក់** អ្នកចែករំលែកព័ត៌មាន(Share) ចំនួន**១៥ ០១៣**នាក់ និងអ្នកតាមដាន(Follow Page) ចំនួន**១ ២៨៤ ១០២**នាក់។

**២៦- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** គេហទំព័រ(website) ឈ្មោះ "www.mlmupc.gov.kh" បានផ្សព្វផ្សាយព័ត៌មានចំនួន១៤អត្ថបទ និងអ្នកតាមដានសរុបចំនួន**១៣៨ ០០០ដង** ផេកហ្វេសប៊ុកផ្លូវការ (Facebook) ឈ្មោះ "ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់" ដែលមានអ្នកFollow សរុបចំនួន**២៨៨ ០០០**នាក់ បានបង្ហោះផ្សព្វផ្សាយព័ត៌មានចំនួន**២១៨អត្ថបទ** និងវីដេអូចំនួន**៣៨វីដេអូ** មានអ្នកតាមដានសរុបចំនួន**៤ ២៨៦ ៧០៨ដង** និងអ្នកចែកចាយបន្ត(Share) ចំនួន**៣២៨ ៣៦៦ដង** តេឡេក្រាម(Telegram) ឈ្មោះ "ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់" ដែលមានអ្នកFollow សរុប**៣៧ ០៩១**នាក់ បានផ្សព្វផ្សាយសមិទ្ធផលរបស់ក្រសួងចំនួន**២២៥អត្ថបទ** និងវីដេអូចំនួន**៣៨វីដេអូ**។

**២៧- រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន** បាននិងកំពុងប្រើប្រាស់វេទិកាឌីជីថល តាមរយៈកម្មវិធីបណ្ដាញសង្គមហ្វេសប៊ុក(Facebook) បានបង្កើតទំព័រហ្វេសប៊ុកផ្លូវការមានឈ្មោះ «**រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**» ដើម្បីផ្សព្វផ្សាយជូនសាធារណជននូវសកម្មភាពនិងព័ត៌មានពិតប្រាកដទាក់ទងនឹងការងារព្រំដែន។ បច្ចុប្បន្ននេះ ទំព័រហ្វេសប៊ុកផ្លូវការរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន មានអ្នកចូលចិត្តចំនួនប្រមាណជាង**១៥៣**ពាន់នាក់ និងអ្នកតាមដានចំនួនប្រមាណជាង**២៥៣ពាន់នាក់**។

**២៨- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល** បានធ្វើការផ្សព្វផ្សាយនិងសកម្មភាពការងារនានាតាមរយៈហ្វេសប៊ុកផេកផ្លូវការរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល(State Secretariat of civil aviation) មានអ្នកតាមដានផេក(Followers) ប្រមាណ**១១៣**ពាន់នាក់ និងផេកផ្លូវការអាកាសយានដ្ឋានអន្តរជាតិតេជោ មានអ្នកតាមដានផេក(Followers) ប្រមាណ**៣៨**ពាន់នាក់។

**២៩- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ បានធ្វើការអប់រំផ្សព្វផ្សាយអំពីគ្រោះថ្នាក់គ្រឿងញៀននៅគេហទំព័រ(www.nacd.gov.kh) មានអ្នកទទួលសារអប់រំចំនួន**១ ០០១ ៣០៨**នាក់ (ស្រី៥៧០ ៤៩០ )។

## ២- ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តន៍ឌីជីថល

**ការងារលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ី ធុរកិច្ចថ្មី ធុរកិច្ចឌីជីថល និងពាណិជ្ជកម្ម**

**២.១- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖**

ចំណូលពន្ធអាករគ្រប់ប្រភេទ ដែលប្រមូលតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានបែងចែកតាមប្រភេទអ្នកជាប់ពន្ធ ក្នុងនោះ អ្នកជាប់ពន្ធធំចំនួន**៩១៧,៦៩ ប៊ីលានរៀល**(ប្រមាណជា២២៨,៥១លានដុល្លារអាមេរិក) ស្មើនឹង**៦៤,០៨%** ធៀបនឹងចំណូលពន្ធអាករសរុប បើធៀបនឹងខែដូចគ្នាឆ្នាំមុន ចំណូលតាមប្រភេទអ្នកជាប់ពន្ធធំ ថយចុះចំនួន**៩២,០៩ប៊ីលានរៀល** (ប្រមាណជា២២,៩៦លានដុល្លារអាមេរិក) ស្មើនឹង៩,**១២%** អ្នកជាប់ពន្ធមធ្យមចំនួន**៤៣៦,១១ប៊ីលានរៀល**

(ប្រមាណជា១០៨,៧៥លានដុល្លារអាមេរិក) ស្មើនឹង**៣០,៨៥%** ធៀបនឹងចំណូលពន្ធអាករសរុប បើធៀបនឹងខែដូចគ្នាឆ្នាំមុន ចំណូលតាមប្រភេទអ្នកជាប់ពន្ធមធ្យមកើនឡើងចំនួន**២០៣,៦១ប៊ីលានរៀល**(ប្រមាណជា៥០,៧៧លានដុល្លារអាមេរិក) ស្មើនឹង**៨៧,៥៨%** អ្នកជាប់ពន្ធតូចចំនួន**១១,៥៦ប៊ីលានរៀល**(ប្រមាណជា២,៨៨លានដុល្លារអាមេរិក) ស្មើនឹង**០,៨១%** ធៀបនឹងចំណូលពន្ធអាករសរុប បើធៀបនឹងខែដូចគ្នាឆ្នាំមុន ចំណូលតាមប្រភេទអ្នកជាប់ពន្ធតូចកើនឡើងចំនួន**១,២០ប៊ីលានរៀល**(ប្រមាណជា០,៣០លានដុល្លារអាមេរិក) ស្មើនឹង**១១,៥៨%** និងផ្សេងៗ(ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើអចលនទ្រព្យ និងពន្ធផ្សេងៗ)ចំនួន៦៦,៨០**ប៊ីលានរៀល**(ប្រមាណជា១៦,៦៦លានដុល្លារអាមេរិក) ស្មើនឹង**៤,៦៦%** បើធៀបនឹងចំណូលពន្ធអាករសរុប បើធៀបនឹងខែដូចគ្នាឆ្នាំមុន ចំណូលពន្ធផ្សេងៗកើនឡើងចំនួន**១៦,៣៤ ប៊ីលានរៀល**(ប្រមាណជា៤,០៧លានដុល្លារអាមេរិក) ស្មើនឹង**៣២,៣៨%**។

**២.២- ក្រសួងពាណិជ្ជកម្ម៖**

- ចុះបញ្ជីក្រុមហ៊ុនថ្មី ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនបរទេសចំនួន**៥៦១ក្រុមហ៊ុន** បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**៥៤៤ក្រុមហ៊ុន** កើនឡើង**១៧ក្រុមហ៊ុន** ស្មើនឹង**៣,១២%**។ ការចុះបញ្ជីកែប្រែផ្សេងៗរបស់ក្រុមហ៊ុនការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនក្នុងស្រុកបានចំនួន**១ ១៣៦ក្រុមហ៊ុន** បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**១ ១៨០ក្រុមហ៊ុន** ថយចុះ**៤៤ ក្រុមហ៊ុន** ស្មើនឹង**៣,៧២%**។ ការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម(តាមការស្នើសុំ)ចំនួន**១០៥ក្រុមហ៊ុន** បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**១០២ក្រុមហ៊ុន** កើនឡើង**៣ក្រុមហ៊ុន** ស្មើនឹង**២,៩៤%**
- ចុះបញ្ជីពាណិជ្ជសញ្ញា**៦១១ម៉ាក** បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**២៣៧ម៉ាក** កើនឡើង **៣៧៤ម៉ាក** ស្មើនឹង**២៥៧,៨១%**។

គិតមកដល់បច្ចុប្បន្ននេះ ការចុះបញ្ជីក្រុមហ៊ុនថ្មី ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនបរទេសមាន**១០៦ ៧៧១ក្រុមហ៊ុន** និងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម តាមការស្នើសុំមាន**៧ ៧២៧ក្រុមហ៊ុន** ព្រមទាំងចុះបញ្ជីពាណិជ្ជសញ្ញាបាន**១១៨ ១៤៥ម៉ាក**។

**៣- ការកសាងនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍៖**

**ក- អ៊ីនធឺណិតចល័តនិងអចល័ត**(គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៥)

ក្រុមហ៊ុនអ៊ីនធឺណិតមាន**៤៣ក្រុមហ៊ុន** មានអ្នកប្រើសេវាអ៊ីនធឺណិតចល័តនិងអចល័តសរុបចំនួន**២០ ៥៧៥ ៩០២នាក់** ក្នុងនោះអ៊ីនធឺណិតចល័តចំនួន**១៩ ៧៤១ ៥៣៣នាក់** និងអ៊ីនធឺណិតអចល័តចំនួន**៨៣៤ ៣៦៩នាក់**។

**ខ- ទូរសព្ទចល័តនិងអចល័ត**(គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៥)

ក្រុមហ៊ុនទូរសព្ទចល័ត និងអចល័តមាន**៨ក្រុមហ៊ុន** មានអ្នកប្រើប្រាស់សរុប**២១ ៥៦៨ ៨៣៥ នាក់/ស៊ីមកាត** ក្នុងនោះ ទូរសព្ទចល័តចំនួន**២១ ៥៥១ ០៤១ស៊ីមកាត** និងទូរសព្ទអចល័តចំនួន**១៧ ៧៩៤ នាក់**។

**គ- បរិមាណនៃការសន្ទនាតាមទូរសព្ទ**(គិតត្រឹមខែធ្នូ ឆ្នាំ២០២៥)

ការសន្ទនាទូរសព្ទក្នុងប្រទេសមាន**៣៦៥ ៥៨៦នាទី** ក្នុងនោះហៅចូលមាន**៩៦ ៨១៦នាទី** និងហៅចេញមាន**២៦៨ ៧៧០នាទី**។ ការសន្ទនាទូរសព្ទក្រៅប្រទេសមាន**៩ ៦៩៤ ៨២១នាទី** ក្នុងនោះហៅចូលមាន**៩ ៦៨៤ ៣៧៦នាទី** និងហៅចេញមាន**១០ ៤៤៥នាទី**។

ឃ- កិច្ចព្រមព្រៀងប្រើប្រាស់ Verify.gov.kh

គិតត្រឹមបំណាច់ខែមករា ឆ្នាំ២០២៦ ក្រសួង ស្ថាប័នចំនួន**២៨** គ្រឹះស្ថានឧត្តមសិក្សារដ្ឋចំនួន**២៧** និងគ្រឹះស្ថានអប់រំឯកជនចំនួន**២៩** នីតិបុគ្គលឯកជនចំនួន**១** និងអង្គការចំនួន**១** បានចុះអនុស្សរណៈ នៃការយោគយល់កិច្ចព្រមព្រៀង និងប្រកាសអន្តរក្រសួងជាមួយក.ប.ទ. និងគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល។ ក.ប.ទ. នៃព្រះរាជាណាចក្រកម្ពុជាក៏បានចុះអនុស្សារណៈនៃការយោគយល់ជាមួយបណ្តាប្រទេស ស្ថាប័ន និងក្រុមហ៊ុនអន្តរជាតិ រួមមាន ប្រទេសឡាវ ទីម័រឡេស្តេ ហ្វីលីពីន កាហ្សាក់ស្ថាន ប្រទេសអាស៊ែបៃហ្សង់ ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD) គណៈកម្មាធិការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់អាស៊ីប៉ាស៊ីហ្វិក(UN-ESCAP) ក្រុមហ៊ុនSTMicroelectronics និងក្រុមហ៊ុន TATIUS Limited

## ៤- ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល

ប្រព័ន្ធផ្សព្វផ្សាយជាតិ បានយកចិត្តទុកដាក់ប្រមូលផ្តុំផ្សព្វផ្សាយនូវព្រឹត្តិការណ៍សំខាន់ៗជូនមជ្ឈដ្ឋានជាតិ និងអន្តរជាតិ មានជាអាទិ៍៖

ក- ព្រះរាជសកម្មភាពរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា៖**

- យាងសួរសុខទុក្ខវីរកងទ័ពសមរភូមិជួរមុខ និងយាងជួបសំណេះសំណាលជាមួយវីរកងទ័ពទាំង**១៨**នាក់ សរុបចំនួន**២លើក**

- ព្រះរាជានុញ្ញាតឱ្យភ្ញៀវជាតិ អន្តរជាតិទូលក្រាបបង្គំគាល់ធ្វើសវនាការនៅព្រះបរមរាជវាំង។

ខ- សកម្មភាពរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភានិងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា៖**

- អញ្ជើញចូលរួមក្នុងពិធីចម្រើនព្រះបរិត្តឡើងអគារវិមានសាមគ្គីភាព(អគារថ្មីព្រឹទ្ធសភា) ពិនិត្យវឌ្ឍនភាពនៃការសាងសង់អគារថ្មីព្រឹទ្ធសភា និងជួបសំណេះសំណាលជាមួយវីរកងទ័ពទាំង**១៨**នាក់ សរុប**៣លើក**

- អនុញ្ញាតឱ្យភ្ញៀវជាតិ អន្តរជាតិចូលសម្តែងការគួរសមនិងធ្វើសវនាការនៅវិមានព្រឹទ្ធសភា។

គ- សកម្មភាពរបស់**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា៖

- អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងកិច្ចប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ សរុប**៣លើក**

- អញ្ជើញចូលរួមក្នុងពិធីចម្រើនព្រះបរិត្តឡើងអគារវិមានសាមគ្គីភាព(អគារថ្មីព្រឹទ្ធសភា) បុណ្យសពនិងគោរពវិញ្ញាណក្ខន្ធសព និងទទួលអំណោយសប្បុរសធម៌ សរុប**៧លើក**

- អនុញ្ញាតឱ្យភ្ញៀវជាតិ អន្តរជាតិចូលសម្តែងការគួរសមនិងធ្វើសវនាការនៅវិមានរដ្ឋសភា។

ឃ- សកម្មភាពរបស់**ទូលព្រះបង្គំជាខ្ញុំ** ព្រមទាំងសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការជាតិនិងអន្តរជាតិ និងសហគមន៍ជាតិ។

ទន្ទឹមនេះ ក៏បានធ្វើការផ្សព្វផ្សាយនាទីសន្តិសុខមាតុភូមិ កងយោធពលខេមរភូមិន្ទ អប់រំ សុខភាព បរិស្ថាន ការប្រែប្រួលអាកាសធាតុ អនាម័យសាធារណៈ ជំងឺរាលដាលផ្លូវដង្ហើមកូវីដ-១៩ កីឡា រមណីយដ្ឋានទេសចរណ៍ សេដ្ឋកិច្ចហិរញ្ញវត្ថុ សេវាកម្មធនាគារ មីក្រូហិរញ្ញវត្ថុ ការអភិវឌ្ឍធនធានមនុស្ស ផ្លូវ ស្ពាន ទឹក អគ្គិសនី កសិកម្ម ឧស្សាហកម្ម សិប្បកម្ម វប្បធម៌ សិល្បៈ ប្រពៃណីជាតិ ការយល់ដឹងពីព្រះពុទ្ធសាសនា ធម្មទេសនា ទីផ្សារអចលនទ្រព្យ នគរូបនីយកម្ម បដិវត្តន៍ឧស្សាហកម្ម៤.០ ចំណេះដឹងទូទៅ ស្ត្រី សមភាពយេនឌ័រ យុវជន និងកុមារជាដើម។

ទូរទស្សន៍ជាតិកម្ពុជា បានធ្វើការផ្សាយនៅក្នុងប្រទេសរយៈពេល**៧១៨ម៉ោង** និងផ្សាយទៅបរទេស**១៤៤ម៉ោង** ជាភាសាខ្មែរ បារាំង និងអង់គ្លេស។

វិទ្យុជាតិកម្ពុជា បានដំណើរការផ្សាយជារៀងរាល់ថ្ងៃ តាមប្រព័ន្ធអាអឹមAM 918MHzនិងស្ថានីយវត្តភ្នំ អេហ្វអឹម(FM) 105.70MHz រយៈពេល**៥៧០ម៉ោង** ជាភាសាខ្មែរ បារាំង និងអង់គ្លេស និងតាមប្រព័ន្ធអេហ្វអឹម(FM) 96MHz រយៈពេល**៥៧០ម៉ោង** ជាភាសាខ្មែរ អង់គ្លេស ចិន វៀតណាម និងអ៊ិស្លាម។

ទីភ្នាក់ងារសារព័ត៌មានកម្ពុជា(AKP) បានបោះពុម្ពផ្សាយព្រឹត្តិបត្រអេឡិចត្រូនិកបាន**១៨លេខ**។

ជាមួយគ្នានេះក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ក៏បានធ្វើការផ្សព្វផ្សាយសកម្មភាពការងាររបស់ខ្លួនតាមរយៈបណ្តាញសង្គមនានាជូនសាធារណជនជាតិ និងអន្តជាតិផងដែរ។

**៥- ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ**

១- **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តាមរយៈអគ្គនាយកដ្ឋានពន្ធដារបានបន្តធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានពន្ធដារសម្រាប់គាំទ្រដល់ការគ្រប់គ្រងការប្រមូលចំណូលពន្ធ និងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធ ក្នុងនោះ ប្រព័ន្ធនិងកម្មវិធីបានបញ្ចប់ការអភិវឌ្ឍថ្មីមានចំនួន**២** ប្រព័ន្ធនិងកម្មវិធីកំពុងអភិវឌ្ឍន៍ថ្មីមានចំនួន**៥** ប្រព័ន្ធនិងកម្មវិធីបានធ្វើបច្ចុប្បន្នភាពមានចំនួន**១៧**(ស្មើនឹង២៨លើក) និងប្រព័ន្ធនិងកម្មវិធីកំពុងធ្វើបច្ចុប្បន្នភាពមានចំនួន**១៨**(ស្មើនឹង៣២លើក)។

២- **ក្រសួងសាធារណការនិងដឹកជញ្ជូន** បានផ្តល់លិខិតអនុញ្ញាតនាំវាបរទេសចេញចូលកំពង់ផែ (តាមប្រព័ន្ធអនឡាញ)ចំនួន**៤៩៩ច្បាប់**។

៣- **ក្រសួងយុត្តិធម៌** បានចេញព្រឹត្តិបត្រថ្កោលទោសថ្មីតាមប្រព័ន្ធអនឡាញ(Online) ជូនប្រជាពលរដ្ឋចំនួន**៥ ៨៥៣ច្បាប់** សល់ពីមុនចំនួន**៤ ៦០៩ច្បាប់** សរុប**១០ ៤៦២ច្បាប់** ក្នុងនោះ ចាត់ការរួចចំនួន**៥ ៩៨៧ច្បាប់** និងកំពុងចាត់ការចំនួន**៤ ៤៧៥ច្បាប់**។

៤- **ក្រសួងមហាផ្ទៃ** ផ្តល់លិខិតឆ្លងដែនជូនប្រជាពលរដ្ឋដែលបំពេញបែបបទស្នើសុំតាមអនឡាញបានចំនួន**១៩០នាក់** និងចុះផ្តល់លិខិតឆ្លងដែនជូនប្រជាពលរដ្ឋដែលមានជំងឺ ចាស់ជរា ឬជនមានពិការភាព ដល់លំនៅឋានចំនួន**២នាក់**។

## វឌ្ឍនភាពនៃការអនុវត្តកម្មវិធីគោលនយោបាយជាអាទិភាពទាំង៦ និងវឌ្ឍនភាពនៃការអនុវត្តវិធានការគន្លឹះទាំង៥

ក្នុងខែមករា ឆ្នាំ២០២៦នេះ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧នៃរដ្ឋសភា បាននិងបន្តខិតខំជំរុញអនុវត្តនូវកម្មវិធីកែទម្រង់សំខាន់ៗ ដូចមានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្នុងនោះមានកម្មវិធីគោលនយោបាយជាអាទិភាពចំនួន៦ និងវឌ្ឍនភាពនៃការអនុវត្តនូវវិធានការគន្លឹះចំនួន៥ ដើម្បីជំរុញនិងបង្កើនល្បឿនបន្ថែមលើកិច្ចការកែទម្រង់លើវិស័យមួយចំនួន ក្នុងគោលដៅកែលម្អនិងឈានទៅកសាងសមត្ថភាពនិងយន្តការស្ថាប័នឱ្យកាន់តែរឹងមាំ ព្រមទាំងធានាបាននូវរដ្ឋបាលសាធារណៈដែលមានសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ដោយសម្រេចបានវឌ្ឍនភាពសំខាន់ៗ ដូចខាងក្រោម៖

### វឌ្ឍនភាពនៃការអនុវត្តកម្មវិធីគោលនយោបាយជាអាទិភាពទាំង៦

**ទី១- ការផ្តល់ការថែទាំសុខភាពឆ្ពោះទៅកម្មវិធីគ្របដណ្តប់សុខភាពជាសកល៖** រាជរដ្ឋាភិបាលបានអនុវត្តដោយចាប់ផ្តើមពី (១) ការផ្តល់សេវាថែទាំសុខភាពជូនគ្រួសារងាយរងហានិភ័យប្រមាណជាង **៤៥ម៉ឺនគ្រួសារ** ស្មើនឹងសមាជិកសរុបជាង**១,៥លាននាក់** តាមរយៈការប្រើប្រាស់មូលនិធិសមធម៌សុខាភិបាល និង(២) ការពង្រីករបប ថែទាំសុខភាពរបស់របបសន្តិសុខសង្គម(ប.ស.ស.) ទាំងសម្រាប់កម្មករ និយោជិត និងសម្រាប់មន្ត្រីសាធារណៈ ដែលគ្របដណ្តប់បន្ថែមដល់សមាជិកគ្រួសារ និងអ្នកក្នុងបន្ទុកពួកគាត់ប្រមាណជាង**៣លាននាក់** តាមគោលការណ៍ស្ម័គ្រចិត្ត។ ជាសរុប គម្រោងទាំងពីរនេះ នឹងធ្វើឱ្យប្រជាជនប្រមាណ **៧,៤លាននាក់** មានលទ្ធភាពទទួលបាននូវប.ស.ស. ផ្នែកសេវាថែទាំសុខភាព។ ជាក់ស្តែង រាជរដ្ឋាភិបាលបានអនុវត្ត «របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិកប.ស.ស.» ដោយក្នុងខែមករា ឆ្នាំ២០២៦នេះ បានចុះបញ្ជីសមាជិកថ្មីតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិកប.ស.ស. ចំនួន **២៧ ៦៨៩នាក់**(ស្រី១៦ ៤៧៦នាក់)។ គិតត្រឹមខែមករា ឆ្នាំ២០២៦នេះ សមាជិកប.ស.ស. ផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តមានចំនួន**៨៨៣ ៣៣០នាក់**(ស្រី៥២៩ ៥៩១នាក់)។ សមាជិក ប.ស.ស. តាមរបបភាគទានដោយស្ម័គ្រចិត្ត បានទៅប្រើប្រាស់សេវាផ្នែកថែទាំសុខភាពតាមមូលដ្ឋានសុខាភិបាលចំនួន**១៩៨ ៦៣៨ដង**(ស្រី១៣១ ៦២១ដង) និងចំណាយតាវកាលិកអស់ប្រមាណ**២០ ៤៦៤ លានរៀល** ព្រមទាំងបានផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រចំនួន១ករណី(ស្រី១ករណី)។

**ទី២- ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស៖** រាជរដ្ឋាភិបាល បានបន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ(១,៥លាននាក់) ដោយមិនបង់ថ្លៃនិងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ តាមអភិក្រម «រៀនឱ្យចប់ ឱ្យចេះ ឱ្យមានការងារ» កម្រិតC1 តាមប្រព័ន្ធTVET 1.5M។ គិតត្រឹមខែមករា ឆ្នាំ២០២៦ កម្មវិធីនេះមានអ្នកស្នើចុះឈ្មោះចូលរៀនសរុបចំនួន**១៥៦ ៤៧០នាក់**(មានបណ្ណសមធម៌ឬបណ្ណងាយរងហានិភ័យចំនួន៦៦ ៨៣០នាក់) សិស្សកំពុង

សិក្សានិងបានបញ្ចប់សរុប៩៤ ៥១៣នាក់(មានបណ្ណសមធម៌ឬបណ្ណងាយរងហានិភ័យចំនួន៤៥ ៩២៦នាក់) ក្នុងនោះ សិស្សកំពុងសិក្សាមានចំនួន**១២ ២៥៨នាក់**(មានបណ្ណសមធម៌ ឬបណ្ណងាយរងហានិភ័យចំនួន៤ ៦៨២នាក់) និងសិស្សបានបញ្ចប់ការសិក្សាចំនួន៨២ **២៥៥នាក់**(មានបណ្ណសមធម៌ឬបណ្ណងាយរងហានិភ័យចំនួន៤១ ២៤៤នាក់) ដោយមានសិស្សទទួលបានការងារធ្វើចំនួន**៥៤ ៣៣០នាក់**(មានបណ្ណសមធម៌ឬបណ្ណងាយរងហានិភ័យចំនួន៤១ ២៤៤នាក់)។

**ទី៣- ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ចនិងគ្រាមានអាសន្នៈ** នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និងគ្រាមានគ្រោះអាសន្ន ដើម្បីជួយទ្រទ្រង់ និងផ្តល់ការគាំពារទាន់ពេល និងក្នុងលក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋ ជាពិសេសគ្រួសារក្រីកនិងងាយរងគ្រោះ និងគ្រួសារងាយរងហានិភ័យទៅតាមស្ថានភាពជាក់ស្តែងនៃវិបត្តិឬគ្រោះអាសន្ន នៅតាមគ្រប់ទីតាំងភូមិសាស្ត្រទូទាំងប្រទេស ដែលនឹងគ្របដណ្តប់លើប្រជាជនសរុបប្រមាណ**៤,៣លាននាក់**។ រាជរដ្ឋាភិបាល បានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារគោលដៅដែលបានចុះឈ្មោះក្នុងកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារសរុប**៧១២ ២៩៦គ្រួសារ** ក្នុងនោះជនចាស់ជរាចំនួន**៣៧៤ ៧៥៩នាក់** ជនមានពិការភាពចំនួន**៥៨ ៩១៩នាក់** អ្នកផ្ទុកមេរោគ/កើតជំងឺអេដស៍ចំនួន**៦ ២២៩នាក់** និងសិស្សានុសិស្សចំនួន៣៩០ ៦៨១នាក់ ស្ត្រីមានផ្ទៃពោះចំនួន៤ ១១៨នាក់ និងកុមារអាយុក្រោម២ឆ្នាំចំនួន **១ ៥២២នាក់** ចំណាយថវិកាសរុប**៤៨ ៩៦៩ ៣៦០ ០០០រៀល**។

**ទី៤- ការដាក់ចេញនិងការជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការៈ** រាជរដ្ឋាភិបាលបានអនុវត្តនិង អាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ តាមរយៈ (១) ការផ្តល់នូវការគាំពារនិងការបង្កើតនូវបរិយាកាសអំណោយផលសម្រាប់ធ្វើធុរកិច្ច និងពាណិជ្ជកម្ម ព្រមជាមួយនឹងការផ្តល់នូវការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈដល់ក្រុមហ៊ុន សហគ្រាសធុនមីក្រូ តូច និងមធ្យម។ ជាក់ស្តែង រាជរដ្ឋាភិបាល បានអនុញ្ញាតឱ្យក្រុមហ៊ុនវិនិយោគលើគម្រោងថ្មី និងគម្រោងពង្រីកផលិតកម្មចំនួន**៤៣គម្រោង** មានទុនវិនិយោគសរុប**៧៥១ ៤៥០ ០១៦ដុល្លារអាមេរិក** និងអាចបង្កើតការងារចំនួន**២៥ ៩៥៧កន្លែង**។ រោងចក្របង្កើតថ្មី**៣៨រោងចក្រ** និងបង្កើតការងារថ្មី**៧ ៤៦៨នាក់**។ គិតត្រឹមដំណាច់ខែមករា ឆ្នាំ២០២៦នេះ មានរោងចក្រសរុប**៣ ១១២រោងចក្រ** និងពលកម្មសរុប**១ ២៧០ ១៣១នាក់**។ សហគ្រាសធុនតូច មធ្យម និងសិប្បកម្មបង្កើតថ្មី**១០៩មូលដ្ឋាន** និងបង្កើតការងារថ្មី**២ ០១៧នាក់**។ គិតត្រឹមដំណាច់ខែមករា ឆ្នាំ២០២៦នេះ មានសហគ្រាសធុនតូច មធ្យម និងសិប្បកម្មសរុប**៤៤ ៨៩៨មូលដ្ឋាន** និងពលកម្មសរុប**៤៩៣ ៩៣២នាក់** (២) ការងាររបបសន្តិសុខសង្គមលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ប.ស.ស. បានបោះពុម្ពបណ្ណមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមគោលដៅ រួមមានកម្មករនិយោជិតក្រៅប្រព័ន្ធ សិល្បករ សិល្បការិនី កីឡាករ កីឡាការិនី សមាគម កម្មករស៊ីក្លូ អ្នករត់ម៉ូតូឌុបនិងម៉ូតូកង់បី និងបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធសរុបចំនួន**១៣៩ ០៦០នាក់**(ស្រី ៧៧ ៩៧៦នាក់)។

**ទី៥- ការដាក់ចេញយន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទានសំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗក្នុងកម្រិតសមរម្យៈ** រាជរដ្ឋាភិបាលបានអនុវត្តក្នុងកម្រិតសមរម្យតាមរយៈការដាក់ចេញកញ្ចប់ថវិកាដាក់លាក់ និងអាចវិភាជថវិកាបន្ថែម ប្រសិនបើមានតម្រូវការចាំបាច់ ដើម្បីធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលក្នុងការទិញកសិផលពីប្រជាកសិករ ជាមួយនឹងគោលដៅរក្សាស្ថិរភាពថ្លៃនៅរាល់រដូវប្រមូលផល ជាពិសេស លើផលិតផលកសិកម្មមួយចំនួន ជាអាទិ៍ ស្រូវ ស្វាយកែវរមៀត មៀនប៉ៃលិន ស្វាយចាន់ទី ដំឡូង ពោត និងផលិតផលផ្សេងទៀតតាមការចាំបាច់។ តាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការចរចារលក្ខខណ្ឌតម្រូវភូតគាមអនាម័យ គួបផ្សំនឹងការជំរុញការនាំចេញផលិតផលកសិកម្មដែលមានទីផ្សារស្រាប់ និងការពង្រឹងការអនុវត្តគោលការណ៍សុវត្ថិភាពនិងគុណភាព ធ្វើឱ្យការនាំចេញផលិតផល សម្រេចបានចំនួន**១ ៥០១ ២៧៤តោន** កើនឡើង**១៤,៤៥%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន ហើយផលិតផលដែលមានកំណើនខ្ពស់ រួមមានស្រូវ អង្ករ ដំឡូងមី គ្រាប់ស្វាយចន្ទី គ្រាប់ពោត មៀនប៉ៃលិន និងស្វាយកែវរមៀត។ ទន្ទឹមនេះ រាជរដ្ឋាភិបាល បានចុះអន្តរាគមន៍នៅពេលជួបប្រទះបញ្ហាស្រូវធ្លាក់ថ្លៃដោយសារការធ្លាក់ចុះនៃតម្លៃអង្ករជាសកល ដោយសហការជាមួយអាជ្ញាធរមូលដ្ឋានស្ថាប័នពាក់ព័ន្ធវិស័យឯកជន មន្ត្រីកសិកម្មឃុំ និងប្រជាកសិករ ដើម្បីសម្របសម្រួលការប្រមូលទិញកសិផលមិនឱ្យកកស្ទះគ្មានទីផ្សារ ដោយទទួលបានតម្លៃសមរម្យទៅតាមគុណភាព ទោះបីជាមិនបានតម្លៃដូចដែលប្រជាកសិករចង់បានក៏ដោយ។ បន្ថែមពីនេះទៀត ក្នុងការជួយសម្របសម្រួលរក្សាស្ថិរភាពតម្លៃ រាជរដ្ឋាភិបាលបានបញ្ចេញថវិកាចំនួន**១៧០លានដុល្លារអាមេរិក** តាមរយៈធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម ក្នុងការផ្តល់កម្ចីអត្រាការប្រាក់ទាបដល់ម្ចាស់រោងម៉ាស៊ីនកិនស្រូវសម្រាប់ប្រមូលទិញស្រូវ។

**ទី៦- ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ សង្កាត់ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេសនិងការរៀបចំសហគមន៍កសិកម្មទំនើប** ដើម្បីជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម និងជួយដល់គ្រួសារកសិករ ក្នុងការលើកស្ទួយផលិតផលកសិកម្មរបស់ខ្លួន។ រាជរដ្ឋាភិបាល នីតិកាលទី៧ នឹងយកចិត្តទុកដាក់ផងដែរ ទៅលើការរៀបចំឱ្យមានសមាគមកសិករនៅតាមទីជនបទ ដើម្បីរក្សាកម្លាំងរបស់កសិករក្នុងការផលិត ក៏ដូចជាថ្លៃជាមួយអ្នកទទួលទិញ។ រាជរដ្ឋាភិបាល បានអនុវត្តដាក់ពង្រាយមន្ត្រីកសិកម្មឃុំចំនួន**១ ៦០០នាក់** ទូទាំងប្រទេស ដើម្បីជួយដោះស្រាយទាន់ពេលវេលា និងបានផ្តល់សេវាបច្ចេកទេសកសិកម្មកៀកនឹងប្រជាកសិករតែម្តង។ បន្ទាប់ពីការដាក់ពង្រាយមន្ត្រីកសិកម្មគ្រប់គោលដៅរួចមក មន្ត្រីកសិកម្មឃុំទាំងអស់បានចុះបំពេញការងារតាមមូលដ្ឋានរៀងខ្លួនដើម្បីជួយប្រជាកសិករ រួមមានបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ការធ្វើបទបង្ហាញ ចុះជួបប្រជាកសិករនៅតាមទីវាល ប្រជុំផ្សព្វផ្សាយបច្ចេកទេស សម្របសម្រួលនិងដោះស្រាយបញ្ហារបស់កសិករ និងបានជួយវិភាគថ្លៃដើមកសិផលរបស់ប្រជាកសិករ។

## ឧបសម្ព័ន្ធ៖ វឌ្ឍនភាពនៃការអនុវត្តវិធានការគន្លឹះទាំង៥

### ១- វិធានការគន្លឹះក្នុងការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ៖

រាជរដ្ឋាភិបាលបានអនុវត្តការជ្រើសរើសមន្ត្រីរាជការតាមនីតិវិធីថ្មី ប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ស្របតាមពាក្យស្លោក **«អ្នកចេះ គឺជាប់» «ជាប់ដោយមោទនៈ និងធ្លាក់ដោយអស់ចិត្ត»**។ គិតចាប់ពីថ្ងៃប្រកាសដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិលឱ្យចូលបម្រើការងារតាមក្រសួង ស្ថាប័ន ប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ក្រសួងបានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ បានរៀបចំការប្រឡងបានចំនួន**៥៣លើក** មានបេក្ខជនសរុប**១៣៤ ៨៥២នាក់**(ស្រី៤ ៤៨៦នាក់) លទ្ធផលប្រឡងជាប់មានចំនួន**៧ ៩៤៥នាក់**(ស្រី៤ ៤៩៧នាក់)។

### ២- វិធានការគន្លឹះក្នុងការលើកកម្ពស់គុណភាពអប់រំ៖

រាជរដ្ឋាភិបាល បានបង្កើតគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ (គ.វ.អ.) ដើម្បីធ្វើការកែទម្រង់និងដាក់ចេញវិធានការសម្រាប់វិស័យអប់រំពីថ្នាក់មត្តេយ្យសិក្សា ដល់មធ្យមសិក្សា ព្រមទាំងបានចុះជ្រើសរើសសាលារៀនគោលដៅចំនួន**១៦១** កម្រិតបឋមសិក្សានៅគ្រប់រាជធានី ខេត្ត សម្រាប់ការអនុវត្តជំហានដំបូង ដោយផ្តោតលើកម្មវិធីក្រៅម៉ោងសិក្សាចំនួន២ម៉ោងបន្ថែមលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា ភាសាអង់គ្លេស ឌីជីថល និងបំណិនទន់ ដែលមានសិស្សប៉ំប៉នសរុបចំនួន**៨៦ ៥៨៨នាក់** ព្រមទាំងបាននិងកំពុងអនុវត្តគន្លងអប់រំថ្មីរួមមាន គន្លងវិទ្យាសាស្ត្រ គន្លងវិទ្យាសាស្ត្រសង្គមនិងគន្លងវិជ្ជាជីវៈនៅវិទ្យាល័យ**៤៩សាលា** សិស្សចុះឈ្មោះចូលរៀននៅគន្លងវិជ្ជាជីវៈ**៤ ៦១១នាក់លើ១៣មុខជំនាញ**។ ចំពោះការអប់រំចំណេះដឹងទូទៅ រាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ «ធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត»។ ជាស្តែង (១) សាលាមត្តេយ្យសិក្សាគ្រប់រូបភាពមាន**៩ ០៣៦សាលា/កន្លែង** មានទីតាំង**១ ១១៩ឃុំ សង្កាត់** ក្នុងចំណោម**១ ៦៥២ឃុំ សង្កាត់** (២) សាលាបឋមសិក្សាសាធារណៈនិងឯកជនមានចំនួន**៨ ២៨៨សាលា** មានទីតាំងនៅគ្រប់ឃុំ សង្កាត់ (៣) គ្រឹះស្ថានមធ្យមសិក្សាសាធារណៈនិងឯកជនមាន**២ ២៦៧សាលា** មានទីតាំងចំនួន**១ ៥៤៥ឃុំសង្កាត់**។ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ មានសិស្សប្រឡងជាប់ចំនួន**១៧១ ៧១៧នាក់** ស្មើនឹង**៩៤,៣៤%** និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានសិស្សប្រឡងជាប់ចំនួន**១២២ ៤៧៣នាក់** ស្មើនឹង**៨៤,៥៦%** បេក្ខជនជាប់និទ្ទេសA ចំនួន**៣ ០០៣នាក់**។

### ៣- វិធានការគន្លឹះក្នុងការលើកកម្ពស់គុណភាពសេវាសុខាភិបាល៖

រាជរដ្ឋាភិបាល បានបង្កើតគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល (គ.វ.ស.) និងបានដាក់ចេញនូវវិធានការបន្តលើកកម្ពស់គុណភាពសេវាសុខាភិបាលតាមរយៈការពង្រឹងសេវានៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក និងការដាក់ពង្រាយបុគ្គលិកសុខាភិបាល ដើម្បីធានាសេវា២៤ម៉ោងលើ២៤ម៉ោង និង៧ថ្ងៃក្នុង១សប្តាហ៍ ព្រមជាមួយការបង្កើនបរិមាណនិងគុណភាពឱសថ

និងបរិក្ខារពេទ្យ និងការពង្រឹងក្រមសីលធម៌និងការទទួលខុសត្រូវវិជ្ជាជីវៈ។ ជាក់ស្តែង សេវាពិគ្រោះជំងឺក្រៅនៅមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជនសរុប**១ ៩២៩ ៤០៥ករណី** ការពិគ្រោះជំងឺក្រៅករណីថ្មីសរុប**១ ៣០៦ ៩៨៤ករណី**។ អ្នកជំងឺសម្រាកព្យាបាលនៅមន្ទីរពេទ្យសាធារណៈ និងមណ្ឌលសុខភាពមានគ្រែទូទាំងប្រទេសចំនួន**១៤៦ ៩៣៣នាក់**។ មជ្ឈមណ្ឌលជាតិផ្តល់ឈាមបានទទួលអ្នកស្ម័គ្រចិត្តផ្តល់ឈាមសរុបចំនួន**១០ ៤៥៤នាក់** និងបានផ្តល់ឈាមសរុបចំនួន**១៣ ៥០២ប្លោក**។ អ្នកទទួលបានការគ្របដណ្តប់ដោយមូលនិធិសមធម៌សុខាភិបាលចំនួន**៣៤៨ ៣៨៨ករណី**។

**៤- វិធានការគន្លឹះក្នុងការពង្រឹងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព៖**

ស្ថានភាពសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ កម្លាំងមានសមត្ថកិច្ចធ្វើការបង្ក្រាបបទល្មើសព្រហ្មទណ្ឌបាន**២៤៨ករណី** ឃាត់ខ្លួនជនសង្ស័យបាន**៤៥៩នាក់** គ្រោះថ្នាក់ចរាចរណ៍កើតឡើងចំនួន**២៥៦លើក** ថយចុះ**៦លើក**។ ការបង្ក្រាបបទល្មើសគ្រឿងញៀនបាន**៨៦៥ករណី** កើនឡើង**៨ករណី** ឃាត់ខ្លួនជនសង្ស័យបាន**២ ១០៨នាក់** បទល្មើសជនទំនើងចំនួន**៨៩ករណី** កើនឡើង**៥លើក** ឃាត់ខ្លួនជនសង្ស័យបាន**២០៦នាក់** ការបង្ក្រាបល្បែងស៊ីសងបាន**៤០ករណី** កើនឡើង**១៥លើក** ឃាត់ខ្លួនជនសង្ស័យបាន**១២៥នាក់** និងការបង្ក្រាបបទល្មើសបច្ចេកវិទ្យាបាន**៨ទីតាំង** ឃាត់ខ្លួនជនសង្ស័យបាន**២ ៥១១នាក់** ស្មើនឹង**១០សញ្ជាតិ**។ ព្រមទាំងបានផ្តល់សេវាផ្លូវច្បាប់ ជួយស្ត្រីរងគ្រោះដោយអំពើហិង្សា និងធ្វើអន្តរាគមន៍ទប់ស្កាត់និងឆ្លើយតបអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ក៏ដូចជាជំរុញបញ្ជ្រាបការងារយេនឌ័រនៅតាមក្រសួងស្ថាប័ន។

**៥- វិធានការគន្លឹះក្នុងការពង្រឹងនិងលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌៖**

រាជរដ្ឋាភិបាលបានបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ(អ.ជ.ក.) ព្រមទាំងបានដាក់ចេញយុទ្ធនាការចំនួន២ គឺ ទី១- យុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងទី២- យុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ព្រមទាំងបានរៀបចំឡើងវិញនូវគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីផ្តល់ការគាំទ្រដល់យុទ្ធនាការទាំងពីរខាងលើ។ ជាក់ស្តែង ក្រសួងយុត្តិធម៌ បានចេញព្រឹត្តប្រថ្កផលទោសចំនួន**១០ ៩៣៥ច្បាប់** ប្រឹក្សាយោបល់ផ្នែកច្បាប់ជូនពលរដ្ឋចំនួន**១៨៦ករណី** ការសម្រុះសម្រួលវិវាទនៅតាមមូលដ្ឋានចំនួន**៣០៧ករណី**។ ក្នុងការកែទម្រង់ច្បាប់ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងដាក់ចេញនូវគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត រួមមានបញ្ជូនសេចក្តីព្រាងច្បាប់ទៅសុំការអនុម័តពីស្ថាប័ននិតិប្បញ្ញត្តិចំនួន១។ រាជរដ្ឋាភិបាលបានក្រាបបង្គំទូលថ្វាយ សូមព្រះករុណា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ព្រះរាជទានព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់**៥** ក្រោយពីស្ថាប័ននីតិប្បញ្ញត្តិបានអនុម័តរួច។ គិតចាប់ពីឆ្នាំ១៩៩៣ ដល់ខែមករា ឆ្នាំ២០២៦ រាជរដ្ឋាភិបាលបានក្រាបបង្គំទូលថ្វាយសូមព្រះករុណា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ព្រះរាជទានព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ សរុបចំនួន**៦៩១ច្បាប់**។

# សន្និដ្ឋាន

ជារួម ក្នុងខែមករា ឆ្នាំ២០២៦នេះ សភាពការណ៍សន្តិសុខផ្ទៃក្នុង នៅព្រះរាជាណាចក្រកម្ពុជា ជាទូទៅនៅតែមានភាពល្អ ស្ថាប័នកំពូលរបស់ជាតិ ព្រះរាជសុវត្ថិភាពព្រះមហាក្សត្រ សុវត្ថិភាពថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ អន្តរជាតិនិងបណ្តាគោលដៅនយោបាយ ការទូត សេដ្ឋកិច្ច វប្បធម៌ វិនិយោគ ពាណិជ្ជកម្ម ទេសចរណ៍ ព្រមទាំងព្រឹត្តិការណ៍នយោបាយនានា ពិសេសទិវាបុណ្យចូលឆ្នាំសកល ខួបអនុស្សាវរីយ៍ទិវាជ័យជម្នះ ៧មករា ត្រូវបានធានាការពារយ៉ាងគត់មត់។ កម្មវិធីជាតិនិងអន្តរជាតិចំនួន**៩៤៧លើក** និងសកម្មភាពបាតុកម្ម កូដកម្មកើតឡើងចំនួន**១០លើក** កើនឡើង**៨លើក** បើធៀបនឹងខែកន្លងទៅ ត្រូវបានធានាសណ្តាប់ធ្នាប់និងដំណើរការដោយរលូន។ កម្លាំងមានសមត្ថកិច្ចបញ្ចៀសបាននូវអំពើភេរវកម្ម និងទប់ស្កាត់បានទាន់ពេលវេលានូវឧបាយកលទុច្ចរិតប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ តាមរយៈបដិវត្តន៍ពណ៌ពីសំណាក់ក្រុមប្រឆាំងជ្រុលនិយមនៅក្នុងនិងក្រៅប្រទេស។

ស្ថានភាពសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ បទល្មើសព្រហ្មទណ្ឌជារួមកើតឡើងចំនួន**២៥៩លើក** បើធៀបនឹងខែកន្លងទៅចំនួន**២៣១លើក** កើនឡើង**២៨លើក** ស្មើនឹង**២%** កម្លាំងមានសមត្ថកិច្ចធ្វើការបង្ក្រាបបទល្មើសព្រហ្មទណ្ឌបាន**២៤៨ករណី** ស្មើនឹង**៩៦%** ឃាត់ខ្លួនជនសង្ស័យបាន**៤៥៩នាក់** គ្រោះថ្នាក់ចរាចរណ៍កើតឡើងចំនួន**២៥៦លើក** បើធៀបនឹងខែកន្លងទៅចំនួន**២៦២លើក** ថយចុះ**៦លើក** ស្មើនឹង**២%**។ ការបង្ក្រាបបទល្មើសគ្រឿងញៀនបាន**៨៦៥ករណី** បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**៨៥៧លើក** កើនឡើង**៨ករណី** ស្មើនឹង**០,៩៣%** ឃាត់ខ្លួនជនសង្ស័យបាន**២ ១០៨នាក់** បទល្មើសជនទំនើងចំនួន**៨៩ករណី** បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន៨៤លើក កើនឡើង**៥លើក** ឃាត់ខ្លួនជនសង្ស័យបាន**២០៦នាក់** ការបង្ក្រាបល្បែងស៊ីសងបាន**៤០ករណី** បើធៀបនឹងខែដូចគ្នាឆ្នាំមុនចំនួន**២៥ករណី** កើនឡើង**១៥លើក** ឃាត់ខ្លួនជនសង្ស័យបាន**១២៥** និងការបង្ក្រាបបទល្មើសបច្ចេកវិទ្យាបាន**៨ទីតាំង** ឃាត់ខ្លួនជនសង្ស័យបាន**២ ៥១១នាក់** ស្មើនឹង**១០សញ្ជាតិ**។

ចំពោះស្ថានភាពសន្តិសុខនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ : យោធាថៃនៅតែរំលោភបទឈប់បាញ់នៅតំបន់មួយចំនួន ក្នុងខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ និងខេត្តពោធិ៍សាត់។ ក្រុមអ្នកសង្កេតការណ៍អាស៊ាន(AOT) បានចុះសង្កេតការណ៍ ផ្ទៀងផ្ទាត់ និងរាយការណ៍អំពីស្ថានភាពតំបន់នានាដែលរងការខូចខាតធ្ងន់ធ្ងរដោយសារការវាយប្រហារប្រដាប់អាវុធរបស់យោធាថៃ នៅក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ ព្រះវិហារ បន្ទាយមានជ័យ ពោធិ៍សាត់ និងខេត្តបាត់ដំបង។ ដោយឡែក ព្រំដែនកម្ពុជា-វៀតណាម និងព្រំដែនកម្ពុជា-ឡាវ ពុំមានអ្វីគួរឱ្យកត់សម្គាល់។ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធបានសហការនិងម្ចាស់ការល្បាតការពារ ត្រួតពិនិត្យបង្គោលសីមាភូមិសាស្ត្រ ក្តាប់សភាពការណ៍នៅតាមខ្សែបន្ទាត់ព្រំដែនចំនួន**១ ២៧០លើក** ក្នុងនោះ ព្រំដែនកម្ពុជា-ថៃចំនួន**៥៩៣លើក** ព្រំដែនកម្ពុជា-វៀតណាមចំនួន**៤៩១លើក** និងព្រំដែនកម្ពុជា-ឡាវចំនួន**១៨៦លើក**។

វិស័យអប់រំ ប្រកាសតាំងស៊ប់ក្នុងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន**២ ៤៥១នាក់** ក្នុងនោះ គ្រូបំប៉ន ជំនាន់ទី១៣ ចំនួន**១ ៤២៧នាក់** គ្រូបង្រៀនកម្រិតមូលដ្ឋានបរិញ្ញាបត្រ+១ ចំនួន**៥នាក់** គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+៤ ប្តូរក្របខ័ណ្ឌក៣.៤ ចំនួន**១ ០១៩នាក់** និងគ្រូបង្រៀនកម្រិតឧត្តមចំនួន**១៧៩នាក់**។

សេវាពិគ្រោះជំងឺក្រៅនៅមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជនសរុប**១ ៩២៩ ៤០៥ករណី** ការពិគ្រោះជំងឺក្រៅករណីថ្មីសរុប**១ ៣០៦ ៩៨៤ករណី**។ អ្នកជំងឺសម្រាកព្យាបាលនៅមន្ទីរពេទ្យសាធារណៈ និងមណ្ឌលសុខភាពមានគ្រែទូទាំងប្រទេសចំនួន**១៤៦ ៩៣៣នាក់**។ មជ្ឈមណ្ឌលជាតិផ្តល់ឈាមបានទទួលអ្នកស្ម័គ្រចិត្តផ្តល់ឈាមសរុបចំនួន**១០ ៥៥៤នាក់** និងបានផ្តល់ឈាមសរុបចំនួន**១៣ ៥០២ថ្លោក**។

សេដ្ឋកិច្ចរបស់កម្ពុជា មានវឌ្ឍនភាពគួរជាទីកត់សម្គាល់។ ជាក់ស្តែង ចំណូលថវិកាជាតិអនុវត្តបានប្រមាណប្រមាណ**៦៧៧,៤៥លានដុល្លារអាមេរិក** កើនឡើង**៦,៣៦%** បើធៀបនឹងខែកន្លងទៅ និងកើនឡើង**២៧,៣៧%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯការចំណាយថវិកាជាតិអនុវត្តបានប្រមាណ**៤៧៣,៦០លានដុល្លារអាមេរិក** ថយចុះ**៣៧,៤២%** បើធៀបនឹងខែកន្លងទៅ និងថយចុះ**៦០,៧៥%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ តុល្យភាពនៃថវិកាជាតិមានអតិរេកប្រមាណ**២០៣,៨៥លានដុល្លារអាមេរិក**។ ការប្រមូលចំណូលពន្ធដារតាមប្រព័ន្ធអនឡាញបានប្រមាណជា**៣៥៧,១៥លានដុល្លារអាមេរិក** ស្មើនឹង**៩,៣៧%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ បើធៀបនឹងខែដូចគ្នាឆ្នាំមុន កើនឡើងប្រមាណជា**៣២,១៩លានដុល្លារអាមេរិក** ស្មើនឹង**៩,៩១%**។ រីឯការប្រមូលចំណូលពីគយនិងរដ្ឋាករកម្ពុជា បានប្រមាណជា**២៨៥,៥៥លានដុល្លារអាមេរិក** ស្មើនឹង**៩,៤៥%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ កើនឡើងប្រមាណ**២២,៥២%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ទំហំពាណិជ្ជកម្មអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា មានប្រមាណ**៥ ៨៧៦,៤៣លានដុល្លារអាមេរិក** ក្នុងនោះ ការនាំចេញមានតម្លៃប្រមាណ**២ ៧៨០,២៣លានដុល្លារអាមេរិក** កើនឡើង**២,១២%** បើធៀបនឹងខែកន្លងទៅ និងកើនឡើង**២៩,២០%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯការនាំចូល មានតម្លៃប្រមាណ**៣ ០៩៦,១៩លានដុល្លារអាមេរិក** ថយចុះ**២,០៥%** បើធៀបនឹងខែកន្លងទៅ ប៉ុន្តែកើនឡើង**១៤,០៥%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ប្រតិបត្តិការជញ្ជីងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា មានឱនភាពប្រមាណ**៣១៥,៩៦លានដុល្លារអាមេរិក**។

រាជរដ្ឋាភិបាល បានអនុញ្ញាតឱ្យក្រុមហ៊ុនវិនិយោគលើគម្រោងថ្មី និងគម្រោងពង្រីកផលិតកម្មចំនួន**៤៣គម្រោង** មានទុនវិនិយោគសរុប**៧៥១ ៤៥០ ០១៦ដុល្លារអាមេរិក** និងអាចបង្កើតការងារចំនួន**២៥ ៩៥៧កន្លែង**។ រោងចក្របង្កើតថ្មី**៣៨រោងចក្រ** និងបង្កើតការងារថ្មី**៧ ៤៦៨នាក់**។ គិតត្រឹមដំណាច់ខែមករា ឆ្នាំ២០២៦នេះ មានរោងចក្រសរុប**៣ ១១២រោងចក្រ** និងពលកម្មសរុប**១ ២៧០ ១៣១នាក់**។ សហគ្រាសធុនតូច មធ្យម និងសិប្បកម្មបង្កើតថ្មី**១០៩មូលដ្ឋាន** និងបង្កើតការងារថ្មី**២ ០១៧នាក់**។ គិតត្រឹមដំណាច់ខែមករា ឆ្នាំ២០២៦នេះ មានសហគ្រាសធុនតូច មធ្យម និងសិប្បកម្មសរុប**៤៤ ៨៩៨មូលដ្ឋាន** និងពលកម្មសរុប**៤៩៣ ៩៣២នាក់**។ បរិមាណផលិតទឹកស្អាតរបស់អង្គភាពរដ្ឋាករទឹកសាធារណៈនិងរដ្ឋាករទឹកឯកជនទូទាំងប្រទេសផលិតបានសរុប**៤៩ ១១០ ៣៣២**ម$^{៣}$។

វិស័យកសិកម្ម ការងារប្រមូលផលស្រូវរដូវប្រាំង ឆ្នាំ២០២៦ សម្រេចបានចំនួន**១៣៥ ០៦៣ហ.ត.** លើផ្ទៃដីសរុប**៧៦០ ៦៣៦ហ.ត.** ដោយទទួលបានបរិមាណផលសរុប**៦៤០ ១៩៧តោន** និងមានទិន្នផលជាមធ្យមប្រមាណ៤,៧៤០តោន/ហ.ត.។ បរិមាណផលិតទឹកស្អាតរបស់អង្គភាពរដ្ឋាករទឹកសាធារណៈ និងរដ្ឋាករទឹកឯកជនទូទាំងប្រទេសផលិតបាន**៤៩ ១១០ ៣៣២ម$^{3}$**។ រាជរដ្ឋាភិបាល បានគិតគូររក្សាទុកដាក់សន្និធិស្បៀងត្រៀមបម្រុងយុទ្ធសាស្ត្រនៅតាមបណ្ដាឃ្លាំងស្តុកនានា សម្រាប់បំពេញតម្រូវការដាក់ស្ដែងឬសម្រាប់ពេលមានគ្រោះមហន្តរាយ រួមមានស្តុកអង្ករ**១ ១៦៨តោន** មីជាតិ**១៥ ០០០កេស** ទឹកសុទ្ធ**៩៥ ០០០កេស** ទឹកត្រី**១៥ ០០០យួរ** ទឹកស៊ីអ៊ីវ**១៥ ០០០យួរ** ត្រីខ**៨ ៥០០យួរ**។

វិស័យទេសចរណ៍ ភ្ញៀវបរទេសចូលមកព្រះរាជាណាចក្រកម្ពុជា ចំនួន**៤០៧ ៤៦៦នាក់** ថយចុះ**៤០,០៥%** រីឯពលរដ្ឋខ្មែរធ្វើដំណើរចេញពីព្រះរាជាណាចក្រកម្ពុជា ចំនួន**៩៤ ៣៧៣នាក់** ថយចុះ**៥៦,០៤%**។ រមណីយដ្ឋានអង្គរ បានលក់សំបុត្រជូនភ្ញៀវទេសចរអន្តរជាតិចូលទស្សនារមណីយដ្ឋានអង្គរសៀមរាបចំនួន**៩៣ ៤៩១នាក់** ថយចុះ**៣៦,០៣%** និងទទួលបានចំណូលបានចំនួន**៤ ៥២២ ៧៧៧ ដុល្លារអាមេរិក** ថយចុះ៣៤,៤៨%។ ជាមួយគ្នានេះ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ច បានផ្ដល់លិខិតអនុញ្ញាតសាងសង់ទូទាំងប្រទេសចំនួន**៣២៥គម្រោង** មានផ្ទៃក្រឡាកម្រាលសំណង់សរុបចំនួន**២ ១៨៤ ៥៤០ម$^{2}$** តម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណចំនួន**៩៦៤ ៩៨៧ ៤៣៥ដុល្លារអាមេរិក** កើនឡើង**៤៥,៤០%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការផលិតនិងនាំចូលថាមពលអគ្គិសនីសរុបចំនួន**១ ១៣៨,៧០លានគីឡូវ៉ាត់ម៉ោង** ក្នុងនោះ ប្រភពផ្គត់ផ្គង់អគ្គិសនីក្នុងប្រព័ន្ធចំនួន**៩០២,១១លានគីឡូវ៉ាត់ម៉ោង** និងអគ្គិសនីនាំចូលចំនួន**២៣៦,៥៩លានគីឡូវ៉ាត់ម៉ោង** ។

វិស័យហេដ្ឋារចនាសម្ព័ន្ធ បាននឹងកំពុងសាងសង់ ជួសជុល ពង្រីកលើកកម្រិតផ្លូវជាតិ រួមមានផ្លូវជាតិលេខ៧ សម្រេចបាន**៨៤,៤៨%** និងស្ពានមិត្តភាពកម្ពុជា-ចិន មេគង្គក្រចេះ សម្រេចបាន**៩១,៩២%**។ អាកាសចរណ៍ក្នុងប្រទេសមាន៤ និងក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិមានចំនួន**៣២** ធ្វើការហោះហើរដឹកជញ្ជូនទំនិញចំនួន**៨ ៥៧៨តោន** និងអ្នកដំណើរទាំងក្នុងនិងក្រៅប្រទេសចំនួន**៦៧៩ ៨៧៩នាក់**។ រីឯការដឹកជញ្ជូនតាមផ្លូវទឹកឆ្លងកាត់កំពង់ផែសំខាន់ៗទាំង២ មានបរិមាណទំនិញនាំចេញ នាំចូលសរុប**១ ២៩៨ ៨១២តោន** រកចំណូលបានចំនួន**២០ ៦៩៤ ៩៨៤ដុល្លារអាមេរិក**។ ការចុះបញ្ជីយានយន្តសរុបចំនួន**៤៦ ៣៥១គ្រឿង**(រថយន្ត**៩ ៣៨៥គ្រឿង** ម៉ូតូ**៣៦ ៩៦៦គ្រឿង**) និងយានយន្តអគ្គិសនីចំនួន**១ ៣៦៥គ្រឿង** ព្រមទាំងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តបានចំនួន**៤១ ១៤៤គ្រឿង**។ គិតត្រឹមដំណាច់ខែមករា ឆ្នាំ២០២៦នេះ ការចុះបញ្ជីយានយន្តសរុប**៨ ២២៩ ៩៩២គ្រឿង**(រថយន្ត**១ ២៤៥ ២២៦គ្រឿង** និងម៉ូតូ**៦ ៩៨៤ ៧៦៦គ្រឿង**) និងចុះបញ្ជីយានយន្តអគ្គិសនីសរុប**១៤ ៥៨៥គ្រឿង** និងការចុះបញ្ជីជលយានសរុប**១ ៤៣០គ្រឿង**(ផ្លូវសមុទ្រ**៤៩៣គ្រឿង** និងទឹកសាប**៩៣៧គ្រឿង**)។

វិស័យទូរគមនាគមន៍ បច្ចុប្បន្នមានក្រុមហ៊ុនទូរសព្ទចល័តនិងអចល័តមាន**៨ក្រុមហ៊ុន** មានអ្នកប្រើប្រាស់សរុប**២១ ៥៦៨ ៨៣៥នាក់/ស៊ីមកាត** និងក្រុមហ៊ុនអ៊ីនធឺណិតចំនួន**៤៣ក្រុមហ៊ុន** មានអ្នកប្រើប្រាស់សេវាអ៊ីនធឺណិតចល័តនិងអចល័តសរុប**២០ ៥៧៥ ៩០២នាក់**។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយខាងលើ សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ព្រះមេត្តាជ្រាបជាព្រះរាជាបយការណ៍ដ៏ខ្ពង់ខ្ពស់បំផុត។

**ទូលព្រះបង្គំជាខ្ញុំ** តាងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមលំឱនកាយវាចាចិត្តគោរពបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមប្រោះព្រំសព្ទសាធុការពរ បវរមហាប្រសើរ ថ្វាយ**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសូមព្រះអង្គមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីយាងគង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ដ៏ត្រជាក់នៃប្រជាជនខ្មែរជាកូនចៅ ចៅទួត ជានិច្ចនិរន្តរ៍តរៀងទៅ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**ចម្លងជូន៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ កាលប្បវត្តិ